PROEUS DARA

ហាមលក់
កម្មសិទ្ធិរបស់រដ្ឋ

ក្រសួងអប់រំ យុវជន និងកីឡា

# គណិតវិទ្យា

## កំរិតខ្ពស់ ១១



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

PROEUS DARA

ក្រសួងអប់រំ យុវជន និងកីឡា

បណ្ណាល័យ

# គណិតវិទ្យា

## កំរិតខ្ពស់

## ថ្នាក់ទី ១១

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

PROEUS DARA

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក អ៊ី ស៊ាងលី | លោកស្រី ទី ប៉ូលីរ៉េត |
| | លោក ឌិក លីនដា | លោកស្រី អ៊ុក សុមនី |
| | លោក ចាន់ រ៉ាដា | លោក ប៊ុន រួ |
| | លោក ន្ធ រ៉េត | |
| **អ្នកវាយអត្ថបទ** | លោកស្រី ឈាង ណារីន | |
| **វិចិត្រករ** | លោក តន់ ជាតិ | |
| **អ្នករៀបរៀង** | លោក ឡុង សុផេង | លោក ព្រំ ងួន |
| **អ្នករចនាទំព័រ** | លោក ខែម ម៉ារី | |
| **អ្នកឯកទេស** | លោក អ៊ិន គឹមស្រ៊ុន | |
| **គណៈកម្មការពិនិត្យ** | លោក ថៃ ហេង | លោក សុខ ធី |
| | លោក ប៊ូ សន | លោក ហេង ចន្ថា |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៣០០១អយក.ប្រក. ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ២០០៨ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពលើកទី ៤ ឆ្នាំ២០១២ ចំនួន ២៧ ២០០ច្បាប់

ISBN 9-789-995-000-691

PROEUS DARA

# អារម្ភកថា

សៀវភៅគណិតវិទ្យាកំរិតខ្ពស់ថ្នាក់ទី 11 រួមមាន ៩ ជំពូក ដែលសិក្សាអំពី ស្ទីតនិងអនុមានរួម គណិតវិទ្យា អនុគមន៍អិចស្ប៉ូណង់ស្យែលនិងអនុគមន៍លោការីត អនុគមន៍ត្រីកោណមាត្រ បំលែងលីនេអ៊ែរ ប្រូបាប ដេរីវេប្លង់កុំផ្លិច និងវ៉ិចទ័រក្នុងលំហ ។ សិស្សដែលជ្រើសរើសយកគណិតវិទ្យាកំរិតខ្ពស់ត្រូវរៀនគណិតវិទ្យាកំរិតមូលដ្ឋានដើម្បីបំពេញបន្ថែម ។

**ការរៀបចំមេរៀននៅក្នុងសៀវភៅនេះ មានទម្រង់ដូចខាងក្រោម ៖**

- មេរៀននីមួយៗ បានបញ្ជាក់អំពីវត្ថុបំណងច្បាស់លាស់
- ខ្លឹមសារមេរៀននីមួយៗ ផ្ដើមចេញពីឧទាហរណ៍ក្នុងជីវភាពរស់នៅ
- មានលំហាត់ប្រតិបត្តិសម្រាប់ពង្រឹងចំណេះដឹងសិស្ស
- នៅចុងមេរៀននៃជំពូកនីមួយៗ មានសង្ខេបគន្លឹះមេរៀនសម្រាប់ឱ្យសិស្សចងចាំនូវអ្វីដែលបានរៀនរួច
- មេរៀននីមួយៗ មានលំហាត់និងលំហាត់ជំពូកសម្រាប់ឱ្យសិស្សអនុវត្តដើម្បីពង្រឹងចំណេះដឹង
- នៅចុងទំព័រនៃសៀវភៅនេះ មានពន្យល់ពាក្យគន្លឹះនិងមានចម្លើយលំហាត់សម្រាប់ឱ្យសិស្សផ្ទៀងផ្ទាត់ ។

**សៀវភៅសិក្សានេះមានការចូលរួមពី ៖**

- លោកគ្រូ អ្នកគ្រូដែលបានសាកល្បងជួយផ្ដល់យោបល់
- លោកគ្រូ អ្នកគ្រូដែលបានសាកល្បងបង្រៀននូវសៀវភៅសិក្សានេះ
- គណៈកម្មការវាយតម្លៃដែលបានជួយត្រួតពិនិត្យនិងផ្ដល់យោបល់ ។

ដើម្បីឱ្យសៀវភៅនេះ កាន់តែល្អប្រសើរ យើងខ្ញុំនឹងរង់ចាំទទួលរាល់ការរិះគន់និងកែលំអបន្ថែមអំពីសំណាក់លោកគ្រូ អ្នកគ្រូ និងប្រិយមិត្តអ្នកប្រើប្រាស់សៀវភៅគណិតវិទ្យាកំរិតខ្ពស់នេះដោយក្ដីរីករាយ ។

**គណៈកម្មការនិពន្ធ**

# បញ្ជីអត្ថបទ

## គណិតវិទ្យាកំរិតខ្ពស់

**ជំពូកទី 1 : ស្វ៊ីតនិងអនុមានរួមគណិតវិទ្យា** ......1
1. ផលបូកតួនៃស្វ៊ីតផ្សេងៗ ......2
2. ទំនាក់ទំនងតួនៃស្វ៊ីត ......16
3. វិចារអនុមានរួម ......24

**ជំពូកទី 2 : អនុគមន៍អិចស្ប៉ូណង់ស្យែលនិងអនុគមន៍លោការីត** ......35
1. អនុគមន៍អិចស្ប៉ូណង់ស្យែល ......36
2. អនុគមន៍លោការីត ......46

**ជំពូកទី 3 : សមីការនិងវិសមីការត្រីកោណមាត្រ** ......57
1. សមីការនិងវិសមីការត្រីកោណមាត្រ ......58

**ជំពូកទី 4 : បំលែងលីនេអ៊ែរ** ......73
1. បំលែងលីនេអ៊ែរ ......74

**ជំពូកទី 5 : លីមីតនិងដេរីវេ** ......103
1. អនុវត្តន៍ដេរីវេចំពោះសមីការនិងវិសមីការ ......104

**ជំពូកទី 6 : ប្រូបាប** ......117
1. ប្រូបាបមានលក្ខខណ្ឌ ......118

**ជំពូកទី 7 : ចំនួនកុំផ្លិច** ......135
1. ចំនួនកុំផ្លិចទម្រង់ពីជគណិត ......136
2. ចំនួនកុំផ្លិចទម្រង់ត្រីកោណមាត្រ ......144
3. ស្វ័យគុណទី n និងឫសទី n នៃចំនួនកុំផ្លិច ......164
4. អនុវត្តន៍ចំនួនកុំផ្លិចក្នុងធរណីមាត្រ ......174

**ជំពូកទី 8 : វ៉ិចទ័រក្នុងលំហ** ......189
1. វ៉ិចទ័រក្នុងលំហ ......190
2. សមីការបន្ទាត់និងសមីការប្លង់ក្នុងលំហ ......216

**ចម្លើយជំពូក** ......235

**បទានុក្រម** ......247

# ជំពូក 1

# ស៊ីតនិងអនុមានរួមគណិតវិទ្យា

1. ផលបូកតួនៃស៊ីតផ្សេងៗ
2. ទំនាក់ទំនងតួនៃស៊ីត
3. វិចារអនុមានរួមគណិតវិទ្យា



ការសិក្សាស៊ីតបណ្តាលឱ្យគណិតវិទ្យាកាន់តែមានការរីកចម្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ តាមរយៈផលបូកតួនៃស៊ីតអាចឱ្យគេសង់បាននូវតារាងនៃអនុគមន៍ត្រីកោណមាត្រនិងអនុគមន៍លោការីតមិនត្រឹមតែប៉ុណ្ណោះក៏អាចឱ្យគេគណនាបាននូវតម្លៃលេខ $e$ និង $\pi$ ទៀតផង ។

$$e = 1 + \frac{1}{1!} + \frac{1}{2!} + \frac{1}{3!} + \frac{1}{4!} + \frac{1}{5!} + \frac{1}{6!} + \frac{1}{7!} + \cdots$$

$$\frac{\pi}{4} = 1 - \frac{1}{3} + \frac{1}{5} - \frac{1}{7} + \frac{1}{9} - \frac{1}{11} + \frac{1}{13} - \frac{1}{15} + \cdots$$

មេរៀនទី 1

# ផលបូកតួនៃស៊ីតផ្សេងៗ

## 1. របៀបគណនាផលបូក

**វត្ថុបំណង**

- គណនាផលបូកតួនៃស៊ីត
- ចេះប្រើនិមិត្តសញ្ញា $\Sigma$ សំរាប់ផលបូកនៃស៊ីត
- កំណត់តួទី $n$ តាមផលសងស៊ីតលំដាប់ 1 និងលំដាប់ 2

ចំពោះស៊ីតផ្សេងៗ គេពុំអាចប្រើរូបមន្តផលបូកនៃស៊ីតនព្វន្ត ឬស៊ីតធរណីមាត្រមកគណនាផលបូកវាបានឡើយ ក្នុងករណីនេះត្រូវប្រើវិធីផ្សេងៗទៅតាមទម្រង់នៃស៊ីត ។

***ឧទាហរណ៍ 1*** ចំពោះផលបូក

$S = 1^2 + 2^2 + 3^2 + \ldots + n^2$ ។

គេអាចគណនាផលបូកនេះដោយប្រើសមភាព

$(k+1)^3 - k^3 = 3k^2 + 3k + 1$ ដោយឱ្យ $k$ យកតម្លៃពី 1 ដល់ $n$

$$2^3 - 1^3 = 3\times 1^2 + 3\times 1 + 1$$

$$3^3 - 2^3 = 3\times 2^2 + 3\times 2 + 1$$

$$4^3 - 3^3 = 3\times 3^2 + 3\times 3 + 1$$

$$\ldots\ldots\ldots\ldots\ldots\ldots\ldots\ldots\ldots\ldots$$

$$n^3 - (n-1)^3 = 3\times(n-1)^2 + 3\times(n-1) + 1$$

$$\underline{(n+1)^3 - n^3 = 3\times n^2 + 3\times n + 1}$$ បូកអង្គនិងអង្គ គេបាន

$$(n+1)^3 - 1^3 = 3\times(1^2 + 2^2 + 3^2 + \ldots + n^2) + 3\times(1 + 2 + 3 + \ldots + n) + (1 + 1 + 1 + \ldots + 1)$$

$$= 3\times S + 3\times\frac{n(n-1)}{2} + n$$

គណនា $S$ គេបាន $1^2 + 2^2 + 3^2 + \ldots + n^2 = \frac{n(n+1)(2n+1)}{6}$ ។

***ឧទាហរណ៍ 2*** ចំពោះផលបូក $S = \frac{1}{1\cdot 2} + \frac{1}{2\cdot 3} + \frac{1}{3\cdot 4} + \ldots + \frac{1}{n\cdot(n+1)}$

គេអាចគណនាផលបូកនេះដោយប្រើសមភាព

$\frac{1}{k\cdot(k+1)} = \frac{1}{k} - \frac{1}{k+1}$ ដោយឱ្យ $k$ យកតម្លៃពី 1 ដល់ $n$

$$\frac{1}{1\cdot 2}=\frac{1}{1}-\frac{1}{2}$$

$$\frac{1}{2\cdot 3}=\frac{1}{2}-\frac{1}{3}$$

$$\frac{1}{3\cdot 4}=\frac{1}{3}-\frac{1}{4}$$

...............

$$\frac{1}{(n-1)\cdot n}=\frac{1}{n-1}-\frac{1}{n}$$

$$\frac{1}{n\cdot(n+1)}=\frac{1}{n}-\frac{1}{n+1}$$

បូកអង្គនិងអង្គ គេបាន $S=1-\frac{1}{n+1}$

ហេតុនេះ $\frac{1}{1\cdot 2}+\frac{1}{2\cdot 3}+\frac{1}{3\cdot 4}+\ldots+\frac{1}{n\cdot(n+1)}=1-\frac{1}{n+1}=\frac{n}{n+1}$

**លំហាត់គំរូ** គណនាផលបូក $S=1^3+2^3+3^3+\ldots+n^3$ ។

**ចម្លើយ** គេអាចគណនាផលបូកនេះដោយប្រើសមភាព

$(k+1)^4-k^4=4k^3+6k^2+4k+1$ ដោយឱ្យ $k$ យកតម្លៃពី 1 ដល់ $n$

$$2^4-1^4=4\times 1^3+6\times 1^2+4\times 1+1$$

$$3^4-2^4=4\times 2^3+6\times 2^2+4\times 2+1$$

$$4^4-3^4=4\times 3^3+6\times 3^2+4\times 3+1$$

.........................................

$$n^4-(n-1)^4=4\times(n-1)^3+6\times(n-1)^2+4\times(n-1)+1$$

$(n+1)^4-n^4=4\times n^3+6\times n^2+4\times n+1$ បូកអង្គនិងអង្គ គេបាន

$$(n+1)^4-1^4=4\times(1^3+2^3+3^3+\ldots+n^3)+6\times(1^2+2^2+3^2+\ldots+n^2)$$
$$+4\times(1+2+3+\ldots+n)+(1+1+1+\ldots+1)$$
$$=4S+6\times(1^2+2^2+3^2+\ldots+n^2)+4\times(1+2+3+\ldots+n)+(1+1+1+\ldots+1)$$

គណនា $S$ គេបាន $1^3+2^3+3^3+\ldots+n^3=\frac{n^2(n+1)^2}{4}=\left[\frac{n(n+1)}{2}\right]^2$

**ប្រតិបត្តិ** គណនា $S=12^3+13^3+14^3+\ldots+50^3$

គណនា $S=\frac{1}{1\cdot 2\cdot 3}+\frac{1}{2\cdot 3\cdot 4}+\frac{1}{3\cdot 4\cdot 5}+\ldots+\frac{1}{n\cdot(n+1)\cdot(n+2)}$

## 2. គណនាផលបូកតាមលំនាំគំរូ

ចំពោះស៊ីតដែលមានតួជាចំនួនគត់ គេអាចគណនាផលបូកវាតាមការសង្កេតលំនាំគំរូ ។

$1 = 1 = 1^2$

$1+3 = 4 = 2^2$

$1+3+5 = 9 = 3^2$

$1+3+5+7 = 16 = 4^2$



ហេតុនេះ $1+3+5+\ldots+(2n-1) = n^2$

**លំហាត់គំរូ** គណនាផលបូក $n$ តួនៃចំនួនគូ $S = 2+4+6+\ldots+2n$

**ចម្លើយ**

$2 = 2 = 1\times 2$

$2+4 = 6 = 2\times 3$

$2+4+6 = 12 = 3\times 4$

$2+4+6+8 = 20 = 4\times 5$



ហេតុនេះ $2+4+6+\ldots\ +2n = n\cdot(n+1)$

**ប្រតិបត្តិ** គេឱ្យលំនាំគំរូនៃស៊ីតខាងក្រោម ៖

$1 = 1$

$1+7 = 8$

$1+7+19 = 27$

$1+7+19+37 = 64$

$1+7+19+37+61 = 125$

គណនាផលបូកនៃស៊ីតនេះដែលមាន 10 តួ

# 3. និមិត្តសញ្ញា Σ សំរាប់ផលបូកនៃស៊ីត

## 3.1 សញ្ញាណ Σ

ក្នុងការសរសេរផលបូកតួនៃស៊ីត $U_1$ , $U_2$ , $U_3$ , ..., $U_n$ គេប្រើនិមិត្តសញ្ញា Σ អានថា ស៊ិចម៉ា សម្រាប់តាងផលបូក $n$ តួនៃស៊ីត ។ គេកំណត់សរសេរ $\sum_{k=1}^{n} U_k = U_1 + U_2 + U_3 + \ldots + U_n$ ។

ក្នុងនោះ $k$ យកតម្លៃពី 1, 2, 3, ... រហូតដល់ $n$ ។

**ឧទាហរណ៍** $1 + 2 + 3 + \ldots + n = \sum_{k=1}^{n} k$

$$1^2 + 2^2 + 3^3 + \ldots + n^2 = \sum_{k=1}^{n} k^2$$

**លំហាត់គំរូ 1** សរសេរផលបូកខាងក្រោមដោយប្រើនិមិត្តសញ្ញា Σ :

ក. $1^3 + 2^3 + 3^3 + \ldots + n^3$

ខ. $2 + 4 + 6 + 8 + \ldots + 100$

គ. $\frac{1}{2} - \frac{1}{3} + \frac{1}{4} - \frac{1}{5} + \ldots + \frac{1}{50}$

**ចម្លើយ** ក. $1^3 + 2^3 + 3^3 + \ldots + n^3 = \sum_{k=1}^{n} k^3$

ខ. $2 + 4 + 6 + 8 + \ldots + 100 = 2\times 1 + 2\times 2 + 2\times 3 + \ldots + 2\times 50$

ផលបូកស៊ីតនេះមានតួទូទៅ $2n$ ហើយ $n$ យកតម្លៃពី 1 ដល់ 50

គេបាន $2 + 4 + 6 + 8 + \ldots + 100 = \sum_{n=1}^{50} 2n$ ។

គ. $\frac{1}{2} - \frac{1}{3} + \frac{1}{4} - \frac{1}{5} + \ldots + \frac{1}{50}$ ផលបូកនេះ $n$ យកតម្លៃពី 2 ដល់ 50 ។

តួទូទៅនៃស៊ីត $\frac{(-1)^n}{n}$ ។

គេបាន $\frac{1}{2} - \frac{1}{3} + \frac{1}{4} - \frac{1}{5} + \ldots + \frac{1}{50} = \sum_{n=2}^{50} \frac{(-1)^n}{n}$ ។

**លំហាត់គំរូ 2**

សរសេរគ្រប់តួទាំងអស់នៃផលបូកដោយមិនប្រើនិមិត្តសញ្ញា Σ

ក. $\sum_{k=1}^{6} 2$

ខ. $\sum_{n=2}^{5} (2n+1)$

គ. $\sum_{j=1}^{5} j(j+1)$

**ចម្លើយ**

ក. $\sum_{k=1}^{6} 2 = 2+2+2+2+2+2$

ខ. $\sum_{n=2}^{5} (2n+1) = 5+7+9+11$

គ. $\sum_{j=1}^{5} j(j+1) = 1\times 2+2\times 3+3\times 4+4\times 5+5\times 6$

**ប្រមតិបត្តិ** សរសេរផលបូកខាងក្រោមដោយប្រើនិមិត្តសញ្ញា Σ :

ក. $2+5+8+\ldots+(3n-1)$

ខ. $3+6+12+\ldots+3(2)^{n-1}$

គ. $1+\frac{1}{2}+\frac{1}{3}+\frac{1}{4}+\ldots+\frac{1}{100}$

PROEUS DARA

## 3.2 ផលបូកមានលក្ខណៈដូចខាងក្រោម ៖

ក. $\sum_{k=1}^{n} c = nc$

ខ. $\sum_{k=1}^{n} ca_k = c\sum_{k=1}^{n} a_k$

គ. $\sum_{k=1}^{n} (a_k + b_k) = \sum_{k=1}^{n} a_k + \sum_{k=1}^{n} b_k$

ឃ. $\sum_{k=1}^{n} (a_k - b_k) = \sum_{k=1}^{n} a_k - \sum_{k=1}^{n} b_k$

ង. $\sum_{k=1}^{n} (a_k + b_k)^2 = \sum_{k=1}^{n} a_k^2 + 2\sum_{k=1}^{n} a_k b_k + \sum_{k=1}^{n} b_k^2$

## សម្រាយបញ្ជាក់

ក. $\sum_{k=1}^{n} c = c + c + c + \ldots + c = nc$

ខ. $\sum_{k=1}^{n} ca_k = ca_1 + ca_2 + ca_3 + \ldots + ca_n = c(a_1 + a_2 + a_3 + \ldots + a_n) = c\sum_{k=1}^{n} a_k$

គ. $\sum_{k=1}^{n} (a_k + b_k) = (a_1 + b_1) + (a_2 + b_2) + \ldots + (a_n + b_n)$

$= (a_1 + a_2 + \ldots + a_n) + (b_1 + b_2 + \ldots + b_n) = \sum_{k=1}^{n} a_k + \sum_{k=1}^{n} b_k$

ឃ. $\sum_{k=1}^{n} (a_k - b_k) = (a_1 - b_1) + (a_2 - b_2) + (a_3 - b_3) + \ldots + (a_n - b_n)$

$= (a_1 + a_2 + a_3 + \ldots + a_n) - (b_1 + b_2 + b_3 + \ldots \quad + b_n)$

$= \sum_{k=1}^{n} a_k - \sum_{k=1}^{n} b_k$

ង. $\sum_{k=1}^{n} (a_k + b_k)^2 = \sum_{k=1}^{n} (a_k^2 + 2a_k b_k + b_k^2) = \sum_{k=1}^{n} a_k^2 + \sum_{k=1}^{n} 2a_k b_k + \sum_{k=1}^{n} b_k^2$

$= \sum_{k=1}^{n} a_k^2 + 2\sum_{k=1}^{n} a_k b_k + \sum_{k=1}^{n} b_k^2$

**លំហាត់គំរូ** គណនា

ក. $\sum_{k=1}^{15}(4k+3)$

ខ. $\sum_{k=1}^{20}(k+3)k$

**ចម្លើយ** ក. $\sum_{k=1}^{15}(4k+3) = \sum_{k=1}^{15}4k + \sum_{k=1}^{15}3 = 4\sum_{k=1}^{15}k + \sum_{k=1}^{15}3$

$$= 4(1+2+3+\ldots+15)+15\times 3 = 4\times\frac{(1+15)\times 15}{2}+45 = 2\times 16\times 15+45 = 525$$

ខ. $\sum_{k=1}^{20}(k+3)k = \sum_{k=1}^{20}(k^2+3k) = \sum_{k=1}^{20}k^2+3\sum_{k=1}^{20}k$

$$= \frac{(20)\times(20+1)\times\ (2\times 20+1)}{6}+3\frac{(1+20)\times 20}{2}$$

$$= 10\times 7\times 41+3\times 21\times 10 = 2870+630 = 3500$$

**ប្រតិបត្តិ** គណនា ក. $\sum_{k=1}^{20}(3k+1)$

ខ. $\sum_{k=1}^{7}2^k$

គ. $\sum_{k=4}^{14}(4k-3)$

ឃ. $\sum_{k=1}^{n}(3+k)^2$

ង. $\sum_{k=1}^{30}k(k+1)$

## 4. របៀបកំណត់តួទី n តាមផលសងតួនៃស៊ីត

គេអាចកំណត់តួទី $n$ របស់ស៊ីត $(a_n)$ ដែលពុំមែនជាស៊ីតនព្វន្ត ឬជាស៊ីតធរណីមាត្រតាមរបៀបដូចខាងក្រោម ៖

### 4.1 ផលសងតួលំដាប់ទី 1

***ឧទាហរណ៍ 1*** កំណត់តួទី $n$ នៃស៊ីត $1, 3, 7, 13, 21, 31,\dots$ ។

**ចម្លើយ** គេសង្កេតឃើញថាស៊ីតនេះមិនមែនជាស៊ីតនព្វន្ត ហើយក៏មិនមែនជាស៊ីតធរណីមាត្រ ។ នោះគេត្រូវធ្វើផលសងនៃតួបន្តបន្ទាប់គ្នានៃស៊ីត $1, 3, 7, 13, 21, 31,\dots$ គេបានលំនាំគំរូដូចជា

| | | | | | | | |
|---|---|---|---|---|---|---|---|
| $n$ | : | 1 | 2 | 3 | 4 | 5 | 6... |
| ស៊ីត $(a_n)$ | : | 1 | 3 | 7 | 13 | 21 | 31... |
| ផលសងលំដាប់ 1 នៃស៊ីត | : | 2 | 4 | 6 | 8 | 10... | |

ផលសងតួនៃស៊ីតអាចជួយឱ្យគេរកលំនាំគំរូ ដែលអាចកំណត់តួទូទៅនៃស៊ីតបានដូចជា

$a_2 - a_1 = 3 - 1 = 2\times 1$

$a_3 - a_2 = 7 - 3 = 4 = 2\times 2$

$a_4 - a_3 = 13 - 7 = 6 = 2\times 3$

.................................

$a_{n-1} - a_{n-2} = 2\times(n-2)$

$a_n - a_{n-1} = 2\times(n-1)$

បូកអង្គនិងអង្គទាំងអស់ គេបាន

$a_n - a_1 = a_n - 1 = 2\times 1 + 2\times 2 + 2\times 3 + \dots + 2\times(n-2) + 2\times(n-1)$

$$a_n = 2\times 1 + 2\times 2 + 2\times 3 + \dots + 2\times(n-2) + 2\times(n-1) + 1$$

$$= 2\times[\ 1 + 2 + 3 + \dots + (n-2) + (n-1)] + 1 = 2\times\frac{[\ 1+(n-1)](n-1)}{2} + 1$$

$$= n(n-1) + 1 = n^2 - n + 1$$

ដូចនេះ តួទី $n$ នៃស៊ីត $1, 3, 7, 13, 21, 31,\dots$ កំណត់ដោយ $a_n = n^2 - n + 1$ ។

**ជាទូទៅ** គេមានស៊ីត $(a_n) : a_1\ , a_2\ , a_3\ , \dots, a_n$ ហើយ $b_1 = a_2 - a_1$ , $b_2 = a_3 - a_2$ , $b_3 = a_4 - a_3$ ,..., $b_{n-1} = a_n - a_{n-1}$ ។ ស៊ីត $(b_n) : b_1\ , b_2\ , b_3\ , \dots, b_{n-1}$ ហៅថាផលសងលំដាប់ 1 នៃស៊ីត $(a_n)$ ។

**ឧទាហរណ៍ 2** បង្ហាញថា $a_n = a_1 + \sum_{k=1}^{n-1} b_k$ ចំពោះ $n \geq 2$ ។

$$\underbrace{a_1 \quad a_2}_{b_1} \underbrace{\quad a_3}_{b_2} \underbrace{\quad a_4}_{b_3} \underbrace{\quad \ldots}_{b_4} \underbrace{\quad a_{n-1}}_{b_{n-2}} \underbrace{\quad a_n}_{b_{n-1}}$$

$$+\begin{cases} a_2 - a_1 = b_1 \\ a_3 - a_2 = b_2 \\ a_4 - a_3 = b_3 \\ \vdots \quad \vdots \quad \vdots \\ \vdots \quad \vdots \quad \vdots \\ a_{n-1} - a_{n-2} = b_{n-2} \\ a_n - a_{n-1} = b_{n-1} \end{cases}$$

$$a_n - a_1 = b_1 + b_2 + b_3 + \ldots + b_{n-1}$$

ចំពោះ $n \geq 2$ គេបាន

$$a_n = a_1 + (b_1 + b_2 + b_3 + \ldots + b_{n-1}) = a_1 + \sum_{k=1}^{n-1} b_k$$

ចំពោះ $n = 1$ គេបាន $b_{n-1} = b_0$ មិនមាន ។

ដូចនេះ $a_n = a_1 + \sum_{k=1}^{n-1} b_k$ ចំពោះ $n \geq 2$ ។

**ជាទូទៅ** គេមានស្វ៊ីត $(a_n)$ និងស្វ៊ីត $(b_n)$ ដែលកំណត់ដោយ $b_n = a_{n+1} - a_n$, $n = 1, 2, 3, \ldots$

តួទី $n$ នៃស្វ៊ីត $(a_n)$ កំណត់ដោយ $a_n = a_1 + \sum_{k=1}^{n-1} b_k$ ចំពោះ $n \geq 2$ ។

**លំហាត់គំរូ 1** កំណត់តួទី $n$ នៃស្វ៊ីត $2, 4, 8, 14, 22, 32, \ldots$ ។

**ចម្លើយ** តាង $a_n$ ជាតួទី $n$ នៃស្វ៊ីតដែលគេឱ្យ ។ ស្វ៊ីត $(b_n)$ ជាផលសងលំដាប់ 1 នៃស្វ៊ីត $(a_n)$ ដែលមានតួ $b_n$ កំណត់ដោយ $b_n = a_{n+1} - a_n$

ស្វ៊ីត $(b_n) : 2, 4, 6, 8, \ldots$

ស្វ៊ីត $(b_n)$ ជាស្វ៊ីតនព្វន្តដែលមានតួទី 1 ស្មើ 2 និងផលសងរួមស្មើ 2 នោះ

$b_n = 2 + 2(n-1) = 2n$

ចំពោះ $n \geq 2$ គេបាន

$$a_n = a_1 + \sum_{k=1}^{n-1} b_k = 2 + \sum_{k=1}^{n-1} 2k = 2 + 2\cdot\frac{1}{2}n(n-1) = 2 + n^2 - n = n^2 - n + 2$$

នោះ $a_n = n^2 - n + 2$ ។

ចំពោះ $n = 1$ , $a_1 = 1^2 - 1 + 2 = 2$ ពិត ។

ដូចនេះ ស្ទីត $(a_n)$ មានតួទី $n$ កំណត់ដោយ $a_n = n^2 - n + 2$ ។

**លំហាត់គំរូ 2** ក. កំណត់តួទី $n$ នៃស្ទីត 1, 2, 5, 10, 17,... ។

ខ. គណនាផលបូក $n$ តួដំបូងនៃស្ទីតនេះ ។

**ចម្លើយ** ក. កំណត់តួទី $n$ នៃស្ទីត $(a_n)$ : 1, 2, 5, 10, 17,...

តាង $a_n$ ជាតួទី $n$ នៃស្ទីតដែលគេឱ្យ $(a_n)$ ។ ស្ទីត $(b_n)$ ជាផលសងលំដាប់ 1 នៃស្ទីត $(a_n)$ ដែលមានតួ $b_n$ កំណត់ដោយ $b_n = a_{n+1} - a_n$ ។ ស្ទីត $(b_n)$ : 1, 3, 5, 7,... ។ ស្ទីត $(b_n)$ ជាស្ទីតនព្វន្តដែលមានតួទី 1 ស្មើ 1 និងផលសងរួមស្មើ 2 នោះ $b_n = 1 + 2(n-1) = 2n - 1$ ។

ចំពោះ $n \geq 2$ គេបាន $a_n = a_1 + \sum_{k=1}^{n-1} b_k = 1 + \sum_{k=1}^{n-1}(2k-1) = 1 + 2\sum_{k=1}^{n-1} k - (n-1)$

$$= 1 + 2\cdot\frac{1}{2}n(n-1) - (n-1) = 1 + n^2 - n - n + 1 = 2 - 2n + n^2$$

នោះ $a_n = 2 - 2n + n^2$

ចំពោះ $n = 1$ គេបាន $a_1 = 2 - 2 + 1 = 1$ ពិត ។ ដូចនេះ $a_n = 2 - 2n + n^2$ ។

ខ. គណនាផលបូក $n$ តួដំបូងនៃស្ទីត $(a_n)$

តាង $S_n$ ជាផលបូកនៃស្ទីត $(a_n)$ គឺ

$$S_n = a_1 + a_2 + a_3 + \ldots + a_n = \sum_{k=1}^{n}(2 - 2k + k^2)$$

$$= 2n - 2\sum_{k=1}^{n} k + \sum_{k=1}^{n} k^2 = 2n - 2\cdot\frac{1}{2}n(n+1) + \frac{1}{6}n(n+1)(2n+1)$$

$$= \frac{12n}{6} - \frac{6}{6}n(n+1) + \frac{1}{6}n(n+1)(2n+1) = \frac{1}{6}n(12 - 6n - 6 + 2n^2 + n + 2n + 1)$$

$$= \frac{1}{6}n(7 - 3n + 2n^2)$$

ដូចនេះ $S_n = \frac{1}{6}n(2n^2 - 3n + 7)$ ។

**ប្រតិបត្តិ** 1. ក. កំណត់តួទី $n$ នៃស៊ីត $4, 5, 7, 10, 14, \ldots$ ។

ខ. គណនាផលបូក $n$ តួដំបូងនៃស៊ីតនេះ ។

2. ក. កំណត់តួទី $n$ នៃស៊ីត $3, 5, 8, 12, 17, 23, \ldots$ ។

ខ. គណនាផលបូក $n$ តួដំបូងនៃស៊ីតនេះ ។

## 4.2 ផលសងលំដាប់ទី 2 តួនៃស៊ីត

បើសិនជាស៊ីត $(b_n)$ នៅតែមិនអាចកំណត់តួទី $n$ នៃស៊ីត $(a_n)$ បានទៀត នោះគេត្រូវធ្វើផលសងលំដាប់តួនៃស៊ីត $(b_n)$ បន្តទៀត ដែលគេហៅថា ផលសងលំដាប់ទី 2 តួនៃស៊ីត ។

***ឧទាហរណ៍*** កំណត់តួទី $n$ នៃស៊ីត $(a_n) : 1, 2, 6, 15, 31, 56, \ldots$ ។

**របៀបទី 1** $n$ : 1 2 3 4 5 6...

ស៊ីត $(a_n)$ : 1 2 6 15 31 56... ។

ផលសងលំដាប់ 1 : 1 4 9 16 25...

តាង $a_n$ ជាតួទី $n$ នៃស៊ីត $(a_n)$ ។ ស៊ីត $(b_n)$ ជាផលសងលំដាប់ 1 នៃស៊ីត $(a_n)$ ។

ស៊ីត $(b_n)$ : 1 4 9 16 25... នោះ $b_n = n^2$ ។

ចំពោះ $n \geq 2$ គេបាន $a_n = a_1 + \sum_{k=1}^{n-1} k^2 = 1 + \frac{1}{6}(2n-1)(n-1)n$

នោះ $a_n = \frac{1}{6}(2n-1)(n-1)n + 1$ ។

ចំពោះ $n = 1$ , $a_1 = 1$ ពិត ។

ដូចនេះ $a_n = \frac{1}{6}(2n-1)(n-1)n + 1$ ។

**របៀបទី 2** $n$ : 1 2 3 4 5 6...

ស៊ីត $(a_n)$ : 1 2 6 15 31 56...

ផលសងលំដាប់ 1 : 1 4 9 16 25...

ផលសងលំដាប់ 2 : 3 5 7 9

តាង $a_n$ ជាតួទី $n$ នៃស៊ីត $(a_n)$ ។ ស៊ីត $(b_n)$ ជាផលសងលំដាប់ 1 នៃស៊ីត $(a_n)$ ដែលមានតួទី $n$ នៃស៊ីតគឺ $b_n = a_{n+1} - a_n$ ។ តាង $c_n$ ជាផលសងតួនៃស៊ីត $(b_n)$ ហៅថា ផលសងលំដាប់ទី 2 ។ គេបានស៊ីត $(c_n) : 3, 5, 7, 9, \ldots$ ។ ស៊ីត $(c_n)$ ជាស៊ីតនព្វន្តដែលមានតួទី 1 ស្មើ 3 និងផលសងរួមស្មើ 2 និង $c_n = 3 + 2(n-1) = 2n+1$ ។

ចំពោះ $n \ge 2$ គេបាន $b_n = b_1 + \sum_{k=1}^{n-1} c_k = b_1 + \sum_{k=1}^{n-1}(2k+1)$

$$= 1 + 2\sum_{k=1}^{n-1} k(n-1) = n + 2\cdot\frac{1}{2}(n-1)n = n^2$$ នោះ $b_n = n^2$ ។

ចំពោះ $n = 1$ , $b_1 = 1$ ពិត ។ ដូចនេះ $b_n = n^2$ ។

ចំពោះ $n \ge 2$ គេបាន $a_n = a_1 + \sum_{k=1}^{n-1} b_k = 1 + \sum_{k=1}^{n-1} k^2 = 1 + \frac{1}{6}(2n-1)(n-1)n$

នោះ $a_n = \frac{1}{6}(2n-1)(n-1)n + 1$ ។

ចំពោះ $n = 1$ , $a_1 = 1$ ពិត

ដូចនេះ $a_n = \frac{1}{6}(2n-1)(n-1)n + 1$ ។

**ជាទូទៅ** គេមានស៊ីត $(a_n)$ ។

ស៊ីត $(b_n)$ កំណត់ដោយ $b_n = a_{n+1} - a_n$ , $n = 1, 2, 3, \ldots$ ហៅថាផលសងលំដាប់ 1 នៃស៊ីត $(a_n)$ ដែលមានតួទី $n$ កំណត់ដោយ $a_n = a_1 + \sum_{k=1}^{n-1} b_k$ ចំពោះ $n \ge 2$ ។

ស៊ីត $(c_n)$ ជាផលសងលំដាប់ 2 នៃស៊ីត $(a_n)$ គឺជាផលសងលំដាប់ 1 នៃស៊ីត $(b_n)$ កំណត់ដោយ $c_n = b_{n+1} - b_n$ , $n = 1, 2, 3, \ldots$ ដែលមានតួទី $n$ នៃស៊ីត $(b_n)$ កំណត់ដោយ $b_n = b_1 + \sum_{k=1}^{n-1} c_k$ ចំពោះ $n \ge 2$ ។

**លំហាត់គំរូ** ក. កំណត់តួទី $n$ នៃស៊ីត 4, 18, 48, 100, 180, 294,... ។

ខ. គណនាផលបូក $n$ តួដំបូងនៃស៊ីតនេះ ។

**ចម្លើយ** ក. កំណត់តួទី $n$ នៃស៊ីត 4, 18, 48, 100, 180, 294,...

តាង $a_n$ ជាតួទី $n$ នៃស៊ីតដែលគេឱ្យ $(a_n)$

ស៊ីត $(b_n)$ ជាផលសងស៊ីតលំដាប់ 1 នៃស៊ីត $(a_n)$ ដែលមានតួ $b_n$ នៃស៊ីតកំណត់ដោយ $b_n = a_{n+1} - a_n$ ។ ស៊ីត $(b_n)$ : 14, 30, 52, 80, 114,... ។

តាងស៊ីត $(c_n)$ ជាផលសងស៊ីតលំដាប់ 1 នៃស៊ីត $(b_n)$ ដែលមានតួ $c_n$ ជាតួទី $n$ នៃស៊ីតកំណត់ដោយ $c_n = b_{n+1} - b_n$ គេបានស៊ីត $(c_n)$ : 16, 22, 28, 34, ... ។

ស្វ៊ីត $(c_n)$ ជាស្វ៊ីតនព្វន្តដែលមានតួទី 1 ស្មើ 16 និងផលសងរួមស្មើ 6

$$c_n = 16+6(n-1) = 16+6n-6 = 6n+10$$

ចំពោះ $n \ge 2$ គេបាន $b_n = b_1 + \sum_{k=1}^{n-1} c_k = 14 + \sum_{k=1}^{n-1}(6k+10)$

$$= 14 + 6\sum_{k=1}^{n-1} k + 10(n-1) = 14 + 6\cdot\frac{1}{2}n(n-1) + 10(n-1) = 3n^2+7n+4$$

ចំពោះ $n = 1$ គេបាន $b_1 = 4+7+3 = 14$ ពិត ។ ដូចនេះ $b_n = 3n^2+7n+4$ ។

ចំពោះ $n \ge 2$ គេបាន $a_n = a_1 + \sum_{k=1}^{n-1} b_k = 4 + \sum_{k=1}^{n-1}(3k^2+7k+4)$

$$= 4 + 3\sum_{k=1}^{n-1} k^2 + 7\sum_{k=1}^{n-1} k + 4(n-1)$$

$$= 4 + 3\cdot\frac{1}{6}n(n-1)(2n-1) + 7\cdot\frac{1}{2}(n-1)n + 4n - 4$$

$$= \frac{1}{2}(n-1)(7n+2n^2-n)+4n = (n-1)(3n+n^2)+4n = n^3+2n^2+n$$

ដូចនេះ $a_n = n^3+2n^2+n$ ។

ខ. គណនាផលបូក $n$ តួដំបូងនៃស្វ៊ីត $(a_n)$

តាង $S_n$ ជាផលបូកនៃស្វ៊ីត $(a_n)$ គឺ

$$S_n = a_1+a_2+a_3+\ldots+a_n$$

$$S_n = \sum_{k=1}^{n} a_k = \sum_{k=1}^{n}(k^3+2k^2+k)$$

$$= \sum_{k=1}^{n} k^3 + 2\sum_{k=1}^{n} k^2 + \sum_{k=1}^{n} k$$

$$= \frac{1}{4}n^2(1+n)^2 + 2\cdot\frac{1}{6}n(n+1)(2n+1) + \frac{1}{2}n(n+1)$$

$$= \frac{1}{12}n(n+1)(3n+3n^2+4+8n+6)$$

$$= \frac{1}{12}n(n+1)(3n^2+11n+10)$$

ចំពោះ $n = 1$ , $a_1 =$ ពិត

ដូចនេះ $S_n = \frac{1}{12}n(n+1)(3n^2+11n+10)$

**ប្រតិបត្តិ** កំណត់តួទី $n$ នៃស្វ៊ីត 1, 2, 5, 12, 27, 58, 121,... ។

## លំហាត់

1. សរសេរផលបូកខាងក្រោមដោយប្រើនិមិត្តសញ្ញា Σ :

ក. $1+2+3+\ldots+100$ ខ. $1+4+9+16+\ldots+484$

គ. $1+8+27+64+\ldots+3375$ ឃ. $1\times3+2\times4+3\times5+\ldots+20\times22$

2. សរសេរគ្រប់តួទាំងអស់នៃផលបូកដោយមិនប្រើនិមិត្តសញ្ញា Σ :

ក. $\sum_{k=1}^{6} k$ ខ. $\sum_{k=1}^{5} k^2$ គ. $\sum_{k=4}^{9} (3k-1)$ ឃ. $\sum_{k=2}^{7} (-1)^k k$

3. គណនា ក. $\sum_{k=1}^{11} k^2$ ខ. $\sum_{k=1}^{24} k^2$ គ. $\sum_{k=12}^{24} k^2$

4. គណនា ក. $\sum_{k=1}^{24} k^3$ ខ. $\sum_{k=1}^{15} k^3$ គ. $\sum_{k=16}^{24} k^3$

5. ក. សម្រួលកន្សោម $\sum_{k=1}^{n} k(k+1)$

ខ. ដោយប្រើចម្លើយ ក. គណនាផលបូក $1\times2+2\times3+3\times4+\ldots+28\times29$

6. ក. សម្រួលកន្សោម $\sum_{k=1}^{n} k(k+1)(k+2)$

ខ. ដោយប្រើចម្លើយ ក. គណនាផលបូក $1\times2\times3+2\times3\times4+3\times4\times5+\ldots+20\times21\times22$

7. ក. កំណត់តួទី $n$ នៃស្វ៊ីត $1, 2, 5, 10, 17,\ldots$ ។

ខ. គណនាផលបូក $n$ តួដំបូងនៃស្វ៊ីតនេះ ។

8. ក. កំណត់តួទី $n$ នៃស្វ៊ីត $1, 5, 14, 30, 55, 91,\ldots$ ។

ខ. រកផលបូក $n$ តួដំបូងនៃស្វ៊ីតនេះ ។

9. កំណត់តួទី $n$ នៃស្វ៊ីត $(a_n) : p, q, p, q, p, q,\ldots$ ។

មេរៀនទី

# 2 ទំនាក់ទំនងតួនៃស៊ីត

## 1. កំណត់តួទី n ដោយប្រើស៊ីតជំនួយ

**វត្ថុបំណង**

- កំណត់តួទី $n$ ដោយប្រើស៊ីតជំនួយ
- កំណត់តួទី $n$ តាមទំនាក់ទំនងរវាង $a_n$ និង $S_n$
- កំណត់តួទូទៅនៃទំនាក់ទំនងតួក្នុងទម្រង់ $a_{n+2}+pa_{n+1}+qa_n = 0$

គេបានសិក្សារួចមកហើយនូវទំនាក់ទំនងតួនៃស៊ីតនព្វន្ត និងស៊ីតធរណីមាត្រ ។

ចំពោះស៊ីតនព្វន្ត $a_{n+1} = a_n + d$ , $d$ ជាផលសងរួម ។

ចំពោះស៊ីតធរណីមាត្រ $a_{n+1} = a_n \times q$ , $q$ ជាផលធៀបរួម ។

តទៅទៀតគេនឹងសិក្សាអំពីទំនាក់ទំនងតួនៃស៊ីតផ្សេងៗទៀតដោយកំណត់រកតួទី $n$ នៃស៊ីតនោះ ។

**លំហាត់គំរូ 1** កំណត់តួទូទៅនៃស៊ីត $(a_n)$ ដោយទំនាក់ទំនងកំណើន $a_1 = 1$ , $a_{n+1} = 1+4a_n$ ។

**ចម្លើយ**

***របៀបទី 1*** គេមាន $a_1 = 1$ ពី $a_{n+1} = 1+4a_n$ គេអាចកំណត់

$a_2 = 1+4a_1 = 1+4$

$a_3 = 1+4a_2 = 1+4\times(1+4) = 1+4+4^2$

$a_4 = 1+4a_2 = 1+4\times(1+4+4^2) = 1+4+4^2+4^3$

..........................

នោះ $a_n = 1+4+4^2+4^3+\ldots+4^{n-1}$

គេបាន $a_n = 1+4+4^2+4^3+\ldots+4^{n-1} = \dfrac{1\times(4^n-1)}{4-1} = \dfrac{4^n-1}{3}$ ។

ដូចនេះ តួទី $n$ នៃស៊ីត $(a_n)$ គឺ $a_n = \dfrac{4^n-1}{3}$ ។

***របៀបទី 2*** ចំពោះ $n\geq 2$ គេបាន $a_{n+1} = 1+4a_n$ , $a_n = 1+4a_{n-1}$

នោះ $a_{n+1} - a_n = 1 + 4a_n - (1 + 4a_{n-1}) = 4(a_n - a_{n-1})$ (1)

បើគេតាង $b_n = a_{n+1} - a_n$ នោះពី (1) គេបាន $b_n = 4b_{n-1} \Rightarrow \frac{b_n}{b_{n-1}} = 4$ នោះស្វ៊ីត $(b_n)$ ជាស្វ៊ីតធរណីមាត្រដែលមានផលធៀបរួមស្មើនឹង 4 និងមានតួទី 1 និងតួទី $n$ គឺ

$b_1 = a_2 - a_1 = 1 + 4 \times 1 - 1 = 4$ , $b_n = 4 \times 4^{n-1} = 4^n$

ស្វ៊ីត $(b_n)$ ជាផលសងស្វ៊ីត $(a_n)$ តាមរូបមន្ត ចំពោះ $n \geq 2$ គេបាន

$$a_n = a_1 + \sum_{k=1}^{n-1} 4^k = 1 + 4^1 + 4^2 + \ldots + 4^{n-1} = \frac{1 \times (4^n - 1)}{4 - 1} = \frac{4^n - 1}{3} \text{ ។}$$

ដូចនេះ តួទី $n$ នៃស្វ៊ីត $(a_n)$ គឺ $a_n = \frac{4^n - 1}{3}$ ។

***របៀបទី 3*** គេប្រើស្វ៊ីតជំនួយ $(r_n)$ រួចធ្វើផលដក $a_{n+1} - r_n$

គេឱ្យ $r_n = -\frac{1}{3}$ គេបាន $a_{n+1} + \frac{1}{3} = 1 + 4a_n + \frac{1}{3} = 4a_n + \frac{4}{3} = 4 \cdot \left(a_n + \frac{1}{3}\right)$

តាង $V_{n+1} = a_{n+1} + \frac{1}{3}$ ហើយ $V_n = a_n + \frac{1}{3}$ (1) ។

គេបាន $V_{n+1} = 4V_n$ ហើយ $V_n = 4^{n-1} \cdot V_1$

គេអាចគណនា $V_1$ តាមទំនាក់ទំនង (1) គឺ $V_1 = a_1 + \frac{1}{3} = \frac{4}{3}$

គេបាន $V_n = 4^{n-1} \cdot \frac{4}{3} = \frac{1}{3} \cdot 4^n$ គេអាចគណនា $a_n$ តាមទំនាក់ទំនង (1)

គឺ $a_n = V_n - \frac{1}{3} = \frac{1}{3} \cdot 4^n - \frac{1}{3} = \frac{4^n - 1}{3}$

**សំគាល់** ដើម្បីកំណត់រកតម្លៃនៃស្វ៊ីតជំនួយ $(r_n)$ គេតាង $r_n = \alpha \cdot n + \beta$ ($\alpha, \beta$ ថេរ) ជាស្វ៊ីតដែលផ្ទៀងផ្ទាត់ $a_{n+1} = 1 + 4a_n$ ។ ជំនួសស្វ៊ីតជំនួយទៅក្នុងស្វ៊ីត $(a_n)$ គេបានសមីការដែលអាចឱ្យគេកំណត់រក $\alpha$ និង $\beta$

$$a_{n+1} = 1 + 4a_n \Leftrightarrow \alpha \cdot (n+1) + \beta = 1 + 4 \cdot (\alpha \cdot n + \beta) \text{ ឬ } 3 \cdot \alpha \cdot n + 3 \cdot \beta - \alpha + 1 = 0$$

គេបានប្រព័ន្ធ $\begin{cases} 3 \cdot \alpha = 0 \\ 3 \cdot \beta - \alpha + 1 = 0 \end{cases}$ ហើយ $\alpha = 0$ , $\beta = -\frac{1}{3}$ ។

ហេតុនេះ $r_n = -\frac{1}{3}$ ដូចនេះស្វ៊ីត $(r_n)$ ហៅថាស្វ៊ីតជំនួយ ។

**ជាទូទៅ** គេប្រើស្វ៊ីតជំនួយ $(r_n)$ ដែល $r_n = \alpha \cdot n + \beta$($\alpha, \beta$ ថេរ) ដែលផ្ទៀងផ្ទាត់ទំនាក់ទំនងនៃស្វ៊ីត ។ ក្នុងករណីនេះ គេជំនួស $r_n$ ក្នុងទំនាក់ទំនងនៃស្វ៊ីត រួចគណនាតម្លៃ $\alpha$ និង $\beta$ បន្ទាប់មកកំណត់បានស្វ៊ីត $(r_n)$ គេនឹងធ្វើផលសង $a_{n+1} - r_n$

**លំហាត់គំរូ 2** គេឱ្យស៊ីត $(a_n)$ កំណត់ដោយ $a_1 = 3$ , $a_{n+1} = 2a_n - n + 1$ ។ កំណត់តួទី $n$ ។

**ចម្លើយ** តាង$(r_n)$ ដែល $r_n = \alpha n + \beta$ ជាស៊ីតជំនួយ

គេបាន $a_{n+1} = 2a_n - n + 1 \Leftrightarrow \alpha \cdot (n+1) + \beta = 2(\alpha \cdot n + \beta) - n + 1$

$n \cdot (\alpha - 1) + \beta - \alpha + 1 = 0$ គេបានប្រព័ន្ធ $\begin{cases} \alpha - 1 = 0 \\ \beta - \alpha + 1 = 0 \end{cases}$ ហើយ $\alpha = 1$ , $\beta = 0$

នោះ $r_n = n$ ធ្វើផលសងរវាងស៊ីត $a_{n+1} - r_n$

$a_{n+1} - n = 2a_n - n + 1 - n = 2a_n - 2n + 1$ , $a_{n+1} - (n+1) = 2(a_n - n)$

តាង $V_n = a_n - n$ (1) នោះ $V_{n+1} = a_{n+1} - (n+1)$ គេបាន $V_{n+1} = 2 \cdot V_n$

ហើយ $V_n = 2^{n-1} \cdot V_1$

គេគណនា $V_1$ តាម $V_n = a_n - n$ , $V_1 = a_1 - 1 = 3 - 1 = 2$ , $V_n = 2^{n-1} \cdot 2 = 2^n$

គេអាចគណនា $V_n$ តាម (1) គឺ $V_n = a_n - n$ នោះ $a_n = V_n + n = 2^n + n$ ។

ដូចនេះ $a_n = 2^n + n$ ។

**ប្រតិបត្តិ** កំណត់តួទី $n$ នៃស៊ីត $(a_n)$ កំណត់ដោយ $a_1 = 5$ , $a_n = 2a_{n-1} - n$ ។

## 2. ទំនាក់ទំនងរវាង $a_n$ និង $S_n$

***ឧទាហរណ៍*** គេមានផលបូក $n$ តួដំបូងនៃស៊ីត $(a_n)$ គឺ $S_n = n^2 + n$ ។ កំណត់តួទី $n$ នៃស៊ីត $(a_n)$ ។

***ចម្លើយ*** កំណត់តួទី $n$ នៃស៊ីត $(a_n)$

គេមានផលបូក $n$ តួដំបូងនៃស៊ីត $(a_n)$ គឺ

$S_n = n^2 + n \Leftrightarrow S_n = a_1 + a_2 + a_3 + \ldots + a_{n-1} + a_n = n^2 + n$

$\Rightarrow S_{n-1} = a_1 + a_2 + a_3 + \ldots + a_{n-1} = (n-1)^2 + (n-1)$

ចំពោះ $n \geq 2$ គេបាន $S_n - S_{n-1} = a_n = n^2 + n - [(n-1)^2 + (n-1)]$

$a_n = n^2 + n - (n-1)^2 - n + 1 = n^2 + n - n^2 + 2n - 1 - n + 1 = 2n$ នោះ $a_n = 2n$ ។

ចំពោះ $n = 1$ គេបាន $S_1 = 1^2 + 1 = 2$ ពិត ព្រោះ $(S_1 = a_1 = 2)$ ។ ដូចនេះ $a_n = 2n$ ។

ឧបមាថា $S_n$ គឺជាផលបូក $n$ តួដំបូងនៃស៊ីត $(a_n)$ នោះ $S_n = a_1 + a_2 + \ldots + a_{n-1} + a_n$ និង $S_{n-1} = a_1 + a_2 + \ldots a_{n-1}$ ។

ចំពោះ $n \geq 2$ គេបាន $S_n - S_{n-1} = a_n$ ។ ម្យ៉ាងទៀត $S_1 = a_1$ ។

**ជាទូទៅ** ចំពោះ $n \geq 2$ គេបាន $S_n - S_{n-1} = a_n$ និង $S_1 = a_1$

**សំគាល់** $S_n$ និង $S_{n+1}$ មានភាពចាំបាច់ដើម្បីរក $a_{n+1}$ គឺ $a_{n+1} = S_{n+1} - S_n$ ។

**លំហាត់គំរូ** គេមានផលបូក $n$ តួដំបូងនៃស្វ៊ីត $(a_n)$ គឺ $S_n = n^3 + 2n$ ។

កំណត់តួទី $n$ នៃស្វ៊ីត $(a_n)$ ។

**ចម្លើយ** កំណត់តួទី $n$ នៃស្វ៊ីត $(a_n)$

គេមានផលបូក $n$ តួដំបូងនៃស្វ៊ីត $(a_n)$ គឺ

$S_n = n^3 + 2n \Rightarrow S_{n-1} = (n-1)^3 + 2(n-1)$

$a_n = S_n - S_{n-1} = n^3 + 2n - (n-1)^3 - 2(n-1)$

$= n^3 + 2n - 2n + 2 - n^3 + 3n^2 - 3n + 1 = 3n^2 - 3n + 3$

ដូចនេះ តួទី $n$ នៃស្វ៊ីត $(a_n)$ គឺ $a_n = 3n^2 - 3n + 3$

**ប្រតិបត្តិ** គេមាន $S_n = 4 - a_n - \frac{1}{2^{n-2}} (n = 1, 2, 3, \ldots)$ ជាផលបូក $n$ តួដំបូងនៃស្វ៊ីត $(a_n)$ ។

ក. កំណត់ទំនាក់ទំនងកំណើនរវាង $a_{n+1}$ និង $a_n$ ។

ខ. កំណត់តួទី $n$ នៃស្វ៊ីត $(a_n)$ ។

## 3. ទំនាក់ទំនងកំណើនក្នុងទម្រង់ $a_{n+2} + pa_{n+1} + qa_n = 0$

***ឧទាហរណ៍*** កំណត់តួទី $n$ នៃស្វ៊ីត $(a_n)$ ដោយ $a_1 = 1$ , $a_2 = 3$ ដែល

$a_{n+2} = 3a_{n+1} - 2a_n (n = 1, 2, \ldots)$ ។

គេស្គាល់ $a_1$ , $a_2$ គេអាចគណនាតួ $a_3$ និងតួបន្តបន្ទាប់ដើម្បីពិនិត្យមើលលំនាំគំរូ

$a_3 = 3 \cdot a_2 - 2 \cdot a_1 = 9 - 2 = 7$

$a_4 = 3 \cdot a_3 - 2 \cdot a_2 = 21 - 6 = 15$

$a_5 = 3 \cdot a_4 - 2 \cdot a_3 = 45 - 14 = 31$

$a_6 = 3 \cdot a_5 - 2 \cdot a_4 = 93 - 30 = 63$

គណនាផលសងតួនៃស្វ៊ីតនេះ

$a_2 - a_1 = 2$

$a_3 - a_2 = 2^2$

$a_4 - a_3 = 2^3$

$\dots\dots\dots\dots\dots$

$a_n - a_{n-1} = 2^{n-1}$

$a_n - a_1 = 2 + 2^2 + 2^3 + \dots + 2^{n-1}$ នោះ $a_n = 1 + 2 + 2^2 + 2^3 + \dots + 2^{n-1}$

ជាផលបូកតួនៃស្វ៊ីតធរណីមាត្រដែលមាន 1 ជាតួទីមួយ និងផលធៀបរួមស្មើនឹង 2

គេបាន $a_n = 2^n - 1$ ។

ជាទូទៅគេអាចគណនា $a_n$ តាមវិធីខាងក្រោម :

$a_{n+2} = 3a_{n+1} - 2a_n \Leftrightarrow a_{n+2} - 2a_{n+1} = a_{n+1} - 2a_n = a_n - 2a_{n-1}$

$= a_{n-1} - 2a_{n-2} = \dots = a_2 - 2a_1 = 3 - 2\times 1 = 1$

នោះ $a_{n+2} - 2a_{n+1} = a_{n+1} - 2a_n = 1$ (1) ។

ម្យ៉ាងទៀត $a_{n+2} = 3a_{n+1} - 2a_n \Leftrightarrow a_{n+2} - a_{n+1} = 2(a_{n+1} - a_n)$

តាង $b_n = a_{n+1} - a_n$ នោះ $(b_n)$ ឬ $(a_{n+1} - a_n)$ ជាស្វ៊ីតធរណីមាត្រដែលមានផលធៀបរួមស្មើនឹង 2 និងតួទីមួយស្មើ $b_1 = a_2 - a_1 = 3 - 1 = 2$ ហើយ $b_n = 2\cdot(2)^{n-1} = 2^n$ (2)

តាម (1) និង (2) គេបាន

$$-\begin{cases} a_{n+1} - 2a_n = 1 & (1) \\ a_{n+1} - a_n = 2^n & (2) \end{cases}$$
$$\overline{\quad -a_n = 1 - 2^n \quad}$$

ដូចនេះ តួទី $n$ នៃស្វ៊ីត $(a_n)$ គឺ $a_n = 2^n - 1$ ។

គេបានរបៀបរកតួទូទៅតាមទំនាក់ទំនងដូចខាងក្រោម :

**ជាទូទៅ របៀបដោះស្រាយ $a_{n+2} + pa_{n+1} + qa_n = 0$**

បើទំនាក់ទំនងនៃស្វ៊ីត $(a_n)$ មានទម្រង់ $a_{n+2} + pa_{n+1} + qa_n = 0$

គេពិចារណាពីរចំនួន $\alpha$ និង $\beta$ ដែលបំពេញលក្ខខណ្ឌ $\alpha + \beta = -p$ , $\alpha\beta = q$ ។

នោះគេបាន $a_{n+2} - (\alpha + \beta)a_{n+1} + \alpha\beta a_n = 0$ ។

ទំនាក់ទំនងនេះអាចបំលែងតាមរបៀបពីរយ៉ាងដូចខាងក្រោម :

$a_{n+2} - \alpha a_{n+1} = \beta(a_{n+1} - \alpha a_n)$

$a_{n+2} - \beta a_{n+1} = \alpha(a_{n+1} - \beta a_n)$

ទំនាក់ទំនងទាំង 2 ខាងលើនេះ គឺជាស្វ៊ីតធរណីមាត្រអាចឱ្យគេរក $a_n$ បាន ។

គេអាចរក $\alpha$ និង $\beta$ ដោយដោះស្រាយសមីការ $x^2+px+q=0$ ព្រោះគេស្គាល់ផលបូក និងផលគុណវា ។

សមីការ $x^2+px+q=0$ ហៅថា " **សមីការសំគាល់នៃ $a_{n+2}+pa_{n+1}+qa_n=0$** "

**លំហាត់គំរូ** ស្វ៊ីត $(a_n)$ កំណត់ដោយ $a_1=1$ , $a_2=13$ , $a_{n+2}=a_{n+1}+6a_n$ $(n=1,\ 2\ldots)$ ។ កំណត់តួទី $n$ នៃស្វ៊ីត ។

**ចម្លើយ** កំណត់តួទី $n$ នៃស្វ៊ីត $(a_n)$

$$a_{n+2}=a_{n+1}+6a_n \Leftrightarrow a_{n+2}-a_{n+1}-6a_n=0$$

សមីការសំគាល់ : $x^2-x-6=0$ នោះឫសសមីការ $x=3$ ឬ $x=-2$ គេបាន

$$\begin{cases} a_{n+2}+2a_{n+1}=3(a_{n+1}+2a_n) & (i) \\ a_{n+2}-3a_{n+1}=-2(a_{n+1}-3a_n) & (ii) \end{cases}$$

$(i)$ $\quad a_{n+2}+2a_{n+1}=3(a_{n+1}+2a_n)$

តាង $b_n=a_{n+1}+2a_n$ នោះស្វ៊ីត $(b_n)$ ជាស្វ៊ីតធរណីមាត្រដែលមានផលធៀបរួមស្មើនឹង 3 ហើយតួទី 1 គឺ $b_1=a_2+2a_1=13+2\times 1=15$ និង $b_n=15\cdot(3)^{n-1}$

គេបាន $a_{n+1}+2a_n=15\cdot(3)^{n-1}$ $\quad (1)$

$(ii)$ $\quad a_{n+2}-3a_{n+1}=-2(a_{n+1}-3a_n)$

តាង $c_n=a_{n+1}-3a_n$ នោះស្វ៊ីត $(c_n)$ ជាស្វ៊ីតធរណីមាត្រដែលមានផលធៀបរួមស្មើនឹង $-2$ ហើយតួទី 1 គឺ $c_1=a_2-3a_1=13-3\times 1=10$ និង $c_n=10\cdot(-2)^{n-1}$

គេបាន $a_{n+1}-3a_n=10\cdot(-2)^{n-1}$ $\quad (2)$ ។

តាម (1) និង (2) គេបាន

$$-\begin{cases} a_{n+1}+2a_n=15\cdot(3)^{n-1} & (1) \\ a_{n+1}-3a_n=10\cdot(-2)^{n-1} & (2) \end{cases}$$

$$5a_n=15(3)^{n-1}-10(-2)^{n-1}$$

$$a_n=3\times 3^{n-1}-2\times(-2)^{n-1}=3^n+(-2)^n$$

ដូចនេះ តួទី $n$ នៃស្វ៊ីត $(a_n)$ គឺ $a_n=3^n+(-2)^n$

**ប្រតិបត្តិ** ស្វ៊ីត $(a_n)$ កំណត់ដោយទំនាក់ទំនង $a_1=0$ , $a_2=3$ , $a_{n+2}=4a_{n+1}-3a_n$ $(n=1,\ 2,\ \ldots)$ ។ កំណត់តួទី $n$ នៃស្វ៊ីត $(a_n)$ ។

## លំហាត់

1. ស្វ៊ីត $(a_n)$ កំណត់ដោយទំនាក់ទំនងកំណើនដូចខាងក្រោម ៖

ក. $a_1 = 3$ , $a_{n+1} = 2a_n - 4$

ខ. $a_1 = 5$ , $a_{n+1} = 3a_n - 2n$ ។

កំណត់តួទី 4 នៃស្វ៊ីតនេះ ។

2. ស្វ៊ីត $(a_n)$ កំណត់ដោយទំនាក់ទំនងកំណើន $a_1 = 1$ , $a_2 = 2$ , $a_{n+2} = a_{n+1} + a_n$ ។ កំណត់តួទី 7 នៃស្វ៊ីតនេះ ។

3. ស្វ៊ីត $(a_n)$ កំណត់ដោយទំនាក់ទំនងកំណើន $a_1 = 1$ , $a_{n+1} = pa_n + q$ ។

គណនាតម្លៃ $p$ និង $q$ បើគេដឹងតួទី 3 ស្មើ 6 និងតួទី 5 ស្មើ 86 ។

4. កំណត់តួទូទៅនៃស្វ៊ីត $(a_n)$ កំណត់ដោយទំនាក់ទំនងកំណើនដូចខាងក្រោម ៖

ក. $a_1 = 1$ , $3a_{n+1} = 2a_n + 3$ $(n = 1, 2, \dots)$

ខ. $a_1 = 1$ , $3a_{n+1} = 3a_n + 4$ $(n = 1, 2, \dots)$

គ. $a_1 = 1$ , $a_{n+1} = a_n + n$ $(n = 1, 2, \dots)$

5. គេមានស្វ៊ីត $(a_n)$ កំណត់ដោយ $a_1 = 4$ , $a_{n+1} = \dfrac{4a_n - 9}{a_n - 2}(n = 1, 2, 3, \dots)$

ក. ស្រាយបញ្ជាក់ថា $a_n \neq 3$ ចំពោះគ្រប់ $n$ ។

ខ. យក $b_n = \dfrac{1}{a_n - 3}$ និងកំណត់តួទូទៅនៃស្វ៊ីត $(b_n)$ ។ កំណត់តួទូទៅនៃស្វ៊ីត $(a_n)$ ។

6. គេមាន $S_n$ ជាផលបូក $n$ តួដំបូងនៃស្វ៊ីត $(a_n)$ ។

បើ $S_n$ បំពេញលក្ខខណ្ឌ $S_n = 4 - a_n - \dfrac{1}{2^{n-2}}$ $(n = 1, 2, 3, \dots)$ ។

ក. កំណត់ទំនាក់ទំនងកំណើនរវាង $a_{n+1}$ និង $a_n$ ។

ខ. កំណត់តួទី $n$ នៃស្វ៊ីត $(a_n)$ ។

7. គេមាន $S_n$ ជាផលបូក $n$ តួដំបូងនៃស្វ៊ីត $(a_n)$ ហើយបំពេញលក្ខខណ្ឌ $(a_n)$ : $a_1 = 1$ , $S_n = a_{n+1} + n^2$ $(n \geq 1)$ ។ កំណត់តួទី $n$ នៃស្វ៊ីត $(a_n)$ ។

8. គេមាន $S_n$ ជាផលបូក $n$ តួដំបូងនៃស៊ីត $(a_n)$ ហើយ $S_n$ បំពេញលក្ខខណ្ឌ $S_n = \frac{n}{n-1} \cdot a_n$ $n \geq 2$ ។

ក. បញ្ជាក់រក $a_n$ $(n \geq 3)$ អនុគមន៍នឹង $n$ និង $a_{n-1}$ ។

ខ. បញ្ជាក់រក $S_n$ $(n \geq 2)$ អនុគមន៍នឹង $n$ និង $S_{n-1}$ ។

គ. ឧបមាថា $a_1 = 1$ រកតួទី $n$ នៃស៊ីត $S_n$ ដែល $n \geq 1$ ។

9. គេមានស៊ីត $(a_n)$ កំណត់ដោយទំនាក់ទំនងកំណើន

$(a_n) : a_1 = 2 \ , \ a_{n+1} = \frac{a_n}{a_n + 3} \quad (n = 1, 2, 3, \ldots)$ ។

ក. តាង $b_n = \frac{1}{a_n}$ ។ កំណត់ទំនាក់ទំនងកំណើនរវាង $b_n$ និង $b_{n+1}$ ។

ខ. កំណត់តួទី $n$ នៃស៊ីត $(a_n)$ ។

មេរៀនទី 3

# វិចារអនុមានរួមគណិតវិទ្យា

## 1. គោលការណ៍នៃវិចារអនុមានរួមគណិតវិទ្យា

**វត្ថុបំណង**

- កំណត់វិចារអនុមានរួមគណិតវិទ្យា
- ការប្រើអនុមានរួមគណិតវិទ្យា
- ទ្រឹស្តីបទទ្វេធា

គេគ្រាន់តែសង្កេតមើលឧទាហរណ៍ខ្លះៗនៃផលបូកចំនួនសេស

ផលបូក 1 តួតាងដោយ $P(1) = 1 = 1^2$

ផលបូក 2 តួតាងដោយ $P(2) = 1+3 = 2^2$

ផលបូក 3 តួតាងដោយ $P(3) = 1+3+5 = 3^2$

គេអាចទាញបានផលបូក $n$ តួតាងដោយ

$P(n) = 1+3+5+\ldots+(2n-1) = n^2$

បន្ទាប់ពីបានរូបមន្តនេះមក គេត្រូវបញ្ជាក់ថារូបមន្ត $P(n)$ ពិតចំពោះគ្រប់តម្លៃនៃ $n$ ។ ក្នុងករណីនេះគេផ្តើមផ្ទៀងផ្ទាត់ $P(n)$ ដោយឱ្យ $n = 1$ ។

បើ $n = 1$ $1 = 1^2$ ហេតុនេះ $P(1)$ ពិត

ឧបមាថា $P(n)$ ពិត ចំពោះតម្លៃ $n$ ណាមួយ

គេត្រូវស្រាយថា $P(n)$ ពិតនាំឱ្យបាន $P(n+1)$ ក៏ពិតដែរ

បើ $P(n)$ ពិត គេបាន $1+3+5+\ldots+(2n-1) = n^2$

ដើម្បីស្រាយបញ្ជាក់ថា $P(n+1)$ ពិតលុះត្រាតែគេបាន $P(n+1) = (n+1)^2$

### របៀបស្រាយបញ្ជាក់

គេដឹងថា $P(n+1) = 1+3+5+\ldots+(2n-1)+[2(n+1)-1] = n^2+(2n+2-1)$

$$= n^2+2n+1 = (n+1)^2$$

$P(n+1)$ ពិត ។

ដូចនេះ $P(n)$ ពិតចំពោះគ្រប់ $n \in \mathbb{N}^*$ ។

គោលការណ៍នៃវិចារអនុមានរួមគណិតវិទ្យា

> **វិចារនុមានរួម** $P(n)$ ជាសំណើដែលទាក់ទងនឹងចំនួនគត់ $n$
>
> ដើម្បីស្រាយបញ្ជាក់ថា $P(n)$ ពិតចំពោះគ្រប់ $n \in \mathbb{N}^*$ គេត្រូវ :
>
> 1. ផ្ទៀងផ្ទាត់ថា $P(n)$ ពិតចំពោះ $n = 1$
> 2. ឧបមាថា $P(n)$ ពិតចំពោះតម្លៃ $n$
> 3. ស្រាយបញ្ជាក់ថា $P(n)$ ពិតនាំឱ្យបាន $P(n+1)$ ពិត ។

**លំហាត់គំរូ** 1 ស្រាយបញ្ជាក់សមភាព $1\times 2 + 2\times 3 + 3\times 4 + \ldots + n\times(n+1) = \frac{1}{3}n(n+1)(n+2)$ ពិតចំពោះគ្រប់ $n \in \mathbb{N}^*$ ដោយប្រើវិចារអនុមានរួមគណិតវិទ្យា

**ចម្លើយ** ចំពោះ $n = 1$

អង្គខាងឆ្វេង $1\times 2 = 2$ អង្គខាងស្តាំ $\frac{1}{3}\times 1\times(1+1)(1+2) = 2$

នោះអង្គខាងឆ្វេង = អង្គខាងស្តាំ

ដូចនេះ ចំពោះ $n = 1$ សមភាពពិត ។

ឧបមាថា សមភាពពិតចំពោះ $n = k$ គេបាន

$$1\times 2 + 2\times 3 + 3\times 4 + \ldots + k\times(k+1) = \frac{1}{3}k(k+1)(k+2) \quad (k = 1,\ 2,\ 3,\ \ldots)$$

បង្ហាញថាសមភាពពិតចំពោះ $n = k$ នាំឱ្យបានសមភាពពិតចំពោះ $n = k+1$

$$1\times 2 + 2\times 3 + 3\times 4 + \ldots + k(k+1) + (k+1)(k+2) = \frac{1}{3}(k+1)(k+2)(k+3)$$

គេមាន $1\times 2 + 2\times 3 + 3\times 4 + \ldots + k\times(k+1) = \frac{1}{3}k(k+1)(k+2)$

ថែម $(k+1)(k+2)$ លើអង្គទាំងពីរនៃសមីការ គេបាន

$$1\times 2 + 2\times 3 + 3\times 4 + \ldots + k\times(k+1) + (k+1)(k+2) = \frac{1}{3}k(k+1)(k+2) + (k+1)(k+2)$$

$$= (k+1)(k+2)\left(\frac{1}{3}k + 1\right) = (k+1)(k+2)\left(\frac{k+3}{3}\right)$$

$$= \frac{1}{3}(k+1)(k+2)(k+3) \text{ ពិត}$$

ដូចនេះ សមភាពពិតចំពោះគ្រប់ $n \in \mathbb{N}^*$

ដូចនេះ $1\times 2 + 2\times 3 + 3\times 4 + \ldots + n\times(n+1) = \frac{1}{3}n(n+1)(n+2)(n = 1,\ 2,\ 3,\ldots)$

**លំហាត់គំរូ 2** ចំពោះ $h>0$ និងចំនួនគត់ធម្មជាតិ $n\geq 2$ បង្ហាញថា $(1+h)^n>1+nh$ ដោយប្រើវិចារអនុមានរួមគណិតវិទ្យា ។

**ចម្លើយ** ចំពោះ $n = 2$

គេបាន $(1+h)^2 = 1+2h+h^2>1+2h$ ព្រោះ $h^2\geq 0$

ដូចនេះ វិសមភាពនេះពិត ចំពោះ $n = 2$

ឧបមាថាវិសមភាពនេះពិត ចំពោះ $n = k$ $(k\geq 2)$ នោះ $(1+h)^k>1+kh$ ពិត

គេនឹងបង្ហាញថាវាពិតដល់ $n = k+1(k\geq 2)$ គឺ $(1+h)^{k+1}>1+(k+1)\times h$ (1)

គេមាន $(1+h)^k>1+kh$ ដោយ $h>0$ នោះ $1+h>0$

គុណអង្គទាំងពីរនៃ (1) និង $1+h>0$

គេបាន $(1+h)^k(1+h)>(1+kh)(1+h)$

$(1+h)^{k+1}>1+kh+h+kh^2 = 1+(k+1)h+kh^2>1+(k+1)h$ ព្រោះ $kh^2\geq 0$ ។

ដូចនេះ វិសមភាព $(1+h)^2>1+nh$ ពិតចំពោះគ្រប់ $n\geq 2$ ។

**លំហាត់គំរូ 3** ស្រាយបញ្ជាក់ថា $n^3+2n$ ជាពហុគុណនៃ 3 ចំពោះគ្រប់ $n\in N$ ដោយប្រើវិចារអនុមានរួមគណិតវិទ្យា ។

**ចម្លើយ** ចំពោះ $n = 0$ គេបាន 0 ជាពហុគុណនៃ 3 ពិត ។

ឧបមាថាសមភាពពិតចំពោះ $n = k$

គេបាន $k^3+2k$ ជាពហុគុណនៃ 3 ពិត

យើងបាន $k^3+2k = 3q$

គេបង្ហាញថាវាពិតចំពោះ $n = k+1$ គឺ $(k+1)^3+2(k+1)$ ជាពហុគុណនៃ 3 ។

គេបាន $(k+1)^3+2(k+1) = k^3+3k^2+3k+1+2k+2$

$$= k^3+3k^2+5k+3 = (k^3+2k)+3\times(k^2+k+1)$$

$$= 3q+3(k^2+k+1) = 3(q+k^2+k+1)$$

មានន័យថា $(k+1)^3+2(k+1)$ ជាពហុគុណនៃ 3

ដូចនេះ $n^3+2n$ ជាពហុគុណនៃ 3 ចំពោះគ្រប់ $n\in\mathbb{N}$ ។

**ប្រតិបត្តិ** ក. ស្រាយបញ្ជាក់វិសមភាព $\left(1+\frac{1}{2}+\frac{1}{3}+\ldots+\frac{1}{n}\right)(1+2+3+\ldots+n)\geq n^2$ ដោយប្រើវិចារអនុមានរួមគណិតវិទ្យា ។

ខ. ស្រាយបញ្ជាក់ថា $2^{n+1}+3^{2n-1}$ ជាពហុគុណនៃ 7 ចំពោះគ្រប់ $n\in\mathbb{N}^*$ ដោយប្រើវិចារអនុមានរួមគណិតវិទ្យា ។

គ. ស្រាយបញ្ជាក់សមភាព $1^2+2^2+3^2+\ldots+n^2=\frac{n(n+1)(2n+1)}{6}$ ដោយប្រើវិចារអនុមានរួមគណិតវិទ្យា ។

## 2. ទ្រឹស្តីបទទ្វេធា

ពេលគេពន្លាតស្វ័យគុណនៃទ្វេធា គេបានពហុធា ឬស៊េរីមួយ ។ វាមិនមែនជាស៊ីតធរណីមាត្រ ឬស៊ីតនព្វន្តឡើយ ។ តែវាមានលំនាំគំរូមួយច្បាស់លាស់ ។ ក្នុងមេរៀននេះគេនឹងសិក្សារូបមន្តពន្លាតនៃស្វ័យគុណនៃទ្វេធាឱ្យបានឆាប់រហ័ស ។ ជាដំបូងពិនិត្យមើលពន្លាតនៃកន្សោម $(x+y)^n$ ចំពោះតម្លៃខ្លះនៃ $n$ ។

***ឧទាហរណ៍ 1***

$$(x+y)^0 = 1$$

$$(x+y)^1 = 1x+1y$$

$$(x+y)^2 = 1x^2+2xy+1y^2$$

$$(x+y)^3 = 1x^3+3x^2y^1+3xy^2+1y^4$$

$$(x+y)^4 = 1x^4+4x^3y^1+6x^2y^2+4xy^3+1y^3$$

$$(x+y)^5 = 1x^5+5x^4y^1+10x^3y^2+10x^2y^3+5xy^4+1y^5$$

..................................................................................

ក្នុងជួរដេកនីមួយៗកើតមានលំនាំគំរូដូចៗគ្នា ។

ពីឧទាហរណ៍ខាងលើ គេសង្កេតក្នុងជួរដេកនីមួយៗនៃពន្លាតកន្សោម $(x+y)^n$ ឃើញថា ៖

- ពន្លាតទ្វេធានីមួយៗជាពហុធាដែលមាន $(n+1)$ តួ ។
- ក្នុងពន្លាតទ្វេធានីមួយៗស្វ័យគុណនៃ $x$ ចុះ 1 ដឺក្រេជាបន្តបន្ទាប់ និងស្វ័យគុណនៃ $y$ កើន 1 ដឺក្រេជាបន្តបន្ទាប់បើគេអានពីឆ្វេងទៅស្តាំ ។
- ផលបូកនៃស្វ័យគុណក្នុងតួនីមួយៗនៃពហុធាស្មើ $n$ ។

- លេខមេគុណចាប់ផ្ដើមនិងចុងក្រោយគឺ 1 ដូចគ្នា ហើយផលបូកនៃលេខមេគុណពីរតួជាប់គ្នា នៃពន្លាត $(x+y)^3$ ជាលេខមេគុណនៃពន្លាត $(x+y)^4$... ។

1 3 3 1 លេខមេគុណនៃ $(x+y)^3$

1 4 6 4 1 លេខមេគុណនៃ $(x+y)^4$

ឬលេខមេគុណនៃតួផ្សេងទៀតកំណត់បានអាស្រ័យនឹងលេខមេគុណនៃតួបន្ទាប់ខាងមុខគឺ

$$\text{លេខមេគុណនៃតួទី } k+1 = \frac{(\text{លេខមេគុណនៃតួទី k}) \times (\text{ស្វ័យគុណនៃ } x \text{ ក្នុងតួទី k})}{k}$$

***ឧទាហរណ៍ 2*** $(x+y)^5 = 1x^5 + 5x^4y^1 + 10x^3y^2 + 10x^2y^3 + 5xy^4 + 1y^5$

$$\frac{1\times 5}{1} \quad \frac{5\times 4}{2} \quad \frac{10\times 3}{3} \quad \frac{10\times 2}{4} \quad \frac{5\times 1}{5}$$

ពីឧទាហរណ៍ 1 បើគេផ្ដាច់យកតែលេខមេគុណនិងតម្រៀបលេខទាំងនេះជារាងត្រីកោណ គេឃើញមានលំនាំគំរូជាច្រើន ។ គេបាន

តម្រៀបលេខមេគុណទាំងនេះជារាងត្រីកោណហៅថា ត្រីកោណប៉ាស្កាល់ និងមានសារៈសំខាន់ណាស់សម្រាប់រកលេខមេគុណក្នុងពន្លាតទ្វេធា $(x+y)^n$ ដែលមានស្វ័យគុណតូចតែវាពិបាកអនុវត្តខ្លាំងណាស់ចំពោះការពន្លាតទ្វេធា $(x+y)^n$ ដែលមានស្វ័យគុណធំ ។




ចំណែកឯស៊ីត 1, 1, 2, 3, 5, 8, 13, 21, ... ហៅថាស៊ីត Fibonacci ។

**លំហាត់គំរូ** ប្រើត្រីកោណប៉ាស្កាល់ពន្លាតកន្សោម $(x+y)^5$ ។

**ចម្លើយ** ដោយប្រើជួរដេកទីប្រាំនៃត្រីកោណប៉ាស្កាល់ គេបានលេខមេគុណ

1 4 6 4 1

1 5 10 10 5 1

គេបាន $(x+y)^5 = 1x^5 + 5x^4y + 10x^3y^2 + 10x^2y^3 + 5xy^4 + 1y^5$ ។

PROEUS DARA


**ប្រតិបត្តិ** ប្រើត្រីកោណប៉ាស្កាល់ពន្លាតកន្សោម $(x+y)^6$ ។

គេចាំបាច់កំណត់គំរូតួទូទៅនៃពន្លាត $(x+y)^n$ គឺ

$$(x+y)^n = 1x^n + \,?\,x^{n-1}y^1 + \,?\,x^{n-2}y^2 + \ldots + \,?\,x^{n-r}y^r + \ldots + 1y^n$$

តួ 1 2 3 ... $(r+1)$ ... $(n+1)$

**លេខមេគុណ** $1 \quad \dfrac{1\times n}{1} \quad \dfrac{n(n-1)}{1\times 2} \quad \ldots \quad \dfrac{n(n-1)(n-2)\ldots(n-r+1)}{1\times 2\times 3\times\ldots\times r} \quad \ldots 1$

$$= 1x^n + \frac{n}{1}x^{n-1}y^1 + \frac{n(n-1)}{1\times 2}x^{n-2}y^2 + \ldots + \frac{n(n-1)(n-2)\ldots(n-r+1)}{1\times 2\times 3\times\ldots\times r}x^{n-r}y^r + \ldots + 1y^n$$

ដូចនេះ

$$(x+y)^n = 1x^n + \frac{n}{1}x^{n-1}y^1 + \frac{n(n-1)}{1\times 2}x^{n-2}y^2 + \ldots + \frac{n(n-1)(n-2)\ldots(n-r+1)}{1\times 2\times 3\times\ldots\times r}x^{n-r}y^r + \ldots + 1y^n$$

ពីត្រីកោណប៉ាស្កាល់ គេឃើញថាលេខមេគុណនៃទ្វេធាជាចំនួនដែលរៀបឆ្លុះគ្នា ហើយគេដឹងថា

$$1 = \frac{n!}{n!0!} = C(n,0) = C(n,n)$$

$$\frac{n}{1} = \frac{n!}{(n-1)!1!} = C(n,1) = C(n,n-1)$$

$$\frac{n(n-1)}{1\cdot 2} = \frac{n\,!}{(n-2)!\cdot 2!} = C(n;2) = C(n,n-2)$$

$$\frac{n(n-1)(n-2)}{1\times 2\times 3} = \frac{n!}{(n-3)!3!} = C(n,3) = C(n,n-3)$$

.....................................................

$$\frac{n(n-1)(n-2)\ldots(n-r+1)}{1\times 2\times 3\times\ldots\times r} = \frac{n!}{(n-r)!r!} = C(n,r) = C(n,n-r)$$

ចំនួនថេរ $C(n,0)$ , $C(n,1)$ , $C(n,2)$ , ... , $C(n,n)$ ហៅថាលេខមេគុណនៃទ្វេធា $(x+y)^n$

គេបាន

$$(x+y)^n = 1x^n + \frac{n}{1}x^{n-1}y^1 + \frac{n(n-1)}{1\times 2}x^{n-2}y^2 + \ldots + \frac{n(n-1)(n-2)\ldots(n-r+1)}{1\times 2\times 3\times\ldots\times r}x^{n-r}y^r + \ldots + 1y^n$$

$$C(n,0)x^n + C(n,1)x^{n-1}y^1 + C(n,2)x^{n-2}y^2 + \ldots + C(n,r)x^{n-r}y^r + \ldots + C(n,n)y^n)$$

ហៅថាទ្រឹស្តីបទទ្វេធា ។

## ទ្រឹស្តីបទទ្វេធា

$$(x+y)^n = \sum_{r=0}^{n} C(n,r)x^{n-r}y^r = C(n,0)x^n + C(n,1)x^{n-1}y^1 + C(n,2)x^{n-2}y^2 + \ldots + C(n,n)y^n$$

**លំហាត់គំរូ** ដោយប្រើជួរដេកទី 6 នៃត្រីកោណប៉ាស្កាល់គណនាលេខមេគុណនៃទ្វេធា

$C(6,0)$ , $C(6,1)$ , $C(6,2)$ , $C(6,3)$ , $C(6,4)$ , $C(6,5)$ , $C(6,6)$

**ចម្លើយ**

1 5 10 10 5 1

1 6 15 20 15 6 1

$C(6,0)$ $C(6,1)$ $C(6,2)$ $C(6,3)$ $C(6,4)$ $C(6,5)$ $C(6,6)$

**ប្រតិបត្តិ** 1. ដោយប្រើទ្រឹស្តីបទទ្វេធាចូរពន្លាតកន្សោមខាងក្រោម ៖

ក. $(1+3x)^4$ ខ. $(2x-y)^5$ គ. $\left(a+\frac{1}{a^2}\right)^6$ ឃ. $(1+x)^n$

2. កំណត់តួទី 4 នៃពន្លាតទ្វេធា $(x+y)^{13}$ ។

## មេរៀនសង្ខេប

- ស្វ៊ីតនៃចំនួនពិត គឺជាអនុគមន៍លេខដែលកំណត់ពី $\mathbb{N}$ ទៅ $\mathbb{R}$ ។
- ស្វ៊ីតនព្វន្ត គឺជាស្វ៊ីតនៃចំនួនពិតដែលមានតួនីមួយៗ ( ក្រៅពីតួទី 1 ) ស្មើនឹងតួមុនបន្ទាប់បូកចំនួនថេរ $d$ មួយ ( ហៅថាផលសងរួម ឬរេសុងដែល $d = U_{n+1}-U_n$ ) ។
- រូបមន្តតួទី $n$ នៃស្វ៊ីតនព្វន្ត $U_n = U_1+(n-1)\times d$
- ផលបូក $n$ តួនៃស្វ៊ីតនព្វន្ត $S_n = \frac{(U_1+U_n)\times n}{2}$ ។
- ស្វ៊ីតធរណីមាត្រ គឺជាស្វ៊ីតចំនួនពិតដែលតួនីមួយៗ ( ក្រៅពីតួទី 1 ) ស្មើនឹងតួមុនបន្ទាប់គុណនឹងចំនួនថេរ $q$ ដែល $q\neq 0$ ។ ចំនួនថេរ $q$ នេះហៅថាផលធៀបរួម ឬរេសុងនៃស្វ៊ីតធរណីមាត្រ ។
- រូបមន្តតួទី $n$ នៃស្វ៊ីតធរណីមាត្រ $U_n = U_1\times q^{n-1}$
- ផលបូក $n$ តួដំបូងនៃស្វ៊ីតធរណីមាត្រ $S_n = \frac{U_1(q^n-1)}{q-1}$ ដែល $q\neq 1$
  ផលបូកស្វ៊ីតធរណីមាត្រមិនកំណត់ $S_n = \frac{U_1}{1-q}$ ចំពោះ $|q|<1$
- រូបមន្តផលបូកស្វ៊ីតនព្វន្តមានលំដាប់ខ្ពស់

$$\sum_{k=1}^{n} k = \frac{1}{2}n(n+1) \quad , \quad \sum_{k=1}^{n} k^2 = \frac{1}{6}n(n+1)(2n+1) \quad , \quad \sum_{k=1}^{n} k^3 = \left[\frac{1}{2}n(n+1)\right]^2$$

- ស្វ៊ីត $(b_n)$ ជាផលសងស្វ៊ីតលំដាប់ 1 នៃស្វ៊ីត $(a_n)$ ដែល $a_n = a_1 + \sum_{k=1}^{n-1} b_k$ , $n \ge 2$ ។
- ស្វ៊ីត $(c_n)$ ជាផលសងស្វ៊ីតលំដាប់ 2 នៃស្វ៊ីត $(a_n)$ ដែល $a_n = a_1 + \sum_{k=1}^{n-1} b_k$ , $n \ge 2$ ។
- ហើយស្វ៊ីត $(b_n)$ ជាផលសងស្វ៊ីតលំដាប់ 1 នៃស្វ៊ីត $(a_n)$ ដែល $b_n = b_1 + \sum_{k=1}^{n-1} c_k$ , $n \ge 2$ ។
- ទំនាក់ទំនងកំណើនគឺជាច្បាប់ដែលកំណត់តួ $a_{n+1}$ ជាអនុគមន៍នៃតួ $a_n$ នៃស្វ៊ីត $(a_n)$ ។
- ទំនាក់ទំនងកំណើនទម្រង់ $a_{k+1} = pa_k + q$ $(p,\ q$ ថេរ$)$

  បំលែងទៅជា $a_{k+1} - c = p(a_k - c)$ ដែលមានសមីការសំគាល់ $c = pc + q$ ។
- ទំនាក់ទំនងកំណើនទម្រង់ $a_{n+1} = a_n + pn$ នោះផលសងស្វ៊ីត $(b_n)$ ដែល

  $b_n = a_{n+1} - a_n = pn$ និង $a_n = a_1 + \sum_{k=1}^{n-1} b_k = a_1 + \sum_{k=1}^{n-1} pk$
- ចំពោះ $n \ge 2$ គេបាន $S_n - S_{n-1} = a_n$ និង $S_1 = a_1$
- ទំនាក់ទំនងកំណើននៃស្វ៊ីត $(a_n)$ ទម្រង់ $a_{n+2} + pa_{n+1} + qa_n = 0$ មានសមីការសំគាល់ $x^2 + px + q = 0$ ដែលឫស $\alpha$ និង $\beta$ បំពេញលក្ខខណ្ឌ $\alpha + \beta = -p$ , $\alpha\beta = q$ នោះ

  គេបាន $a_{n+2} - (\alpha + \beta)a_{n+1} + \alpha\beta a_n = 0$ អាចបំលែងជា

  $a_{n+2} - \alpha a_{n+1} = \beta(a_{n+1} - \alpha a_n)$

  $a_{n+2} - \beta a_{n+1} = \alpha(a_{n+1} - \beta a_n)$ ទំនាក់ទំនងទាំង 2 នេះគឺជាស្វ៊ីតធរណីមាត្រ ។
- សំណើ $P(n)$ ពិតចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ ហើយសំណើខាងក្រោម $(i)$ និង $(ii)$ ពិតគឺ :

  $(i)$ $P(n)$ ពិតចំពោះ $n = 1$

  $(ii)$ ឧបមាថា $P(n)$ ពិតចំពោះគ្រប់ $n = k$ រួចបង្ហាញថា $P(n+1)$ ពិតចំពោះគ្រប់ $n = k + 1$ ។

**ទ្រឹស្តីបទទ្វេធា**

$$(x+y)^n = \sum_{r=0}^{n} C(n,r)x^{n-r}y^r$$

$$= C(n,0)x^n + C(n,1)x^{n-1}y^1 + \ldots + C(n,r)x^{n-r}y^r + \ldots + C(n,n)y^n$$

## លំហាត់

1. ស្រាយបញ្ជាក់ថាចំពោះគ្រប់ $n \geq 1$ ; $1^2+2^2+3^2+\ldots+n^2 = \frac{n(n+1)(2n+1)}{6}$ ដោយប្រើវិចារអនុមានរួមគណិតវិទ្យា ។

2. បង្ហាញថាចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$

   ក. ចំនួន $4^n+2$ ចែកដាច់នឹង 3 ។

   ខ. ចំនួន $3^{n+3}-4^{4n+2}$ ចែកដាច់នឹង 11 ។

3. គេមានស៊ីត $(U_n)_{n\in IN}$ កំណត់ដោយ $U_{n+1} = \sqrt{U_n+2}$ និង $U_0 = 0$ ។ បង្ហាញតាមវិចារអនុមានរួមគណិតវិទ្យាថា

   ក. ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$, $U_n \leq 2$ ។

   ខ. ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$, $U_n \leq U_{n+1}$ ។

4. បង្ហាញតាមវិចារអនុមានរួមគណិតវិទ្យាថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ $(1+x)^n \geq 1+nx+\frac{n(n-1)}{2}x^2$ ចំពោះគ្រប់ចំនួនពិត $x \geq 0$ ។

5. ដោយប្រើទ្រឹស្តីបទទ្វេធា ចូរពន្លាតកន្សោមខាងក្រោម :

   ក. $(3x-1)^4$

   ខ. $(2x+y)^6$

   គ. $(a+b)^6$

6. សរសេរពន្លាតកន្សោមខាងក្រោមដោយប្រើ $\Sigma$ :

   ក. $(x-y)^5$

   ខ. $(2x+y)^6$

   គ. $(a+b)^{12}$

# លំហាត់ជំពូក

1. សរសេរបីតួដំបូងនៃស្វ៊ីតនព្វន្តដោយដឹងថា $S_{10} = 210$ និង $S_{20} = 820$ ។

2. គេដឹងថាផលបូកតួទី 1 និងតួទី 4 នៃស្វ៊ីតនព្វន្តស្មើនឹង 2 និងផលបូកការេរបស់វាស្មើនឹង 20 ។ គណនាផលបូកប្រាំបីតួដំបូងនៃស្វ៊ីត ។

3. គេមាន $S_m$ និង $S_n$ ជាផលបូក $m$ តួដំបូងនិង $n$ តួដំបូងរៀងគ្នានៃស្វ៊ីតនព្វន្តមួយដែល $\dfrac{S_m}{S_n} = \dfrac{m^2}{n^2}(n \neq m)$ ។ តាងតួទី $m$ គឺ $u_m$ និងតួទី $n$ គឺ $u_n$ ។ បង្ហាញថា $\dfrac{u_m}{u_n} = \dfrac{2m-1}{2n-1}$ ។

4. គេមានស្វ៊ីតធរណីមាត្រ $12,\ 4,\ \frac{4}{3},\ \ldots$ ។

   ក. គណនាតួទី 10

   ខ. តើចំនួន $\dfrac{4}{729}$ ជាតួទីប៉ុន្មាននៃស្វ៊ីត ?

   គ. គណនាផលបូក 20 តួដំបូងនៃស្វ៊ីតធរណីមាត្រ ។

5. គេឱ្យ $(U_n)$ ជាស្វ៊ីតធរណីមាត្រ បើគេដឹងថា $U_n = 2(3)^{n-1}$ ។ គណនា $S_n$ ។

6. គណនាផលបូកស្វ៊ីតធរណីមាត្រ $1 + 2x + 3x^2 + \ldots + (n-1)x^{n-2} + nx^{x-1}$ ។

7. គណនាតួទី 1 នៃស្វ៊ីតធរណីមាត្រអនន្តតួដែលមាន $q = \dfrac{3}{5}$ និង $S_\infty = 40$ ។

8. គេឱ្យបីចំនួនជាស្វ៊ីតធរណីមាត្រ ។ គណនាចំនួនទាំងនោះបើគេដឹងថាផលគុណនៃចំនួនទាំងនោះស្មើនឹង 3375 ហើយផលបូកវាស្មើនឹង 93 ។

9. គណនាផលបូក $n$ តួដំបូងនៃស្វ៊ីតនីមួយៗខាងក្រោម

   ក. ស្វ៊ីត $(a_n)$ : $1\ ,\ \dfrac{1}{1+2}\ ,\ \dfrac{1}{1+2+3},\ \ldots,\ \dfrac{1}{1+2+3+4+\ldots+n}$

   ខ. ស្វ៊ីត $(b_n)$ : $\dfrac{1}{(1\times 3)^2}\ ,\ \dfrac{2}{(3\times 5)^2}\ ,\ \dfrac{3}{(5\times 7)^2},\ \ldots,\ \dfrac{n}{[(2n-1)(2n+1)]^2}$

10. ក. កំណត់តួទី $n$ នៃស្វ៊ីត $1,\ 2,\ 6,\ 15,\ 31,\ 56,\ \ldots$

    ខ. គណនាផលបូក $n$ តួដំបូងនៃស្វ៊ីតនេះ ។

11. ក. គណនា $\displaystyle\sum_{k=1}^{n}(2k^2-1)$

    ខ. ដោយប្រើសំណួរ ក. គណនាផលបូក $1 + 7 + 17 + 31 + \ldots + 799$

12. សរសេរផលបូក $1 + 4 + 7 + 10 + 13 + \ldots + 298$ ដោយប្រើ $\Sigma$ ។

13. ដោយប្រើវិចារអនុមានរួមគណិតវិទ្យាស្រាយបញ្ជាក់ថា $\sum_{k=1}^{n} 2^{k-1} = 2^n - 1$ ។

14. គេមានស្វ៊ីត $(U_n)$ កំណត់ដោយ $U_{n+1} = 2U_n + 1$ និង $U_0 = 1$ ហើយស្វ៊ីត $(V_n)$ កំណត់ដោយ $V_n = U_n + 1$ ។

ក. បង្ហាញថាស្វ៊ីត $(V_n)$ ជាស្វ៊ីតធរណីមាត្រ។

ខ. ទាញរក $U_n$ ជាអនុគមន៍នៃ $n$ ។

គ. សិក្សាភាពម៉ូណូតូននៃស្វ៊ីត $(U_n)$ ។

ឃ. ចំពោះគ្រប់ $n \in \mathbb{N}$ គណនាផលបូក $S_n = U_0 + U_1 + U_2 + \ldots + U_n$ ។

15. គេមានស្វ៊ីត $(U_n)$ កំណត់ដោយ $U_{n+1} = \dfrac{U_n + 2}{U_n + 1}$ និង $U_0 = 2$ ។

ក. គណនា $U_1$ , $U_2$ , $U_3$ ។

ខ. បង្ហាញថាចំពោះគ្រប់ $n \in \mathbb{N}$ , $U_{n+1} - \sqrt{2} = \dfrac{(\sqrt{2}-1)(\sqrt{2}-U_n)}{U_n + 1}$

គ. បង្ហាញថាចំពោះគ្រប់ $n \in \mathbb{N}$ , $U_n > 1$ ។

ឃ. ទាញពីសំណួរ ខ. និង គ. ថា $|U_{n+1} - \sqrt{2}| \le \dfrac{\sqrt{2}-1}{2} \times |U_n - \sqrt{2}|$ ។

ង. បង្ហាញតាមវិចារអនុមានរួមគណិតវិទ្យាថា $|U_n - \sqrt{2}| \le \left(\dfrac{\sqrt{2}-1}{2}\right)^n \times |\sqrt{2} - U_0|$ ។

16. គេមាន $(a_n)$ កំណត់ដោយទំនាក់ទំនងកំណើន $a_1 = 1$ , $a_{n+1} = \dfrac{1}{2}a_n + n$

ក. តាង $b_n = 2^n a_n$ ។ កំណត់តួទី $n$ នៃស្វ៊ីត $(b_n)$ ។

ខ. កំណត់តួទី $n$ នៃស្វ៊ីត $(a_n)$ ។

17. ក. សរសេរ $(x^2 - 2y)^7$ ដោយប្រើ $\Sigma$

ខ. កំណត់តួទី 6 នៃពន្លាត $(x^2 - 2y)^7$ ។

18. បង្ហាញថាផលបូកនៃលេខមេគុណក្នុងពន្លាត $(1+x)^n$ គឺ $2^n$ ។

19. បង្ហាញថា $C(n,0) + C(n,2) + C(n,4) + \ldots + C(n,n-1)$

$= C(n,1) + C(n,3) + C(n,5) + \ldots + C(n,n) = 2^{n-1}$ ដែល $C(n,0)$ , $C(n,1)$

$Cn,2$ ,... $C(n,n)$ ជាលេខមេគុណក្នុងពន្លាត $(1+x)^n$ ដែល $n$ ជាចំនួនគត់សេស។

PROEUS DARA

# ជំពូក 2

# អនុគមន៍អិចស្ប៉ូណង់ស្យែលនិងអនុគមន៍លោការីត

1. អនុគមន៍អិចស្ប៉ូណង់ស្យែល
2. អនុគមន៍លោការីត



នៅក្នុងជំពូកនេះ គេចាប់ផ្ដើមសិក្សាពីបញ្ញត្តិនៃអនុគមន៍អិចស្ប៉ូណង់ស្យែល សង់ក្រាបតាងអនុគមន៍ ដោះស្រាយសមីការ និងវិសមីការអិចស្ប៉ូណង់ស្យែល ដែលជាមធ្យោបាយសំខាន់សម្រាប់សិក្សាពីបញ្ញត្តិ ក្រាប សមីការនិងវិសមីការលោការីត។ បន្ទាប់ពីទទួលបានបញ្ញត្តិអនុគមន៍អិចស្ប៉ូណង់ស្យែល និងលោការីត សិស្សអាចយកចំណេះដឹងនិងបំណិនទៅដោះស្រាយចំណោទបញ្ហាដែលទាក់ទងនឹងការប្រាក់ កំណើនភ្ញៀវទេសចរ កំណើនប្រជាពលរដ្ឋ និងសម្រាប់ដោះស្រាយចំណោទបញ្ហាផ្សេងទៀតដែលជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃ។

មេរៀនទី 1

# អនុគមន៍អិចស្ប៉ូណង់ស្យែល

## 1. អនុគមន៍អិចស្ប៉ូណង់ស្យែល

### 1.1 ក្រាបនៃអនុគមន៍អិចស្ប៉ូណង់ស្យែល

សង់ក្រាបនៃអនុគមន៍ក្នុងតម្រុយតែមួយ

$f(x) = 2^x$ , $g(x) = (1.5)^x$

$h(x) = 1^x$ , $k(x) = (0.5)^x$

**វត្ថុបំណង**

- សង់ក្រាបនៃអនុគមន៍អិចស្ប៉ូណង់ស្យែល
- ដោះស្រាយសមីការនិងវិសមីការអិចស្ប៉ូណង់ស្យែល ។

| $x$ | $y = 1.5^x$ |
|---|---|
| −2 | 0.44 |
| −1 | 0.66 |
| 0 | 1 |
| 1 | 1.5 |
| 2 | 2.25 |




តាមក្រាបយើងសង្កេតឃើញថា គ្រប់ក្រាបរបស់អនុគមន៍អិចស្ប៉ូណង់ស្យែល កាត់តាម ចំណុចដែលមានកូអរដោនេ $(0, 1)$ ជានិច្ច ។

- បើ $x>0$ នោះ $(1.5)^x<2^x$ ។ ដូចនេះ ក្នុងកាដ្រង់ទី1 ក្រាបនៃអនុគមន៍ $g(x) = (1.5)^x$ ស្ថិតនៅក្រោមក្រាបនៃអនុគមន៍ $f(x) = 2^x$ ។
- អនុគមន៍ $h(x) = 1^x$ មានក្រាបជាបន្ទាត់ស្របនឹងអ័ក្សអាប់ស៊ីសនិងនៅពីលើអ័ក្សអាប់ស៊ីសចំនួន 1 ឯកតា ចំពោះគ្រប់តម្លៃ $x$ ។

PROEUS DARA


- បើ $x>0$ នោះ $(0.5)^x<1$ ។ ដូចនេះ បើ $x$ យកតម្លៃកើនធំឡើងៗ នោះ $k(x)=0.5^x$ មានតម្លៃចុះតូចទៅៗ ហើយខិតទៅរក 0 ។
- បើ $x<0$ នោះ $(0.5)^x$ មានតម្លៃធំឡើងៗគ្មានកំណត់ ។

**ជាទូទៅ** អនុគមន៍អិចស្ប៉ូណង់ស្យែល $y=a^x$ មានក្រាប :
- បើ $a>1$ ក្រាបនៃ $y=a^x$ កើនពីឆ្វេងទៅស្តាំ គេថា $y=a^x$ ជាអនុគមន៍កើន
- បើ $0<a<1$ ក្រាបនៃ $y=a^x$ ចុះពីឆ្វេងទៅស្តាំ គេថា $y=a^x$ ជាអនុគមន៍ចុះ
- អនុគមន៍ $y=a^x$ វិជ្ជមានជានិច្ច $\forall x\in\mathbb{R}$ បើ $a$ ជាចំនួនពិតវិជ្ជមាននិងខុសពី 1
- ក្រាបនៃអនុគមន៍ $y=a^x$ កាត់អ័ក្សអរដោនេត្រង់ $(0,1)$ ជានិច្ច ។

**លំហាត់គំរូ** សង់ក្រាប ក. $y=4^x$ ខ. $y=\left(\frac{1}{4}\right)^x$

**ចម្លើយ** ក. តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $x$ | $y=4^x$ |
|---|---|
| $-2$ | 0.06 |
| $-1$ | 0.25 |
| 0 | 1 |
| 1 | 4 |
| 2 | 16 |




ខ. តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $x$ | $y=\left(\frac{1}{4}\right)^x$ |
|---|---|
| $-2$ | 16 |
| $-1$ | $-1$ |
| 0 | 1 |
| 1 | 0.25 |
| 2 | 0.06 |




**ប្រតិបត្តិ** សង់ក្រាបអនុគមន៍ ក. $y=10^x$ ខ. $y=\left(\frac{1}{10}\right)^x$

## 1.2 លក្ខណៈក្រាបនៃអនុគមន៍អិចស្ប៉ូណង់ស្យែល

***ឧទាហរណ៍*** សង់ក្រាបនៃអនុគមន៍

ក. $y = 2^x + 1$ ខ. $y = 2^{x+1}$ គ. $y = 2^{x-2}$ ឃ. $y = -2^x$

**ចម្លើយ** **ក. សង់ក្រាបនៃអនុគមន៍** $y = 2^x + 1$

| $x$ | $y = 2^x$ | $y = 2^x + 1$ |
|---|---|---|
| –2 | 0.25 | 1.25 |
| –1 | 0.5 | 1.50 |
| 0 | 1 | 2 |
| 1 | 2 | 3 |
| 2 | 4 | 5 |




តាមក្រាបគេសង្កេតឃើញថា

ដើម្បីសង់ក្រាប $y = 2^x + 1$ ដំបូងគេសង់ក្រាប $y = 2^x$ រួចរំកិល ចំនួនមួយឯកតាឡើងលើស្រប អ័ក្ស $(oy)$ គេបានក្រាប $y = 2^x + 1$ ។

**ខ. សង់ក្រាបនៃអនុគមន៍** $y = 2^{x+1}$

តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $x$ | $y = 2^x$ | $y = 2^{x+1}$ |
|---|---|---|
| –2 | 0.25 | 0.5 |
| –1 | 0.5 | 1 |
| 0 | 1 | 2 |
| 1 | 2 | 4 |
| 2 | 4 | 8 |




តាមក្រាប គេសង្កេតឃើញថា ដើម្បីសង់ក្រាប $y = 2^{x+1}$ ដំបូងគេសង់ក្រាប $y = 2^x$ រួចរំកិល ចំនួនមួយឯកតាទៅខាងឆ្វេងស្របអ័ក្ស $(ox)$ គេបានក្រាប $y = 2^{x+1}$ ។

គ. សង់ក្រាបនៃអនុគមន៍ $y = 2^{x-2}$

តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $x$ | $y = 2^x$ | $y = 2^{x-2}$ |
|---|---|---|
| –2 | 0.25 | 0.06 |
| –1 | 0.5 | 0.12 |
| 0 | 1 | 0.25 |
| 1 | 2 | 0.5 |
| 2 | 4 | 1 |




តាមក្រាប គេសង្កេតឃើញថា

ដើម្បីសង់ក្រាប $y = 2^{x-2}$

ដំបូងគេសង់ក្រាប $y = 2^x$ រួចរំកិលចំនួនពីរឯកតាទៅខាងស្តាំស្របអ័ក្ស $(ox)$ គេបាន
ក្រាប $y = 2^{x-2}$ ។

ង. សង់ក្រាបនៃអនុគមន៍ $y = -2^x$

តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $x$ | $y = 2^x$ | $y = -2^x$ |
|---|---|---|
| –2 | 0.25 | –0.25 |
| –1 | 0.5 | –0.5 |
| 0 | 1 | –1 |
| 1 | 2 | –2 |
| 2 | 4 | –4 |




តាមក្រាប គេសង្កេតឃើញថា

ដំបូងគេសង់ក្រាប $y = 2^x$ រួចគូស ក្រាបឆ្លុះគ្នា ធៀបនឹងអ័ក្ស $(ox)$

គេបានក្រាប $y = -2^x$ ។

**ជាទូទៅ**

- ដើម្បីសង់ក្រាបនៃអនុគមន៍ $y = a^x + q$ គេត្រូវសង់ក្រាប $y = a^x$ រួចធ្វើបំលែងកិលស្របអ័ក្ស $(oy)$ ចំនួន $q$ ឯកតាឡើងលើបើ $q > 0$ ហើយចំនួន $q$ ឯកតាចុះក្រោមបើ $q < 0$ ។
- ដើម្បីសង់ក្រាបនៃអនុគមន៍ $y = a^{(x-p)}$ គេត្រូវសង់ក្រាប $y = a^x$ រួចធ្វើបំលែងកិលស្របអ័ក្ស $(ox)$ ចំនួន $p$ ឯកតាទៅខាងស្តាំបើ $p > 0$ ហើយ $p$ ឯកតាទៅខាងឆ្វេងបើ $p < 0$ ។
- ដើម្បីសង់ក្រាបនៃអនុគមន៍ $y = -a^x$ គេត្រូវសង់ក្រាប $y = a^x$ រួចគូក្រាបឆ្លុះធៀបនឹងអ័ក្ស $(ox)$ គេបានក្រាប $y = -a^x$ ។

**ប្រតិបត្តិ** សង់ក្រាបអនុគមន៍

ក. $y = 3^x - 3$

ខ. $y = 3^x + 1$

គ. $y = 1.5^{x-2}$

ឃ. $y = 1.5^{x+3}$

ង. $y = -5^x$

# 2. សមីការនិងវិសមីការអិចស្ប៉ូណង់ស្យែល

## 2.1 សមីការអិចស្ប៉ូណង់ស្យែល

សមីការអិចស្ប៉ូណង់ស្យែល ជាសមីការដែលមានអញ្ញាត ជានិទស្សន្ត ។

***ឧទាហរណ៍*** បើ $2^x = 2^4$ នោះ $x = 4$

**ជាទូទៅ** បើ $a$ ជាចំនួនវិជ្ជមានខុសពី 1 នោះ $a^x = a^y$ គេបាន $x = y$

**លំហាត់គំរូ** ដោះស្រាយសមីការ

ក. $2^{3x+5} = 128$ ឃ. $49^{x} = 7^{x^2-15}$

ខ. $5^{x-3} = \frac{1}{25}$ ង. $36^{2x} = 216^{x-1}$

គ. $\left(\frac{1}{9}\right)^{x} = 81^{x+4}$ ច. $10^{x-1} = 100^{2x-3}$

**ចម្លើយ**

ក. $2^{3x+5} = 128$

$2^{3x+5} = 2^{7}$

$3x+5 = 7$

$x = \frac{2}{3}$

ខ. $5^{x-3} = \frac{1}{25}$

$5^{x-3} = 5^{-2}$

$x-3 = -2$

$x = 1$

គ. $\left(\frac{1}{9}\right)^{x} = 81^{x+4}$

$9^{-x} = 9^{2(x+4)}$

$-x = 2x+8$

$x = \frac{-8}{3}$

ឃ. $49^{x} = 7^{x^2-15}$

$7^{2x} = 7^{x^2-15}$

$2x = x^2-15$

$x = 5$ , $x = -3$

ង. $36^{2x} = 216^{x-1}$

$6^{2(2x)} = 6^{3(x-1)}$

$4x = 3x-3$

$x = -3$

ច. $10^{x-1} = 100^{2x-3}$

$10^{x-1} = 10^{2(2x-3)}$

$x-1 = 4x-6$

$x = \frac{5}{3}$ ។

**ប្រតិបត្តិ** ក. $5^{x}\cdot 2^{\frac{2x-1}{x+1}} = 50$ គ. $27^{x}+12^{x} = 2\cdot 8^{x}$

ខ. $3^{4x+8}-4\cdot 3^{2x+5}+27 = 0$ ឃ. $3^{2x^2-6x+3}+6^{x^2-3x+1} = 2^{2x^2-6x+3}$

## 2.2 វិសមីការអិចស្ប៉ូណង់ស្យែល

វិសមីការអិចស្ប៉ូណង់ស្យែលមានទម្រង់ $a^{x} > a^{y}$

- បើ $a>1$ វិសមីការ $a^{x}>a^{y}$ សមមូល $x>y$ ហើយវិសមីការ $a^{x}<a^{y}$ សមមូល $x<y$
- បើ $0<a<1$ វិសមីការ $a^{x}>a^{y}$ សមមូល $x<y$ ហើយវិសមីការ $a^{x}<a^{y}$ សមមូល $x>y$

***ឧទាហរណ៍*** ដោះស្រាយវិសមីការ $2^{3x+1} < \frac{1}{32}$

$2^{3x+1} < \frac{1}{32}$ វិសមីការដើម

$2^{3x+1} < 2^{-5}$ ព្រោះ $\frac{1}{32} = \frac{1}{2^5}$ ឬ $2^{-5}$ ហេតុនេះ អង្គទាំងពីរមានគោលដូចគ្នា

$3x+1 < -5$ លក្ខណៈនៃវិសមីការអិចស្ប៉ូណង់ស្យែល

$3x < -6$ ដក 1 ពីអង្គទាំងពីរ គេបាន $x < -2$ ចែកអង្គទាំងពីរនឹង 3

***ផ្ទៀងផ្ទាត់*** ឱ្យតម្លៃ $x$ តូចជាង $-2$ ដូចជា $x = -3$

$2^{3x+1} < \frac{1}{32}$

$2^{3(-3)+1} < \frac{1}{32}$ ជំនួស $x$ ដោយ $-3$ គេបាន $2^{-8} < \frac{1}{32}$ សម្រួល

$\frac{1}{256} < \frac{1}{32}$ ពិត (ប្រើលក្ខណៈ: $a^{-n} = \frac{1}{a^n}$ )

**លំហាត់គំរូ** ដោះស្រាយវិសមីការ

ក. $25^{2x} \le 5\sqrt{5}$ ខ. $\left(\frac{2}{3}\right)^{-3x} > \frac{16}{81}$ គ. $5^x > -7$ ឃ. $(0.1)^x > 10$

ង. $27^x \cdot 3^{1-x} < \frac{1}{3}$ ច. $2^{9x-x^3} < 1$ ឆ. $\left(\frac{1}{3}\right)^{\frac{2}{x}} + 3\left(\frac{1}{3}\right)^{\frac{1}{x}+1} > 12$

**ចម្លើយ** ក. $25^{2x} \le 5\sqrt{5}$ , $25^{2x} \le 5\left(5^{\frac{1}{2}}\right)$

$5^{4x} \le 5^{\frac{3}{2}}$ , $x \le \frac{3}{8}$

ខ. $\left(\frac{2}{3}\right)^{-3x} > \frac{16}{81}$ , $\left(\frac{2}{3}\right)^{-3x} > \left(\frac{2}{3}\right)^4$

$-3x < 4$ , $x > -\frac{4}{3}$

គ. $5^x > -7$

$5^x$ វិជ្ជមានជានិច្ច

$-7$ អវិជ្ជមានជានិច្ច

ដូចនេះ វិសមីការមានឫសគ្រប់តម្លៃ $x \in \mathbb{R}$

ឃ. $(0.1)^x > 10$

$10^{-x} > 10$

$-x > 1$

$x < -1$

ង. $27^x \cdot 3^{1-x} < \frac{1}{3}$

$3^{3x} \cdot 3^{1-x} < 3^{-1}$

$3^{2x+1} < 3^{-1}$

$2x+1 < -1$

$2x < -2$

$x < -1$

ច. $2^{9x-x^3} < 1$

$2^{9x-x^3} < 2^0$

$9x - x^3 < 0$

$(9-x^2)x < 0$

$(9-x^2)x < 0$

$-3 < x < 0$ ឬ $x > 3$

ឆ. $\left(\frac{1}{3}\right)^{\frac{2}{x}}+3\left(\frac{1}{3}\right)^{\frac{1}{x}+1}>12$ , $\left[\left(\frac{1}{3}\right)^{\frac{1}{x}}\right]^2+\left(\frac{1}{3}\right)^{\frac{1}{x}}-12>0$ , $(x\neq 0)$

តាង $t=\left(\frac{1}{3}\right)^{\frac{1}{x}}$ , $t>0$ យើងបាន $t^2+t-12>0$

$t<-4$ , $t>3$

ដោយ $t>0$ នាំឱ្យឫសរបស់វិសមីការគឺ $t>3$

ឬ $\left(\frac{1}{3}\right)^{\frac{1}{x}}>3=\left(\frac{1}{3}\right)^{-1}$

ដោយ $\frac{1}{3}<1$ នោះ $\frac{1}{x}<-1$

$-1<x<0$

ដូចនេះ វិសមីការមានចម្លើយ $-1<x<0$ ។

## ប្រតិបត្តិ ដោះស្រាយវិសមីការ

ក. $(7)^{3x+1}>49$

ខ. $\left(\frac{1}{5}\right)^x<\sqrt[3]{0.04}$

គ. $3^x<\frac{1}{9\sqrt{3}}$

ឃ. $3^x\leq -3$

ង. $(0.2)^x>25$

ច. $(0.1)^{4x^2-2x-2}<(0.1)^{2x-3}$

## លំហាត់

1. សង់ក្រាបនៃអនុគមន៍ខាងក្រោមក្នុងតម្រុយតែមួយ :

ក. $f(x) = 2^x$ ; $g(x) = 5^x$ ; $h(x) = 10^x$

ខ. $f(x) = \left(\frac{1}{2}\right)^x$ ; $g(x) = \left(\frac{1}{5}\right)^x$ ; $h(x) = \left(\frac{1}{10}\right)^x$

2. ចូររកតម្លៃ $a$ បើខ្សែកោងនៃ $f(x) = a^x$ កាត់តាមចំណុចនីមួយៗដូចខាងក្រោម ៖

ក. $A(3, 216)$ ខ. $B(5, 32)$

គ. $C(3, 512)$ ឃ. $D(4, 256)$

ង. $E(-(2, 64))$ ច. $F\left(-3, \frac{1}{216}\right)$

ឆ. $G(3, 343)$ ជ. $h\left(\frac{1}{3}, 3\right)$

3. បង្ហាញថា បើ $f(x) = a^x$ នោះ $f(x)f(y) = f(x+y)$

4. ក. បើ $(x_1, y_1)$ និង $(x_2, y_2)$ ជាចំណុចពីរនៅលើខ្សែកោង $f(x) = a^x$ នោះចំណុចទាំង ពីរ $(x_1 + x_2, y_1 y_2)$ និង $\left(x_1 - x_2, \frac{y_1}{y_2}\right)$ ជាចំណុចនៅលើខ្សែកោង ។

ខ. បើ $(x_1, y_1)$ ជាចំណុចពីរនៅលើខ្សែកោង $f(x) = a^x$ នោះចំណុចទាំងពីរ $(2x_1, y_1^2)$ និង $\left(-x_1, \frac{1}{y_1}\right)$ ជាចំណុចនៅលើខ្សែកោង $f(x) = a^x$ ។

5. ក. សង់ក្រាបនៃអនុគមន៍ $f(x) = 2^x$

ខ. សង់ក្រាបនៃអនុគមន៍នីមួយៗក្នុងតម្រុយតែមួយជាមួយក្រាបនៃអនុគមន៍ $f(x) = 2^x$

$i$ ). $y = f(x) - 1$

$ii$ ). $y = f(x-1)$

$iii$ ). $y = f(x+1)$

$iv$ ). $y = f(0.5x)$

$v$ ). $y = f(2x)$

$vi$ ). $y = f(-x)$

6. បើ $a>0$ ។ ចូររកតម្លៃ $a$ និង $x$ ដែលធ្វើឱ្យសមភាព និងវិសមភាពខាងក្រោមផ្ទៀងផ្ទាត់

ក. $a^x = 1$ ខ. $a^x > 1$ គ. $0 < a^x < 1$

7. សង់ក្រាបនៃអនុគមន៍

ក. $f(x) = 2^{|x|}$ ខ. $f(x) = x(2^x)$ គ. $f(x) = x^x$

8. សង់ក្រាបនៃអនុគមន៍ខាងក្រោម

ក. $y = 2^{x-1}$ ឃ. $y = 2^{-x^2}$

ខ. $y = 2^{|x-1|}$ ង. $y = 3^{-|x+1|^2}$

គ. $y = 2^x + 2^{-x}$ ច. $y = 2^{|x^2-8|}$

**9.** ដោះស្រាយសមីការ

ក. $3^{x^2+4x} = \dfrac{1}{27}$ ខ. $3^{5x} \cdot 9^{x^2} = 27$ គ. $4^{3x^2+2x+1} = 16$

មេរៀនទី

# 2 អនុគមន៍លោការីត

## 1. ក្រាបនៃអនុគមន៍លោការីត

**វត្ថុបំណង**

- សង់ក្រាបនៃអនុគមន៍លោការីត
- ដោះស្រាយសមីការនិងវិសមីការលោការីត ។

អនុគមន៍លោការីត ជាអនុគមន៍ច្រាសនៃអនុគមន៍អិចស្ប៉ូណង់ស្យែល ។ ហេតុនេះក្រាបរបស់វាឆ្លុះគ្នាធៀបនឹងបន្ទាត់ $y = x$ ។

**ក. បើគោល $a > 1$**

សង់ក្រាបនៃអនុគមន៍ $y = 4^x$ និង $y = \log_4 x$ ។

តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $y = 4^x$ | | | $y = \log_4 x$ | |
|---|---|---|---|---|
| $x$ | $y$ | | $x$ | $y$ |
| −2 | 0.06 | | 0.25 | −1 |
| −1 | 0.25 | | 0.50 | −0.50 |
| 0 | 1 | | 1 | 0 |
| 1 | 4 | | 2 | 0.50 |
| 2 | 16 | | 4 | 1 |




តាមក្រាប យើងសង្កេតឃើញថា

- តម្លៃ $x$ កើន គេបានតម្លៃត្រូវគ្នានៃ $y = \log_4 x$ កើន
- ក្រាបនៃអនុគមន៍ $y = \log_4 x$ កាត់អ័ក្ស $(ox)$ ត្រង់ចំណុច $(1, 0)$ ជានិច្ច ។
- ក្រាបនៃអនុគមន៍ $y = \log_4 x$ និង $y = 4^x$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y = x$ ។

**ជាទូទៅ** បើ $a > 1$ នោះអនុគមន៍ $y = \log_a x$ ជាអនុគមន៍កើន ។

**ខ.** បើគោល $0<a<1$

សង់ក្រាបនៃអនុគមន៍ $y=\left(\frac{1}{4}\right)^x$ និង $y=\log_{\frac{1}{4}}x$

តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $y=\left(\frac{1}{4}\right)^x$ | | | $y=\log_{\frac{1}{4}}x$ | |
|---|---|---|---|---|
| $x$ | $y$ | | $x$ | $y$ |
| $-2$ | 16 | | 0.25 | 1 |
| $-1$ | 4 | | 0.50 | 0.50 |
| 0 | 1 | | 1 | 0 |
| 1 | 0.25 | | 2 | $-0.50$ |
| 2 | 0.06 | | 4 | $-1$ |




តាមក្រាប យើងសង្កេតឃើញថា

- តម្លៃ $x$ កើន គេបានតម្លៃត្រូវគ្នានៃ $y=\log_{\frac{1}{4}}x$ ចុះ
- ក្រាបនៃអនុគមន៍ $y=\log_{\frac{1}{4}}x$ កាត់អ័ក្ស $(ox)$ ត្រង់ចំណុច $(1,\ 0)$ ។
- ក្រាបនៃអនុគមន៍ $y=\log_{\frac{1}{4}}x$ និង $y=\left(\frac{1}{4}\right)^x$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=x$ ។

**ជាទូទៅ** បើ $0<a<1$ នោះអនុគមន៍ $y=\log_a x$ ជាអនុគមន៍ចុះ ។

ជាសន្និដ្ឋាន អនុគមន៍ $y=\log_a x$ មានក្រាប ៖

- បើ $a>1$ ក្រាបកើនពីឆ្វេងទៅស្តាំ គេថា $y=\log_a x$ ជាអនុគមន៍កើន
- បើ $0<a<1$ ក្រាបចុះពីឆ្វេងទៅស្តាំ គេថា $y=\log_a x$ ជាអនុគមន៍ចុះ
- អនុគមន៍ $y=\log_a x$ មានក្រាបកាត់តាមចំណុចដែលមានកូអរដោនេ $(1,0)$ ជានិច្ច ។
- អនុគមន៍ $y=\log_a x$ មានដែនកំណត់ $x>0$ ជានិច្ច ។
- អនុគមន៍ $y=\log_a x$ និង $y=a^x$ ជាអនុគមន៍ច្រាសគ្នា ហើយមានក្រាបឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=x$ ។

**លំហាត់គំរូ** សង់ក្រាបនៃអនុគមន៍

ក. $y = \log_{10}x$ ខ. $y = \log_{\frac{1}{10}} x$

**ចម្លើយ** ក. តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $y = \log_{10}x$ | |
|---|---|
| $x$ | $y$ |
| 1/100 | –2 |
| 1/10 | –1 |
| 1 | 0 |
| 10 | 1 |
| 100 | 2 |




យើងសង្កេតឃើញថា អនុគមន៍ $y = \log_{10}x$ មានក្រាបកើន ។

ខ. តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $y = \log_{\frac{1}{10}} x$ | |
|---|---|
| $x$ | $y$ |
| 1/100 | 2 |
| 1/10 | 1 |
| 1 | 0 |
| 10 | –1 |
| 100 | –2 |




យើងសង្កេតឃើញថា អនុគមន៍ $y = \log_{\frac{1}{10}} x$ មានក្រាបចុះ ។

**ប្រតិបត្តិ** សង់ក្រាបនៃអនុគមន៍

ក. $y = \log_7 x$ ខ. $y = \log_{\frac{1}{7}} x$

## 2. លក្ខណៈក្រាបនៃអនុគមន៍លោការីត

សង់ក្រាបនៃអនុគមន៍

ក. $y = -2 + \log_3 x$ ខ. $y = \log_3(x-2)$ គ. $y = -\log_3 x$ ។

### ចម្លើយ

ក. សង់ក្រាបនៃអនុគមន៍ $y = -2 + \log_3 x$

តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $x$ | $\log_3 x$ | $y = -2 + \log_3 x$ |
|---|---|---|
| 1/3 | −1 | −3 |
| 1 | 0 | −2 |
| 3 | 1 | −1 |
| 9 | 2 | 0 |




ដើម្បីសង់ក្រាបនៃអនុគមន៍ $y = -2 + \log_3 x$ ដំបូងគេសង់ក្រាបនៃអនុគមន៍ $y = \log_3 x$ រួច រំកិលចំនួន 2 ឯកតាចុះក្រោមស្របអ័ក្ស $(oy)$ គេបានក្រាបនៃអនុគមន៍ $y = -2 + \log_3 x$ ។

ខ. សង់ក្រាបនៃអនុគមន៍ $y = \log_3(x-2)$

តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $x$ | $y = \log_3(x-2)$ |
|---|---|
| 7/3 | −1 |
| 3 | 0 |
| 5 | 1 |
| 11 | 2 |




ដើម្បីសង់ក្រាបនៃអនុគមន៍ $y = \log_3(x-2)$ ដំបូងគេសង់ក្រាបនៃអនុគមន៍ $y = \log_3 x$ រួច រំកិលចំនួន 2 ឯកតា ទៅខាងស្តាំស្របអ័ក្ស $(ox)$ គេបានក្រាបនៃអនុគមន៍ $y = \log_3(x-2)$ ។

គ. សង់ក្រាបនៃអនុគមន៍ $y = -\log_3 x$

តារាងតម្លៃត្រូវគ្នានៃ $x$ និង $y$

| $y = -\log_3 x$ | |
|---|---|
| $x$ | $y$ |
| $1/9$ | $2$ |
| $1/3$ | $1$ |
| $1$ | $0$ |
| $3$ | $-1$ |
| $9$ | $-2$ |




ដើម្បីសង់ក្រាបនៃអនុគមន៍ $y = -\log_3 x$ ដំបូងគេសង់ក្រាបនៃអនុគមន៍ $y = \log_3 x$ រួចគូសក្រាបឆ្លុះរបស់វាធៀបនឹងអ័ក្ស $(ox)$ គេបានក្រាបនៃអនុគមន៍ $y = -\log_3 x$ ។

**ជាទូទៅ :**

- ដើម្បីសង់ក្រាបនៃអនុគមន៍ $y = \log_a x + q$ គេត្រូវសង់ក្រាប $y = \log_a x$ រួចធ្វើបំលែងកិលស្របអ័ក្ស $(oy)$ ចំនួន $q$ ឯកតាឡើងលើបើ $q > 0$ ហើយចំនួន $q$ ឯកតា ចុះក្រោមបើ $q < 0$ ។
- ដើម្បីសង់ក្រាបនៃអនុគមន៍ $y = \log_a(x - p)$ គេត្រូវសង់ក្រាប $y = \log_a x$ រួចធ្វើបំលែងកិលស្របអ័ក្ស $(ox)$ ចំនួន $p$ ឯកតាទៅខាងស្តាំបើ $p > 0$ ហើយ $p$ ឯកតាទៅខាងឆ្វេងបើ $p < 0$ ។
- ដើម្បីសង់ក្រាបនៃអនុគមន៍ $y = -\log_a x$ គេត្រូវសង់ក្រាប $y = \log_a x$ រួចគូសក្រាបឆ្លុះធៀបនឹងអ័ក្ស $(ox)$ គេបានក្រាប $y = -\log_a x$ ។

**ប្រតិបត្តិ** សង់ក្រាបនៃអនុគមន៍

ក. $y = \log_7(x+3)$ ខ. $y = \log_7 x + 3$

គ. $y = -\log_7 x$ ឃ. $y = \log_2(x-1)^2$

ង. $y = 2 - \log_2 x^2$

## 3. រូបមន្តប្តូរគោល

ទ្រឹស្តីបទខាងក្រោម អាចឱ្យអ្នកសិក្សាអនុគមន៍លោការីត ប្រើសម្រាប់ប្តូរគោលនៃលោការីតទៅជា គោលដែលគេអាចគណនាបាន ។

| |
|---|
| បើ $a$ , $b$ និង $x$ ជាចំនួនពិតវិជ្ជមាន ហើយ $a \neq 1$ , $b \neq 1$ គេបាន $\log_a x = \dfrac{\log_b x}{\log_b a}$ |

**សំរាយបញ្ជាក់** $\log_a x = \dfrac{\log_b x}{\log_b a}$ ?

តាង $M = \log_a x$

$a^M = x$ សរសេរជាទម្រង់អិចស្ប៉ូណង់ស្យែល

គេបាន $\log_b a^M = \log_b x$ លើកលោការីតគោល $b$ លើអង្គទាំងពីរ

$M\log_b a = \log_b x$ តាមលក្ខណៈនៃលោការីត

$M = \dfrac{\log_b x}{\log_b a}$ ដោះស្រាយរក $M$

$\log_a x = \dfrac{\log_b x}{\log_b a}$ ជំនួស $M$ ដោយ $\log_a x$

**លំហាត់គំរូ** គណនា

ក. $\log_9 27$ ខ. $\log_{27} \dfrac{1}{3}$

គ. $\log_7 27$ ឃ. $\log_5 125$

**ចម្លើយ** ក. $\log_9 27 = \dfrac{\log_3 27}{\log_3 9} = \dfrac{\log_3 3^3}{\log_3 3^2} = \dfrac{3}{2}$

ខ. $\log_{27} \dfrac{1}{3} = \log_{3^3} 3^{-1} = -\dfrac{1}{3}$

គ. $\log_7 27 = \dfrac{\log_{10}27}{\log_{10}7} \approx 1.6937$

ឃ. $\log_5 125 = \log_5 5^3 = 3$

**ប្រតិបត្តិ** គណនា

ក. $\log_5 625$ ខ. $\log_5 346$ គ. $\log_6 4870$

# 4. សមីការនិងវិសមីការលោការីត

## 4.1 សមីការលោការីត

បើ $a>0$ , $a \neq 1$ នោះសមីការ $\log_a x = \log_a y$ គេបាន $x = y$

***ឧទាហរណ៍ 1*** បើ $\log_4 x = \log_4 7$ នោះ $x = 7$

***ឧទាហរណ៍ 2*** ដោះស្រាយសមីការ $\log_4 x = \dfrac{5}{2}$

$\log_4 x = \dfrac{5}{2}$ , $\log_4 x = \log_4 4^{\frac{5}{2}}$ ប្រើរូបមន្ត $\log_a a = 1$

$x = 4^{\frac{5}{2}} = (2^2)^{\frac{5}{2}}$ ព្រោះ $4 = 2^2$

$x = 2^5$ ឬ $x = 32$

***ឧទាហរណ៍ 3*** ដោះស្រាយសមីការ $6(\log_x 8 + \log_8 x) = 13$

$6\left(\dfrac{1}{\log_8 x} + \log_8 x\right) = 13$ ប្រើរូបមន្តប្តូរគោល $\log_x 8 = \dfrac{1}{\log_8 x}$

$6 + 6(\log_8 x)^2 = 13\log_8 x$ ព្រោះ $(\log_8 x)^2 - 13\log_8 x + 6 = 0$

$(3\log_8 x - 2)(2\log_8 x - 3) = 0$

$\log_8 x = \dfrac{2}{3}$ , $\log_8 x = \dfrac{3}{2}$

$x = 8^{\frac{2}{3}}$ , $x = 8^{\frac{3}{2}}$

$\Rightarrow x = 4$ , $x = 16\sqrt{2}$

***ឧទាហរណ៍ 4*** ដោះស្រាយសមីការ $\log_9 x + \log_x 9 = \dfrac{5}{2}$

$\log_9 x + \dfrac{1}{\log_9 x} = \dfrac{5}{2} \Leftrightarrow (\log_9 x)^2 + 1 = \dfrac{5}{2}\log_9 x$

$2(\log_9 x)^2 - 5\log_9 x + 2 = 0$

$(2\log_9 x - 1)(\log_9 x - 2) = 0$ សមមូល $\log_9 x = \frac{1}{2}$ , $\log_9 x = 2$

បើ $\log_9 x = \frac{1}{2}$ ឬ $x = 9^{\frac{1}{2}} \Rightarrow x = 3$

$\log_9 x = 2$ ឬ $x = 9^2 \Rightarrow x = 81$

**ប្រតិបត្តិ** ដោះស្រាយសមីការ

ក. $\log_9 x = \frac{3}{2}$ ខ. $\log_{\frac{1}{10}} x = -3$ គ. $\log_x 9 = 2$

## 4.2 វិសមីការលោការីត

- បើ $a > 1$ នោះវិសមីការ $\log_a x > \log_a y$ សមមូល $x > y$

ហើយ $\log_a x < \log_a y$ សមមូល $x < y$

**ឧទាហរណ៍** បើ $\log_3 x > \log_3 7$ នោះ $x > 7$

- បើ $0 < a < 1$ នោះវិសមីការ $\log_a x > \log_a y$ សមមូល $x < y$

ហើយ $\log_a x < \log_a y$ សមមូល $x > y$

**ឧទាហរណ៍** បើ $\log_{\frac{1}{2}} x > \log_{\frac{1}{2}} 7$ នោះ $x < 7$

**លំហាត់គំរូ** ដោះស្រាយវិសមីការខាងក្រោម រួចផ្ទៀងផ្ទាត់

ក. $\log_3(3x-5) > \log_3(x+7)$ ខ. $\log_{\frac{1}{2}}(2x-1) \le 2$

**ចម្លើយ** ក. $\log_3(3x-5) > \log_3(x+7)$

$3x - 5 > x + 7$ លក្ខណៈនៃវិសមីការរបស់អនុគមន៍លោការីត

$2x > 12$ លក្ខណៈបូកបន្ថែម ឬដកលើអង្គទាំងពីរនៃវិសមីការ

$x > 6$ ចែកអង្គទាំងពីរនឹង 2

**ផ្ទៀងផ្ទាត់** $\log(3x-5)$ មានន័យបើ $3x - 5 > 0$ ឬ $x > \frac{5}{3}$

$\log(x+7)$ មានន័យបើ $x + 7 > 0$ ឬ $x > -7$

ដូចនេះ វិសមីការមានសំណុំចម្លើយ $x > 6$ ឬ $x \in ]6, +\infty[$ ។

ខ. $\log_{\frac{1}{2}}(2x-1) \le 2$

$\log_{\frac{1}{2}}(2x-1) \le \log_{\frac{1}{2}}\left(\frac{1}{2}\right)^2$ សរសេរ $2 = \log_{\frac{1}{2}}\left(\frac{1}{2}\right)^2$ តាមលក្ខណៈលោការីតនៃគោល

$2x-1 \ge \frac{1}{4}$ ប្តូរទិសដៅព្រោះគោលស្មើនឹង $\frac{1}{2} < 1$

$x \ge \frac{5}{8}$

***ផ្ទៀងផ្ទាត់*** $\log_{\frac{1}{2}}(2x-1)$ មានន័យបើ $2x-1>0$

ឬ $x > \frac{1}{2}$

ដូចនេះ វិសមីការមានសំណុំចម្លើយ $x \ge \frac{5}{8}$

ឬ $x \in \left[\frac{5}{8}, +\infty\right[$

**ប្រតិបត្តិ** ដោះស្រាយវិសមីការ

ក. $\log_5(x^2-6) > \log_5 x$ ខ. $\log_{\frac{1}{3}} x < 0$ គ. $\log_x 27 \ge 3$

## លំហាត់

1. សរសេរអនុគមន៍ច្រាសនៃអនុគមន៍ខាងក្រោម :

ក. $f(x) = 10^x$ ខ. $g(x) = 3^x$

គ. $h(x) = 7^x$ ឃ. $f(x) = \left(\frac{1}{2}\right)^x$

ង. $g(x) = \left(\frac{1}{5}\right)^x$ ច. $h(x) = \left(\frac{1}{10}\right)^x$

2. សរសេរអនុគមន៍ច្រាសនៃអនុគមន៍ខាងក្រោម :

ក. $f(x) = \log x$ ខ. $g(x) = \log_3 x$

គ. $h(x) = \log_5 x$ ឃ. $f(x) = \log_{\frac{1}{3}} x$

ង. $g(x) = \log_{\frac{5}{4}} x$ ច. $h(x) = \log_{21} x$

3. ក. សង់ក្រាបនៃអនុគមន៍អិចស្ប៉ូណង់ស្យែល $f(x) = 5^x$

ខ. សង់ក្រាបនៃអនុគមន៍ច្រាសរបស់អនុគមន៍ $f(x) = 5^x$ ក្នុងតម្រុយតែមួយ

គ. សរសេរសមីការអនុគមន៍ច្រាសរបស់អនុគមន៍ខាងលើ ។

4. សង់ក្រាបនៃអនុគមន៍ខាងក្រោម :

ក. $f(x) = \log_6 x$ ខ. $g(x) = \log_{\frac{1}{6}} x$ គ. $h(x) = \log_{0.8} x$

5. បង្ហាញថា បើ $f(x) = \log_a x$ នោះ $f(xy) = f(x) + f(y)$

6. ក. បង្ហាញថា បើ $(x_1, y_1)$ និង $(x_2, y_2)$ ជាចំណុចពីរនៅលើខ្សែកោង $y = \log_a x$ នោះចំណុច $\left(\frac{x_1}{x_2}, y_1 - y_2\right)$ ក៏ស្ថិតនៅលើខ្សែកោង $y = \log_a x$ ។

ខ. បង្ហាញថា បើ $(x_1, y_1)$ ជាចំណុចនៅលើខ្សែកោង $y = \log_a x$ នោះចំណុច $(x_1^2, 2y_1)$ និងចំណុច $\left(\frac{1}{x_1}, -y_1\right)$ ក៏ស្ថិតនៅលើខ្សែកោង $y = \log_a x$ ។

7. គេឱ្យអនុគមន៍ $f(x) = a^x$ និងអនុគមន៍ច្រាស $f^{-1}(x) = \log_a x$ ដែល $a > 0$ ។ រកតម្លៃ $a$ ដើម្បីឱ្យខ្សែកោងនៃអនុគមន៍ $f(x)$ និង $f^{-1}(x)$ កាត់គ្នា ។

8. គេឱ្យ $f(x) = x - \log_2 x$ ហើយ $g(x) = 2^x$ ។

   គណនា

   ក. $f(g(x))$ ខ. $g(f(x))$

9. ដោះស្រាយសមីការនិងផ្ទៀងផ្ទាត់

   ក. $\log_2(2x+4) - \log_2(x-1) = 3$ គ. $\log_5 x + \log_{10} x = 5$

   ខ. $\log_2 x + \log_4 x = 5$ ឃ. $\log(x+10) + \frac{1}{2}\log x^2 = 2 - \log 4$

10. រកតម្លៃ $m$ ដើម្បីឱ្យវិសមីការ $1 + \log_5(x^2+1) \geq \log_5(mx^2 + 4x + m)$ ផ្ទៀងផ្ទាត់ចំពោះ $\forall x$

11. រកតម្លៃ $a$ ដើម្បីឱ្យវិសមីការ $\log_{\frac{1}{a+1}}(x^2+2) \geq 1$ មានសំណុំឫសចំពោះ $\forall x$ ។

# ជំពូក 3
# សមីការនិងវិសមីការត្រីកោណមាត្រ

## ❶ សមីការនិងវិសមីការត្រីកោណមាត្រ



នៅក្នុងគណិតវិទ្យាកម្រិតមូលដ្ឋាន យើងបានសិក្សាពីសមីការនិងវិសមីការត្រីកោណមាត្រងាយៗ ដូចជា $\cos x = a$ , $\sin x = a$ , $\tan x = t$ , $\cos x > a$ , $\sin x < a ...$ ។

ផ្នែកនេះ យើងនឹងសិក្សាពីសមីការនិងវិសមីការត្រីកោណមាត្រទម្រង់ផ្សេងៗទៀត ដែលមានលក្ខណៈស៊ីជម្រៅជាងមុន ។

មេរៀនទី

# 1 សមីការនិងវិសមីការត្រីកោណមាត្រ

យើងបានសិក្សារួចមកហើយពីសមីការនិងវិសមីការត្រីកោណមាត្រងាយៗ នៅក្នុងសៀវភៅភាគ 1 ។ ក្នុងផ្នែកនេះយើងនឹងសិក្សាពីសមីការនិងវិសមីការត្រីកោណមាត្រ ដែលមានទម្រង់ផ្សេងៗទៀត ។

**វត្ថុបំណង**
- ដោះស្រាយសមីការត្រីកោណមាត្រ
- ដោះស្រាយវិសមីការត្រីកោណមាត្រ

## 1. សមីការត្រីកោណមាត្រ

### 1.1 សមីការដឺក្រេទី 1 ធៀបនឹង sinx និង cosx

ជាសមីការត្រីកោណមាត្រដែលក្រោយពីបង្រួមហើយមានរាង : $a\cos x + b\sin x = c$ ។

ដំណោះស្រាយសមីការនេះមានពីររបៀប :

***របៀបទី 1***

- បំលែងសមីការនេះជារាង $\cos(x-\theta) = \frac{c}{r}$ ដែល $r = \sqrt{a^2+b^2}$ , $(r \geq 0)$ និង $\cos\theta = \frac{a}{r}$ , $\sin\theta = \frac{b}{r}$ ។ ដោយ $\cos\theta = \frac{a}{r}$ នាំឱ្យ $a = r\cos\theta$ , $\sin\theta = \frac{b}{r}$ នាំឱ្យ $b = r\sin\theta$ ។

  សមីការ $a\cos x + b\sin x = r\cos\theta\cos x + r\sin\theta\sin x = c$

  $r(\cos x\cos\theta + \sin x\sin\theta) = c$ , $r\cos(x-\theta) = c$ ឬ $\cos(x-\theta) = \frac{c}{r}$ ។

- ដោះស្រាយសមីការ $\cos(x-\theta) = \frac{c}{r}$ តាមរូបមន្ត $\cos x = \cos\alpha$ ។

***ឧទាហរណ៍ 1*** ដោះស្រាយសមីការ $\sin x + \sqrt{3}\cos x = 0 \quad (1)$

គេបាន $r = \sqrt{1+3} = 2$ , $\cos\theta = \frac{a}{r} = \frac{1}{2}$ , $\sin\theta = \frac{b}{r} = \frac{\sqrt{3}}{2}$ នាំឱ្យ $\theta = \frac{\pi}{3}$ ។

សមីការ $\sin x + \sqrt{3}\cos x = 2\cos\frac{\pi}{3}\sin x + 2\sin\frac{\pi}{3}\cos x = 0$

$$2\left(\sin x\cos\frac{\pi}{3} + \cos x\sin\frac{\pi}{3}\right) = 0$$

$$2\sin\left(x+\frac{\pi}{3}\right) = 0 \text{ ឬ } \sin\left(x+\frac{\pi}{3}\right) = 0$$

សមីការ (1) មានចម្លើយ : $\sin\left(x+\frac{\pi}{3}\right) = 0$ , $x+\frac{\pi}{3} = k\pi$ ។

ដូចនេះ $x = \frac{-\pi}{3}+k\pi$ , $k\in\mathbb{Z}$ ។ ចំនួនចុងធ្នូចម្លើយមានពីរ

***របៀបទី 2*** គណនា $\sin x$ និង $\cos x$ ជាអនុគមន៍នៃ $\tan\frac{x}{2}$ ដោយ $x\neq\pi+2k\pi$ , $(k\in\mathbb{Z})$ ។ គេជំនួស $\cos x = \frac{1-t^2}{1+t^2}$ និង $\sin x = \frac{2t}{1+t^2}$ នោះសមីការ $a\cos x+b\sin x = c$ ទៅជាសមីការដឺក្រេទី 2 ដែលមាន $t$ ជាអញ្ញាត : $(c+a)t^2-2bt+c-a = 0$ ។

ដោះស្រាយសមីការដឺក្រេទី 2 រកឫសរួចដោះស្រាយសមីការតាមរូបមន្ត $\tan\frac{x}{2} = \tan\alpha$ ។

**សំគាល់** វិធីនេះអាចបាត់ឫសត្រង់ $x = \pi+2k\pi$ ដូចនេះ ដំបូងគេត្រូវពិនិត្យមើលថាតើ $x = \pi+2k\pi$ ជាឫសរបស់សមីការ $a\cos x+b\sin x = c$ ឬទេ ?

***ឧទាហរណ៍ 2*** ដោះស្រាយសមីការ $\sin x+7\cos x = 5$ ។

តាង $t = \tan\frac{x}{2}(x\neq\pi+2k\pi)$ សមីការសរសេរ $\frac{2t}{1+t^2}+7\left(\frac{1-t^2}{1+t^2}\right) = 5$

$2t+7-7t^2 = 5+5t^2$ ឬ $6t^2-t-1 = 0$ ។

សមីការមានឫស $t_1 = \frac{1}{2}$ , $t_2 = -\frac{1}{3}$ ។

- បើ $t_1 = \frac{1}{2}$ គេបាន $\tan\frac{x}{2} = \frac{1}{2}$ នោះមាន $\alpha_1\in\mathbb{R}$ ដែល $\tan\alpha_1 = \frac{1}{2}$

  គេបាន $\tan\frac{x}{2} = \tan\alpha_1$ នាំឱ្យ $\frac{x}{2} = \alpha_1+k\pi$ ឬ $x = 2\alpha_1+2k\pi$ , $k\in\mathbb{Z}$ ។

- បើ $t_2 = -\frac{1}{3}$ គេបាន $\tan\frac{x}{2} = -\frac{1}{3}$ នោះមាន $\alpha_2\in\mathbb{R}$ ដែល $\tan\alpha_2 = -\frac{1}{3}$

  គេបាន $\tan\frac{x}{2} = \tan\alpha_2$ នាំឱ្យ $\frac{x}{2} = \alpha_2+k\pi$ ឬ $x = 2\alpha_2+2k\pi$ , $k\in\mathbb{Z}$ ។

  ដូចនេះ សមីការមានចម្លើយ : $x = 2\alpha_1+2k\pi$ , $x = 2\alpha_2+2k\pi$ , $k\in\mathbb{Z}$ ។

**លំហាត់គំរូ** ដោះស្រាយសមីការ $\sqrt{3}\sin 2x+\cos 2x = \sqrt{2}$ (1)

**ចម្លើយ** គេបាន $\cos 2x+\sqrt{3}\sin 2x = \sqrt{2}$ ហើយ $r = \sqrt{3+1} = 2$ , $\cos\theta = \frac{1}{2}$ , $\sin\theta = \frac{b}{r} = \frac{\sqrt{3}}{2}$

សមីការសរសេរ $2\left(\frac{1}{2}\cos 2x+\frac{\sqrt{3}}{2}\sin 2x\right) = \sqrt{2}$ ឬ $\cos\left(2x-\frac{\pi}{3}\right) = \frac{\sqrt{2}}{2} = \cos\frac{\pi}{4}$

សមីការ (1) មានចម្លើយ :
$$2x-\frac{\pi}{3} = \frac{\pi}{4}+2k\pi\ ,\quad x = \frac{7\pi}{24}+k\pi\ ,\quad k\in\mathbb{Z}$$
$$2x-\frac{\pi}{3} = -\frac{\pi}{4}+2k\pi\ ,\quad x = -\frac{\pi}{24}+k\pi\ ,\quad k\in\mathbb{Z}$$

ចំនួនចុងធ្នូចម្លើយមាន 4

**ប្រតិបត្តិ** ដោះស្រាយសមីការ

ក. $2\sin x - 3\cos x = 3$

ខ. $\cos 2x - \sin 2x = -1$

គ. $\cos x + \sqrt{3}\sin x = 1$

ឃ. $\cos x - \sqrt{3}\sin x = 3$

## 1.2 សមីការដឺក្រេទី 2 ធៀបនឹងអនុគមន៍ត្រីកោណមាត្រនៃចំនួនពិត x

សមីការទាំងនោះមានរាង : $a\cos^2 x + b\cos x + c = 0$ , $a\sin^2 x + b\sin x + c = 0$

$a\tan^2 x + b\tan x + c = 0$ និង $a\cot^2 x + b\cot x + c = 0$ ។

ដើម្បីដោះស្រាយសមីការបែបនេះ គេត្រូវ :

- បំលែងសមីការឱ្យទៅជាសមីការដឺក្រេទី 2 ដូចខាងលើសិន ។
- តាងអនុគមន៍ត្រីកោណមាត្រនៃចំនួនពិត $x$ ដោយ $X$ ឬ $Y$ ឬ $t$... ។
- ដាក់លក្ខខណ្ឌទៅតាមអនុគមន៍ត្រីកោណមាត្រដែលឱ្យ ។
- ដោះស្រាយសមីការដឺក្រេទី 2 ដែលមានអញ្ញាត $X$ ឬ $Y$ ឬ $t$... ។
- យកឬសដែលបានមកជំនួសជាអនុគមន៍ត្រីកោណមាត្រវិញ រួចផ្ទៀងផ្ទាត់លក្ខខណ្ឌខាងលើ ហើយដោះស្រាយតាមរូបមន្តសមីការត្រីកោណមាត្រ ។

***ឧទាហរណ៍ 1*** ដោះស្រាយសមីការ $4 - \cos 2x - 7\sin x = 0$ ។

ដោយ $\cos 2x = 1 - 2\sin^2 x$ សមីការអាចសរសេរ $2\sin^2 x - 7\sin x + 3 = 0$ (1)

តាង $t = \sin x$ ដែលមានលក្ខខណ្ឌ $-1 \le t \le 1$ ។

សមីការ (1) អាចសរសេរ $2t^2 - 7t + 3 = 0$ , $\Delta = 25$ , $t_1 = \frac{1}{2}$ , $t_2 = 3$ មិន ផ្ទៀងផ្ទាត់លក្ខខណ្ឌខាងលើ

ដូចនេះ $t_1 = \sin x = \frac{1}{2} = \sin\frac{\pi}{6}$ យើងបាន $x_1 = \frac{\pi}{6} + 2k\pi$ , $x_2 = \frac{5\pi}{6} + 2k\pi$ , $k \in \mathbb{Z}$ ។

***ឧទាហរណ៍ 2*** ដោះស្រាយសមីការ $\tan^2\frac{x}{2} - (1-\sqrt{3})\tan\frac{x}{2} - \sqrt{3} = 0$ ។

គេតាង $\tan\frac{x}{2} = t$ សមីការ (1) សរសេរ $t^2 - (1-\sqrt{3})t - \sqrt{3} = 0$ ដោះស្រាយសមីការនេះ

គេបាន $t_1 = -1$ , $t_2 = \sqrt{3}$ ។ $t_1 = \tan\frac{x}{2} = -1 = \tan\left(-\frac{\pi}{4}\right)$ , $t_2 = \tan\frac{x}{2} = \sqrt{3} = \tan\frac{\pi}{3}$ ។

ដូចនេះ $\tan\frac{x}{2} = \tan\left(-\frac{\pi}{4}\right)$ , $\frac{x}{2} = -\frac{\pi}{4} + k\pi$ , $x = -\frac{\pi}{8} + 2k\pi$

$\tan\frac{x}{2} = \tan\frac{\pi}{3}$ , $\frac{x}{2} = \frac{\pi}{3} + k\pi$ , $x = \frac{2\pi}{3} + 2k\pi$ , $k \in \mathbb{Z}$ ។

ដូចនេះ សមីការមានចម្លើយ : $x = -\frac{\pi}{8} + 2k\pi$ និង $x = \frac{2\pi}{3} + 2k\pi$ , $k \in \mathbb{Z}$ ។

**លំហាត់គំរូ** ដោះស្រាយសមីការ $\frac{\cos x(2\sin x + 3\sqrt{2}) - 2\cos^2 x - 1}{1 + \sin 2x} = 1$ ។

**ចម្លើយ** លក្ខខណ្ឌ $1 + \sin 2x \neq 0$ , $\sin 2x \neq -1$ , $2x \neq -\frac{\pi}{2} + 2k\pi$ , $x \neq -\frac{\pi}{4} + k\pi, k \in \mathbb{Z}$

សមីការសរសេរ $\cos x(2\sin x + 3\sqrt{2}) - 2\cos^2 x - 1 = 1 + \sin 2x$

$2\sin x\cos x + 3\sqrt{2}\cos x - 2\cos^2 x - 1 = 1 + \sin 2x$ , $2\cos^2 x - 3\sqrt{2}\cos x + 2 = 0$

តាង $t = \cos x$ សមីការទៅជា $2t^2 - 3\sqrt{2}t + 2 = 0$ ។

ដោះស្រាយសមីការនេះ គេបាន $t_2 = \sqrt{2}$ , $t_2 = \frac{1}{\sqrt{2}}$ ។

$t_1 = \cos x = \sqrt{2}$ ( មិនយក ) ។ $t_2 = \cos x = \frac{1}{\sqrt{2}} = \cos\frac{\pi}{4}$ ។

ដូចនេះ $\cos x = \cos\frac{\pi}{4}$ នាំឱ្យ $x = \pm\frac{\pi}{4} + 2k\pi$ , $k \in \mathbb{Z}$ ។

តាមលក្ខខណ្ឌខាងលើសមីការមានឫស $x = \frac{\pi}{4} + 2k\pi$ , $k \in \mathbb{Z}$ ។

**ប្រតិបត្តិ** ដោះស្រាយសមីការ

ក. $2\cos^2 - 3\sqrt{2}\cos x + 2 = 0$

ខ. $\frac{1}{\sin^2 x} = \cot x + 3$

គ. $5\tan^2 y + 5\tan y = 2(1 + \tan^2 y)$

ឃ. $8\sin^2 x - 6\sin x = 5$ ។

## 2. សមីការដែលមានរាង $a\sin^2x + b\sin x\cos x + c\cos^2x = d$ ដែល $a, b, c \neq 0$

ដើម្បីដោះស្រាយសមីការនេះ គេត្រូវចែកអង្គទាំងពីរនៃសមីការនឹង $\cos^2x \neq 0$ , $x \neq \frac{\pi}{2} + k\pi$ ។ គេបានសមីការ $a\tan^2x + b\tan x + c = 0$ រួចដោះស្រាយតាមសមីការដឺក្រេទី 2 ដូចខាងលើ ។

***ឧទាហរណ៍ 1*** ដោះស្រាយសមីការ $3\sin^2x + 3\sin x\cos x - 6\cos^2x = 0$ ។

ចែកអង្គទាំងពីរនៃសមីការនឹង $\cos^2x$ សមីការសរសេរ $3\tan^2x + 3\tan x - 6 = 0$ ។

តាង $t = \tan x$ គេបាន $3t^2 + 3t - 6 = 0$ សមីការនេះមានឫសពីរគឺ : $t_1 = 1$ , $t_2 = -2$ ។

$t_1 = \tan x = 1$ គេបាន $\tan x = \tan\frac{\pi}{4}$ , $x = \frac{\pi}{4} + k\pi$ $(k \in \mathbb{Z})$ ។ $t_2 = -2$ តាង $\tan\alpha = -2$ , $\tan x = \tan\alpha$ , $x = \alpha + k\pi$ , $k \in \mathbb{Z}$ ។ សមីការមានចម្លើយ $x = \frac{\pi}{4} + k\pi$ និង $x = \alpha + k\pi$ , $k \in Z$ ។

***ឧទាហរណ៍ 2*** ដោះស្រាយសមីការ $\dfrac{\sin^4\frac{x}{2} + \cos^4\frac{x}{2}}{1 - \sin x} - \tan^2x\sin x = \dfrac{1 + \sin x}{2} + \tan^2x$ ។

លក្ខខណ្ឌ $\sin x \neq 1$ , $\cos x \neq 0$ , $x \neq \frac{\pi}{2} + k\pi$

សមីការអាចសរសេរ $$\frac{\left(\sin^2\frac{x}{2} + \cos^2\frac{x}{2}\right)^2 - 2\sin^2\frac{x}{2}\cos^2\frac{x}{2}}{1 - \sin x} = \frac{1 + \sin x}{2} + \tan^2x(1 + \sin x)$$

$$\frac{1 - \frac{1}{2}\sin^2x}{1 - \sin x} = (1 + \sin x)\left(\frac{1}{2} + \tan^2x\right)$$

$$1 - \frac{1}{2}\sin^2x = (1 - \sin^2x)\left(\frac{\cos^2x + 2\sin^2x}{2\cos^2x}\right)$$

$$\frac{2 - \sin^2x}{2} = (1 - \sin^2x)\frac{(\cos^2x + \sin^2x + \sin^2x)}{2(1 - \sin^2x)}$$

$$2 - \sin^2x = 1 + \sin^2x$$

$\sin^2x = \frac{1}{2}$ , $\sin x = \pm\frac{\sqrt{2}}{2}$ , $x = \pm\frac{\pi}{4} + k\pi$ $(k \in Z)$ ជាចម្លើយរបស់សមីការ ។

**លំហាត់គំរូ 1** ដោះស្រាយសមីការ $3\sin^2x + 2\sin x\cos x = 2$ ។

**ចម្លើយ** សមីការសរសេរ $3\sin^2x + 2\sin x\cos x = 2(\sin^2x + \cos^2x)$

$\sin^2x + 2\sin x\cos x - 2\cos^2x = 0$ ចែកអង្គទាំងពីរនៃសមីការនឹង $\cos^2x \neq 0$ ។

គេបាន $\tan^2x + 2\tan x - 2 = 0$ , $\tan x = 1 \pm \sqrt{3}$ ។ តាង $\tan\alpha = 1 \pm \sqrt{3}$

$\tan x = \tan\alpha$ , $x = \alpha + k\pi$ , $k \in \mathbb{Z}$ ។

**លំហាត់គំរូ 2** រកតម្លៃ $m$ ដែលនាំឱ្យសមីការ $1+m\cos x = m^2-\cos^2 x$ មានឫស ។

**ចម្លើយ** តាង $\cos x = t$ ដែល $-1\le t\le 1$ ។

គេបាន $t^2+mt+1-m^2 = 0$ ។ តាង $f(t)=t^2+mt+1-m^2$

សមីការមានឫសមួយលើចន្លោះ $[-1,\ 1]$ កាលណា $f(-1)\times f(1)\le 0$ ។

គេបាន $(2-m-m^2)(2+m-m^2)\le 0$

$$(m^2+m-2)(m^2-m-2)\le 0\ ,\ -2\le m\le -1 \text{ ឬ } 1\le m\le 2 \quad (1)$$

សមីការមានឫសពីរលើ $[-1,\ 1]$ កាលណា

$$\begin{cases}\Delta\ge 0\\ f(-1)>0\\ f(1)>0\\ -1<\frac{s}{2}<1\end{cases}\quad \begin{cases}m^2-4(1-m^2)\ge 0\\ -m^2-m+2>0\\ -m+m+2>0\\ -1<-\frac{m}{2}<1\end{cases}\quad \begin{cases}m\le -\frac{2}{\sqrt5}\ ,\ \frac{2}{\sqrt5}\le m\\ -2<m<1\\ -1<m<2\\ -2<m<2\end{cases}$$

$$-1<m\le -\frac{2\sqrt5}{5}\ ,\ \frac{2\sqrt5}{5}\le m\le 2 \quad (2)$$

តាម (1) និង (2) នាំឱ្យសមីការមានឫសកាលណា $-2\le m\le -\frac{2\sqrt5}{5}$ ឬ $\frac{2\sqrt5}{5}\le m\le 2$ ។

**ប្រតិបត្តិ 1** ដោះស្រាយសមីការខាងក្រោម :

ក. $7\cos^2 x+6\sqrt3\sin x\cos x-\sin^2 x+2 = 0$

ខ. $2\cos^2 x+\cot^2 x = \dfrac{\sin^3 x+1}{\sin^2 x}$

គ. $\tan^3 x+\tan^2 x-3\tan x = 3$

ឃ. $\sin^2 x+3\cos^2 x-2\sin 2x = 0$

**ប្រតិបត្តិ 2** រកតម្លៃ $m$ ដើម្បីឱ្យសមីការ $\sin 4x = m\tan x$ មានឫស $x\ne k\pi$ ។

# 3. ប្រព័ន្ធសមីការត្រីកោណមាត្រ

***ឧទាហរណ៍ 1*** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} x+y = \frac{\pi}{3} \\ \sin x + \sin y = 1 \end{cases}$

ប្រើរូបមន្តបំលែងពីផលបូកទៅជាផលគុណ គេបានសមីការ

$\sin x + \sin y = 2\sin\left(\frac{x+y}{2}\right)\cos\left(\frac{x-y}{2}\right) = 1$ ដោយ $x+y = \frac{\pi}{3}$ គេបាន $2\sin\frac{\pi}{6}\cos\left(\frac{x-y}{2}\right) = 1$ ។

គេមាន $\sin\frac{\pi}{6} = \frac{1}{2}$ នាំឱ្យ $\cos\left(\frac{x-y}{2}\right) = 1 = \cos 0$ គេបាន $\frac{x-y}{2} = 2k\pi$ ឬ $x-y = 4k\pi$

គេបានប្រព័ន្ធ $\begin{cases} x+y = \frac{\pi}{3} \\ x-y = 4k\pi \end{cases}$ , $\begin{cases} x = \frac{\pi}{6} + 2k\pi \\ y = \frac{\pi}{6} - 2k\pi \end{cases}$ $(k \in \mathbb{Z})$ ។

ដូចនេះប្រព័ន្ធសមីការមានគូចម្លើយ $\left(x = \frac{\pi}{6} + 2k\pi \ , \ y = \frac{\pi}{6} - 2k\pi\right)$ , $(k \in \mathbb{Z})$ ។

***ឧទាហរណ៍ 2*** ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} x+y = \frac{\pi}{2} & (1) \\ \tan x + \tan y = \sqrt{3} + \frac{\sqrt{3}}{3} & (2) \end{cases}$

លក្ខខណ្ឌ $x \neq \frac{\pi}{2} + k\pi$ , $y \neq \frac{\pi}{2} + k\pi$ , $k \in Z$ ។ ដោយ $\tan y = \cot x$ តាមមុំបំពេញ

គេបាន $\begin{cases} x+y = \frac{\pi}{2} & (1) \\ \tan x + \tan y = \sqrt{3} + \frac{\sqrt{3}}{3} & (2) \end{cases}$ , $\begin{cases} x+y = \frac{\pi}{2} \\ \tan^2 x - \left(\sqrt{3} + \frac{\sqrt{3}}{3}\right)\tan x + 1 = 0 \end{cases}$

សមីការ $\tan^2 x - \left(\sqrt{3} + \frac{\sqrt{3}}{3}\right)\tan x + 1 = 0$ មានឫសពីរគឺ $t_1 = \sqrt{3}$ , $t_2 = \frac{\sqrt{3}}{3}$ ។

ដូចនេះគេបាន $\begin{cases} x+y = \frac{\pi}{2} \\ \tan x = \sqrt{3} = \tan\frac{\pi}{3} \end{cases}$ ឬ $\begin{cases} x+y = \frac{\pi}{2} \\ \tan x = \frac{\sqrt{3}}{3} = \tan\frac{\pi}{6} \end{cases}$ , $\begin{cases} x+y = \frac{\pi}{2} \\ x = \frac{\pi}{3} + k\pi \end{cases}$ ឬ $\begin{cases} x+y = \frac{\pi}{2} \\ x = \frac{\pi}{6} + k\pi \end{cases}$

$\begin{cases} x = \frac{\pi}{3} + k\pi \\ y = \frac{\pi}{6} - k\pi \end{cases}$ ឬ $\begin{cases} x = \frac{\pi}{6} + k\pi \\ y = \frac{\pi}{3} - k\pi \end{cases}$ $(k \in \mathbb{Z})$ ជាចម្លើយរបស់ប្រព័ន្ធសមីការ ។

**លំហាត់គំរូ** រកតម្លៃ $m$ ដែលនាំឱ្យប្រព័ន្ធសមីការខាងក្រោមមានឫស

$$\begin{cases} x - y = m & (1) \\ 2(\cos 2x + \cos 2y) - 1 - 4\cos^2 m = 0 & (2) \end{cases}$$

**ចម្លើយ** គេបានសមីការ (2) សរសេរ : $4\cos(x+y)\cos(y-x)-1-4\cos^2 m = 0$ តាម (1) ជំនួសចូល

គេបាន : $4\cos^2 m-4\cos(x+y)\cos m+1 = 0$ , $[2\cos m-\cos(x+y)]^2+\sin^2(x+y) = 0$

$$\begin{cases}\sin(x+y) = 0\\ \cos(x+y) = 2\cos m\end{cases} , \begin{cases}x+y = 2k\pi\\ \cos m = \frac{1}{2}\end{cases} \text{ ឬ } \begin{cases}x-y = \pi+2k\pi\\ \cos m = -\frac{1}{2}\end{cases}$$

- ចំពោះ $\cos m = \frac{1}{2}$ , $m = \pm\frac{\pi}{3}+2k\pi$ នោះ $\cos(x+y) = 1$ គេបាន

$$\begin{cases}x+y = 2k\pi\\ x-y = \pm\frac{\pi}{3}+2k\pi\end{cases} , \begin{cases}x = \frac{\pi}{6}+k\pi\\ y = -\frac{\pi}{6}+k\pi\end{cases} , k\in\mathbb{Z}$$

- ចំពោះ $\cos m = -\frac{1}{2}$ , $m = \pm\frac{2\pi}{3}+2k\pi$ នោះ $\cos(x+y) = -1$

គេបានប្រព័ន្ធ : $\begin{cases}x+y = \pi+2k\pi\\ x-y = m\end{cases}$ , $\begin{cases}x+y = (2k+1)\pi\\ x-y = m\end{cases}$ , $\begin{cases}m = \frac{m}{2}+(2k+1)\frac{\pi}{2}\\ y = -\frac{m}{2}+(2k+1)\frac{\pi}{2}\end{cases}$

ដូចនេះ • $m = \pm\frac{\pi}{3}+2k\pi$ ប្រព័ន្ធមានឫស $\begin{cases}x = \frac{m}{2}+k\pi\\ y = -\frac{m}{2}+k\pi\end{cases}$ , $k\in\mathbb{Z}$

• $m = \pm\frac{2\pi}{3}+2k\pi$ ប្រព័ន្ធមានឫស $\begin{cases}x = \frac{m}{2}+(2k+1)\frac{\pi}{2}\\ y = -\frac{m}{2}+(2k+1)\frac{\pi}{2}\end{cases}$ , $k\in\mathbb{Z}$ ។

**ប្រតិបត្តិ 1** ដោះស្រាយប្រព័ន្ធសមីការ

ក. $\begin{cases}\cos^2 x+\cos^2 y = \frac{1}{4}\\ x+y = \frac{5\pi}{6}\end{cases}$

ខ. $\begin{cases}\sin x\cos y = \frac{1}{4}\\ 3\tan x = \tan y\end{cases}$

**ប្រតិបត្តិ 2** គេឱ្យប្រព័ន្ធសមីការ $\begin{cases}\sin x\cos 2y = m^2+1\\ \cos x\sin 2y = m\end{cases}$

ក. បញ្ជាក់តម្លៃ $m$ ដែលនាំឱ្យប្រព័ន្ធសមីការមានឫស ។

ខ. ដោះស្រាយប្រព័ន្ធសមីការតាមតម្លៃ $m$ ដែលរកបាននោះ ។

# 4. វិសមីការត្រីកោណមាត្រ

## 4.1 វិសមីការដែលមានរាង $a\cos x + b\sin x > c$

**ឧទាហរណ៍.1** ដោះស្រាយវិសីមការ $\sin x - \cos x > 0$ ។

គេបាន $\sqrt{2}\left(\frac{\sqrt{2}}{2}\sin x - \frac{\sqrt{2}}{2}\cos x\right) > 0$ , $\sqrt{2}\left(\sin x\cos\frac{\pi}{4} - \sin\frac{\pi}{4}\cos x\right) > 0$ , $\sqrt{2}\sin\left(x-\frac{\pi}{4}\right) > 0$ ។

$\sin\left(x-\frac{\pi}{4}\right) > 0$ ត្រូវនឹងចុងធ្នូនៅលើកន្លះរង្វង់ដែលមិនឆូត

ដូចនេះវិសមីការមានចម្លើយ $2k\pi < x-\frac{\pi}{4} < \pi + 2k\pi$

ឬ $\frac{\pi}{4} + 2k\pi < x < \frac{5\pi}{4} + 2k\pi \quad (k \in \mathbb{Z})$ ។




**សំគាល់** បើវិសមីការដែលមានទម្រង់ជាកន្សោមប្រភាគ ឬវិសីមការដឺក្រេទី 2 គេត្រូវដោះស្រាយរកសំណុំឫសដោយសិក្សាសញ្ញា ។

**ឧទាហរណ៍ 2** ដោះស្រាយវិសមីការ $\sin x + \frac{1}{\sin x} \ge \frac{5}{2}$ ។

គេមាន $\sin x + \frac{1}{\sin x} \ge \frac{5}{2}$ , $\sin x + \frac{1}{\sin x} - \frac{5}{2} \ge 0$

$$\frac{2\sin^2 x - 5\sin x + 2}{2\sin x} \ge 0$$

$$\frac{(\sin x - 2)(2\sin x - 1)}{2\sin x} \ge 0$$ ដោយ $\sin x - 2 < 0$ ចំពោះគ្រប់ $x \in \mathbb{R}$

គេបាន $\frac{2\sin x - 1}{2\sin x} \le 0 \quad (1)$

វិសមីការមានចម្លើយលុះត្រាតែ $\sin x \ne 0$ ឬ $x \ne k\pi$ ។

តាង $\sin x = X$ ដែល $-1 \le X \le 1$ វិសមីការ (1) ទៅជា $\frac{2X-1}{2X} \le 0$ សិក្សាសញ្ញាគេបាន

| $X$ | $-1$ | | $0$ | | $\frac{1}{2}$ | | $1$ |
|---|---|---|---|---|---|---|---|
| $2X-1$ | | $-$ | | $-$ | $0$ | $+$ | |
| $X$ | | $-$ | $0$ | $+$ | | $+$ | |
| $\frac{2X-1}{X}$ | | $+$ | | $-$ | $0$ | $+$ | |



គេបាន $0 < X \le \frac{1}{2}$ , $0 < \sin x \le \frac{1}{2}$ ត្រូវនឹង $2k\pi < x \le \frac{\pi}{6} + 2k\pi$

ឬ $\frac{5\pi}{6} + 2k\pi \le x < \pi + 2k\pi$ , $k \in Z$ ចុងធ្នូចម្លើយនៅលើធ្នូចរណីមាត្រ ( ខ្សែរពេញ )

**លំហាត់គំរូ** 1 ដោះស្រាយវិសមីការ $2\cos 2x + \sin^2 x\cos x + \sin x\cos^2 x > 2(\sin x + \cos x)$

**ចម្លើយ** គេមាន $2\cos 2x + \sin^2 x\cos x + \sin x\cos^2 x > 2(\sin x + \cos x)$

$2(\cos^2 x - \sin^2 x) + \sin x\cos x(\sin x + \cos x) - 2(\sin x + \cos x) > 0$

$(\cos x + \sin x)[2(\cos x - \sin x) + \sin x\cos x - 2] > 0$

តាង $f(x) = (\cos x + \sin x)[2(\cos x - \sin x) + \sin x\cos x - 2]$

ដោយ $f(x)$ ជាអនុគមន៍ដែលមានខួប $2\pi$ នោះគេអាចសិក្សាវិសមីការក្នុងចន្លោះ $(0,\ 2\pi)$ ។

គេបាន $f(x) = 0$ , $\cos x + \sin x = 0$ (1) ឬ $2(\cos x - \sin x) + \sin x\cos x - 2 = 0$ (2)

(1) : $\tan x = -1$ , $\left(x = \frac{3\pi}{4}\ ,\ x = \frac{7\pi}{4}\right)$ ។

(2) តាង $t = \cos x - \sin x = \sqrt{2}\cos\left(x + \frac{\pi}{4}\right)$ ដែល $-\sqrt{2} \le t \le \sqrt{2}$

$$t^2 = 1 - 2\sin x\cos x\ ,\quad \sin x\cos x = \frac{1 - t^2}{2}$$

(2) អាចសរសេរ $2t + \frac{1 - t^2}{2} - 2 = 0$ ឬ $t^2 - 4t + 3 = 0$

ដោះស្រាយសមីការនេះ គេបាន $t = 1$ ; $t = 3$ ( មិនយក )

$t = 1$ , $\sqrt{2}\cos\left(x + \frac{\pi}{4}\right) = 1$ , $\cos\left(x + \frac{\pi}{4}\right) = \frac{\sqrt{2}}{2} = \cos\frac{\pi}{4}$ ។ គេបាន $x = 0$ , $x = \frac{3\pi}{2}$

គេបានសញ្ញាដូចខាងក្រោម

| $x$ | $0$ | | $\frac{3\pi}{4}$ | | $\frac{3\pi}{2}$ | | $\frac{7\pi}{4}$ | | $2\pi$ |
|---|---|---|---|---|---|---|---|---|---|
| $f(x)$ | | $-$ | $0$ | $+$ | $0$ | $-$ | $0$ | $+$ | |

ដូចនេះ វិសមីការមានសំណុំចម្លើយ $\frac{3\pi}{4} + 2k\pi < x < \frac{3\pi}{2} + 2k\pi$ ឬ

$\frac{7\pi}{4} + 2k\pi < x < 2\pi + 2k\pi$ $(k \in \mathbb{Z})$ ។

**លំហាត់គំរូ 2** បង្ហាញថាក្នុងត្រីកោណ $ABC$ គេបាន $\cos A+\cos B+\cos C\le\frac{3}{2}$

**ចម្លើយ** គេមាន $\frac{3}{2}-(\cos A+\cos B+\cos A) = \frac{1}{2}[3-2(\cos A+\cos B+\cos C)]$

$$=\frac{1}{2}\left[1-4\cos\frac{A+B}{2}\cos\frac{A-B}{2}+2-2\cos C\right]$$

$$=\frac{1}{2}\left[1-4\cos\frac{A+B}{2}\cos\frac{A-B}{2}+2(1-\cos C)\right]$$

$$=\frac{1}{2}\left[1-4\cos\frac{A+B}{2}\cos\frac{A-B}{2}+4\sin^2\frac{C}{2}\right]$$

$$=\frac{1}{2}\left[1-4\sin\frac{C}{2}\cos\frac{A-B}{2}+4\sin^2\frac{C}{2}\right]$$

ព្រោះ $\cos\frac{A+B}{2}=\sin\frac{C}{2}$

$$=\frac{1}{2}\left[\left(2\sin\frac{C}{2}-\cos\frac{A-B}{2}\right)^2+1-\cos^2\frac{A-B}{2}\right]$$

$$=\frac{1}{2}\left[\left(2\sin\frac{C}{2}-\cos\frac{A-B}{2}\right)^2+\sin^2\frac{A-B}{2}\right]\ge 0$$

ដូចនេះ $\frac{3}{2}\ge\cos A+\cos B+\cos C$ ឬ $\cos A+\cos B+\cos C\le\frac{3}{2}$

**ប្រតិបត្តិ 1** ដោះស្រាយវិសមីការខាងក្រោម :

ក. $\sin x+\cos x>\cos\frac{\pi}{6}$

ខ. $\frac{2\cos x-5\sin x}{\cos x}>0$

គ. $\frac{\cos x}{1-3\cos x}<\frac{1-\cos x}{1-9\cos^2 x}$

ឃ. $2\sin^2\left(x+\frac{\pi}{4}\right)+\sqrt{3}\cos 2x>0$

**ប្រតិបត្តិ 2** បង្ហាញថាក្នុងត្រីកោណ $ABC$ គេបាន $\sin^2 A+\sin^2 B+\sin^2 C\le\frac{9}{4}$ ។

# មេរៀនសង្ខេប

ដើម្បីដោះស្រាយសមីការ $a\cos x + b\sin x = c$ គេមានពីរបៀប :

1. បំលែងសមីការនេះជារាង $\cos(x-\theta) = \frac{c}{r}$ ដែល $r = \sqrt{a^2+b^2}$ , $(r \geq 0)$ និង $\cos\theta = \frac{a}{r}$ ,

$\sin\theta = \frac{b}{r}$ រួចដោះស្រាយសមីការ $\cos(x-\theta) = \frac{c}{r}$ តាមរូបមន្ត $\cos x = \cos\alpha$ ។

2. គណនា $\sin x$ និង $\cos x$ ជាអនុគមន៍នៃ $\tan\frac{x}{2} (x \neq \pi + 2k\pi \ , \ k \in \mathbb{Z})$ ។

គេជំនួស $\cos x = \frac{1-t^2}{1+t^2}$ និង $\sin x = \frac{2t}{1+t^2}$ នោះសមីការ $a\cos x + b\sin x = c$ ទៅជា សមីការដឺក្រេទី 2 ដែលមាន $t$ ជាអញ្ញាត : $(c+a)t^2 - 2bt + c - a = 0$ ។ រកឫសសមីការដឺក្រេទី2 រួចដោះស្រាយសមីការតាមរូបមន្ត $\tan\frac{x}{2} = \tan\alpha$ ។

ដើម្បីដោះស្រាយសមីការ : $a\cos^2 x + b\cos x + c = 0$ , $a\sin^2 x + b\sin x + c = 0$

$a\tan^2 x + b\tan x + c = 0$ និង $a\cot^2 x + b\cot x + c = 0$ គេត្រូវ :

- បំលែងសមីការឱ្យទៅជាសមីការដឺក្រេទី 2 ដូចខាងលើសិន ។
- តាងអនុគមន៍ត្រីកោណមាត្រនៃចំនួនពិត $x$ ដោយ $X$ ឬ $Y$ ឬ $t$... ។
- ដាក់លក្ខខណ្ឌទៅតាមអនុគមន៍ត្រីកោណមាត្រដែលឱ្យ ។
- ដោះស្រាយសមីការដឺក្រេទី 2 ដែលមានអញ្ញាត $X$ ឬ $Y$ ឬ $t$... ។
- យកឫសដែលបានមកជំនួសជាអនុគមន៍ត្រីកោណមាត្រវិញ រួចផ្ទៀងផ្ទាត់លក្ខខណ្ឌខាងលើ ហើយដោះស្រាយតាមរូបមន្តសមីការត្រីកោណមាត្រ ។

ដើម្បីដោះស្រាយវិសមីការដែលមានទម្រង់ $a\cos x + b\sin x < c$ ឬ $a\cos x + b\sin x > c, \ldots$ គេត្រូវ :

- បំលែងអង្គទី 1 នៃវិសមីការឱ្យមានរាង $\cos(x-\theta)$ ឬ $\sin(x-\theta)$ ។
- ដោះស្រាយវិសមីការ $\cos(x-\theta) > \cos\alpha$ ឬ $\sin(x-\theta) < \sin\alpha, \ldots$

តាមរបៀបដោះស្រាយវិសមីការ $\cos x > a$ ឬ $\sin x < a$

បើវិសមីការដែលមានទម្រង់ជាកន្សោមប្រភាគ ឬវិសមីការដឺក្រេទី 2 គេត្រូវដោះស្រាយរកសំណុំឫសដោយសិក្សាសញ្ញា ។

## លំហាត់

1. ដោះស្រាយសមីការខាងក្រោម ៖

ក. $\cos x + \sqrt{3}\sin x = \cos 3x$

ខ. $\sin 3x + 2\cos x - 2 = 0$

គ. $\sin 2x + \tan x = 2$

ឃ. $\sin 5x + \cos 5x = \sqrt{2}\cos 13x$

ង. $6\sin x - 2\cos^3 x = 5\sin 2x\cos x$

ច. $\sqrt{5\cos x - \cos 2x} + 2\sin x = 0$

2. ដោះស្រាយសមីការខាងក្រោម ៖

ក. $1 + \cot 2x = \dfrac{1 - \cos 2x}{\sin^2 2x}$

ខ. $\cos^6 x + \sin^6 x = \dfrac{7}{16}$

គ. $(1 - \tan x)(1 + \sin 2x) = 1 + \tan x$

ឃ. $3\sin 3x - \sqrt{3}\cos 9x = 1 + 4\sin^3 3x$

ង. $1 + 3\cos x + \cos 2x = \cos 3x + 2\sin x\sin 2x$

ច. $\cos^4 x + \sin^6 x = \cos 2x$

3. គេឱ្យសមីការ $\cos 2x - (2m + 1)\cos x + m + 1 = 0 \quad (1)$ ។

ក. ដោះស្រាយសមីការ $(1)$ កាលណា $m = \dfrac{3}{2}$ ។

ខ. រកតម្លៃ $m$ ដែលធ្វើឱ្យសមីការមានឫស $x$ នៅចន្លោះ $\dfrac{\pi}{2} < x < \dfrac{3\pi}{2}$ ។

4. ដោះស្រាយប្រព័ន្ធសមីការត្រីកោណមាត្រខាងក្រោម ៖

ក. $\begin{cases} \sin(x + y) = \dfrac{1}{2} \\ \cos(x - y) = \dfrac{\sqrt{2}}{2} \end{cases}$

ខ. $\begin{cases} \sin x + \sin y = \sqrt{2} \\ \cos x + \sin y = \sqrt{2} \end{cases}$

គ. $\begin{cases} \sin(x + y) = \cos(x - y) \\ \tan x - \tan y = 1 \end{cases}$ ។

5. ដោះស្រាយវិសមីការខាងក្រោម ៖

ក. $\sin^2\left(\frac{x}{2}-\frac{\pi}{4}\right) < \cos^2\frac{x}{2}$

ខ. $6\sin^2 x - \sin x\cos x - \cos^2 x) > 2$

គ. $\frac{\cos x}{1+2\cos x} > \frac{1-\cos x}{1-2\cos x}$

ឃ. $\frac{1-\sin x}{1-3\sin x} < \frac{1+\sin x}{1-9\sin^2 x}$ ។

6. បង្ហាញថា

ក. $\sin^4\alpha + \cos^4\alpha \geq \frac{1}{2}$

ខ. $\sin^6\alpha + \cos^6\alpha \geq \frac{1}{4}$

គ. $\sin^8\alpha + \cos^8\alpha \geq \frac{1}{8}$ ។

7. បង្ហាញថាក្នុង $\Delta ABC$ គេបាន : $\sin\frac{A}{2}\cdot\sin\frac{B}{2}\cdot\sin\frac{C}{2} \leq \frac{1}{8}$ ។

8. បង្ហាញថា $\Delta ABC$ ដែលបំពេញលក្ខខណ្ឌ ៖ $\tan A\tan B\tan^2\frac{C}{2} = 1$ ជាត្រីកោណកែងសមបាត ។

## លំហាត់ជំពូក

1. ដោះស្រាយសមីការខាងក្រោម ៖

ក. $2\cos 3x + \sqrt{3}\sin x + \cos x = 0$

ខ. $\sin^6 x + \cos^3 x = 2(\sin^6 x + \cos^8 x)$

គ. $\frac{\sin 5x}{5\sin x} = 1$

ឃ. $\sin^2 x + \sin^2 3x = \cos^2 2x + \cos^2 4x$

ង. $\cos^3 x + \frac{3\sqrt{2}}{4}\sin 2x - 2\cos x = 0$

ច. $\sin x + \sin 2x + \sin 3x + \sin 4x + \sin 5x + \sin 6x = 0$ ។

2. ដោះស្រាយវិសមីការខាងក្រោម ៖

ក. $2\cos^2 x - \cos x + 1 \le 0$ ក្នុង $[0,\ \pi]$

ខ. $\dfrac{2\sin^2 x - \sin x - 1}{\sin x} > 0$ ក្នុង $[0,\ \pi]$

គ. $\dfrac{\sin x - \cos x + 1}{\sin x + \cos x - 1} > 0$ ។

3. ក. ពន្លាតកន្សោម $\left(x + \frac{1}{2}\right)(x - 8)(x - 1)$

ខ. ដោះស្រាយសមីការ $2\sin^3 x - 17\sin^2 x + 7\sin x + 8 = 0$ ។

4. គេឱ្យសមីការ $\cos 2x - (2m + 1)\cos x + m + 1 = 0 \qquad (1)$

ក. ដោះស្រាយសមីការ (1) កាលណា $m = 1$

ខ. រកតម្លៃ $m$ ដែលធ្វើឱ្យសមីការមានឫសនៅចន្លោះ $[0,\ \pi]$ ។

5. គេមានវិសមីការ $(E)$ : $2\sin^2 x - 5\sin x + 2 > 0$

គេតាង $X = \sin x$ វិសមីការសរសេរ $2X^2 - 5X + 2 > 0$ ។

ក. ដាក់ជាផលគុណកត្តាកន្សោម $2x^2 - 5x + 2$

ខ. បង្ហាញថាវិសមីការ $(E)$ សរសេរជារាង $2(\sin x - 2)\left(\sin x - \frac{1}{2}\right) > 0$

គ. សិក្សាសញ្ញា $(\sin x - 2)\left(\sin x - \frac{1}{2}\right)$ នៅលើចន្លោះ $[0,\ 2\pi]$ ។

ឃ. រកសំណុំចម្លើយនៃវិសមីការ $(E)$ ។

6. ដោះស្រាយប្រព័ន្ធសមីការត្រីកោណមាត្រខាងក្រោម ៖

ក. $\begin{cases} \sin x + \sin y = \frac{3}{2} \\ \sin^2 x + \sin^2 y = \frac{5}{4} \end{cases}$ ខ. $\begin{cases} \cos^3 x - \cos x + \sin y = 0 \\ \sin^3 x - \sin y + \cos x = 0 \end{cases}$ គ. $\begin{cases} \dfrac{1 - \tan x}{1 + \tan x} = \tan y \\ x - y = \dfrac{\pi}{6} \end{cases}$ ។

7. គេមាន $\Delta ABC$ ដែលមានមុំ និងជ្រុងបំពេញលក្ខខណ្ឌ ៖ $\dfrac{1 + \cos A}{1 + \cos B} = \dfrac{2a + c}{2a - c}$ ។

បង្ហាញថា $\Delta ABC$ ជាត្រីកោណសមបាត ។

8. មុំ $A,\ B,\ C$ នៃ $\Delta ABC$ មួយមាន $\dfrac{A + C}{2} = B$ ។

រករង្វាស់មុំនៃត្រីកោណនោះបើគេដឹងថា $\sin A + \sin B + \sin C = \dfrac{3 + \sqrt{3}}{2}$ ។

PROEUS DARA


# ជំពូក 4 បំលែងលីនេអ៊ែរ

## ❶ បំលែងលីនេអ៊ែរ



TAKAKAZU SEKI

អ្នកដែលនាំឱ្យមានបញ្ញត្តិម៉ាទ្រីសមុនគេ គឺ Arthur Cayley ( 1875-1921 ) ។ តាមពិតដេទែរមីណង់បានកើតឡើងមុនម៉ាទ្រីស ហើយមានប្រភពនៅក្នុងចម្លើយទូទៅនៃប្រព័ន្ធសមីការលីនេអ៊ែរ ។ ដើមកំណើតនៃដេទែរមីណង់ត្រូវបានសរសេរដោយ Leibniz នៅឆ្នាំ 1678 ស្របពេលដែលនៅក្នុងប្រទេសជប៉ុន TAKAKAZU SEKI បានសម្រេចស្នាដៃដ៏ធំធេងលើបញ្ហានេះក្នុងឆ្នាំ 1680 ។

នៅចុងសតវត្សទី 19 Cayley, Jame Syluester and Ferdinand Frobenius បានសិក្សាទ្រឹស្តីម៉ាទ្រីស និងដេទែរមីណង់យ៉ាងស៊ីជំរៅ ។ ដោយមានការរីកចំរើនក្នុងពីជគណិតលីនេអ៊ែរ ម៉ាទ្រីសត្រូវបានគេយកទៅដោះស្រាយក្នុងបំលែងលីនេអ៊ែរ ឬអនុគមន៍លីនេអ៊ែរ ហើយក៏ក្លាយជាបញ្ញត្តិសំខាន់ក្នុងទ្រឹស្តីពីជគណិតលីនេអ៊ែរ ។

មេរៀនទី 1

# បំលែងលីនេអ៊ែរ

## 1. បំលែងលីនេអ៊ែរ

### 1.1 សញ្ញាណ

យើងធ្លាប់រៀនរួចមកហើយនូវបំលែងចំណុចមួយចំនួននៅក្នុងប្លង់ ។

***ឧទាហរណ៍*** បើគេប្លែងចំណុច $M(x, y)$ ទៅជា $M'(x', y')$ តាមបំលែង $H$ ដែលមានផ្ចិត $O$ និងផលធៀប 4 នោះគេបានសមីការ

$x' = 4x$

$y' = 4y$

សមីការនៃបំលែងទាំងដែលសរសេរបែបនេះហៅថាសមីការដឺក្រេទី 1 ឬហៅថាសមីការលីនេអ៊ែរ ។

**វត្ថុបំណង**

- បកស្រាយបំលែងលីនេអ៊ែរជាម៉ាទ្រីស
- កំណត់រូបភាពតាមបំលែងលីនេអ៊ែរ
- កំណត់រូបភាពតាមបំលែងលីនេអ៊ែរបណ្តាក់
- កំណត់រូបភាពតាមបំលែងលីនេអ៊ែរបណ្តាក់ក្នុងត្រីកោណមាត្រ

ក្នុងករណីនេះ គេថាបំលែងទាំងជាបំលែងលីនេអ៊ែរ ។

**ជាទូទៅ** បំលែងលីនេអ៊ែរដែលប្លែងចំណុច $M(x, y)$ ទៅ $M'(x', y')$ កំណត់ដោយសមីការ $x' = ax + cy$

$y' = bx + dy$

ដើម្បីងាយស្រួលសិក្សាទៅមុខ គេអាចបកស្រាយបំលែងលីនេអ៊ែរឱ្យមានទម្រង់ជាម៉ាទ្រីស

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} a & c \\ b & d \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$$ ។

ក្នុងករណីនេះគេថា $A = \begin{bmatrix} a & c \\ b & d \end{bmatrix}$ ជាម៉ាទ្រីសនៃបំលែងលីនេអ៊ែរ ។

ចំណុច $\begin{bmatrix} x' \\ y' \end{bmatrix}$ ជារូបភាពនៃ $\begin{bmatrix} x \\ y \end{bmatrix}$ តាមបំលែងលីនេអ៊ែរ $A$ ។

គេអាចគណនា $x', y'$ បានដោយគេគុណម៉ាទ្រីស $\begin{bmatrix} a & c \\ b & d \end{bmatrix}$ និង $\begin{bmatrix} x \\ y \end{bmatrix}$ រួចផ្ទឹមតួម៉ាទ្រីសនៃអង្គទី 1 និងតួម៉ាទ្រីសនៃអង្គទី 2 ។

**សំគាល់** ដើម្បីសម្រួលក្នុងសំណេរ គេអាចប្រើអក្សរ $A$ ដដែលនេះសម្រាប់សំគាល់ថាជាម៉ាទ្រីសផង និងជាបំលែងលីនេអ៊ែរផង ។

**ឧទាហរណ៍ 1** រូបភាពនៃចំណុច $\left(2, \frac{1}{2}\right)$ តាមបំលែង $A = \begin{bmatrix} -\frac{1}{2} & 1 \\ 4 & 3 \end{bmatrix}$ គឺ

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -\frac{1}{2} & 1 \\ 4 & 3 \end{bmatrix}\begin{bmatrix} 2 \\ \frac{1}{2} \end{bmatrix} = \begin{bmatrix} -\frac{1}{2} \times 2 + 1 \times \frac{1}{2} \\ 4 \times 2 + 3 \times \frac{1}{2} \end{bmatrix} = \begin{bmatrix} -\frac{1}{2} \\ \frac{19}{2} \end{bmatrix}$$

ដូចនេះ រូបភាពនៃ $\left(2, \frac{1}{2}\right)$ គឺ $\left(-\frac{1}{2}, \frac{19}{2}\right)$ ។

ចំពោះបំលែងលីនេអ៊ែរដែលមានម៉ាទ្រីស $I = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}$

រូបភាពវាគឺ

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} x+0 \\ 0+y \end{bmatrix} = \begin{bmatrix} x \\ y \end{bmatrix} \text{ ។}$$

គេសង្កេតឃើញថា រូបភាពនៃ $\begin{bmatrix} x' \\ y' \end{bmatrix}$ ត្រួតលើភាពដើម $\begin{bmatrix} x \\ y \end{bmatrix}$ ។

គេថា $I$ ជាបំលែងលីនេអ៊ែរដដែល ។ មានន័យថាចំណុចដែលប្លែងដោយ $I$ នៅតែជាចំណុចនោះដដែល ។

**ឧទាហរណ៍ 2** រូបភាពនៃចំណុច $\left(-\frac{1}{2}, 3\right)$ តាម $I = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}$ គឺ

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}\begin{bmatrix} -\frac{1}{2} \\ 3 \end{bmatrix} = \begin{bmatrix} -\frac{1}{2} \\ 3 \end{bmatrix} \text{ ។}$$

ដូចនេះ $x' = -\frac{1}{2},\ y' = 3$ ។

**លំហាត់គំរូ 1** បង្ហាញថា បើម៉ាទ្រីស $A$ ប្លែងចំណុច $M \neq 0$ នៅតែជាចំណុច $M$ ដដែល នោះម៉ាទ្រីស $A = I$ ។

**ចម្លើយ** តាង $A = \begin{bmatrix} a & c \\ b & d \end{bmatrix}$ ជាម៉ាទ្រីសដែលប្លែង $M(x,\ y)$ ទៅ $M(x,\ y)$ ដដែល

យើងបាន $\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} a & c \\ b & d \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ ឬ $\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} ax+cy \\ bx+dy \end{bmatrix}$

យើងបាន $x = ax + cy$

$y = bx + dy$

$x(1-a) - cy = 0 \quad (1)$

$y(1-d) - bx = 0 \quad (2)$

ដោយ $M \neq 0$ នោះ $x \neq 0$ , $y \neq 0$ ហើយសមីការ (1) និង (2) ផ្ទៀងផ្ទាត់

លុះត្រា $\begin{cases} 1-a = 0 \\ c = 0 \end{cases}$ និង $\begin{cases} 1-d = 0 \\ b = 0 \end{cases}$ នាំឱ្យ $\begin{matrix} 0 = 1; b = 0 \\ c = 0; d = 1 \end{matrix}$

យើងបាន $A = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}$ ។

**លំហាត់គំរូ 2** កំណត់ម៉ាទ្រីស $A$ ដែលប្លែងពីចំណុច $(1,\ 2)$ ទៅចំណុច $(8,\ 1)$ និងប្លែងពីចំណុច $(-1,\ 1)$ ទៅ $(1,\ 2)$ ។

**ចម្លើយ** តាង $A = \begin{bmatrix} a & c \\ b & d \end{bmatrix}$ ជាម៉ាទ្រីសប្លែងពីចំណុច $(1,\ 2)$ ទៅចំណុច $(8,\ 1)$ នោះយើងបាន

$$\begin{bmatrix} 8 \\ 1 \end{bmatrix} = \begin{bmatrix} a & c \\ b & d \end{bmatrix}\begin{bmatrix} 1 \\ 2 \end{bmatrix}$$

យើងបានសមីការ $\begin{matrix} a + 2c = 8 & (1) \\ b + 2d = 1 & (2) \end{matrix}$

$$\begin{bmatrix} 1 \\ 2 \end{bmatrix} = \begin{bmatrix} a & c \\ b & d \end{bmatrix}\begin{bmatrix} -1 \\ 1 \end{bmatrix}$$

យើងបានសមីការ $\begin{matrix} -a + c = 1 & (3) \\ -b + d = 2 & (4) \end{matrix}$

ដោះស្រាយប្រព័ន្ធសមីការ (1) និង (3) យើងបាន $a = 2$ , $c = 3$

ដោះស្រាយប្រព័ន្ធសមីការ (2) និង (4) យើងបាន $b = -1$ , $d = 1$

ដូចនេះ ម៉ាទ្រីសដែលត្រូវរកគឺ $A = \begin{bmatrix} 2 & 3 \\ -1 & 1 \end{bmatrix}$ ។

**ប្រតិបត្តិ** 1. គេប្លែងចំណុច $M(x, y)$ ទៅ $M'(x', y')$ តាមម៉ាទ្រីស $A$ ដែល $x' = x\cos\alpha - y\sin\alpha$ , $y' = x\sin\alpha + y\cos\alpha$ ។ កំណត់ម៉ាទ្រីស $A$ ។

2. កំណត់ $\alpha$ ដើម្បីឱ្យចំណុច $M'$ ត្រួតលើ $M$ ។

## 1.2 ចំណុចឥតប្រែប្រួល

***ឧទាហរណ៍*** កំណត់រូបភាពនៃចំណុច $P(3, 2)$ និង $Q(5, 2)$ ដែលប្លែងដោយបំលែងលីនេអ៊ែរ $A = \begin{bmatrix} 3 & -5 \\ 2 & -4 \end{bmatrix}$ ។

តាមបម្រាប់រូបភាពនៃ $P$ កំណត់ដោយ :

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 3 & -5 \\ 2 & -4 \end{bmatrix}\begin{bmatrix} 3 \\ 2 \end{bmatrix} = \begin{bmatrix} 3\times 3 - 5\times 2 \\ 2\times 3 - 4\times 2 \end{bmatrix} = \begin{bmatrix} -1 \\ -2 \end{bmatrix}$$ ដូចនេះ $P'(-1, -2)$ ។

រូបភាពនៃ $Q$ កំណត់ដោយ :

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 3 & -5 \\ 2 & -4 \end{bmatrix}\begin{bmatrix} 5 \\ 2 \end{bmatrix} = \begin{bmatrix} 3\times 5 - 5\times 2 \\ 2\times 5 - 4\times 2 \end{bmatrix} = \begin{bmatrix} 5 \\ 2 \end{bmatrix}$$ ដូចនេះ $Q'(5, 2)$ ។

តាមបំលែង $A$ រូបភាពនៃ $P(3, 2)$ គឺ $P'(-1, -2)$ ហើយ $Q(5, 2)$ គឺ $Q'(5, 2)$ នោះគេសង្កេតឃើញថា ចំណុច $Q$ មិនផ្លាស់ប្តូរទីតាំងទៅតាម $A$ នោះទេ ព្រោះរូបភាពរបស់វា $Q'$ នៅតែជាចំណុច $Q$ ដដែល ។

ក្នុងករណីនេះ គេថា $Q$ ជាចំណុចឥតប្រែប្រួលតាមបំលែង $A$ ។

**ជាទូទៅ** $Q$ ជាចំណុចឥតប្រែប្រួលតាមបំលែង $A$ កាលណា $A(Q) = Q$ ។

- ចំពោះបំលែងថាំង $H(0, k)$ កំណត់ដោយ $x' = kx$ , $y' = ky$ ។
- គល់ $O$ គឺជាចំណុចឥតប្រែប្រួល ។ ព្រោះ $O(0, 0)$ ផ្តល់រូបភាព $O(0, 0)$ ដដែល ។
- ចំពោះបំលែងដែលមានម៉ាទ្រីសឯកតា $I$ គឺ $I = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}$ ។

- គ្រប់ចំណុចនៃប្លង់ដែលប្លែងតាម $I$ នៅតែជាចំណុចខ្លួនឯងដដែល ។

ព្រោះ $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} x \\ y \end{bmatrix}$ ។

**លំហាត់គំរូ 1** គេប្លែងចំណុច $M(x, y)$ ទៅ $M'(x', y')$ កំណត់ដោយ

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 2 & -1 \\ 3 & 4 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} + \begin{bmatrix} 3 \\ -3 \end{bmatrix} \text{ ។}$$

កំណត់ចំណុចឥតប្រែប្រួល ។

**ចម្លើយ** បើ $M(x, y)$ ជាចំណុចឥតប្រែប្រួល លុះត្រាតែ $x' = x$ , $y' = y$

$$\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} 2 & -1 \\ 3 & 4 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} + \begin{bmatrix} 3 \\ -3 \end{bmatrix}$$

$$\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} 2x - y \\ 3x + 4y \end{bmatrix} + \begin{bmatrix} 3 \\ -3 \end{bmatrix} = \begin{bmatrix} 2x - y + 3 \\ 3x + 4y - 3 \end{bmatrix}$$

យើងបានប្រព័ន្ធ $\begin{cases} 2x - y + 3 = x \\ 3x + 4y - 3 = y \end{cases}$ ឬ $\begin{cases} x - y = -3 \\ 3x + 3y = 3 \end{cases}$

ដោះស្រាយប្រព័ន្ធ យើងបាន $x = -1$ , $y = 2$ ។

ដូចនេះ ចំណុចឥតប្រែប្រួលគឺ $(-1, 2)$ ។

**លំហាត់គំរូ 2** បង្ហាញថាបន្ទាត់ $y = 2x - 1$ ប្លែងតាមម៉ាទ្រីស $\begin{bmatrix} 3 & -1 \\ 4 & -1 \end{bmatrix}$ បានរូបភាពខ្លួនឯងដដែល ។

**ចម្លើយ** យក $M(x, y)$ ប្លែងទៅ $M'(x', y')$ តាមម៉ាទ្រីស $\begin{bmatrix} 3 & -1 \\ 4 & -1 \end{bmatrix}$ នោះយើងបាន

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 3 & -1 \\ 4 & -1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} \text{ ។}$$

បើ $M$ ជាចំណុចមួយនៃបន្ទាត់ $y = 2x - 1$ នោះ $M$ មានកូអរដោនេ $(a, 2a - 1)$ ។

ដូចនេះ $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 3 & -1 \\ 4 & -1 \end{bmatrix}\begin{bmatrix} a \\ 2a - 1 \end{bmatrix} = \begin{bmatrix} 3a - 2a + 1 \\ 4a - 2a + 1 \end{bmatrix} = \begin{bmatrix} a + 1 \\ 2a + 1 \end{bmatrix}$

នោះយើងបាន $x' = a + 1$ , $y' = 2a + 1$ ។

ដោយបំបាត់ $a$ យើងបាន $y' = 2x' - 1$ ដែលជារូបភាពនៃបន្ទាត់ $y = 2x - 1$ ។

បន្ទាត់ដើម និងរូបភាពវាមានសមីការដូចគ្នាគឺ $y = 2x - 1$

**ប្រតិបត្តិ** 1. គេប្លែងចំណុច $M(x, y)$ ទៅ $M'(x', y')$ កំណត់ដោយ

ក. $x' = 2y - 3$ , $y' = x + 1$

ខ. $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 3 & 3 \\ -2 & -1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} + \begin{bmatrix} -4 \\ 2 \end{bmatrix}$ ។

កំណត់ចំណុចឥតប្រែប្រួល ។

2. បង្ហាញថាបន្ទាត់ $y = 2x - 3$ ប្លែងតាមម៉ាទ្រីស $\begin{bmatrix} 2 & 1 \\ 3 & -1 \end{bmatrix}$ បានរូបភាពខ្លួនឯងដដែល ។

3. រកចំណុចឥតប្រែប្រួលតាមបំលែង $\begin{bmatrix} 2 & 1 \\ 2 & 3 \end{bmatrix}$ ។

4. រកចំណុចឥតប្រែប្រួលតាមបំលែង $\begin{bmatrix} 3 & 2 \\ 3 & 4 \end{bmatrix}$ ។

## 1.3 បំលែងលីនេអ៊ែរច្រាស

***ឧទាហរណ៍ 1*** គេប្លែងចំណុច $M(x, y)$ ទៅ $M'(x', y')$ តាមបំលែងចាំងដែលមានម៉ាទ្រីស $H = \begin{bmatrix} k & 0 \\ 0 & k \end{bmatrix}$ ដែល $k \neq 0$ ។

គេបាន $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} k & 0 \\ 0 & k \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} kx \\ ky \end{bmatrix}$ នាំឱ្យគេបាន $\begin{cases} x' = kx \\ y' = ky \end{cases}$

គេថា $M'$ ជារូបភាពនៃ $M$ តាមបំលែង $H$ ។

ឥឡូវនេះ គេយក $M$ ជារូបភាពនៃ $M'$ វិញ ហើយក្នុងករណីនេះគេត្រូវគណនា $x, y$ ជាអនុគមន៍នៃ $x'$ និង $y'$ ។

គេបាន $x = \frac{1}{k}x'$ និង $y = \frac{1}{k}y'$ បកស្រាយសមីការនេះជាម៉ាទ្រីស គឺ

$\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} \frac{1}{k} & 0 \\ 0 & \frac{1}{k} \end{bmatrix}\begin{bmatrix} x' \\ y' \end{bmatrix}$ នោះគេថា $M$ ជារូបភាពនៃ $M'$ តាមបំលែងចាំង $H$ ។

គេកំណត់បំលែងចាំងនៃ $H$ ដោយ $H^{-1}$ ដែលមានម៉ាទ្រីស $\begin{bmatrix} \frac{1}{k} & 0 \\ 0 & \frac{1}{k} \end{bmatrix}$ ។

ដូចនេះ $H^{-1} = \begin{bmatrix} \frac{1}{k} & 0 \\ 0 & \frac{1}{k} \end{bmatrix}$ ជាម៉ាទ្រីសច្រាសនៃ $H = \begin{bmatrix} k & 0 \\ 0 & k \end{bmatrix}$ ។

**ជាទូទៅ** គេប្លែង $M(x, y)$ ទៅ $M'(x', y')$ តាមបំលែង $A = \begin{bmatrix} a & c \\ b & d \end{bmatrix}$ នោះ

$M' = A(M)$ ឬ $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} a & c \\ b & d \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ នាំឱ្យ $\begin{matrix} x' = ax + cy \\ y' = bx + dy \end{matrix}$

ដើម្បីកំណត់បំលែងច្រាស $A^{-1}$ ដែលប្លែង $M'(x', y')$ ទៅ $M(x, y)$ វិញនោះ គេត្រូវគណនា $(x, y)$ ជាអនុគមន៍នៃ $(x', y')$ ។

$\begin{cases} ax + cy = x' \\ bx + dy = y' \end{cases}$ ឬ $\begin{cases} adx + cdy = dx' \\ -bcx - cdy = -cy' \end{cases}$ សមមូល

$(ad - bc)x = dx' - cy'$ ក្នុងករណី $ad - bc \neq 0$ នាំឱ្យគេបាន

$x = \frac{1}{ad - bc}(dx' - cy')$ , $y = \frac{1}{ad - bc}(-bx' + ay')$

បកស្រាយជាម៉ាទ្រីស គេបាន

$\begin{bmatrix} x \\ y \end{bmatrix} = \frac{1}{ad - bc}\begin{bmatrix} d & -c \\ -b & c \end{bmatrix}\begin{bmatrix} x' \\ y' \end{bmatrix}$ ឬ $M = A^{-1}(M')$

គេថា $A^{-1}$ ជាបំលែងច្រាសដែលមានម៉ាទ្រីសច្រាស $A^{-1} = \frac{1}{ad - bc}\begin{bmatrix} d & -c \\ -b & a \end{bmatrix}$ ដែល $ad - bc \neq 0$

ហេតុនេះ ម៉ាទ្រីសច្រាសនៃ $A = \begin{bmatrix} a & c \\ b & d \end{bmatrix}$ គឺ $A^{-1} = \frac{1}{ad - bc}\begin{bmatrix} d & -c \\ -b & a \end{bmatrix}$ ដែល $ad - bc \neq 0$

**លំហាត់គំរូ 1** $L$ ជាបន្ទាត់ដែលមានសមីការ $x + 3y - 3 = 0$ ។

រកបំលាស់ទីនៃ $L$ តាមម៉ាទ្រីស $\begin{bmatrix} 1 & -1 \\ 2 & 4 \end{bmatrix}$ ។

**ចម្លើយ** តាង $L'$ ជាបម្លាស់ទីនៃ $L$ : $x + 3y - 3 = 0$ តាមម៉ាទ្រីស $\begin{bmatrix} 1 & -1 \\ 2 & 4 \end{bmatrix}$ ។

ដើម្បីកំណត់ $L'$ គេត្រូវរកចំណុច $A', B'$ ដែលជារូបភាពរៀងគ្នារបស់ចំណុច $A, B$ នៃបន្ទាត់ $L$ ហើយបំលាស់ទីនៃ $L$ គឺជាបន្ទាត់ដែលកាត់តាមចំណុច $A', B'$ ។

គេយក $A(0, 1)$ និង $B(3, 0)$ ជាចំណុចនៃ $L$ នោះគេបាន

រូបភាពនៃ $A'$ កំណត់ដោយ $\begin{bmatrix} 1 & -1 \\ 2 & 4 \end{bmatrix}\begin{bmatrix} 0 \\ 1 \end{bmatrix} = \begin{bmatrix} -1 \\ 4 \end{bmatrix}$

នាំឱ្យ $A'(-1, 4)$ ។

រូបភាពនៃ $B'$ គឺ $\begin{bmatrix} 1 & -1 \\ 2 & 4 \end{bmatrix}\begin{bmatrix} 3 \\ 0 \end{bmatrix} = \begin{bmatrix} 3 \\ 6 \end{bmatrix}$

នាំឱ្យ $B'(3, 6)$ ។

ដូចនេះ បន្ទាត់ $L'$ កាត់តាមពីរចំណុច $A'$ និង $B'$ កំណត់ដោយសមីការ : $L' : x - 2y + 9 = 0$ ។




ជាទូទៅ ដើម្បីកំណត់រូបភាពនៃបន្ទាត់ $L$ គេត្រូវគណនា $x, y$ ជាអនុគមន៍នៃ $x', y'$ រួចយកទៅជំនួសក្នុងសមីការ $L : x + 3y - 3 = 0$ ។

បើ $A = \begin{bmatrix} 1 & -1 \\ 2 & 4 \end{bmatrix}$ នោះ $A^{-1} = \frac{1}{6}\begin{bmatrix} 4 & 1 \\ -2 & 1 \end{bmatrix}$

$$\begin{bmatrix} x \\ y \end{bmatrix} = A^{-1}\begin{bmatrix} x' \\ y' \end{bmatrix} = \frac{1}{6}\begin{bmatrix} 4 & 1 \\ -2 & 1 \end{bmatrix}\begin{bmatrix} x' \\ y' \end{bmatrix} = \frac{1}{6}\begin{bmatrix} 4x' + y' \\ -2x' + y' \end{bmatrix}$$

យើងបាន $x = \frac{4x' + y'}{6}$ , $y = \frac{-2x' + y'}{6}$

ជំនួសក្នុងសមីការបន្ទាត់ $L : \frac{4x' + y'}{6} + 3\left(\frac{-2x' + y'}{6}\right) - 3 = 0$ ឬ $x' - 2y' + 9 = 0$

ដូចនេះ បន្ទាត់ $L : x + 3y - 3 =$ ផ្លាស់ទីបន្ទាត់ $L : x - 2y + 9 = 0$ ។

**លំហាត់គំរូ 2** កំណត់រូបភាពនៃរង្វង់ $C : x^2 + y^2 = 4$ តាម $A = \begin{bmatrix} 3 & 0 \\ 0 & 3 \end{bmatrix}$ ។

**ចម្លើយ** $A = \begin{bmatrix} 3 & 0 \\ 0 & 3 \end{bmatrix}$ នោះ $A^{-1} = \frac{1}{9}\begin{bmatrix} 3 & 0 \\ 0 & 3 \end{bmatrix}$

$$\begin{bmatrix} x \\ y \end{bmatrix} = A^{-1}\begin{bmatrix} x \\ y \end{bmatrix} = \frac{1}{9}\begin{bmatrix} 3 & 0 \\ 0 & 3 \end{bmatrix}\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} \frac{1}{3}x' \\ \frac{1}{3}y' \end{bmatrix}$$




ជំនួស $x, y$ ក្នុងសមីការរង្វង់

$$\left[\frac{1}{3}x'\right]^2 + \left[\frac{1}{3}y'\right]^2 = 4$$

$$\left[\frac{1}{9}x'^2\right] + \left[\frac{1}{9}y'^2\right] = 4$$

$$x'^2 + y'^2 = 36$$

ហេតុនេះ រូបភាពនៃរង្វង់ $x^2 + y^2 = 4$ គឺជារង្វង់ដែលមានសមីការ $x'^2 + y'^2 = 36$ ។

**លំហាត់គំរូ 3** កំណត់រូបភាពនៃសមីការវ៉ិចទ័រ $\vec{r} = \begin{bmatrix} 1 \\ 3 \end{bmatrix} + \lambda\begin{bmatrix} -1 \\ 4 \end{bmatrix}$ ដែលប្លែងដោយម៉ាទ្រីស $\begin{bmatrix} 2 & 1 \\ -1 & 1 \end{bmatrix}$ ។

**ចម្លើយ** ដោយវ៉ិចទ័រ $\vec{r} = \begin{bmatrix} 1 \\ 3 \end{bmatrix} + \lambda\begin{bmatrix} -1 \\ 4 \end{bmatrix}$ ប្លែងទៅ $\vec{r} = \vec{a}' + \lambda\vec{b}'$ ។

ក្នុងករណីនេះគូអរដោនេនៃវ៉ិចទ័រ $\vec{a} = \begin{bmatrix} 1 \\ 3 \end{bmatrix}$ និង $\vec{b} = \begin{bmatrix} -1 \\ 4 \end{bmatrix}$

ដូចនេះ $\vec{a}' = \begin{bmatrix} 2 & 1 \\ -1 & 1 \end{bmatrix}\begin{bmatrix} 1 \\ 3 \end{bmatrix} = \begin{bmatrix} 5 \\ 2 \end{bmatrix}$ និង $\vec{b}' = \begin{bmatrix} 2 & 1 \\ -1 & 1 \end{bmatrix}\begin{bmatrix} -1 \\ 4 \end{bmatrix} = \begin{bmatrix} 2 \\ 5 \end{bmatrix}$

ដូចនេះរូបភាពនៃសមីការវ៉ិចទ័រគឺ $\vec{r} = \begin{bmatrix} 5 \\ 2 \end{bmatrix} + \lambda\begin{bmatrix} 2 \\ 5 \end{bmatrix}$ ។

**ប្រតិបត្តិ** 1. កំណត់រូបភាពនៃបន្ទាត់ដែលប្លែងដោយម៉ាទ្រីស $\begin{bmatrix} 1 & 2 \\ 3 & 4 \end{bmatrix}$

ក. $y = 2x + 1$ ខ. អ័ក្សអាប់ស៊ីស គ. $2x + y + 1 = 0$

2. កំណត់រូបភាពនៃបន្ទាត់ $y = 2x - 3$ ដែលប្លែងដោយម៉ាទ្រីស $\begin{bmatrix} 2 & 1 \\ 3 & -1 \end{bmatrix}$ ។

3. កំណត់រូបភាពនៃវ៉ិចទ័រ $\vec{r} = \begin{bmatrix} 1 \\ 3 \end{bmatrix} + \lambda\begin{bmatrix} 1 \\ 2 \end{bmatrix}$ ដែលប្លែងដោយម៉ាទ្រីស $\begin{bmatrix} 2 & -1 \\ -4 & 2 \end{bmatrix}$ ។

# 2. បំលែងឆ្លុះ

## 2.1 បំលែងឆ្លុះធៀបនឹងអ័ក្ស x'x

បើ $M'(x', y')$ ជារូបភាពនៃ $M(x, y)$ តាមបំលែងឆ្លុះធៀបនឹងអ័ក្ស $x'x$ នោះគេបាន $HM' = HM$ ហើយកូអរដោនេនៃចំណុច $x' = x$ , $y' = -y$ ។




$M'$ ជារូបភាពនៃ $M$ តាមបំលែងឆ្លុះធៀបនឹងអ័ក្ស $x'x$ គឺ $M \xrightarrow{S_{x'x}} M'$

ក្នុងករណីនេះ គេត្រូវគណនា $(x', y')$ ជាអនុគមន៍នៃ $(x, y)$

តាមបំលែងឆ្លុះធៀបនឹងអ័ក្ស $x'x$ គេបាន : $\begin{cases} x' = 1 \cdot x + 0 \cdot y \\ y' = 0 \cdot x + (-1) \cdot y \end{cases}$

ដើម្បីឱ្យងាយស្រួលសិក្សា គេអាចបកស្រាយបំលែងឆ្លុះនេះជាទម្រង់ម៉ាទ្រីសដូចខាងក្រោម ៖

$$S_{x'x} : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 1 & 0 \\ 0 & -1 \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$$ ។

ចំណុច $\begin{bmatrix} x' \\ y' \end{bmatrix}$ ជារូបភាពនៃ $\begin{bmatrix} x \\ y \end{bmatrix}$ តាមបំលែងឆ្លុះធៀបនឹងអ័ក្ស $x'x$ ។

**ជាទូទៅ** បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $x'x$ គឺ : $S_{x'x} : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 1 & 0 \\ 0 & -1 \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$ ។

## 2.2 បំលែងឆ្លុះធៀបនឹងអ័ក្ស y'y

បើ $M'(x',\ y')$ ជារូបភាពនៃ $M(x,\ y)$ តាមបំលែងឆ្លុះធៀបនឹងអ័ក្ស $y'y$ នោះគេបាន $HM' = HM$ ហើយកូអរដោនេនៃចំណុច $x' = -x$ , $y' = y$ ។




$M'$ ជារូបភាពនៃ $M$ តាមបំលែងឆ្លុះធៀបនឹងអ័ក្ស $y'y$ គឺ $M \xrightarrow{S_{y'y}} M'$

ដូចនេះគេបានបំលែងឆ្លុះធៀបនឹងអ័ក្ស $y'y$ គឺ ៖

$$\begin{cases} x' = (-1)\cdot x + 0\cdot y \\ y' = 0\cdot x + y \end{cases}$$

ដើម្បីឱ្យងាយស្រួលសិក្សា គេអាចបកស្រាយបំលែងឆ្លុះនេះជាទម្រង់ម៉ាទ្រីសដូចខាងក្រោម ៖

$$S_{y'y} : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & 1 \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix} \text{ ។}$$

ចំណុច $\begin{bmatrix} x' \\ y' \end{bmatrix}$ ជារូបភាពនៃ $\begin{bmatrix} x \\ y \end{bmatrix}$ តាមបំលែងឆ្លុះធៀបនឹងអ័ក្ស $y'y$ ។

**ជាទូទៅ** បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $y'y$ គឺ : $S_{y'y} : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & 1 \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$ ។

## 2.3 បំលែងឆ្លុះធៀបនឹងគល់ $O$




បើ $M'(x', y')$ ជារូបភាពនៃ $M(x, y)$ តាមបំលែងឆ្លុះធៀបនឹងគល់ $O$ ។ នោះគេបាន $OM' = OM$ ហើយកូអរដោនេនៃចំណុច $x' = -x$ , $y' = -y$ ។

$M'$ ជារូបភាពនៃ $M$ តាមបំលែងឆ្លុះធៀបនឹងគល់ $O$ គឺ $M \xrightarrow{S_o} M'$

ដូចនេះ គេបានបំលែងឆ្លុះធៀបនឹងគល់ $O$ គឺ ៖

$$\begin{cases} x' = (-1)\cdot x + 0\cdot y \\ y' = 0\cdot x + (-1)\cdot y \end{cases}$$

ដើម្បីឱ្យងាយស្រួលសិក្សា គេអាចបកស្រាយបំលែងឆ្លុះនេះជាទម្រង់ម៉ាទ្រីសដូចខាងក្រោម ៖

$S_0 = \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & -1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ ។ ចំណុច $\begin{bmatrix} x' \\ y' \end{bmatrix}$ ជារូបភាពនៃ $\begin{bmatrix} x \\ y \end{bmatrix}$ តាមបំលែងឆ្លុះធៀបនឹងគល់ $O$ ។

**ជាទូទៅ** បំលែងលីនេអ៊ែរឆ្លុះធៀបនឹងគល់ $O$ គឺ : $S_o : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & -1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ ។

**លំហាត់គំរូ**

1. បំលែងបន្ទាត់ $ax + by + c = 0$ តាមបំលែងឆ្លុះ $S_{y'y}$ ។
2. បំលែងប៉ារ៉ាបូល $y = (x+1)^2$ តាមបំលែងឆ្លុះ $S_{x'x}$ ។

**ចម្លើយ**

1. ដោយ $ax + by + c = 0$ នាំឱ្យ $by = -(ax + c)$ នោះ $y = -\left(\frac{a}{b}x + \frac{c}{b}\right)$

តាងកូអរដោនេ $\left(k,\ -\frac{a}{b}k - \frac{c}{b}\right)$ នៅលើបន្ទាត់ $ax + by + c = 0$ នោះគេបាន

បំលែងបន្ទាត់ $ax + by + c = 0$ តាមបំលែងឆ្លុះ $S_{y'y}$ គឺ ៖

$$S_{y'y} : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & 1 \end{bmatrix}\begin{bmatrix} k \\ -\frac{a}{b}k - \frac{c}{b} \end{bmatrix} = \begin{bmatrix} -k \\ -\frac{a}{b}k - \frac{c}{b} \end{bmatrix}$$

នាំឱ្យ $x' = -k$ , $y' = -\frac{a}{b}k - \frac{c}{b}$ នោះ $y' = \frac{a}{b}x' - \frac{c}{b}$ គេបាន $-ax + by - c = 0$ ។

2. ដោយ $y = (x+1)^2$ នោះ $y = x^2+2x+1$

តាងកូអរដោនេ $(m,\ m^2+2m+1)$ នៅលើប៉ារ៉ាបូល $y = (x+1)^2$ នោះ គេបានបំលែងប៉ារ៉ាបូល $y = (x+1)^2$ តាមបំលែងឆ្លុះ $S_{x'x}$ គឺ ៖

$$S_{x'x} : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 1 & 0 \\ 0 & -1 \end{bmatrix}\begin{bmatrix} m \\ m^2+2m+1 \end{bmatrix} = \begin{bmatrix} m \\ -m^2-2m-1 \end{bmatrix}$$ នាំឱ្យ

$x' = m$ , $y' = -m^2-2m-1$ នោះ $y' = -x'2-2x'-1 = -(x'+1)^2$ នាំឱ្យ $y = -(x+1)^2$ ។

**ប្រតិបត្តិ**

1. ចូរបំលែងបន្ទាត់ $2x+3y-6 = 0$ តាមបំលែងឆ្លុះ $S_{y'y}$ និង $S_{x'x}$ ។
2. ចូរបំលែងប៉ារ៉ាបូល $y = (x-1)^2$ តាមបំលែងឆ្លុះ $S_{x'x}$ និង $S_{y'y}$ ។
3. កំណត់រូបភាពនៃចំណុច $A(2,\ 3)$ និង $B(-2,\ -5)$ តាមបំលែងឆ្លុះ $S_{x'x}$ , $S_{y'y}$ និង $S_o$

## 3. បំលែងចាំង

បើ $M'(x',\ y')$ ជារូបភាពនៃ $M(x,\ y)$ តាមបំលែងចាំង $H$ ដែលមានផលធៀប $k$ ដែល $k \neq 0$ នោះគេបានកូអរដោនេ $x' = kx$ , $y' = ky$ អាចសរសេរជា $\begin{cases} x' = kx+0\cdot y \\ y' = 0\cdot x+ky \end{cases}$

ដើម្បីឱ្យងាយស្រួលសិក្សា គេអាចបកស្រាយបំលែងចាំង $H$ នោះជាទម្រង់ម៉ាទ្រីសដូចនេះ ៖

$$H(O,\ k) : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} k & 0 \\ 0 & k \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$$ ។

បើ $k = 1$ នោះ $H = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}$ បើ $k = -1$ នោះ $H = \begin{bmatrix} -1 & 0 \\ 0 & -1 \end{bmatrix}$

**ជាទូទៅ** បំលែងចាំង $H$ ដែលមានផលធៀប $k$ គឺ : $H(O,\ k) : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} k & 0 \\ 0 & k \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ ។

**លំហាត់គំរូ** កំណត់រូបភាពនៃចំណុច $A(2,\ 4)$ , $B\left(\frac{1}{2},\ -\frac{1}{2}\right)$ តាមបំលែងចាំង $H(O,\ 2)$ និង $H(O,\ -1)$ ។

PROEUS DARA

**ចម្លើយ** តាមបំលែងចាំង $H(O,\ k)$ គឺ : $H(O,\ k)\ :\ \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} k & 0 \\ 0 & k \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$

- ចំណុច $A(2,\ 4)$ គឺ $H(O,\ 2)\ :\ \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 2 & 0 \\ 0 & 2 \end{bmatrix}\begin{bmatrix} 2 \\ 4 \end{bmatrix} = \begin{bmatrix} 4 \\ 8 \end{bmatrix}$

  $H(O,\ -1)\ :\ \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & -1 \end{bmatrix}\begin{bmatrix} 2 \\ 4 \end{bmatrix} = \begin{bmatrix} -2 \\ -4 \end{bmatrix}$

- ចំណុច $B\left(\frac{1}{2},\ -\frac{1}{2}\right)$ គឺ : $H(0,\ 2)\ :\ \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 2 & 0 \\ 0 & 2 \end{bmatrix}\begin{bmatrix} \frac{1}{2} \\ -\frac{1}{2} \end{bmatrix} = \begin{bmatrix} 1 \\ -1 \end{bmatrix}$

  $H(O,\ -1)\ :\ \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & -1 \end{bmatrix}\begin{bmatrix} \frac{1}{2} \\ -\frac{1}{2} \end{bmatrix} = \begin{bmatrix} -\frac{1}{2} \\ \frac{1}{2} \end{bmatrix}$

**ប្រតិបត្តិ**

1. បំលែងបន្ទាត់ $ax + by + c = 0$ តាមបំលែងចាំង $H(O,\ 1)$ និង $H(O,\ -1)$ ។
2. បំលែងប៉ារ៉ាបូល $y = x^2$ តាមបំលែងចាំង $H(O,\ 1)$ និង $H(O,\ -1)$ ។

## 4. បំលែងវិល

បើ $M'(x',\ y')$ ជារូបភាពនៃ $M(x,\ y)$ តាមបំលែងវិល $\mathfrak{R}(O,\ \alpha)$ នោះគេបាន $OM' = OM$ , $(\overrightarrow{OM},\ \overrightarrow{OM'}) = \alpha$ ។




គេនឹងបកស្រាយបំលែងវិលជាសមីការ ។

ដើម្បីគណនា $x',\ y'$ ជាអនុគមន៍នៃ $x,\ y$ គេត្រូវដៅ $P$ និង $Q$ ជាចំណោលកែងរៀងគ្នានៃ $M$ មកលើអ័ក្ស $\overrightarrow{ox}$ និង $\overrightarrow{oy}$ ។

បើ $M$ ផ្លាស់ទីមក $M'$ តាមមុំ $\alpha$ នោះ $P$ និង $Q$ ក៏ផ្លាស់ទីរៀងគ្នាមក $P'$ និង $Q'$ តាមមុំ $\alpha$ ដែរ ។ ឥឡូវគេគណនាកូអរដោនេនៃចំណុច $P'$ និង $Q'$

តាមរូបបើគេយកកូអរដោនេ : $P'(x\cos\alpha,\ x\sin\alpha)$ , $Q'(-y\sin\alpha,\ y\cos\alpha)$

ចំពោះចតុកោណ $OP'M'Q'$ គេមាន $\overrightarrow{OM'} = \overrightarrow{OP'} + \overrightarrow{OQ'}$

$\overrightarrow{OM'} = x'\vec{i} + y'\vec{j}$ និង $\overrightarrow{OP'} + \overrightarrow{OQ'} = (x\cos\alpha\vec{i} + x\sin\alpha\vec{j}) + (-y\sin\alpha\vec{i} + y\cos\alpha\vec{j})$

$$x'\vec{i} + y'\vec{j} = (x\cos\alpha\vec{i} + x\sin\alpha\vec{j}) + (-y\sin\alpha\vec{i} + y\cos\alpha\vec{j})$$

$$= (x\cos\alpha - y\sin\alpha)\vec{i} + (x\sin\alpha + y\cos\alpha)\vec{j}$$

គេទាញបាន : $x' = x\cos\alpha - y\sin\alpha$ , $y' = x\sin\alpha + y\cos\alpha$

ក្នុងករណី $\alpha = 60°$ សមីការទៅជា

$$x' = \frac{1}{2}x - \frac{\sqrt{3}}{2}y \quad , \quad y' = \frac{\sqrt{3}}{2}x + \frac{1}{2}y$$

បំលែងវិលបកស្រាយដោយសមីការដឺក្រេទី 1 ជាបំលែងលីនេអ៊ែរ ។

គេអាចបកស្រាយបំលែងវិលពីសមីការទៅជាម៉ាទ្រីស

$$x' = \frac{1}{2}x - \frac{\sqrt{3}}{2}y \quad , \quad y' = \frac{\sqrt{3}}{2}x + \frac{1}{2}y$$

គេអាចសរសេរជាទម្រង់ម៉ាទ្រីស $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} \frac{1}{2} & -\frac{\sqrt{3}}{2} \\ \frac{\sqrt{3}}{2} & \frac{1}{2} \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$ ។

**ជាទូទៅ** បំលែងវិលនៃមុំ $\alpha$ កំណត់ដោយ $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$ ។

***ឧទាហរណ៍*** រូបភាពនៃចំណុច $(-1, 3)$ តាមបំលែងវិល $\Re(O, 60°)$ កំណត់ដោយ

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} \cos 60° & -\sin 60° \\ \sin 60° & \cos 60° \end{bmatrix} \begin{bmatrix} -1 \\ 3 \end{bmatrix} = \begin{bmatrix} \frac{1}{2} & \frac{\sqrt{3}}{2} \\ -\frac{\sqrt{3}}{2} & \frac{1}{2} \end{bmatrix} \begin{bmatrix} -1 \\ 3 \end{bmatrix}$$

$$= \begin{bmatrix} -\frac{1}{2} + \frac{3\sqrt{3}}{2} \\ \frac{3}{2} + \frac{\sqrt{3}}{2} \end{bmatrix} = \begin{bmatrix} \frac{3\sqrt{3} - 1}{2} \\ \frac{3 + \sqrt{3}}{2} \end{bmatrix}$$ ។

- ករណី $\alpha = 180°$ នោះ $\Re = \begin{bmatrix} -1 & 0 \\ 0 & -1 \end{bmatrix} = S_O$

  កាលណាមុំនៃបំលែងរិលស្មើនឹង 180° នោះ បំលែងរិលជាបំលែងឆ្លុះធៀបនឹងគល់ $O$ ។




- ករណី $\alpha = 360°$ នោះ $\Re = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix} = 1$

  កាលណាមុំនៃបំលែងរិលស្មើនឹង 360° នោះបំលែងរិលជាបំលែងដដែលក្នុងករណីនេះរូបភាព $M'$ ត្រួតលើធាតុ $M$ ។




- បំលែងរិលមានម៉ាទ្រីសច្រាស

  $\Re^{-1} = \begin{bmatrix} \cos\alpha & \sin\alpha \\ -\sin\alpha & \cos\alpha \end{bmatrix}$ ព្រោះដេទែមីណង់វា $\cos^2\alpha + \sin^2\alpha = 1$ ។

**លំហាត់គំរូ 1** កំណត់រូបភាពនៃចំណុច $(2, \sqrt{3})$ តាមបំលែងរិល $\Re(O, 30°)$ ។

**ចម្លើយ** ម៉ាទ្រីសនៃបំលែងរិលតាមមុំ 30°

$$\begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix} = \begin{bmatrix} \cos 30° & -\sin 30° \\ \sin 30° & \cos 30° \end{bmatrix} = \begin{bmatrix} \frac{\sqrt{3}}{2} & -\frac{1}{2} \\ \frac{1}{2} & \frac{\sqrt{3}}{2} \end{bmatrix}$$

រូបភាពនៃចំណុច $(2, \sqrt{3})$ តាម $\Re$ កំណត់ដោយ

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} \frac{\sqrt{3}}{2} & -\frac{1}{2} \\ \frac{1}{2} & \frac{\sqrt{3}}{2} \end{bmatrix} \begin{bmatrix} 2 \\ \sqrt{3} \end{bmatrix} = \begin{bmatrix} \frac{\sqrt{3}}{2} \cdot 2 - \frac{1}{2}\sqrt{3} \\ \frac{1}{2} \cdot 2 + \frac{\sqrt{3}}{2} \cdot \sqrt{3} \end{bmatrix} = \begin{bmatrix} \frac{\sqrt{3}}{2} \\ \frac{5}{2} \end{bmatrix} ។$$

**លំហាត់គំរូ 2** កំណត់រូបភាពនៃបន្ទាត់ $D : y = 2x - 1$ តាមបំលែង $\Re(O, 45°)$ ។

**ចម្លើយ** ម៉ាទ្រីសនៃបំលែងរិលតាមមុំ 45°

$$\begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix} = \begin{bmatrix} \cos 45° & -\sin 45° \\ \sin 45° & \cos 45° \end{bmatrix} = \begin{bmatrix} \frac{\sqrt{2}}{2} & -\frac{\sqrt{2}}{2} \\ \frac{\sqrt{2}}{2} & \frac{\sqrt{2}}{2} \end{bmatrix}$$

រូបភាពនៃ $D$ តាម $\mathfrak{R}$ តាងដោយ $D'$ ដើម្បីកំណត់ $D'$ គេត្រូវជ្រើសរើសយក $A$ និង $B$ នៃបន្ទាត់ $D$ រួចកំណត់រក $A'$ និង $B'$ ។ បន្ទាត់ដែលកាត់តាម $A'$ និង $B'$ គឺជារូបភាពនៃ $D$ ។

ចំណុច $A(1,\ 1)$ និង $B(2,\ 3)$ ផ្ទៀងផ្ទាត់សមីការបន្ទាត់ $y = 2x - 1$

នោះរូបភាពនៃ $A'$ និង $B'$ កំណត់ដោយ : $A' = \begin{bmatrix} \frac{\sqrt{2}}{2} & -\frac{\sqrt{2}}{2} \\ \frac{\sqrt{2}}{2} & \frac{\sqrt{2}}{2} \end{bmatrix}\begin{bmatrix} 1 \\ 1 \end{bmatrix} = \begin{bmatrix} \frac{\sqrt{2}}{2} - \frac{\sqrt{2}}{2} \\ \frac{\sqrt{2}}{2} + \frac{\sqrt{2}}{2} \end{bmatrix} = \begin{bmatrix} 0 \\ \sqrt{2} \end{bmatrix}$

$$B' = \begin{bmatrix} \frac{\sqrt{2}}{2} & -\frac{\sqrt{2}}{2} \\ \frac{\sqrt{2}}{2} & \frac{\sqrt{2}}{2} \end{bmatrix}\begin{bmatrix} 2 \\ 3 \end{bmatrix} = \begin{bmatrix} \sqrt{2} - \frac{3\sqrt{2}}{2} \\ \sqrt{2} + \frac{3\sqrt{2}}{2} \end{bmatrix} = \begin{bmatrix} -\frac{\sqrt{2}}{2} \\ \frac{5\sqrt{2}}{2} \end{bmatrix}$$

សមីការបន្ទាត់ $D'$ កំណត់ដោយសមីការ

$\dfrac{x-0}{-\frac{\sqrt{2}}{2} - 0} = \dfrac{y - \sqrt{2}}{\frac{5\sqrt{2}}{2} - \sqrt{2}}$ យើងបានរូបភាពនៃ $D$ គឺ $D' : y = -3x + \sqrt{2}$ ។

ជាទូទៅ គេគណនា $x,\ y$ ជាអនុគមន៍នៃ $x',\ y'$ រួចជំនួស $x,\ y$ ក្នុងសមីការ $y = 2x - 1$ ។ គេនឹងបានសមីការ $D'$ ដែលជារូបភាពនៃ $D$ ។

បើ $\begin{bmatrix} x' \\ y' \end{bmatrix} = \mathfrak{R}\begin{bmatrix} x \\ y \end{bmatrix}$ នោះ $\begin{bmatrix} x \\ y \end{bmatrix} = \mathfrak{R}^{-1}\begin{bmatrix} x' \\ y' \end{bmatrix}$ ដែល $R^{-1} = \begin{bmatrix} \frac{\sqrt{2}}{2} & \frac{\sqrt{2}}{2} \\ -\frac{\sqrt{2}}{2} & \frac{\sqrt{2}}{2} \end{bmatrix}$

$$\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} \frac{\sqrt{2}}{2} & \frac{\sqrt{2}}{2} \\ -\frac{\sqrt{2}}{2} & \frac{\sqrt{2}}{2} \end{bmatrix}\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} \frac{\sqrt{2}}{2}x' + \frac{\sqrt{2}}{2}y' \\ -\frac{\sqrt{2}}{2}x' + \frac{\sqrt{2}}{2}y' \end{bmatrix}$$

ជំនួស $x = \frac{\sqrt{2}}{2}(x' + y')$ និង $y = \frac{\sqrt{2}}{2}(-x' + y')$ ទៅក្នុងសមីការ $y = 2x - 1$ យើងបាន

$\frac{\sqrt{2}}{2}(-x' + y') = 2 \cdot \frac{\sqrt{2}}{2}(x' + y') - 1$ យើងបាន $y' = -3x' + \sqrt{2}$ ។

ហេតុនេះ រូបភាពនៃបន្ទាត់ $y = 2x - 1$ តាមបំលែងវិល គឺបន្ទាត់ : $y = -3x + \sqrt{2}$ ។

**ប្រតិបត្តិ** 1. កំណត់ចំណុចដែលមានរូបភាព $(-2,\ 2)$ តាមបំលែងវិលនៃមុំ $120°$ ។

2. កំណត់រូបភាពនៃ $y = x$ ដែលវិលជុំវិញគល់ $O$ តាមមុំ $130°$ ។

# 5. បំលែងលីនេអ៊ែរបណ្ដាក់

## 5.1 បណ្ដាក់នៃបំលែងលីនេអ៊ែរពីរ




***ឧទាហរណ៍*** គេប្លែងចំណុច $M(x, y)$ ទៅ $M'(x', y')$ តាមបំលែងឆ្លុះធៀបនឹងអ័ក្ស $y'y$ រួចគេបន្តប្លែងចំណុច $M'(x', y')$ ទៅ $M''(x'', y'')$ តាមបំលែងចាំង $H(O, 2)$ ។ តើចំណុច $M''$ ជារូបភាពនៃ $M$ តាមបំលែងអ្វី ? $M''$ ជារូបភាពនៃ $M$ តាមបំលែងបន្តបន្ទាប់ $M \xrightarrow{S} M' \xrightarrow{H} M''$ ក្នុងករណីនេះ គេត្រូវគណនា $(x'', y'')$ ជាអនុគមន៍នៃ $(x, y)$ តាមសមីការបណ្ដាក់ដូចខាងក្រោម ៖

តាមបំលែងឆ្លុះ $S_{y'y}$ យើងបាន $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & 1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ នាំឱ្យ $x' = -x$ , $y' = y$ ។

តាមបំលែងចាំង $H(O, 2)$ យើងបាន $\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} 2 & 0 \\ 0 & 2 \end{bmatrix}\begin{bmatrix} x' \\ y' \end{bmatrix}$ នាំឱ្យ $x'' = 2x'$ , $y'' = 2y'$ ។

ជាសរុប យើងបាន $x'' = (-2x)$ , $y'' = 2y$

បកស្រាយសមីការជាម៉ាទ្រីស យើងបាន $\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} -2 & 0 \\ 0 & 2 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ ។

ដូចនេះ $M''$ ជារូបភាពនៃ $M$ តាមបំលែងដែលមានម៉ាទ្រីស $\begin{bmatrix} -2 & 0 \\ 0 & 2 \end{bmatrix}$ ។

បំលែងដែលប្លែងចំណុច $M$ ទៅ $M''$ កកើតដោយបំលែងពីរ ហៅថា **បំលែងបណ្ដាក់** ។

ជាទូទៅ បើ $A = \begin{bmatrix} a & c \\ b & d \end{bmatrix}$ និង $B = \begin{bmatrix} a' & c' \\ b' & d' \end{bmatrix}$ ជាបំលែងលីនេអ៊ែរ ដែលប្លែងចំណុចរៀងគ្នាពី $M$ ទៅ $M'$ និងពី $M'$ ទៅ $M''$ យើងបាន

$$\begin{bmatrix} x \\ y \end{bmatrix} \xrightarrow{A} \begin{bmatrix} x' \\ y' \end{bmatrix} \xrightarrow{B} \begin{bmatrix} x'' \\ y'' \end{bmatrix} \text{ ដែល } \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} a & c \\ b & d \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} \text{ និង } \begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} a' & c' \\ b' & d' \end{bmatrix}\begin{bmatrix} x' \\ y' \end{bmatrix} \text{ ។}$$

បំលែងលីនេអ៊ែរបណ្ដាក់ដែលប្លែងពី $\begin{bmatrix} x \\ y \end{bmatrix}$ ទៅ $\begin{bmatrix} x'' \\ y'' \end{bmatrix}$ កំណត់ដោយ

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} a' & c' \\ b' & d' \end{bmatrix}\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} a' & c' \\ b' & d' \end{bmatrix}\begin{bmatrix} a & c \\ b & d \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} \text{ ។}$$

ម៉ាទ្រីសបំលែងបណ្ដាក់ដែលប្លែងពី $M$ ទៅ $M'$ ស្មើនិងផលគុណនៃម៉ាទ្រីស $\begin{bmatrix} a' & c' \\ b' & d' \end{bmatrix}\begin{bmatrix} a & c \\ b & d \end{bmatrix}$ ។

ដើម្បីកំណត់វិធានគណនាផលគុណម៉ាទ្រីស គេត្រូវគណនា $x''$, $y''$ ជាអនុគមន៍នៃ $x$, $y$ តាមសមីការបណ្តាក់ដូចខាងក្រោម :

$$x' = ax + cy \qquad x'' = a'x' + c'y'$$

$$y' = bx + dy \qquad y'' = b'x' + d'y'$$

នោះ $x'' = (aa' + bc')x + (a'c + c'd)y$

$y'' = (ab' + bd')x + (c'b + d'd)y$

បកស្រាយជាម៉ាទ្រីស $\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} aa' + bc' & a'c + c'd \\ ab' + bd' & cb' + dd' \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$

យើងបានវិធានផលគុណនៃម៉ាទ្រីសគឺ : $\begin{bmatrix} a' & c' \\ b' & d' \end{bmatrix} \begin{bmatrix} a & c \\ b & d \end{bmatrix} = \begin{bmatrix} aa' + bc' & a'c + c'd \\ ab' + bd' & cb' + dd' \end{bmatrix}$

**ជាទូទៅ** បើគេប្លែងចំណុច $M$ ទៅ $M''$ តាមម៉ាទ្រីសបន្តបន្ទាប់ $A$ និង $B$ នោះ $M'' = BA(M)$ ។

**លំហាត់គំរូ 1** កំណត់រូបភាពនៃចំណុច $(2, -1)$ តាមម៉ាទ្រីស $BA$ ដែល

$$A = \begin{bmatrix} 2 & -1 \\ 1 & 0 \end{bmatrix} , \ B = \begin{bmatrix} -\frac{1}{2} & 2 \\ 4 & -5 \end{bmatrix} \text{ ។}$$

**ចម្លើយ** តាង $M'(x', y')$ ជារូបភាពនៃ $(2, -1)$ នោះ

$$\begin{bmatrix} x' \\ y' \end{bmatrix} = BA\begin{bmatrix} 2 \\ -1 \end{bmatrix} = \begin{bmatrix} -\frac{1}{2} & 2 \\ 4 & -5 \end{bmatrix} \begin{bmatrix} 2 & -1 \\ 1 & 0 \end{bmatrix} \begin{bmatrix} 2 \\ -1 \end{bmatrix}$$

$$= \begin{bmatrix} -\frac{1}{2} \cdot 2 + 2 \cdot 1 & -\frac{1}{2}(-1) + 2 \cdot 0 \\ 4(2) + (-5) & 4(-1) + (-5) \cdot 0 \end{bmatrix} \begin{bmatrix} 2 \\ -1 \end{bmatrix} = \begin{bmatrix} 1 & \frac{1}{2} \\ 3 & -4 \end{bmatrix} \begin{bmatrix} 2 \\ -1 \end{bmatrix} = \begin{bmatrix} \frac{3}{2} \\ 10 \end{bmatrix}$$

ហេតុនេះ $M'\left(\frac{3}{2}, 10\right)$ ជារូបភាពនៃចំណុច $(2, -1)$ តាម $BA$ ។

**លំហាត់គំរូ 2** គេឱ្យបំលែងពីរ $A = \begin{bmatrix} 3 & 5 \\ -2 & 7 \end{bmatrix}$ និង $B = \begin{bmatrix} 0 & 1 \\ 1 & 1 \end{bmatrix}$ ។

កំណត់រូបភាពនៃចំណុច $M'(2, 3)$ តាម $AB$ និង $BA$ ។

**ចម្លើយ** រូបភាពនៃ $(2, 3)$ តាម $AB$ គឺ

$$\begin{bmatrix} x' \\ y' \end{bmatrix} = BA\begin{bmatrix} 2 \\ 3 \end{bmatrix} = \begin{bmatrix} 3 & 5 \\ -2 & 7 \end{bmatrix}\begin{bmatrix} 0 & 1 \\ 1 & 1 \end{bmatrix}\begin{bmatrix} 2 \\ 3 \end{bmatrix} = \begin{bmatrix} 5 & 8 \\ 7 & 5 \end{bmatrix}\begin{bmatrix} 2 \\ 3 \end{bmatrix} = \begin{bmatrix} 34 \\ 29 \end{bmatrix}$$

រូបភាពនៃ $(2, 3)$ តាម $BA$ គឺ

$$\begin{bmatrix} x' \\ y' \end{bmatrix} = BA\begin{bmatrix} 2 \\ 3 \end{bmatrix} = \begin{bmatrix} 0 & 1 \\ 1 & 1 \end{bmatrix}\begin{bmatrix} 3 & 5 \\ -2 & 7 \end{bmatrix}\begin{bmatrix} 2 \\ 3 \end{bmatrix} = \begin{bmatrix} -2 & 7 \\ 1 & 12 \end{bmatrix}\begin{bmatrix} 2 \\ 3 \end{bmatrix} = \begin{bmatrix} 17 \\ 38 \end{bmatrix}$$

យើងឃើញថារូបភាពនៃ $(2, 3)$ តាម $AB$ មិនស្មើគ្នានឹងរូបភាពតាម $BA$ នោះទេ ។

**ប្រតិបត្តិ** កំណត់រូបភាពនៃចំណុច $(x, y)$ តាមបំលែង $AA$ ដែល $A = \begin{bmatrix} 1 & 1 \\ 1 & 1 \end{bmatrix}$ ។

## 5.2 បណ្ដាក់រវាង $\mathfrak{R}$ និង H

បើ $M'(x', y')$ ជារូបភាពនៃ $M(x, y)$ តាមបំលែងរិល $\mathfrak{R}(O, \alpha)$ ហើយ $M''(x'', y'')$ ជារូបភាពនៃ $M'(x', y')$ តាមបំលែងរិល $\mathfrak{R}(O, \alpha)$ នោះ $M''$ ជារូបភាពនៃ $M$ តាមបំលែងបណ្ដាក់ដែលគេកំណត់ដូចខាងក្រោម :

$M''$ ជារូបភាពនៃ $M$ តាមបំលែងបន្តបន្ទាប់ $M \xrightarrow{H} M' \xrightarrow{\mathfrak{R}} M''$

ក្នុងករណីនេះ គេត្រូវគណនា $(x'', y'')$ ជាអនុគមន៍នៃ $(x, y)$ តាមសមីការបណ្ដាក់ដូចខាងក្រោម :

តាមបំលែងថាំង $H(O, k)$ យើងបាន $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} k & 0 \\ 0 & k \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ នាំឱ្យ $x' = kx$ , $y' = ky$

តាមបំលែងរិល $\mathfrak{R}(O, \alpha)$ យើងបាន $\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix}\begin{bmatrix} x' \\ y' \end{bmatrix}$

នាំឱ្យ $x'' = x'\cos\alpha - y'\sin\alpha$ , $y'' = x'\sin\alpha + y'\cos\alpha$

ជាសរុប យើងបាន $x'' = k(x\cos\alpha - y\sin\alpha)$ , $y'' = k(x\sin\alpha + y\cos\alpha)$

បកស្រាយសមីការជាម៉ាទ្រីស $\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} k\cos\alpha & -\sin\alpha \\ k\sin\alpha & k\cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$

**ជាទូទៅ** បើគេប្លែងចំណុច $M(x, y)$ ទៅ $M'(x', y')$ តាមបំលែងថាំង $H(O, k)$ រួចគេបន្តប្លែងចំណុច $M'(x', y')$ ទៅ $M''(x'', y'')$ តាមបំលែងរិល $\Re(O, \alpha)$ នោះគេបាន $M''$ ជារូបភាពនៃ $M$ តាមបំលែងបណ្តាក់ដែលគេកំណត់ដូចខាងក្រោម :

- $$\left.\begin{array}{l} H(O, K): \quad M \to M' \\ \Re(O, \alpha): \quad M' \to M'' \end{array}\right\} \Rightarrow M'' = \Re H(M)$$

បានន័យថា $\begin{bmatrix} x'' \\ y'' \end{bmatrix} = k\begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} k\cos\alpha & -k\sin\alpha \\ k\sin\alpha & k\cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$

ដូចគ្នាដែរបណ្តាក់រវាង $H$ និង $R$ ។

**លំហាត់គំរូ** 1. គេមានចំណុច $M(2, 1)$ ដែលចំណុច $M$ នេះប្លែងតាមបំលែងរិល $\Re(O, 30°)$ និងបន្តប្លែងតាមបំលែងថាំង $H(O, 2)$ ។ ចូរកំណត់រូបភាព $M$ តាម $\Re H$ ។

**ចម្លើយ** 1. រូបភាពនៃ $M$ តាម $\Re H$ គឺ

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = k\begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} k\cos\alpha & -k\sin\alpha \\ k\sin\alpha & k\cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$$

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = 2\begin{bmatrix} \cos 30° & -\sin 30° \\ \sin 30° & \cos 30° \end{bmatrix}\begin{bmatrix} 2 \\ 1 \end{bmatrix} = 2\begin{bmatrix} \frac{\sqrt{3}}{2} & -\frac{1}{2} \\ \frac{1}{2} & \frac{\sqrt{3}}{2} \end{bmatrix}\begin{bmatrix} 2 \\ 1 \end{bmatrix} = \begin{bmatrix} \sqrt{3} & -1 \\ 1 & \sqrt{3} \end{bmatrix}\begin{bmatrix} 2 \\ 1 \end{bmatrix}$$

$$= \begin{bmatrix} 2\sqrt{3} - 1 \\ 2 + \sqrt{3} \end{bmatrix}$$

**ប្រតិបត្តិ** 1. គេឱ្យចំណុច $P(2, 5)$ , $Q(-3, 4)$ ដែលចំណុច $P$ និង $Q$ នេះប្លែងតាមបំលែងរិល $\Re(O, 60°)$ រួចបន្តប្លែងតាមបំលែងថាំង $H(O, 2)$ ។ រករូបភាពរបស់ $P$ និង $Q$ តាម $RH$ ។

2. គេមានត្រីកោណ $ABC$ មួយ ដែលកំពូល $A(4, 3)$ , $B(2, 1)$ និង $C(6, 3)$ ដែលកំពូល $A, B$ និង $C$ ប្លែងតាមបំលែងរិល $\Re(O, 60°)$ រួចបន្តប្លែងតាមបំលែងថាំង $H(O, 3)$ ។ ចូររករូបភាពនៃកំពូល $A, B$ និង $C$ តាមបំលែង $H\Re$ ។

## 5.3 អនុវត្តន៍ក្នុងត្រីកោណមាត្រ

នៅមេរៀនត្រីកោណមាត្រ យើងបានបកស្រាយនូវរូបមន្តវិធីបូកកូស៊ីនុសនិងស៊ីនុស

$\cos(a+b) = \cos a\cos b - \sin a\sin b$

$\sin(a+b) = \sin a\cos b + \sin b\cos a$

ឥឡូវនេះ យើងនឹងបកស្រាយរូបមន្តនេះឡើងវិញដោយប្រើបំលែងបណ្ដាក់នៃបំលែងវិលពីរ ។

គេប្លែង $M$ ទៅ $M'$ តាមបំលែងវិលនៃមុំ $a$ គឺ $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} \cos a & -\sin a \\ \sin a & \cos a \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$

គេបន្តប្លែង $M'$ ទៅ $M''$ តាមបំលែងវិលនៃមុំ $b$ គឺ $\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \cos b & -\sin b \\ \sin b & \cos b \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$

យើងបាន $M''$ ជារូបភាពនៃ $M$ តាមបំលែងបណ្ដាក់នៃបំលែងវិលទាំងពីរ

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \cos b & -\sin b \\ \sin b & \cos b \end{bmatrix}\begin{bmatrix} \cos a & -\sin a \\ \sin a & \cos a \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$$

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \cos a\cos b - \sin a\sin b & -\sin a\cos b - \sin b\cos a \\ \sin b\cos a + \sin a\cos b & \cos a\cos b - \sin a\sin b \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$$

ម្យ៉ាងវិញទៀត $M''$ ក៏ជារូបភាពនៃ $M$ តាមបំលែងវិលនៃមុំ $a+b$ ដែរ គឺ ៖

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \cos(a+b) & -\sin(a+b) \\ \sin(a+b) & \cos(a+b) \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$$

ផ្ទឹមជួរទី 1 នៃម៉ាទ្រីសទាំងពីរ យើងបាន ៖

$\cos(a+b) = \cos a\cos b - \sin a\sin b$

$\sin(a+b) = \sin a\cos b + \sin b\cos a$

**លំហាត់គំរូ 1** គេប្លែងចំណុច $(2,\ 1)$ តាមបំលែងវិល $\Re(O,\ 30°)$ រួចបន្តប្លែងតាម $\Re(O,\ 45°)$ ។ កំណត់រូបភាពចុងក្រោយរបស់វា ។

**ចម្លើយ** តាង $a$ និង $b$ ជាមុំដែលងាយរករបស់កូស៊ីនុស និងស៊ីនុស នោះគេបាន

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \cos a\cos b - \sin a\sin b & -\sin a\cos b - \sin b\cos a \\ \sin b\cos a + \sin a\cos b & \cos a\cos b - \sin a\sin b \end{bmatrix}\begin{bmatrix} 2 \\ 1 \end{bmatrix}$$

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \cos 30°\cos 45° - \sin 30°\sin 45° & -\sin 30°\cos 45° - \sin 45°\cos 30° \\ \sin 45°\cos 30° + \sin 30°\cos 45° & \cos 30°\cos 45° - \sin 30°\sin 45° \end{bmatrix}\begin{bmatrix} 2 \\ 1 \end{bmatrix}$$

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \frac{\sqrt{3}}{2}\times\frac{\sqrt{2}}{2}-\frac{1}{2}\times\frac{\sqrt{2}}{2} & -\frac{1}{2}\times\frac{\sqrt{2}}{2}-\frac{\sqrt{2}}{2}\times\frac{\sqrt{3}}{2} \\ \frac{\sqrt{2}}{2}\times\frac{\sqrt{3}}{2}+\frac{1}{2}\times\frac{\sqrt{2}}{2} & \frac{\sqrt{3}}{2}\times\frac{\sqrt{2}}{2}-\frac{1}{2}\times\frac{\sqrt{2}}{2} \end{bmatrix}\begin{bmatrix} 2 \\ 1 \end{bmatrix}$$

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \frac{\sqrt{6}-\sqrt{2}}{4} & \frac{-\sqrt{6}-\sqrt{2}}{4} \\ \frac{\sqrt{6}+\sqrt{2}}{4} & \frac{\sqrt{6}-\sqrt{2}}{4} \end{bmatrix}\begin{bmatrix} 2 \\ 1 \end{bmatrix} = \begin{bmatrix} \frac{\sqrt{6}-3\sqrt{2}}{4} \\ \frac{3\sqrt{6}+\sqrt{2}}{4} \end{bmatrix}$$

**លំហាត់គំរូ 2** គេប្លែងចំណុច (3, 2) តាមបំលែងវិល $\mathfrak{R}(O, 12°)$ រួចបន្តប្លែងតាម $\mathfrak{R}(O, 18°)$ ។ កំណត់រូបភាពចុងក្រោយរបស់វា ។

**ចម្លើយ** តាង $a$ និង $b$ ជាមុំដែលលំបាករករបស់កូស៊ីនុស និងស៊ីនុស នោះគេបាន

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = \begin{bmatrix} \cos(a+b) & -\sin(a+b) \\ \sin(a+b) & \cos(a+b) \end{bmatrix}\begin{bmatrix} 3 \\ 2 \end{bmatrix}$$

$$= \begin{bmatrix} \cos 30° & -\sin 30° \\ \sin 30° & \cos 30° \end{bmatrix}\begin{bmatrix} 3 \\ 2 \end{bmatrix}$$

$$= \begin{bmatrix} \frac{\sqrt{3}}{2} & -\frac{1}{2} \\ \frac{1}{2} & \frac{\sqrt{3}}{2} \end{bmatrix}\begin{bmatrix} 3 \\ 2 \end{bmatrix} = \begin{bmatrix} \frac{3\sqrt{3}-2}{2} \\ \frac{3+2\sqrt{3}}{2} \end{bmatrix}$$

**ប្រតិបត្តិ** កំណត់រូបភាពចុងក្រោយនៃចំណុច (3, 0) ដោយដឹងថា គេប្លែងវាតាមបំលែងវិល $\mathfrak{R}(O, 60°)$ រួចបន្តប្លែងតាម $\mathfrak{R}(O, -45°)$ ។

# មេរៀនសង្ខេប

## • បំលែងលីនេអ៊ែរ

បំលែងលីនេអ៊ែរដែលប្លែងចំណុច $M(x,\ y)$ ទៅ $M(x',\ y')$ កំណត់ដោយសមីការ

$x' = ax + cy$ , $y' = bx + dy$

## • ចំណុចឥតប្រែប្រួល

បើ $Q$ ជាចំណុចឥតប្រែប្រួលទៅតាមបំលែង $A$ កាលណា $A(Q) = Q$ ។

- ចំពោះបំលែងចាំង $H(O,\ k)$ កំណត់ដោយ $x' = kx$ , $y' = ky$ ។

គល់ $O$ គឺជាចំណុចឥតប្រែប្រួល ព្រោះ $O(0,\ 0)$ ផ្តល់រូបភាព $O(0,\ 0)$ ដដែល ។

- ចំពោះបំលែងដែលមានម៉ាទ្រីសឯកតា $I$ គឺ $I = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}$ ។

- គ្រប់ចំណុចនៃប្លង់ដែលប្លែងតាម $I$ នៅតែជាចំណុចខ្លួនឯងដដែល ។

ព្រោះ $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} x \\ y \end{bmatrix}$ ។

## • បំលែងលីនេអ៊ែរច្រាស

គេប្លែង $M(x,\ y)$ ទៅ $M'(x',\ y')$ តាមបំលែង $A = \begin{bmatrix} a & c \\ b & d \end{bmatrix}$ នោះ

$M' = A(M)$ , $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} a & c \\ b & d \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ , $\begin{matrix} x' = ax + cy \\ y' = bx + dy \end{matrix}$ ។

ម៉ាទ្រីសច្រាសនៃ $A = \begin{bmatrix} a & c \\ b & d \end{bmatrix}$ គឺ $A^{-1} = \dfrac{1}{ad - bc}\begin{bmatrix} d & -c \\ -b & a \end{bmatrix}$ ។

- **បំលែងលីនេអ៊ែរ**

បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $x'x$ គឺ ៖ $S_{x'x}\ :\ \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 1 & 0 \\ 0 & -1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ ។

បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $y'y$ គឺ ៖ $S_{y'y}\ :\ \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & 1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ ។

បំលែងលីនេអ៊ែរឆ្លុះធៀបនឹងគល់ $O$ គឺ ៖ $S_O\ :\ \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & -1 \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$

បំលែងថាំង $H$ ដែលមានផលធៀប $k$ គឺ ៖ $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} k & 0 \\ 0 & k \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ ។

បំលែងវិលនៃមុំ $\alpha$ កំណត់ដោយ

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$$ ។




- ករណី $\alpha = 180°$ នោះ $\Re = \begin{bmatrix} -1 & 0 \\ 0 & -1 \end{bmatrix} = S_o$

កាលណាមុំនៃបំលែងវិលស្មើនឹង $180°$ នោះ បំលែងវិលជាបំលែងឆ្លុះធៀបនឹងគល់ $O$ ។




- ករណី $\alpha = 360°$ នោះ $\Re = \begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix} = I$

កាលណាមុំនៃបំលែងវិលស្មើនឹង $360°$ នោះ បំលែងវិលជាបំលែងដដែល ក្នុងករណីនេះ រូបភាព $M'$ ត្រួតលើធាតុ $M$ ។

- បំលែងវិលមានម៉ាទ្រីសច្រាស

$$\Re^{-1} = \begin{bmatrix} \cos\alpha & \sin\alpha \\ -\sin\alpha & \cos\alpha \end{bmatrix}$$

ព្រោះដេទែមីណង់វា $\cos^2\alpha + \sin^2\alpha = 1$ ។

- **បំលែងលីនេអ៊ែរបណ្ដាក់**

បើគេប្លែងចំណុច $M$ ទៅ $M''$ តាមម៉ាទ្រីសបន្តបន្ទាប់ $A$ និង $B$ នោះ $M'' = BA(M)$ ។

- **បណ្ដាក់រវាង R និង H**

$$\left.\begin{array}{l} -\ \Re(O,\ \alpha)\ :\ M \to M' \\ \ \ H(O,\ K)\ :\ M' \to M'' \end{array}\right\} \Rightarrow M'' = H\Re(M)$$

| | |
|---|---|
| **បានន័យថា** | $\begin{bmatrix} x'' \\ y'' \end{bmatrix} = k\begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} k\cos\alpha & -k\sin\alpha \\ k\sin\alpha & k\cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ |

$$\left.\begin{array}{l} \bullet\ H(O,\ K) : M \to M' \\ \ \ \Re(O,\ \alpha) : M' \to M'' \end{array}\right\} \text{នាំឱ្យ}\quad M'' = \Re H(M)$$

| | |
|---|---|
| **បានន័យថា** | $\begin{bmatrix} x'' \\ y'' \end{bmatrix} = k\begin{bmatrix} \cos\alpha & -\sin\alpha \\ \sin\alpha & \cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} k\cos\alpha & -k\sin\alpha \\ k\sin\alpha & k\cos\alpha \end{bmatrix}\begin{bmatrix} x \\ y \end{bmatrix}$ |

## លំហាត់

1. តើបំលែងនីមួយៗដែលប្លែងចំណុច $P(x, y)$ ទៅចំណុច $P'(x', y')$ នៅលើប្លង់មួយដែលបញ្ជាក់បំលែងលីនេអ៊ែរ ឬមិនបំលែងលីនេអ៊ែរខាងក្រោម ៖

   ក. ចំណុច $P'$ គឺជាចំណុចឆ្លុះទៅនឹងចំណុច $P$ ធៀបទៅនឹងបន្ទាត់ $x = 1$ ។

   ខ. ចំណុច $P'$ ជាចំណុចកែងទៅនឹងបន្ទាត់គូសពីចំណុច $P$ ទៅអ័ក្សអាប់ស៊ីស ។

   គ. ចំណុច $P'$ ជាចំណុចដែលបានដោយការបំលែងចំណុច $P$ តាមវ៉ិចទ័រ $(1, -2)$ ។

   ឃ. ចំណុច $P'$ ជាចំណុចដែលបន្ទាត់កាត់តាមចំណុច $P$ ដែលមានមេគុណប្រាប់ទិស 2 ហើយប្រសព្វទៅនឹងបន្ទាត់ $y = x$ ។

2. យក $f$ ជាបំលែងលីនេអ៊ែរ ដែលប្លែងពីរចំណុច $(1, 0)$ និង $(0, 1)$ ទៅចំណុច $(-1, 2)$ និង $(3, 1)$ ។

   ក. រកម៉ាទ្រីសនៃ $f$ ។

   ខ. រកភាពនៃចំណុច $(-3, 2)$ តាម $f$ ។

   គ. រករូបភាពនៃចំណុច $(5, -3)$ តាមបំលែងច្រាសនៃ $f$ ។

3. គេឱ្យបំលែងលីនេអ៊ែរ $f$ ។ រក $f(3\vec{u}-2\vec{v})$ ចំពោះ $f(\vec{u}) = \begin{bmatrix}1\\2\end{bmatrix}$ និង $f(\vec{v}) = \begin{bmatrix}-2\\1\end{bmatrix}$ ។

4. តើរូបអ្វី ដែលប្លង់មួយប្លែងតាមបំលែងលីនេអ៊ែរ ដែលបង្ហាញដោយម៉ាទ្រីសខាងក្រោម :

   ក. $\begin{bmatrix}2 & -3\\1 & 1\end{bmatrix}$ ខ. $\begin{bmatrix}2 & 1\\6 & 3\end{bmatrix}$ គ. $\begin{bmatrix}0 & 0\\0 & 0\end{bmatrix}$

5. រករូបធរណីមាត្រដែលបន្ទាត់ $2x-y+3 = 0$ ប្លែងតាមបំលែងលីនេអ៊ែរ $(x, y) \to (3x-y, -2x+y)$ ។

6. រកម៉ាទ្រីសនៃបំលែងលីនេអ៊ែរ ដែលប្លែងដោយពីរចំណុច $(2, 1)$ និង $(-1, 3)$ ទៅចំណុច $(8, -5)$ និង $(-11, 6)$ រៀងគ្នា។

7. រករូបភាពនៃចំណុច $(-6, 7)$ តាមបំលែងបណ្តាក់ $g \circ f^{-1}$ ដែលឱ្យដោយម៉ាទ្រីសនៃបំលែងលីនេអ៊ែរ $f$ និង $g$ គឺ $\begin{bmatrix}1 & 2\\-1 & -3\end{bmatrix}$ និង $\begin{bmatrix}-2 & 3\\1 & -2\end{bmatrix}$ រៀងគ្នា។

# លំហាត់ជំពូក

1. រកតម្លៃនៃ $x$ និង $y$ ដែល $x\begin{bmatrix}1&0\\0&1\end{bmatrix}+y\begin{bmatrix}2&1\\0&1\end{bmatrix}=\begin{bmatrix}2&1\\0&1\end{bmatrix}^3$ ពិត ។

2. រកតម្លៃ $x$ និង $y$ ដែលម៉ាទ្រីស $\begin{bmatrix}x&5\\-7&y\end{bmatrix}$ ជាម៉ាទ្រីសច្រាសនៃខ្លួនវា ។

3. កំណត់តម្លៃនៃចំនួនថេរ $k$ ដែលប្រព័ន្ធសមីការ $\begin{cases}2x+3y=kx\\4x+3y=ky\end{cases}$ មានចម្លើយផ្សេងទៀត $x=y=0$ ។

4. បង្ហាញថា $ps-qr=(ad-bc)(a'd'-b'c')$ បើ $\begin{bmatrix}a&b\\c&d\end{bmatrix}\begin{bmatrix}a'&b'\\c'&d'\end{bmatrix}=\begin{bmatrix}p&q\\r&s\end{bmatrix}$ ។

5. រកម៉ាទ្រីសនៃបំលែងថាំងដែលប៉ារ៉ាបូល $y=ax^2$ ប្លែងទៅប៉ារ៉ាបូល $y=x^2$ ។

6. រកម៉ាទ្រីសនៃបំលែងលីនេអ៊ែរដែលប្លែងទៅគ្រប់ចំណុចទាំងអស់នៅលើបន្ទាត់ $3x+2y-1=0$ ទៅចំណុច $(-1,\ 1)$ ។

7. រកម៉ាទ្រីសនៃបំលែងលីនេអ៊ែរដែលប្លែងទៅគ្រប់ចំណុចទាំងអស់លើប្លង់ទៅបន្ទាត់ $y=2x$ ។

8. យក $L$ ជាបន្ទាត់ដែលកាត់តាមចំណុចគល់តម្រុយ ហើយបង្កើតបានមុំ $\theta$ ជាមួយអ័ក្សអាប់ស៊ីស ។

   ក. យក $P'$ ជាចំណុចឆ្លុះគ្នាជាមួយចំណុច $P$ ធៀបទៅនឹងអ័ក្សអាប់ស៊ីស ហើយបំលែងវិល ជុំវិញគល់តម្រុយតាមមុំ $2\theta$ ។ បង្ហាញថា $P'$ ស៊ីមេទ្រីទៅនឹង $P$ ធៀបទៅនឹងបន្ទាត់ $L$ ។

   ខ. រកម៉ាទ្រីសនៃបំលែងលីនេអ៊ែរដែលបង្ហាញពីការឆ្លុះគ្នាធៀបទៅនឹងបន្ទាត់ $L$ ។

9. គេតាងប៉ារ៉ាម៉ែត្រនៃបន្ទាត់ $L$ គឺ $\begin{bmatrix}x\\y\end{bmatrix}=\begin{bmatrix}4\\3\end{bmatrix}+t\begin{bmatrix}2\\1\end{bmatrix}$ ។ តើរូបនៃ $L$ ប្លែងតាមបំលែងលីនេអ៊ែរដែល បញ្ជាក់ដោយម៉ាទ្រីស $\begin{bmatrix}4&-3\\-2&2\end{bmatrix}$ គឺជារូបអ្វី ?

10. យក $\begin{bmatrix}-2&a\\a&0\end{bmatrix}$ ជាម៉ាទ្រីសនៃបំលែងលីនេអ៊ែរ $f$ ដែល $a\neq 0$ ។

   ក. តើរូបអ្វីដែលអ័ក្សអាប់ស៊ីស និងអ័ក្សអរដោនេប្លែងតាម $f$ ?

   ខ. បង្ហាញថាមានបន្ទាត់ពីរកាត់តាមគល់តម្រុយដែលមិនប្លែងតាម $f$ ហើយវាប្រសព្វគ្នាបាន មុំកែង ។

11. រកតម្លៃនៃ $a$ និង $b$ បើបន្ទាត់ $3x-4y+1=0$ ប្លែងទៅបន្ទាត់ $3x+2y-1=0$ តាមបំលែងលីនេអ៊ែរដែលបញ្ជាក់ដោយម៉ាទ្រីស $\begin{bmatrix}1 & a\\ b & 5\end{bmatrix}$ ។

12. បន្ទាត់ពីរ $x+y=1$ និង $2x-y=1$ ប្លែងទៅនីមួយៗផ្សេងទៀតតាមបំលែងលីនេអ៊ែរ $f$ ។ រកម៉ាទ្រីស $f$ ។

13. បើចំណុច $P_1$ និង $P_2$ ប្លែងទៅចំណុច $P'_1$ និង $P'_2$ តាមបំលែងលីនេអ៊ែរ $f:(x,\ y)\rightarrow ax+by,(\ cx+dy)$ ហើយបើ $P_1P_2 = P'_1P'_2$ ពិតនោះ $a^2+c^2=b^2+d^2=1$ និង $ab+cd=0$ ។

14. យក $f$ ជាបំលែងលីនេអ៊ែរដែលបញ្ជាក់ដោយម៉ាទ្រីស $\begin{bmatrix}1 & 2\\ -2 & -5\end{bmatrix}$ ។ រកសមីការនៃបន្ទាត់ $L_1$ និង $L_2$ បើ $L_1$ ប្លែងទៅ $L_2$ តាម $f$ ហើយ $L_1$ និង $L_2$ ប្រសព្វគ្នាត្រង់ចំណុច $P(0,\ 1)$ ។

PROEUS DARA


# ជំពូក 5 លីមីត និងដេរីវេ

## ❶ អនុវត្តន៍ដេរីវេចំពោះសមីការនិងវិសមីការ



នៅក្នុងជំពូកនេះ គេចាប់ផ្ដើមសិក្សាពីបញ្ញត្តិមូលដ្ឋាននៃលីមីតនិងប្រមាណវិធីលើលីមីតដែលជាមធ្យោបាយដ៏សំខាន់សម្រាប់ឈានទៅសិក្សាបញ្ញត្តិនៃដេរីវេនិងប្រមាណវិធីលើដេរីវេនៃអនុគមន៍ ។ បន្ទាប់ពីទទួលបានបញ្ញត្តិ លីមីត ដេរីវេ និងបំណិនក្នុងការគណនាលីមីត ដេរីវេ គេនឹងអាចប្រើចំណេះដឹង និងបំណិនទាំងនោះក្នុងការដោះស្រាយចំណោទបន្ទាត់ប៉ះនឹងក្រាបតាងអនុគមន៍ត្រង់ចំណុចមួយ ការសិក្សាអថេរភាពសង់ក្រាបតាងអនុគមន៍សនិទានងាយៗ មួយចំនួន ការគណនាតម្លៃអតិបរមា តម្លៃអប្បបរមា ការគណនាល្បឿននៃចលនា ហើយលើសពីនេះទៅទៀត គេឈានទៅប្រើក្រាប តាងអនុគមន៍សម្រាប់ដោះស្រាយសមីការនិងវិសមីការមួយចំនួនទៀត ។

ការអនុវត្តទាំងអស់នេះ អាចឆ្លុះបញ្ចាំងឱ្យឃើញពីអត្ថន័យពេញលេញនិងសារប្រយោជន៍នៃគណិតវិទ្យាចំពោះវិទ្យាសាស្ត្រនិងការដោះស្រាយចំណោទបញ្ហាខ្លះក្នុងជីវភាពប្រចាំថ្ងៃ ។

មេរៀនទី 1

# អនុវត្តន៍ដេរីវេចំពោះសមីការនិងវិសមីការ

## 1. អនុវត្តន៍ដេរីវេចំពោះសមីការ

ដោយប្រើក្រាបនៃអនុគមន៍ $y = f(x)$ គេអាចបញ្ជាក់បានដោយងាយពីអត្ថិភាពឬស ទីតាំងឬសធៀបនឹងចំនួននិងចំនួនឬសនៃសមីការ $f(x) = \lambda$ ទៅតាមតម្លៃប៉ារ៉ាម៉ែត្រ $\lambda$ ។

**វត្ថុបំណង**

- សិក្សាទៅតាមតម្លៃប៉ារ៉ាម៉ែត្រពីអត្ថិភាពឬស ទីតាំងឬសធៀបនឹងចំនួននិងចំនួនឬសនៃសមីការដឺក្រេទីបីនិងសមីការដឺក្រេទីបួន ដោយប្រើក្រាប ។
- ដោះស្រាយវិសមីការដឺក្រេទីបីនិងវិសមីការដឺក្រេទីបួន ដោយប្រើដេរីវេ និងក្រាប ។
- បង្ហាញវិសមីការដឺក្រេទីបីនិងទីបួន ដោយប្រើដេរីវេ និងក្រាប ។

### 1.1 អនុវត្តន៍ដេរីវេចំពោះសមីការដឺក្រេទីបី

***ឧទាហរណ៍*** អនុគមន៍

$y = f(x) = x^3 + 3x^2 - 2$ មានក្រាប $C$ ។

ក. សង់ក្រាប $C$ នៃអនុគមន៍ $f$ ។

ខ. សិក្សាតាមក្រាភិចទៅតាមតម្លៃប៉ារ៉ាម៉ែត្រ $\lambda$ អត្ថិភាពនិងចំនួនឬសនៃសមីការ $x^3 + 3x^2 - 2 = \lambda$ ។

ក. សង់ក្រាបនៃ $f$ :

$f'(x) = 3x^2 + 6x = 3x(x+2)$

$f'(x) = 0$ , $x = 0$ , $x = -2$

ចំពោះ $x = 0$ គេបាន $f(0) = -2$

ចំពោះ $x = -2$ គេបាន $f(-2) = 2$

| $x$ | $-\infty$ | | $-2$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | + | 0 | − | 0 | + | |
| $f(x)$ | $-\infty$ | ↗ | 2 | ↘ | $-2$ | ↗ | $+\infty$ |

$y = 0 \ , x^3 + 3x^2 - 2 = 0$

$x^3 + x^2 + 2x^2 - 2 = 0$

$x^2(x+1) + 2(x^2-1) = 0$

$(x+1)(x^2+2x-2) = 0$

$x = -1 \ , \ x = -1-\sqrt{3} = 2.7 \ , \ x = -1+\sqrt{3} = 0.7$




ខ. សិក្សាទៅតាមតម្លៃ $\lambda$ អត្ថិភាពនិងចំនួនឫសនៃសមីការ :

គេបាន $x^3+3x^2-2 = \lambda$ ជាសមីការអាប់ស៊ីសនៃចំណុចប្រសព្វរវាងក្រាប $C$ និងបន្ទាត់ $D : y = \lambda$ ។

សង់បន្ទាត់ $D$ នៅក្នុងតម្រុយតែមួយ ហើយនៅត្រង់ផ្នែកណាមួយដែលជួបក្រាប $C$ បានច្រើនចំណុចបំផុត ។

ចំនួនឫសនៃសមីការ ស្មើនឹងចំនួនចំណុចប្រសព្វរវាង $C$ និង $D$ ។

- បើ $\lambda > 2$ នោះសមីការមានឫស 1
- បើ $\lambda = 2$ នោះសមីការមានឫសឌុបមួយនិងឫសមួយផ្សេងទៀត
- បើ $-2 < \lambda < 2$ នោះសមីការមានឫស 3
- បើ $\lambda = -2$ នោះសមីការមានឫសឌុបមួយនិងឫសមួយផ្សេងទៀត
- បើ $\lambda < -2$ នោះសមីការមានឫស 1 ។

**លំហាត់គំរូ** សិក្សាតាមក្រាភិចទៅតាមតម្លៃ $m$ អត្ថិភាពនិងទីតាំងឫសនៃសមីការ $x^3-3x-m = 0$ ធៀបនឹងចំនួន 0 និង 1 ។

**ចម្លើយ** ***ជំហានទី 1*** : សង់ក្រាបនៃអនុគមន៍ $y = x^3-3x$

$y' = 3x^2-3$

$y' = 0 \ , \ x = \pm 1$

ចំពោះ $x = -1$ គេបាន $y = 2$

$x = 1$ គេបាន $y = -2$

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $y$ | $-\infty$ | $\nearrow$ | $2$ | $\searrow$ | $-2$ | $\nearrow$ | $+\infty$ |




**ជំហានទី 2** : បំប្លែងសមីការឱ្យមានរាង $f(x) = m$

**ជំហានទី 3** : សង់បន្ទាត់ដេកមានសមីការ $y = m$ នៅក្នុងតម្រុយតែមួយហើយ នៅត្រង់ផ្នែកណាដែលបន្ទាត់ជួបក្រាបបានច្រើនចំណុចបំផុត ។

**ជំហានទី 4** : ប្រើក្រាបដើម្បីសិក្សាទៅតាមតម្លៃ $m$ ពីអត្ថិភាពនិងទីតាំងឬសធៀប នឹងចំនួន 0 និង 1 ។

- បើ $m > 2$ នោះសមីការមានឬស $x_3$ ដែល $0 < 1 < x_3$
- បើ $m = 2$ នោះសមីការមានឬសដែល $x_1 = x_2 = -1 < 0 < 1 < x_3$
- បើ $0 < m < 2$ នោះសមីការមានឬសដែល $x_1 < x_2 < 0 < 1 < x_3$
- បើ $m = 0$ នោះសមីការមានឬសបី $x_1 < x_2 = 0 < 1 < x_3$
- បើ $-2 < m < 0$ នោះសមីការមានឬសដែល $x_1 < 0 < x_2 < 1 < x_3$
- បើ $m = -2$ នោះសមីការមានឬសដែល $x_1 < 0 < 1 = x_2 = x_3$
- បើ $m < -2$ នោះសមីការមានឬសដែល $x_1 < 0 < 1$ ។

**ជាទូទៅ** សមីការ $ax^3 + bx^2 + cx + d = \lambda$ មានឬសជាអាប់ស៊ីសនៃចំណុចប្រសព្វ រវាងក្រាបនៃ $y = ax^3 + bx^2 + cx + d$ និងបន្ទាត់មានសមីការ $y = \lambda$ ។

**ប្រតិបត្តិ** អនុគមន៍ $y = x^3 - 3x + 2$ មានក្រាប $C$ ។

រកតម្លៃ $a$ ដើម្បីឱ្យសមីការ $x^3 - 3x + 2 = a$ :

ក. មានឫសបីផ្សេងគ្នា ។

ខ. មានឫសវិជ្ជមានពីរផ្សេងគ្នានិងឫសអវិជ្ជមានមួយទៀត ។




## 1.2 អនុវត្តន៍ដេរីវេចំពោះសមីការបីការេ

***ឧទាហរណ៍*** អនុគមន៍ $y = x^4 - 2x^2$ មានក្រាប $C$ ។

ក. សង់ក្រាប $C$ នៃអនុគមន៍ ។

ខ. ដោយប្រើក្រាប $(C)$ សិក្សាទៅតាមតម្លៃ $m$ អត្ថិភាពនិងចំនួនឫសនៃសមីការ $x^4 - 2x^2 - m = 0$ ។

ក. សង់ក្រាប $C$ :

$y' = 4x^3 - 4x = 4x(x^2 - 1)$

$y' = 0$ , $x = 0$ , $x = -1$ , $x = 1$

ចំពោះ $x = 0$ , $y = 0$ និងចំពោះ $x = \pm 1$ , $y = -1$ ។

សញ្ញានៃ $y'$ :

| $x$ | $-\infty$ | | $-1$ | | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $4x$ | | $-$ | | $-$ | $0$ | $+$ | | $+$ | |
| $x^2-1$ | | $+$ | $0$ | $-$ | | $-$ | $0$ | $+$ | |
| $y'$ | | $-$ | $0$ | $+$ | $0$ | $-$ | $0$ | $+$ | |

តារាងអថេរភាព

| $x$ | $-\infty$ | | $-1$ | | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | $0$ | $-$ | $0$ | $+$ | |
| $y$ | $+\infty$ | ↘ | $-1$ | ↗ | $0$ | ↘ | $-1$ | ↗ | $+\infty$ |

$x = 0$ នាំឱ្យ $y = 0$ , $y = 0$ , $x^2(x^2 - 2) = 0$ , $x = 0$ , $x = \pm\sqrt{2}$




បើ $m>0$ នោះសមីការមានឫស 2

បើ $m=0$ នោះសមីការមានឫស 3 គឺ 0 , $\pm\sqrt{2}$

បើ $-1<m<0$ នោះសមីការមានឫស 4

បើ $m=-1$ នោះសមីការមានឫសឌុប 2

បើ $m<-1$ នោះសមីការគ្មានឫស ។

**លំហាត់គំរូ** គេឱ្យអនុគមន៍ $f(x)=x^4-2x^2+2$ និងក្រាប $C$ :

សិក្សាទៅតាមតម្លៃប៉ារ៉ាម៉ែត្រ $\lambda$ អត្ថិភាព និងទីតាំងឫសនៃសមីការ $x^4-2x^2=\lambda-2$ ធៀបនឹងចំនួន $-1$ និង $1$ តាមក្រាប ។




**ចម្លើយ** ***ជំហានទី 1*** : បម្លែងសមីការជារាង

$$x^4-2x^2+2=\lambda$$

***ជំហានទី 2*** : សង់បន្ទាត់ដេកមានសមីការ $y=\lambda$ ក្នុងតម្រុយតែមួយ ហើយនៅត្រង់ផ្នែកណាដែលអាចជួបក្រាបបានច្រើនចំណុចជាងគេ ។

***ជំហានទី 3*** : សិក្សាលើក្រាបទៅតាមតម្លៃ $\lambda$ :

- បើ $\lambda>2$ នោះសមីការមានឫសដែល $x_1<-1<1<x_2$
- បើ $\lambda=2$ នោះសមីការមានឫស ដែល $x_1<-1<x_2=x_3=0<1<x_4$
- បើ $1<\lambda<2$ នោះសមីការមានឫស ដែល $x_1<-1<x_2<x_3<1<x_4$
- បើ $\lambda=1$ នោះសមីការមានឫស ដែល $x_1=x_2=-1<x_3=x_4=1$
- បើ $\lambda<1$ នោះសមីការគ្មានឫសទេ ។

**ជាទូទៅ** សមីការ $ax^4+bx^2+c=\lambda$ មានឫសជាអាប់ស៊ីសនៃចំណុចប្រសព្វរវាងក្រាបនៃ $y=ax^4+bx^2+c$ និងបន្ទាត់មានសមីការ $y=\lambda$ ។

 PROEUS DARA

**ប្រតិបត្តិ** គេឱ្យក្រាបនៃអនុគមន៍ $y = x^4 - 4x^2 + 3$ ដូចខាងក្រោម ៖




រកតម្លៃ $m$ ដើម្បីឱ្យសមីការ $x^4 - 4x^2 = m - 3$ ៖

ក. មានឫសបួនផ្សេងគ្នា ។

ខ. មានឫសពីរផ្សេងគ្នានៅក្រៅចន្លោះ $[-2,\ 2]$ ។

# 2. អនុវត្តន៍ដេរីវេចំពោះវិសមីការ

## 2.1 អនុវត្តន៍ដេរីវេចំពោះវិសមីការដឺក្រេទីបី

***ឧទាហរណ៍*** បង្ហាញថាវិសមីការ $x^3 + x + 2 > 0$ ផ្ទៀងផ្ទាត់ចំពោះ $x > -1$ ។

***របៀបទី 1*** ៖ ប្រើប្រាស់អនុគមន៍ $y = x^3 + x + 2$

$$y' = 3x^2 + 1 > 0 \quad , \quad y'' = 6x \quad , \quad y'' = 0 \ , \ x = 0$$

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $y'$ | | $+$ | |
| $y$ | $-\infty$ | $\nearrow$ | $+\infty$ |




$x = 0 \ , \ y = 2$

$y = 0 \ , \ x^3 + x + 2 = 0$

ឬ $(x+1)(x^2 - x + 2) = 0 \ , \ x = -1$

តាមក្រាបគ្រប់ចំណុច $(x,\ y)$ ដែលមាន $y > 0$ ត្រូវស្ថិតនៅផ្នែកខាងលើអ័ក្សអាប់ស៊ីស ហើយត្រូវគ្នានឹង $x > -1$ ។

គេបាន $y = x^3 + x + 2 > 0$ ចំពោះ $x > -1$ ។

ដូចនេះ វិសមីការ $x^3 + x + 2 > 0$ ផ្ទៀងផ្ទាត់ចំពោះ $x > -1$ ។

***របៀបទី 2*** ៖ ប្រើទិសដៅអថេរភាពនៃអនុគមន៍ $y = x^3 + x + 2$ កើនលើ $\mathbb{R}$ ។

គេមាន ៖ $y(-1) = (-1)^3 + (-1) + 2 = 0$

$x > -1 \ , \ y(x) > y(-1)$ ( ព្រោះអនុគមន៍កើន )

$y(x) > 0$

ដូចនេះ វិសមីការ $x^3+x+2>0$ ផ្ទៀងផ្ទាត់ចំពោះ $x>-1$ ។

**លំហាត់គំរូ** អនុគមន៍ $y = f(x) = x^3-3x+2$ មានក្រាប $C$ ។

ក. ដោះស្រាយវិសមីការ $x^3-3x+2<0$ តាមក្រាប ។

ខ. បង្ហាញថា $0\le x^3-3x+2\le 4$ ចំពោះ $x\in[-2, 2]$ ។




**ចម្លើយ** ក. តាមក្រាប គ្រប់ចំណុច $(x, y)$ នៃក្រាបដែលមាន $y<0$ ត្រូវស្ថិតនៅផ្នែកខាងក្រោមអ័ក្សអាប់ស៊ីស ហើយត្រូវគ្នានឹង $x<-2$ ។ ដូចនេះ វិសមីការមានសំណុំឬស $S = (-\infty, -2)$ ។

ខ. ***របៀបទី 1*** : តាមក្រាបចំណុច $(x, y)$ នៃក្រាបដែលមាន $x\in[-2, 2]$ ត្រូវស្ថិតលើក្រាបដែលនៅខាងលើអ័ក្សអាប់ស៊ីស ជួបអ័ក្សអាប់ស៊ីសត្រង់ $x = -2$ $x = 1$ ហើយជួបបន្ទាត់ $y = 4$ ត្រង់ $x = -1$ និង $x = 2$ ។

ដូចនេះ $0\le y = x^3-3x+2\le 4$

ចំពោះ $x\in[-2, 2]$ ។

***របៀបទី 2*** : ដោយមិនប្រើក្រាប ( ករណីគ្មានក្រាប ) :

$y' = 3x^2-3$

$y' = 0$ , $x = \pm 1$

$x = -1$ , $y = 4$

$x = 1$ , $y = 0$

| $x$ | $-\infty$ | | $-2$ | | $-1$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|---|---|
| $y'$ | | + | | + | 0 | − | 0 | + | | + | |
| $y$ | $-\infty$ | ↗ | 0 | ↗ | 4 | ↘ | 0 | ↗ | 4 | ↗ | $+\infty$ |

តាមតារាងអថេរភាពនៃអនុគមន៍ខាងលើ គេបាន : $0\le x^3-3x+2\le 4$ ចំពោះ $x\in[-2,\ 2]$ ។

**ជាទូទៅ** - វិសមីការ $ax^3+bx^2+cx+d>0$ មានសំណុំឫសជាសំណុំតម្លៃ អាប់ស៊ីស $x$ នៃចំណុចនៅលើក្រាបតាងអនុគមន៍ $y=ax^3+bx^2+cx+d$ ដែលស្ថិតនៅផ្នែកខាងលើអ័ក្សអាប់ស៊ីស ។

- វិសមីការ $ax^3+bx^2+cx+d<0$ មានសំណុំឫសជាសំណុំតម្លៃ អាប់ស៊ីស $x$ នៃចំណុចនៅលើក្រាបតាងអនុគមន៍ $y=ax^3+bx^2+cx+d$ ដែលស្ថិតនៅផ្នែកខាងក្រោមអ័ក្សអាប់ស៊ីស ។

**ប្រតិបត្តិ** អនុគមន៍ $y=-x^3+3x-2$ មានក្រាប $C$ ។

ក. រកសំណុំឫសនៃវិសមីការ $-x^3+3x-2\le 0$ តាមក្រាប ។

ខ. បង្ហាញថា $-4\le -x^3+3x-2\le 0$ ចំពោះ $-2\le x\le 2$ ។



## 2.2 អនុវត្តន៍ដេរីវេចំពោះវិសមីការដែលអង្គទី 1 ជាកន្សោមប៊ីការេ




**ឧទាហរណ៍** គេឱ្យក្រាប $C$ នៃ $y = -x^4 - 2x^2 + 3$ ។

រកសំណុំឫសនៃវិសមីការ $-x^4 - 2x^2 + 3 \geq 0$ តាមក្រាភិច ។

តាមក្រាប ចំណុច $(x, y)$ នៃក្រាបដែលមាន $y \geq 0$ ត្រូវស្ថិតនៅផ្នែកខាងលើ ឬជួបនឹងអ័ក្សអាប់ស៊ីស ហើយត្រូវគ្នានឹង $-1 \leq x \leq 1$ ។

ដូចនេះ វិសមីការមានសំណុំឫស $S = [-1, 1]$ ។




**លំហាត់គំរូ** អនុគមន៍ $y = -\frac{1}{2}x^4 + 3x^2 - \frac{5}{2}$ មានក្រាប $C$ ។

ក. ដោះស្រាយវិសមីការ $-\frac{1}{x}x^4 + 3x^2 - \frac{5}{2} < 0$ តាមក្រាប ។

ខ. បង្ហាញថា $0 < -\frac{1}{2}x^4 + 3x^2 - \frac{5}{2} \leq 2$ ចំពោះ $x \in (-\sqrt{5}, -1) \cup (1, \sqrt{5})$ តាមក្រាប ។

**ចម្លើយ** ក. តាមក្រាបវិសមីការ $-\frac{1}{2}x^4 + 3x^2 - \frac{5}{2} < 0$ មានសំណុំឫស $S = (-\infty, -\sqrt{5}) \cup (-1, 1) \cup (\sqrt{5}, +\infty)$ ។

ខ. តាមក្រាបចំណុច $(x, y)$ នៃក្រាប $C$ ដែលមាន $0 < y \leq 2$ ត្រូវស្ថិតនៅផ្នែកខាងលើអ័ក្សអាប់ស៊ីស ហើយប៉ះនឹងបន្ទាត់ $y = 2$ ដែលត្រូវគ្នានឹង $x \in (-\sqrt{5}, -1) \cup (1, \sqrt{5})$

ដូចនេះ $0 < -\frac{1}{2}x^4 + 3x^2 - \frac{5}{2} \leq 2$ ចំពោះ $x \in (-\sqrt{5}, -1) \cup (1, \sqrt{5})$

**ជាទូទៅ**

- វិសមីការ $ax^4 + bx^2 + c > 0$ មានសំណុំឫសជាសំណុំតម្លៃអាប់ស៊ីស $x$ នៃចំណុចនៅលើក្រាបតាងអនុគមន៍ $y = ax^4 + bx^2 + c$ ដែលស្ថិតនៅផ្នែកខាងលើអ័ក្សអាប់ស៊ីស ។
- វិសមីការ $ax^4 + bx^2 + c < 0$ មានសំណុំឫសជាសំណុំតម្លៃអាប់ស៊ីស $x$ នៃចំណុចនៅលើក្រាបតាងអនុគមន៍ $y = ax^4 + bx^2 + c$ ដែលស្ថិតនៅផ្នែកខាងក្រោមអ័ក្សអាប់ស៊ីស ។

**ប្រតិបត្តិ** អនុគមន៍ $y = x^4 - 2x^2 + 1$ មានក្រាប $C$ ។

ក. ដោះស្រាយវិសមីការ $x^4 - 2x^2 + 1 > 0$ តាមក្រាប ។

ខ. បង្ហាញថា $0 \le x^2 - 2x^2 + 1 \le 1$

ចំពោះ $x \in [-\sqrt{2}, \sqrt{2}]$ ។




## មេរៀនសង្ខេប

- សមីការ $ax^3 + bx^2 + cx + d = \lambda$ មានឫសជាអាប់ស៊ីសនៃចំណុចប្រសព្វរវាងក្រាបនៃ $y = ax^3 + bx^2 + cx + d$ និងបន្ទាត់ $y = \lambda$ ។
- សមីការ $ax^4 + bx^2 + c = \lambda$ មានឫសជាអាប់ស៊ីសនៃចំណុចប្រសព្វរវាងក្រាបនៃ $y = ax^4 + bx^2 + c$ និងបន្ទាត់ $y = \lambda$ ។
- វិសមីការ $ax^3 + bx^2 + cx + d > 0$ មានសំណុំឫសជាសំណុំតម្លៃអាប់ស៊ីស $x$ នៃចំណុចនៅលើក្រាបតាងអនុគមន៍ $y = ax^3 + bx^2 + cx + d$ ដែលស្ថិតនៅផ្នែកខាងលើអ័ក្សអាប់ស៊ីស ។
- វិសមីការ $ax^3 + bx^2 + cx + d < 0$ មានសំណុំឫសជាសំណុំតម្លៃអាប់ស៊ីស $x$ នៃចំណុចនៅលើក្រាបតាងអនុគមមន៍ $y = ax^3 + bx^2 + cx + d$ ដែលស្ថិតនៅផ្នែកខាងក្រោមអ័ក្សអាប់ស៊ីស ។
- វិសមីការ $ax^4 + bx^2 + c > 0$ មានសំណុំឫសជាសំណុំតម្លៃអាប់ស៊ីស $x$ នៃចំណុចនៅលើក្រាបតាងអនុគមន៍ $y = ax^4 + bx^2 + c$ ដែលស្ថិតនៅផ្នែកខាងលើអ័ក្សអាប់ស៊ីស ។
- វិសមីការ $ax^4 + bx^2 + c < 0$ មានសំណុំឫសជាសំណុំតម្លៃអាប់ស៊ីសនៃចំណុចនៅលើក្រាបតាងអនុគមន៍ $y = ax^4 + bx^2 + c$ ដែលស្ថិតនៅផ្នែកខាងក្រោមអ័ក្សអាប់ស៊ីស ។
- ក្នុងការដោះស្រាយវិសមីការដឺក្រេទីបី ឬវិសីមការដឺក្រេទីបួន គេអាចប្រើ :
  - ក្រាបតាងអនុគមន៍ដឺក្រេទីបី ឬអនុគមន៍ដឺក្រេទីបួន
  - តារាងអថេរភាពនៃអនុគមន៍ដឺក្រេទីបី ឬអនុគមន៍ដឺក្រេទីបួន ។

## លំហាត់

1. អនុគមន៍ $y = x^3 - 3x^2$ មានក្រាប $C$ ។

   ក. សង់ក្រាប $C$ នៃអនុគមន៍ ។

   ខ. សិក្សាទៅតាមតម្លៃប៉ារ៉ាម៉ែត្រ $m$ ពីអត្ថិភាពនិងចំនួនឫសនៃសមីការ $x^3 - 3x^2 = m$ តាមក្រាប ។

2. អនុគមន៍ $f$ កំណត់ដោយ $f(x) = x^3 - 6x + 5$ ។

   ក. សង់ក្រាបនៃ $f$ ។

   ខ. សិក្សាលើក្រាបទៅតាមតម្លៃ $a$ ពីអត្ថិភាពនិងសញ្ញាឫសនៃសមីការ $x^3 - 6x + 5 - a = 0$ ។

3. គេឱ្យសមីការ $2x^3 - 3x^2 - 12x - k = 0$ ដែលមានអញ្ញាត $x$ និងប៉ារ៉ាម៉ែត្រ $k$ ។

   ក. រកតម្លៃ $k$ ដើម្បីឱ្យសមីការមានឫសបីផ្សេងគ្នា ។

   ខ. រកតម្លៃ $k$ ដើម្បីឱ្យសមីការមានឫសវិជ្ជមានពីរផ្សេងគ្នានិងឫសអវិជ្ជមានមួយទៀត ។

4. អនុគមន៍ $f$ កំណត់ដោយ $f(x) = x^3 - 3x + 1$ មានក្រាប $C$ ។

   ក. សង់ក្រាប $C$ នៃ $f$ ។

   ខ. សិក្សាលើក្រាបទៅតាមតម្លៃ $p$ ពីអត្ថិភាពនិងទីតាំងឫសនៃសមីការ $f(x) = p$ ធៀបនឹងចំនួន $-1$ និង $1$ ។

5. ក. សង់ក្រាបនៃអនុគមន៍ $y = \frac{3}{2}x^4 + \frac{1}{2}x^2 - 4$ ។

   ខ. សិក្សាលើក្រាបទៅតាមតម្លៃ $m$ ពីអត្ថិភាពនិងទីតាំងឫសនៃសមីការ $\frac{3}{2}x^4 + \frac{1}{2}x^2 - 4 - m = 0$ ធៀបនឹង $-1$ និង $2$ ។

6. គេឱ្យសមីការ $-2x^4 + 3x^2 - 1 = a$ ។

   ក. រកតម្លៃ $a$ ដើម្បីឱ្យសមីការមានឫសបួនផ្សេងគ្នា ។

   ខ. រកតម្លៃ $a$ ដើម្បីឱ្យសមីការគ្មានឫស ។

7. ក. សង់ក្រាបនៃអនុគមន៍ $f(x) = -\frac{1}{3}x^3 + 2x^2 - 3x - 1$ ។

   ខ. ដោះស្រាយវិសមីការ $f(x) + 1 \le 0$ តាមក្រាប ។

8. អនុគមន៍ $y = x^3 + 3x^2 - 4$ មានក្រាប $C$ ។

ក. សង់ក្រាប $C$ នៃអនុគមន៍ ។

ខ. បង្ហាញថា $x^3 + 3x^2 - 4 \le 0$ ចំពោះ $x \le -2$ ។

9. គេឱ្យក្រាប $C$ នៃអនុគមន៍ $y = \frac{1}{2}x^4 + x^2 - \frac{3}{2}$ ។




ក. ដោះស្រាយវិសមីការ $\frac{1}{2}x^4 + x^2 - \frac{3}{2} \ge 0$ តាមក្រាប ។

ខ. បង្ហាញថា $\frac{1}{2}x^4 + x^2 - \frac{3}{2} < 0$ ចំពោះ $x \in (-1,\ 1)$ ។

10. $f$ ជាអនុគមន៍កំណត់ដោយ $f(x) = -x^4 + 2x^2 - 2$ ។

ក. សង់ក្រាបនៃ $f$ ។

ខ. ដោះស្រាយទ្វេវិសមីការ $-2 \le f(x) \le -1$ តាមក្រាប ។

គ. បង្ហាញថា $f(x) < -2$ ចំពោះ $x \in (-\infty,\ -\sqrt{2}) \cup (\sqrt{2},\ +\infty)$ តាមក្រាប ។

11. ក. សង់ក្រាប $C_1$ នៃ $y = 3x^4 + 1$ និង $C_2$ នៃ $y = 8x^3 - 18x^2$ នៅក្នុងតម្រុយតែមួយ ។

ខ. បង្ហាញថា $3x^4 + 1 > 8x^3 - 18x^2$ ចំពោះ $x \ge 0$ តាមក្រាប ។

គ. រកដេរីវេនៃអនុគមន៍ $f(x) = 3x^4 - 8x^3 + 18x^2 + 1$ និងគណនា $f(0)$ ។

ឃ. បង្ហាញថា $f(x) > 0$ ចំពោះ $x \ge 0$ ហើយទាញបញ្ជាក់ថា $3x^4 + 1 > 8x^3 - 18x^2$ ចំពោះ $x \ge 0$ ។

## លំហាត់ជំពូក

1. គេឱ្យអនុគមន៍ $f(x) = x^2$ និង $h$ ជាចំនួនពិតខុសពីសូន្យ ។ រកតម្លៃ $\alpha$ ដើម្បីឱ្យ $f(x_0 + h) = f(x_o) + h \cdot f'(x_0 + \alpha h)$ ។

2. បន្ទាត់ $T$ មួយប៉ះនឹងក្រាបនៃអនុគមន៍ $y = x^3$ ត្រង់ចំណុច $M$ មួយ ហើយជួបអ័ក្សអាប់ស៊ីសនិងអ័ក្សអរដោនេរៀងគ្នាត្រង់ចំណុច $A$ និង $B$ ។ រកផលធៀប $AM : MB$ ។

3. គេឱ្យអនុគមន៍ $y = 6x^5 - 15x^4 + 10x^3 - 2$ ។

ក. គណនាដេរីវេ $y'$ និងសិក្សាសញ្ញានៃ $y'$ ។

ខ. សង់តារាងអថេរភាព និងក្រាបនៃអនុគមន៍ $y$ ។

4. ប៉ារ៉ាបូលតាង $y = 9 - x^2$ កាត់អ័ក្សអាប់ស៊ីសត្រង់ចំណុច $E$ និង $F$ ។

ចតុកោណព្នាយ $EFGH$ ចារឹកក្នុងប៉ារ៉ាបូល ហើយមាន $[EF]$ ជាបាតធំ និង $[GH]$ ជាបាតតូច ។

ក. រកកូអរដោនេនៃចំណុច $G$ និង $H$ ដើម្បីឱ្យចតុកោណព្នាយមានផ្ទៃក្រឡាធំបំផុត ។

ខ. គណនាផ្ទៃក្រឡាធំបំផុតនោះ ។




5. ក្រាប $C_1$ នៃអនុគមន៍ $y = x^3 + ax$ និង $C_2$ នៃ $y = x^2 + bx + c$ កាត់គ្នាត្រង់ $A(1, 2)$ ហើយមានបន្ទាត់ប៉ះរួមត្រង់ចំណុចនោះ ។

6. ក. រកតម្លៃនៃចំនួនពិត $a, b$ និង $c$ ។

ខ. សង់ក្រាប $C_1, C_2$ និងបន្ទាត់ប៉ះរួមត្រង់ $A$ ។

7. ក. រកតម្លៃ $k$ ដើម្បីឱ្យអនុគមន៍ $f(x) = x^3 - 4x^2 + 2kx$ គ្មានបរមា ។

ខ. រកតម្លៃ $a$ ដើម្បីឱ្យអនុគមន៍ $y = x^4 + 2ax^2 + a$ មានអតិបរមានិងអប្បបរមា ។

8. រកតម្លៃអតិបរមា និងអប្បបរមានៃអនុគមន៍ $y = 2x^3 - 3ax^2 + 1$ លើចន្លោះ $0 \le x \le 3$ ដែល $a > 0$ ។

9. គេឱ្យចតុមុខនិយ័ត $ABCD$ មួយដែលមានទ្រនុង 12cm ។

ចំណុច $M, N, P$ ស្ថិតនៅលើទ្រនុង $[AB]$ , $[AC]$ , $[AD]$ រៀងគ្នា ហើយមានចម្ងាយ $x$ ដូចគ្នាពីកំពូល $A$ ។ ចំណុច $M', N', P'$ ជាចំណោលកែងនៃ $M, N, P$ រៀងគ្នាទៅលើបាត $BCD$ ។ រកតម្លៃ $x$ បើគេដឹងថាព្រិសត្រីមុខនិយ័ត $MNP \cdot M'N'P'$ មានមាឌធំបំផុត ។

10. គេឱ្យសមីការ $2x^3 - 3x^2 - 12x - k = 0 \quad (E)$ ។

ក. រកតម្លៃ $k$ ដើម្បីឱ្យ $(E)$ មានឫសបីផ្សេងគ្នា ។

ខ. ដោះស្រាយវិសមីការ $2x^3 - 3x^2 - 12x \le 0$ តាមក្រាប ។

11. អនុគមន៍ $f(x) = x^2(6 - 3x^2)$ មានក្រាប $C$ ។

ក. រកតម្លៃ $P$ ដើម្បីឱ្យសមីការ $f(x) = P$ មានឫសបួនផ្សេងគ្នាតាមក្រាប ។

ខ. បង្ហាញថា $0 \le 6x^2 - 3x^4 < 3$ ចំពោះ $x \in (-1, 1)$ ។

PROEUS DARA

# ជំពូក 6

# ប្រូបាប

## ❶ ប្រូបាបមានលក្ខខណ្ឌ



ការគណនាប្រូបាប គឺជាផ្នែកមួយដែលមានការទាក់ទាញអារម្មណ៍ខ្លាំងជាងគេនិងមានការពិបាកតិចជាងគេនៅក្នុងគណិតវិទ្យា ។ បញ្ហាទាក់ទងនឹងល្បែងចៃដន្យ ជាពិសេសល្បែងបោះគ្រាប់ឡុកឡាក់ ក៏ដូចជាបញ្ហាទាក់ទងនឹងការរស់នៅប្រចាំថ្ងៃរបស់មនុស្សក្នុងពិភពលោក ជាប្រភពនៃការគណនាប្រូបាប ។ ការសិក្សាស្រាវជ្រាវពីការគណនាប្រូបាបត្រូវបានយកចិត្តទុកដាក់ដោយគណិតវិទូជាច្រើន ដូចជា Blaise, Pascal, Cardan, Feunat, Bernoullè, Laplace, Polsson, . . . ជាពិសេសគណិតវិទូរុស្ស៊ី AN Kolmogorov នៅឆ្នាំ 1933 បានសរសេររចនាសម្ព័ន្ធស្វ័យសត្យជាទ្រឹស្តីប្រូបាប ។

មេរៀនទី 1

# ប្រូបាបមានលក្ខខណ្ឌ

## 1. ប្រូបាបមានលក្ខខណ្ឌ

### 1.1 និយមន័យ

**វត្ថុបំណង**

- កំណត់និយមន័យនៃប្រូបាបមានលក្ខខណ្ឌ
- បង្ហាញភាពមិនអាស្រ័យគ្នាក្នុងប្រូបាប
- បង្ហាញរូបមន្តប្រូបាបសរុប

***ឧទាហរណ៍*** គេដឹងថាសិស្សដែលរៀនចប់ចេញពីវិទ្យាល័យមួយមានចំនួន 200 នាក់ ដែលក្នុងនោះមានសិស្សស្រី 90 នាក់ និងសិស្សប្រុស 110 នាក់ ។ ក្នុងចំណោមនោះមានតែសិស្សស្រី 27 នាក់ប៉ុណ្ណោះដែលបន្តការសិក្សាទៅឧត្តមសិក្សា ។ ឯសិស្សប្រុសមានតែ 66 នាក់ដែលបន្តការសិក្សា ។ គេចង់ជួបសម្ភាសន៍សិស្សម្នាក់ក្នុងចំណោមសិស្សទាំងនេះ ។

រកប្រូបាបដែលអ្នកសម្ភាសន៍ :

ក. ជួបសិស្សស្រី ខ. ជួបសិស្សប្រុស គ. ជួបសិស្សស្រីដែលបន្តការសិក្សា

ឃ. ជួបសិស្សប្រុសដែលបន្តការសិក្សា ង. ជួបសិស្សបន្តការសិក្សា

ច. ជួបសិស្សបន្តការសិក្សាដោយបានដឹងមុនថាជាសិស្សស្រី

ឆ. ជួបសិស្សស្រីដោយបានដឹងមុនថាជាសិស្សបន្តការសិក្សា ។

**ចម្លើយ** គេអាចស្រង់ទិន្នន័យទាំងអស់ដាក់ក្នុងតារាង

| ភេទ / ការសិក្សា | ស្រី | ប្រុស | សរុប |
|---|---|---|---|
| បន្តការសិក្សា | 27 | 66 | 93 |
| មិនបន្តការសិក្សា | 63 | 44 | 107 |
| សរុប | 90 | 110 | 200 នាក់ |

តាង $S$ ជាលំហសំណាក

$F$ ជាព្រឹត្តិការណ៍ជួបសិស្សស្រី

$B$ ជាព្រឹត្តិការណ៍ជួបសិស្សប្រុស

$C$ ជាព្រឹត្តិការណ៍ជួបសិស្សបន្តការសិក្សា

$\bar{C}$ ជាព្រឹត្តិការណ៍ជួបសិស្សមិនបន្តការសិក្សា។

គេបាន ព្រឹត្តិការណ៍ជួបសិស្សស្រីដែលបន្តការសិក្សា ជាព្រឹត្តិការណ៍ $F \cap C$

ព្រឹត្តិការណ៍ជួបសិស្សប្រុសបន្តការសិក្សា ជាព្រឹត្តិការណ៍ $B \cap C$

គេមាន សិស្សទាំងអស់ 200 នាក់ គេបាន $n(S) = 200$

សិស្សស្រី 90 នាក់ : $n(F) = 90$

សិស្សប្រុស 110 នាក់ : $n(B) = 110$

សិស្សស្រីដែលបន្តការសិក្សា 27 នាក់: $n(F \cap C) = 27$

សិស្សប្រុសដែលបន្តការសិក្សា 66 នាក់: $n(B \cap C) = 66$

សិស្សបន្តការសិក្សាមានស្រី 27 ប្រុស 66 នាក់: $n(C) = 27 + 66 = 93$

ក. ប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សស្រី $P(F) = \dfrac{n(F)}{n(S)} = \dfrac{90}{200} = 0.45$

ខ. ប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សប្រុស $P(B) = \dfrac{n(B)}{n(S)} = \dfrac{110}{200} = 0.55$

គ. ប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សស្រីបន្តការសិក្សា $P(F \cap C) = \dfrac{n(F \cap C)}{n(S)} = \dfrac{27}{200} = 0.135$

ឃ. ប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សប្រុសបន្តការសិក្សា

$$P(B \cap C) = \frac{n(B \cap C)}{n(S)} = \frac{66}{200} = 0.33$$

ង. ប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សដែលបន្តការសិក្សា $P(C) = \dfrac{n(C)}{n(S)} = \dfrac{93}{200} = 0.465$

ច. ប្រូបាបនៃព្រឹត្តិការណ៍បន្តការសិក្សា ដោយដឹងមុនថាជាសិស្សស្រី

បើគេដឹងមុនថាអ្នកដែលគេចង់ជួបជាសិស្សស្រីនោះ បានន័យថាគេចង់ជួបសិស្សស្រីបន្តការសិក្សាក្នុងចំណោមសិស្សស្រី ដោយចំនួនសិស្សស្រីបន្តការសិក្សាមាន $n(F \cap C) = 27$ នាក់ ហើយចំនួនសិស្សស្រីមាន $n(F) = 90$ នាក់ នោះប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សបន្តការសិក្សាដោយដឹងមុនថាជាសិស្សស្រីគឺ $\dfrac{n(F \cap C)}{n(F)} = \dfrac{27}{90} = 0.30$

ចំពោះផលធៀប $\frac{n(F\cap C)}{n(F)}$ គេអាចសរសេរ :

$$\frac{n(F\cap C)}{n(F)}=\frac{\frac{n(F\cap C)}{n(S)}}{\frac{n(F)}{n(S)}}=\frac{P(F\cap C)}{P(F)}=\frac{0.135}{0.45}=0.3$$

ប្រូបាបនេះហៅថាប្រូបាបមានលក្ខខណ្ឌនៃព្រឹត្តិការណ៍ $C$ ដោយដឹងថាព្រឹត្តិការណ៍ $F$ បានកើតឡើងគេកំណត់សរសេរ :$P(C/F)$ ឬ $P_F(C)$

ដូចនេះ ប្រូបាបមានលក្ខខណ្ឌនៃ $C$ ដោយដឹង $F$ គឺ $P(C/F)=\frac{P(F\cap C)}{P(F)}=0.3$

$P(C/F)$ អានថា : ប្រូបាបនៃ $C$ ដោយដឹង $F$ ( ឬ $C$ កើតក្រោយ $F$ )

ឆ. ប្រូបាបដែលជួបសិស្សស្រីដោយបានដឹងមុនថាជាសិស្សបន្តការសិក្សា

បើគេដឹងមុនថាជាសិស្សបន្តការសិក្សានោះ គឺគេចង់ជួបសិស្សស្រីបន្តការសិក្សាក្នុងចំណោមសិស្សបន្តការសិក្សាប្រូបាបនេះជាប្រូបាបមានលក្ខខណ្ឌនៃព្រឹត្តិការណ៍ $F$ ដោយដឹងថាព្រឹត្តិការណ៍ $C$ បានកើតឡើង : $P(F/C)=\frac{P(C\cap F)}{P(C)}=\frac{0.135}{0.465}=0.290$

**និយមន័យ**

- បើ $A$ និង $B$ ជាព្រឹត្តិការណ៍ 2 ក្នុងលំហសំណាកមួយដែល $P(A)\neq 0$ នោះប្រូបាបមានលក្ខខណ្ឌនៃព្រឹត្តិការណ៍ $B$ ដោយដឹង $A$ គឺ :

  $P(B/A)=\frac{P(A\cap B)}{P(A)}$
- គេអាចគណនាបានដូចគ្នា $P(A/B)=\frac{P(A\cap B)}{P(B)}$ $(P(B)\neq 0)$
- តាមរូបមន្តនេះ គេអាចទាញបានប្រូបាបនៃព្រឹត្តិការណ៍ផលគុណ $A$ និង $B$

  $P(A\cap B)=P(A)\times P(B/A)=P(B)\times P(A/B)$

គេអាចប្រើដ្យាក្រាមដើមឈើដើម្បីបង្ហាញប្រូបាបមានលក្ខខណ្ឌ :



**លំហាត់គំរូ** ក្នុងភូមិមួយមានប្រជាជន 85 % បានចាក់ថ្នាំការពារជំងឺឆ្លង ។ ក្នុងចំណោមអ្នកចាក់ថ្នាំការពារ គេឃើញមានអ្នកឆ្លងជំងឺ 2 % និងចំណោមអ្នកមិនចាក់ថ្នាំការពារមាន 1 % មិនឆ្លងជំងឺ ។ រកប្រូបាបដែល :

ក. អ្នកឆ្លងជំងឺដោយដឹងថាបានចាក់ថ្នាំការពារ

ខ. អ្នកចាក់ថ្នាំការពារ ហើយឆ្លងជំងឺ

គ. អ្នកឆ្លងជំងឺដោយដឹងថាមិនបានចាក់ថ្នាំការពារ

ឃ. អ្នកមិនបានចាក់ថ្នាំការពារ ហើយឆ្លងជំងឺ ។

ង. បើក្នុងភូមិមានប្រជាជន 1000 នាក់ តើអ្នកចាក់ថ្នាំការពារមានប៉ុន្មាននាក់ ? ហើយឆ្លងជំងឺមានប៉ុន្មាននាក់ ? អ្នកមិនបានចាក់ថ្នាំការពារប៉ុន្មាននាក់ ? អ្នកមិនបានចាក់ថ្នាំការពារ ហើយឆ្លងជំងឺមានប៉ុន្មាននាក់ ?

**ចម្លើយ** តាង $V$ ជាព្រឹត្តិការណ៍អ្នកចាក់ថ្នាំការពារ

$\bar{V}$ ជាព្រឹត្តិការណ៍អ្នកមិនបានចាក់ថ្នាំការពារ

$M$ ជាព្រឹត្តិការណ៍អ្នកឆ្លងជំងឺ $\bar{M}$ ជាព្រឹត្តិការណ៍អ្នកមិនឆ្លងជំងឺ

គេបាន $P(V) = \frac{85}{100} = 0.85$ , $P(\bar{V}) = 1 - P(V)$ ព្រោះ $\bar{V}$ ជាព្រឹត្តិការណ៍ផ្ទុយនឹង $V$

ក. ប្រូបាបអ្នកឆ្លងជំងឺ ដោយដឹងថាបានចាក់ថ្នាំការពារ

អ្នកឆ្លងជំងឺដោយដឹងថាបានចាក់ថ្នាំការពារ គឺជាអ្នកឆ្លងជំងឺក្នុងចំណោមអ្នកចាក់ថ្នាំការពារដែលមាន 2 % ដូចនេះ ប្រូបាបដែលអ្នកជំងឺដោយដឹងថាបានចាក់ថ្នាំ ជាប្រូបាបមានលក្ខខណ្ឌនៃព្រឹត្តិការណ៍ $M$ ដោយដឹងថា $V$ : $P(M/V) = 2\,\% = 0.02$

ខ. ប្រូបាបដែលអ្នកចាក់ថ្នាំការពារ ហើយឆ្លងជំងឺ

ព្រឹត្តិការណ៍អ្នកចាក់ថ្នាំការពារ ហើយឆ្លងជំងឺជាព្រឹត្តិការណ៍ $V \cap M$

គេបាន $P(V \cap M) = P(V) \times P(M/V) = 0.85 \times 0.02 = 0.017$

គ. ប្រូបាបដែលអ្នកឆ្លងជំងឺ ដោយដឹងថាមិនបានចាក់ថ្នាំការពារ

ដើម្បីងាយមើលគេសង់ដ្យាក្រាមដើមឈើ




$M$ : $P(V \cap M) = P(V) \times P(M/V) = 0.85 \times 0.02$
$= 0.017$

$M$ : $P(\bar{V} \cap M) = P(\bar{V}) \times P(M/\bar{V})$

គេដឹងថា អ្នកមិនឆ្លងដោយដឹងថាមិនបានចាក់ថ្នាំការពារមាន 1 % : $P(\bar{M}/\bar{V}) = 0.01$
ព្រឹត្តិការណ៍អ្នកឆ្លងដោយដឹងថាមិនបានការពារ ជាព្រឹត្តិការណ៍ផ្ទុយនឹងព្រឹត្តិការណ៍អ្នកមិនឆ្លងដោយដឹងថាមិនការពារ : $P(M/\bar{V}) = 1 - P(\bar{M}/\bar{V}) = 1 - 0.01 = 0.99$

ឃ. ប្រូបាបដែលអ្នកមិនបានចាក់ថ្នាំ ហើយឆ្លងជំងឺ

$P(\bar{V} \cap M) = P(\bar{V}) \times P(M/\bar{V}) = 0.15 \times 0.99 = 0.148$

ង. អ្នកចាក់ថ្នាំការពារហើយឆ្លងជំងឺមានប្រូបាប $P(V \cap M) = 0.017$ ដូចនេះក្នុង 1000 នាក់មានអ្នកឆ្លង 17 នាក់ ។ អ្នកមិនបានចាក់ថ្នាំការពារ ហើយឆ្លងជំងឺមានប្រូបាប $P(\bar{V} \cap M) = 0.148$ ដូចនេះ ក្នុង 1000 នាក់មានអ្នកឆ្លង 148 នាក់ ។

**ប្រតិបត្តិ** សិប្បកម្មមួយមានម៉ាស៊ីន 2 ផលិតវត្ថុដូចគ្នា ។ គេដឹងថាម៉ាស៊ីនទី 1 ផលិតវត្ថុបាន 45 % ដែលក្នុងនោះមានខូច 3 % និងម៉ាស៊ីនទី 2 ផលិតវត្ថុបាន 55 % ដែលក្នុងនោះមានខូច 2 % ។

ក. តើប្រូបាបដែលមានវត្ថុខូច ដោយដឹងថាផលិតដោយម៉ាស៊ីនទី 1 ស្មើនឹងប៉ុន្មាន ?

ខ. រកប្រូបាបដែលមានវត្ថុខូចក្នុងម៉ាស៊ីនទី 1

គ. រកប្រូបាបដែលមានវត្ថុខូចក្នុងម៉ាស៊ីនទី 2

ឃ. បើម៉ាស៊ីនទាំងពីរ ផលិតបានវត្ថុចំនួន 1000 តើម៉ាស៊ីនទី 1 ធ្វើខូចអស់ប៉ុន្មាន ? ម៉ាស៊ីនទី 2 ធ្វើខូចអស់ចំនួនប៉ុន្មាន ?

## 2. ព្រឹត្តិការណ៍ទាក់ទងគ្នានិងមិនទាក់ទងគ្នា

***ឧទាហរណ៍*** ថង់មួយមានឃ្លីខៀវ 4 ចុះលេខ 1, 1, 2 និង 3 និងឃ្លីក្រហម 6 ចុះលេខ 1; 1, 1, 2, 3 និង 4 ។ គេចាប់យកឃ្លីមួយចេញពីថង់ដោយចៃដន្យ ។

គេតាងព្រឹត្តិការណ៍ : $B$ : " ឃ្លីយកចេញពណ៌ខៀវ " , $A$ : " ឃ្លីយកចេញមានលេខ 1 " $C$ : " ឃ្លីយកចេញមានលេខ 4 "

- គេឃើញថាឃ្លីទាំងអស់មាន 10 ក្នុងនោះឃ្លីខៀវមាន 4 ហើយឃ្លីលេខ 1 មានចំនួន 5 និងឃ្លីពណ៌ខៀវលេខ 1 មាន 2 គេបាន $P(B) = \dfrac{4}{10}$ , $P(A) = \dfrac{5}{10}$ ,
  $P(B\cap A) = \dfrac{2}{10}$ ដោយ $P(B)\times P(A) = \dfrac{4}{10}\times\dfrac{5}{10} = \dfrac{2}{10} = P(B\cap A)$
  បើ $P(A\cap B) = P(A)\times P(B)$ នោះគេថាព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $B$ មិនទាក់ទងគ្នា ។
- បើ $A$ និង $B$ មិនទាក់ទងគ្នា នោះគេបាន :
  $$P(A/B) = \frac{P(A\cap B)}{P(B)} = \frac{P(A)\times P(B)}{P(B)} = P(A)$$
  $$P(B/A) = \frac{P(A\cap B)}{P(A)} = \frac{P(A)\times P(B)}{P(A)} = P(B)$$
  ដូចនេះ $P(A/B) = P(A)$ , $P(B/A) = P(B)$
- គេឃើញថា $P(C) = \dfrac{1}{10}$ , $P(B\cap C) = 0$ ព្រោះ $B\cap C = \varnothing$
  $P(C)\times P(B) = \dfrac{1}{10}\times\dfrac{4}{10} = \dfrac{1}{25} \neq P(B\cap C)$
  គេថាព្រឹត្តិការណ៍ $B$ និងព្រឹត្តិការណ៍ $C$ ទាក់ទងគ្នា ។
  ដោយ $B\cap C = \varnothing$ នោះ $B$ និង $C$ ជាព្រឹត្តិការណ៍មិនចុះសម្រុង ។

**ជាទូទៅ** $A$ និង $B$ ជាព្រឹត្តិការណ៍ 2 ដែលមានប្រូបាបមិនសូន្យ

- គេថាព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $B$ មិនទាក់ទងគ្នា កាលណាព្រឹត្តិការណ៍ទាំង 2 ផ្ទៀងផ្ទាត់លក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម :
  1 . $P(A\cap B) = P(A)\times P(B)$ ឬ 2 . $P(A/B) = P(A)$ ឬ 3 . $P(B/A) = P(B)$
- គេថាព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $B$ ទាក់ទងគ្នា កាលណា
  $P(A\cap B) \neq P(A)\times P(B)$

**សំគាល់** ព្រឹត្តិការណ៍2 មិនអាស្រ័យគ្នាមិនមែនមានន័យថាព្រឹត្តិការណ៍ 2 នោះមិនចុះសម្រុងគ្នាទេ ។

**លំហាត់គំរូ 1** គេបោះគ្រាប់ឡុកឡាក់ដូចគ្នា 2 ព្រមគ្នា ។ តាង$A$ ជាព្រឹត្តិការណ៍ " ផលបូកលេខដែលគ្រាប់ឡុកឡាក់ទាំង2 ចេញជាចំនួនគូ " និង$B$ ជាព្រឹត្តិការណ៍ " គម្លាតរវាងលេខទាំង2 ជាចំនួនគូ " ។

ក. គណនា $P(A)$ , $P(B)$ និង $P(A\cap B)$

ខ. តើព្រឹត្តិការណ៍ $A$ និង $B$ ជាព្រឹត្តិការណ៍ទាក់ទងគ្នា ឬមិនទាក់ទងគ្នា ?

គ. គណនា $P(A/B)$ និង $P(B/A)$

**ចម្លើយ** លទ្ធផលនីមួយៗក្នុងការបោះគ្រាប់ឡុកឡាក់ដូចគ្នា 2 ព្រមគ្នា ជាគូគ្មានលំដាប់ $\{a,\ b\}$ ដែល $a$ និង $b$ អាចស្មើនឹង 1, 2, 3, 4, 5, 6 ។

គេបានលំហសំណាក $S = \{\{a,\ b\}$ ដែល $a$ និង $b \in \{1,\ 2,\ 3,\ 4,\ 5,\ 6\}\}$

$$n(S) = 6^2 = 36$$

ផលបូកទាំង 2 ជាចំនួនគូ គឺជាផលបូកលេខដែលអាចស្មើនឹង 2, 4, 6, 8, 10, 12

គេបាន $A = \{(1,1),(1,3),(2,2),(1,5),(2,4),(3,3),(2,6),(3,5),(3,1),(5,1),(4,2),(6,2)$ ,

$(5,3),(6,4),(4,4),(4,6),(5,5),(6,6)$ $\quad n(A) = 18$

គម្លាតរវាងលេខទាំង 2 អាចស្មើនឹង 2 ឬស្មើនឹង 4 :

$B = \{(1,3),(1,5),(2,4),(2,6),(3,5),(4,6),(3,1),(5,1),(4,2),(6,2),(5,3),(6,4)\}$ $\quad n(B) = 12$

$A\cap B = \{(1,3),(1,5),(2,4),(2,6),(3,5),(4,6),(3,1),(5,1),(4,2),(6,2),(5,3),(6,4)\} = B$

ក. គណនា $P(A)$ , $P(B)$ និង $P(A\cap B)$

$$P(A) = \frac{n(A)}{n(S)} = \frac{18}{36} = \frac{1}{2} \quad , \quad P(B) = \frac{n(B)}{n(S)} = \frac{12}{36} = \frac{1}{3}$$

$$P(A\cap B) = \frac{n(A\cap B)}{n(S)} = \frac{12}{36} = \frac{1}{3} \quad , \quad P(A)\times P(B) = \frac{1}{2}\times\frac{1}{3} = \frac{1}{6}$$

ខ. ដោយ $P(A\cap B) \neq P(A)\times P(B)$ នោះ $A$ និង $B$ ជាព្រឹត្តិការណ៍ទាក់ទងគ្នា

គ. គណនា $P(A/B)$ និង $P(B/A)$

ដោយព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $B$ ជាទាក់ទងគ្នា គេបាន :

$$P(A/B) = \frac{P(A\cap B)}{P(B)} = \frac{\frac{1}{3}}{\frac{1}{3}} = 1 \quad , \quad P(B/A) = \frac{P(A\cap B)}{P(A)} = \frac{\frac{1}{3}}{\frac{1}{2}} = \frac{2}{3}$$

**លំហាត់គំរូ 2** ថង់មួយមានប៊ូល ស 3 មានលេខខុសគ្នានិងប៊ូលខ្មៅ 2 មានលេខខុសគ្នា។ គេចាប់យកប៊ូលម្ដងមួយៗចំនួន 2 ដងដោយចៃដន្យចេញពីថង់ ដោយដាក់វិញ។

តាងព្រឹត្តិការណ៍ $A$ : " ចាប់លើកទី 1 បានប៊ូល ស " $B$ : " ចាប់លើកទី 2 បានប៊ូលខ្មៅ " ។

ក. ចូររកប្រូបាបនៃព្រឹត្តិការណ៍ $A$ , $B$ និង $A \cap B$

ខ. តើព្រឹត្តិការណ៍ $A$ និង $B$ អាស្រ័យគ្នាឬទេ ?

គ. គណនា $P(A/B)$ និង $P(B/A)$

**ចម្លើយ** ក. គណនា $P(A)$ , $P(B)$ និង $P(A \cap B)$

គេធ្វើវិញ្ញាសាយកហើយដាក់វិញ គេបានលទ្ធផលនីមួយៗជាចម្លាស់ច្រំដែល 2 ធាតុយកពី 5 ធាតុលំហសំណាក $n(S) = 5^2$

ព្រឹត្តិការណ៍ $n(A) = 3^2 + 3 \times 2 = 15$ ព្រឹត្តិការណ៍ $n(B) = 3 \times 2 + 2^2 = 10$

ព្រឹត្តិការណ៍ $n(A \cap B) = 3 \times 2 = 6$

គេបាន $P(A) = \frac{15}{25} = \frac{3}{5}$ , $P(B) = \frac{10}{25} = \frac{2}{5}$ , $P(A \cap B) = \frac{6}{25}$

ខ. តើព្រឹត្តិការណ៍ $A$ និង $B$ ទាក់គ្នាឬទេ ?

ដោយ $P(A) \times P(B) = \frac{3}{5} \times \frac{2}{5} = \frac{6}{26}$ នោះគេបាន $P(A \cap B) = P(A) \times P(B)$

ដូចនេះ $A$ និង $B$ ជាព្រឹត្តិការណ៍មិនទាក់ទងគ្នា

គ. គណនា $P(A/B)$ និង $P(B/A)$

ដោយព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $B$ មិនទាក់ទងគ្នានោះ គេបាន :

$P(A/B) = P(A) = \frac{3}{5}$ , $P(B/A) = P(B) = \frac{2}{5}$

**ប្រតិបត្តិ** គេបោះគ្រាប់ឡុកឡាក់មួយគ្រាប់ 2 ដងបន្តបន្ទាប់គ្នា។ គេតាងព្រឹត្តិការណ៍ :

$A$ : " ផលបូកលេខដែលបោះបានជាចំនួនគូ " $B$ : " បោះលើកទី 1 បានលេខ 6 "

$C$ : " បោះលើកទី 1 បានលេខធំជាងលើកទី 2 "

ក. គណនាប្រូបាបមានលក្ខខណ្ឌ $P(B/A)$ , $P(C/B)$ និង $P(C/A)$

ខ. តើព្រឹត្តិការណ៍ 2 ខាងក្រោមនេះទាក់ទងគ្នា ឬមិនទាក់ទងគ្នា ?

$A$ និង $B$   $A$ និង $C$   $B$ និង $C$

# 3. រូបមន្តប្រូបាបសរុប

**ឧទាហរណ៍** ( លំហាត់គំរូផ្នែក 1.1 )

មានប្រជាជន 85 % បានចាក់ថ្នាំការពារជំងឺឆ្លង ។ 2 % កើតជំងឺឆ្លងដោយដឹងថាចាក់ថ្នាំការពាររួចហើយ ។ 1 % មិនកើតជំងឺឆ្លងដោយដឹងថាមិនបានចាក់ថ្នាំការពារ ។

ក. គណនាប្រូបាបដែលអ្នកកើតជំងឺឆ្លង

ខ. គណនាប្រូបាបដែលអ្នកបានចាក់ថ្នាំការពារ ដោយដឹងថាកើតជំងឺឆ្លង

**ចម្លើយ** ក. ប្រូបាបដែលអ្នកកើតជំងឺឆ្លង

ចំនួនអ្នកកើតជំងឺឆ្លង ជាផលបូកចំនួនអ្នកជំងឺដែលចាក់ថ្នាំការពារនិងអ្នកជំងឺដែលមិនបានចាក់ថ្នាំការពារ

តាងព្រឹត្តិការណ៍ $V$ : “ អ្នកបានចាក់ថ្នាំការពារ ” $\bar{V}$ : “ អ្នកមិនបានចាក់ថ្នាំការពារ ”

$M$ : “ អ្នកកើតជំងឺឆ្លង ” $\bar{M}$ : “ អ្នកមិនឆ្លងជំងឺ ”

អ្នកជំងឺដែលបានចាក់ថ្នាំការពារ ជាព្រឹត្តិការណ៍ $M \cap V$

អ្នកជំងឺដែលមិនបានចាក់ថ្នាំការពារ ជាព្រឹត្តិការណ៍ $M \cap \bar{V}$

គេបាន $P(M) = P(M \cap V) + P(M \cap \bar{V})$ ដោយ $P(M \cap V) = P(V) \times P(M/V)$

$$P(M \cap \bar{V}) = P(\bar{V}) \times P(M/\bar{V})$$




$$P(M/\bar{V}) = 1 - P(\bar{M}/\bar{V}) = 1 - \frac{1}{100} = 0.99$$

$$P(M \cap \bar{V}) = 0.15 \times 0.99 = 0.1485$$

ដូចនេះ $P(M) = P(M \cap V) + P(M \cap \bar{V}) = 0.017 + 0.1485$ , $P(M) = 0.1655$

អ្នកកើតជំងឺទាំងអស់មាន 16.55 %

- ការរកភាគរយនៃអ្នកកើតជំងឺទាំងអស់ដែលបានចាក់ថ្នាំការពារនិងអ្នកមិនបានចាក់ថ្នាំការពារ ហៅថា រូបមន្តប្រូបាបសរុប : $P(M) = P(M/V)\times P(V) + P(M/\bar{V})\times P(\bar{V})$ ជាប្រូបាបដែលមានមនុស្សម្នាក់នៅក្នុងភូមិត្រូវកើតជំងឺឆ្លង ។

ខ. ប្រូបាបដែលអ្នកបានចាក់ថ្នាំដោយដឹងថាកើតជំងឺ

អ្នកបានចាក់ថ្នាំដោយដឹងថាកើតជំងឺ គឺជាអ្នកចាក់ថ្នាំហើយឆ្លងជំងឺក្នុងចំណោមអ្នកកើតជំងឺ ប្រូបាបដែលអ្នកបានចាក់ថ្នាំដោយដឹងថាកើតជំងឺគឺ $P(V/M)$

$$P(V/M) = \frac{P(V\cap M)}{P(M)} = \frac{P(M/V)\times P(V)}{P(M/V)\times P(V) + P(M/\bar{V})\times P(\bar{V})} = \frac{0.017}{0.1655} = 0.1027$$

- តាមការគណនានេះ បានឱ្យដឹងថាភាគរយនៃអ្នកចាក់ថ្នាំការពារហើយឈឺក្នុងចំណោមអ្នកជំងឺគឺ 10.27 %

ការគណនាភាគរយនេះហៅថា ទ្រឹស្តីបទបៃយេស

ជាទូទៅ :




- បើ $A_1, A_2, \ldots, A_n$ ជាព្រឹត្តិការណ៍មិនចុះសម្រុងគ្នាពីរៗ ក្នុងលំហសំណាកមួយ ហើយមានព្រឹត្តិការណ៍ $B$ មួយកើតឡើងក្នុងព្រឹត្តិការណ៍ $A_1, A_2, \ldots, A_n$

នោះ $B = (A_1\cap B)\cup(A_2\cap B)\cup\ldots\cup(A_n\cap B)$

$$P(B) = P(A_1\cap B) + P(A_2\cap B) + \ldots + P(A_n\cap B)$$

ដោយ $P(A_1\cap B) = P(B/A_1)\times P(A_1)$

គេបាន $P(B) = P(A_1)\times P(B/A_1) + P(A_2)P(B/A_2) + \ldots + P(A_n)\times P(B/A_n)$

$$P(B) = \sum_{i=1}^{n}[P(B/A_i)\times P(A_i)]$$

- បើ $A_k$ ជាព្រឹត្តិការណ៍មួយក្នុងលំហសំណាក នោះ

$$P(A_k/B) = \frac{P(A_k\cap B)}{P(B)} = \frac{P(B/A_k)\times P(A_k)}{\sum_{i=1}^{n}[P(B/A_i)\times P(A_i)]}$$

**រូបមន្តប្រូបាបសរុប :**

$$P(B) = \sum_{i=1}^{n}[P(B/A_i)\times P(A_i)]$$

**ទ្រឹស្តីបទបៃយេស :**

$$P(A_k/B) = \frac{P(B/A_k)\times P(A_k)}{\sum_{i=1}^{n}[P(B/A_i)\times P(A_i)]}$$

**លំហាត់គំរូ** គេមានម៉ាស៊ីន $A$, $B$ និង $C$ ផលិតវត្ថុដូចគ្នា។ ម៉ាស៊ីន $A$ ផលិតបាន 50 % $B$ បាន 30 % និង $C$ បាន 20 % ។ គេដឹងថាវត្ថុដែលផលិតដោយម៉ាស៊ីន $A$ មានខូច 3 % ម៉ាស៊ីន $B$ ខូច 4 % និងម៉ាស៊ីន $C$ ខូច 4 % ។

ក. រកប្រូបាបដែលមានវត្ថុខូច

ខ. ក្នុងចំណោមវត្ថុខូចចំនួន 1000 តើម៉ាស៊ីន $A$ ធ្វើខូចចំនួនប៉ុន្មាន ? $B$ ធ្វើខូចចំនួនប៉ុន្មាន ? $C$ ខូចចំនួនប៉ុន្មាន ?

**ចម្លើយ** តាងព្រឹត្តិការណ៍ $A$ : " ម៉ាស៊ីន $A$ ផលិតវត្ថុ " , $B$ : " ម៉ាស៊ីន $B$ ផលិតវត្ថុ "
$C$ : " ម៉ាស៊ីន $C$ ផលិតវត្ថុ " , $D$ : " វត្ថុខូច "

ក. ប្រូបាបដែលមានវត្ថុខូច

វត្ថុខូចជាវត្ថុដែលខូច ផលិតក្នុងម៉ាស៊ីន $A$, $B$ និង $C$

តាមរូបមន្តប្រូបាបសរុប គេបានប្រូបាបដែលមានវត្ថុខូចគឺ :

$P(D) = P(A\cap D)+P(B\cap D)+P(C\cap D)$




ប្រូបាបដែលវត្ថុខូចផលិតដោយម៉ាស៊ីន $A$ គឺ $P(A\cap D)$

$P(A \cap D) = P(A) \times P(D/A) = 0.50 \times 0.03 = 0.015$

ប្រូបាបដែលវត្ថុខូចផលិតដោយម៉ាស៊ីន $B$ គឺ $P(B \cap D)$

$P(B \cap D) = P(B) \times P(D/B) = 0.30 \times 0.04 = 0.012$

ប្រូបាបដែលវត្ថុខូចផលិតដោយម៉ាស៊ីន $C$ គឺ $P(D \cap C)$

$P(C \cap D) = P(C) \times P(D/C) = 0.20 \times 0.04 = 0.008$

ដូចនេះ $P(D) = 0.015 + 0.012 + 0.008 = 0.035$ ។

ខ. ចំនួនវត្ថុខូចក្នុងម៉ាស៊ីននីមួយៗក្នុងចំណោមវត្ថុខូច 1000

ប្រូបាបដែលម៉ាស៊ីន $A$ ផលិតវត្ថុ ដោយដឹងថាវត្ថុខូចគឺ $P(A/D)$

ប្រូបាបដែលម៉ាស៊ីន $B$ ផលិតវត្ថុ ដោយដឹងថាវត្ថុខូចគឺ $P(B/D)$

ប្រូបាបដែលម៉ាស៊ីន $C$ ផលិតវត្ថុ ដោយដឹងថាវត្ថុខូចគឺ $P(C/D)$

តាមទ្រឹស្តីបទបៃយេស គេបាន :

$$P(A/D) = \frac{P(D/A) \times P(A)}{P(D)} = \frac{0.03 \times 0.50}{0.035} = 0.428$$

$$P(B/D) = \frac{P(D/B) \times P(B)}{P(D)} = \frac{0.04 \times 0.30}{0.035} = 0.343$$

$$P(C/D) = \frac{P(D/C) \times P(C)}{P(D)} = \frac{0.04 \times 0.20}{0.035} = 0.229$$

ក្នុងចំណោមវត្ថុខូច 1000 :
- ម៉ាស៊ីន $A$ ផលិតវត្ថុខូចបានចំនួន $1000 \times 0.428 = 428$
- ម៉ាស៊ីន $B$ ផលិតវត្ថុខូចបានចំនួន $1000 \times 0.343 = 343$
- ម៉ាស៊ីន $C$ ផលិតវត្ថុខូចបានចំនួន $1000 \times 0.229 = 229$

**ប្រតិបត្តិ** ក្នុងក្រូចមួយកញ្ចេមានលាយក្រូចបាត់ដំបង 70 % និងក្រូចកំពង់ចាម 30 % ។ គេដឹងថាក្រូចទាំង 2 ប្រភេទនេះ មានផ្លែខ្លះជូរ ផ្លែខ្លះផ្អែម ។ ក្រូចបាត់ដំបងមានក្រូចជូរ 5 % និងក្រូចកំពង់ចាម 9 % ។

ក. រកប្រូបាបដែលគេជ្រើសរើសក្រូចមួយផ្លែបានក្រូចជូរ

ខ. រកប្រូបាបដែលក្រូចបាត់ដំបង ដោយដឹងថាក្រូចជូរ

គ. រកប្រូបាបដែលក្រូចកំពង់ចាម ដោយដឹងថាក្រូចផ្អែម

ឃ. បើក្នុងកញ្ចេរនេះមានក្រូច 1000 ផ្លែ តើមានក្រូចជូរចំនួនប៉ុន្មានផ្លែ ? ក្រូចជូរជាក្រូចបាត់ដំបងមានប៉ុន្មានផ្លែ ?

# មេរៀនសង្ខេប

- បើ $A$ និង $B$ ជាព្រឹត្តិការណ៍ 2 ក្នុងលំហសំណាកមួយដែល $P(A)\neq 0$ នោះប្រូបាប មានលក្ខខណ្ឌនៃព្រឹត្តិការណ៍ $B$ ដោយដឹងថា $A$ គឺ : $P(B/A)=\dfrac{P(A\cap B)}{P(A)}$
- គេអាចគណនាបានដូចគ្នា $P(A/B)=\dfrac{P(A\cap B)}{P(B)}$ $(P(B)\neq 0)$
- តាមរូបមន្តនេះ គេអាចទាញបានប្រូបាបនៃព្រឹត្តិការណ៍ផលគុណ $A$ និង $B$

  $P(A\cap B)=P(A)\times P(B/A)=P(B)\times P(A/B)$

  $A$ និង $B$ ជាព្រឹត្តិការណ៍ 2 ដែលមានប្រូបាបមិនសូន្យ
- គេថាព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $B$ មិនអាស្រ័យគ្នា កាលណាព្រឹត្តិការណ៍ទាំង 2 ផ្ទៀងផ្ទាត់លក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម :

  1 . $P(A\cap B)=P(A)\times P(B)$ ឬ

  2 . $P(A/B)=P(A)$ ឬ

  3 . $P(B/A)=P(B)$
- គេថាព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $B$ អាស្រ័យគ្នា កាលណា

  $P(A\cap B)\neq P(A)\times P(B)$

**រូបមន្តប្រូបាបសរុប :** $P(B)=\sum_{i=1}^{n}[P(B/A_i)\times P(A_i)]$

**ទ្រឹស្តីបទបៃយេស :** $P(A_k/B)=\dfrac{P(B/A_k)\times P(A_k)}{\sum_{i=1}^{n}[P(B/A_i)\times P(A_i)]}$

## លំហាត់

1. គេបោះគ្រាប់ឡុកឡាក់ 2 គ្រាប់ខុសគ្នា ។ រកប្រូបាបដែលគ្រាប់ឡុកឡាក់មួយចេញលេខ 1 ដោយដឹងថាគ្រាប់ឡុកឡាក់ទាំង 2 ចេញលេខខុសគ្នា ។

2. ថង់មួយមានប៊ូលក្រហម 5 និងប៊ូលខ្មៅ 1 ។ គេចាប់យកប៊ូលម្តងមួយៗចំនួន 3 ដង ដោយចៃដន្យចេញពីថង់ដោយមិនដាក់វិញ ។ គេតាងព្រឹត្តិការណ៍ :

   $A$ : " ប៊ូលយកចេញលើកទី 1 ពណ៌ក្រហម "

   $B$ : " ប៊ូលចាប់លើកទី 2 ពណ៌ក្រហម "

   $C$ : " ប៊ូលចាប់លើកទី 3 ពណ៌ខ្មៅ "

   ក. គណនាប្រូបាបមានលក្ខខណ្ឌ : $P(A/B)$ , $P(C/A\cap B)$ , $P(A/C)$

   ខ. តើព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $C$ អាស្រ័យគ្នា ឬមិនអាស្រ័យគ្នា ?

   គ. តើព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $B$ អាស្រ័យគ្នា ឬមិនអាស្រ័យគ្នា ?

3. ថង់មួយមានកាក់ 100 ដែលកាក់ 25 ត្រឹមត្រូវល្អ និងកាក់ 75 គ្មានលំនឹងល្អ ។ ចំពោះកាក់គ្មានលំនឹងល្អនីមួយៗមានប្រូបាបបោះបានខាងលេខស្មើនឹង $\frac{3}{5}$ ។ គេចាប់យកកាក់មួយចេញពីថង់ដោយចៃដន្យ រួចបោះ ។

   គេតាងព្រឹត្តិការណ៍ $A$ : " ចាប់បានកាក់ល្អ " , $B$ : " ចាប់បានកាក់គ្មានលំនឹងល្អ "

   $C$ : " បោះកាក់បានខាងលេខ "

   ក. គណនាប្រូបាបនៃព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ $B$ ខ. គណនាប្រូបាបនៃព្រឹត្តិការណ៍ $C$

   គ. គណនាប្រូបាបដែលចាប់យកបានកាក់ល្អ ដោយដឹងថាបោះកាក់បានខាងលេខ

4. គ្រូសរសេរសំណួរពីជគណិត និងសំណួរធរណីមាត្រធ្វើជាសន្លឹកឆ្នោតឱ្យសិស្សចាប់ ដើម្បីឆ្លើយយកពិន្ទុដែលប្រូបាបនៃការចាប់បានសំណួរពីជគណិតស្មើនឹងប្រូបាប ដែលចាប់បានសំណួរធរណីមាត្រ ។ គ្រូដឹងថាប្រូបាបដែលសិស្សសុខឆ្លើយត្រូវសំណួរពីជគណិតគឺ 0.7 និងប្រូបាបដែលឆ្លើយសំណួរធរណីមាត្របានត្រឹមត្រូវគឺ 0.5 ។

   ក. រកប្រូបាបដែលសិស្សសុខឆ្លើយត្រូវ

   ខ. គេដឹងហើយថា សុខឆ្លើយសំណួរត្រូវ តើប្រូបាបដែលឆ្លើយត្រូវសំណួរធរណីមាត្រស្មើនឹងប៉ុន្មាន ?

# លំហាត់ជំពូក

1. ក្នុងថង់មួយមានឃ្លី 6 : ឃ្លី 3 មានលេខ 1 ឃ្លី 2 មានលេខ 2 និងឃ្លី 1 មានលេខ 3 ។ គេចាប់យកឃ្លី 2 ព្រមគ្នាដោយចៃដន្យ ។

   ក. ចូរកំណត់លំហសំណាក $S$ និងគណនាប្រូបាបនៃលទ្ធផលនីមួយៗក្នុងលំហសំណាក ។

   ខ. គណនាប្រូបាបដែលយកបានឃ្លី 2 មានលេខខុសគ្នា ? យកបានឃ្លីលេខ 1 តែ 1 គត់ ? យកបានឃ្លីលេខ 1 យ៉ាងតិចម្តង ?

   គ. គណនាប្រូបាបដែលឃ្លីយកចេញមានផលបូកលេខស្មើនឹង 4 ។

2. $A$ និង $B$ ជាព្រឹត្តិការណ៍ក្នុងលំហសំណាក $S$ ។

   គេស្គាល់ប្រូបាបនៃព្រឹត្តិការណ៍ : $P(A) = 0.3$ , $P(B) = 0.5$ , $P(A \cap B) = 0.2$

   ក. គណនា $P(\bar{A})$ , $P(\bar{B})$ , $P(A \cup B)$ , ($\bar{A}$, $\bar{B}$ ជាព្រឹត្តិការណ៍ផ្ទុយនឹង $A$ និង $B$)

   ខ. បង្ហាញថា $A = (A \cap B) \cup (A \cap \bar{B})$ រួចទាញរក $P(A \cap \bar{B})$ និង $P(A \cup \bar{B})$

   គ. គណនា $P(\bar{A} \cap B)$ និង $P(\bar{A} \cup B)$ ។

3. គេរៀបចំឆ្នោត 150 សន្លឹកដើម្បីលក់ឱ្យអស់មុនពេលចេញឆ្នោត ដែលក្នុងនោះមានឆ្នោតត្រូវរង្វាន់ 7 សន្លឹក ។

   ក. បើអ្នកទិញ បានទិញឆ្នោត 1 សន្លឹក តើប្រូបាបដែលគាត់ត្រូវរង្វាន់ស្មើនឹងប៉ុន្មាន ?

   ខ. បើអ្នកទិញបានទិញឆ្នោត 2 សន្លឹក រកប្រូបាបដែលគាត់ត្រូវរង្វាន់យ៉ាងតិច 1 សន្លឹក ?

   គ. ឧបមាថាក្នុងឆ្នោត 150 សន្លឹកនេះមានឆ្នោតត្រូវរង្វាន់ $\frac{1}{10}$ ។ បើគេទិញឆ្នោត 15 សន្លឹក តើគេប្រាកដក្នុងចិត្តថា ពិតជាត្រូវរង្វាន់ទាំង $\frac{1}{10}$ នេះ ឬទេ ? រកប្រូបាបដែលអ្នកមានឆ្នោតត្រូវយ៉ាងតិច 3 សន្លឹក ។

4. ក្នុងកម្មវិធីប្រឡងមួយ គ្រូឱ្យសំណួរត្រៀមទៅសិស្ស 100 សំណួរ ។ សិស្សម្នាក់ៗត្រូវចាប់យកសំណួរ 3 ដោយចៃដន្យដើម្បីឆ្លើយ ។ សិស្ស $A$ រៀបចំដោះស្រាយចម្លើយបាន $\frac{1}{4}$ នៃសំណួរទាំងអស់ ។

   រកប្រូបាបដែលសិស្ស $A$ ចាប់បានសំណួរដែលបានត្រៀមចម្លើយរួចស្រេច :

   ក. 3 សំណួរ

   ខ. 2 សំណួរ

   គ. គ្មានបានសំណួរដែលត្រៀមហើយ 1 សោះ

ឃ. យ៉ាងតិច 1 សំណួរ

5. គេចាប់បៀមួយដៃមាន 8 សន្លឹកចេញពីហ៊ូបៀ 52 សន្លឹក ។

រកប្រូបាបដែលបៀក្នុងដៃមាន :

ក. សន្លឹកជួងតែ 2 នាក់

ខ. សន្លឹកការ៉ូ 2 និងសន្លឹកអាត់ 1

គ. សន្លឹកការ៉ូ 3 និងសន្លឹកស្តេចចាស់ 2 សន្លឹក ។

6. គ្រូចង់ដឹងពីចំណង់ចំណូលចិត្តសិស្សក្នុងវិស័យកីឡា ។ ក្នុងចំណោមសិស្ស 30 នាក់មាន 20 នាក់ចូលចិត្តអានទស្សនាវដ្តីកីឡា 14 នាក់ចូលចិត្តលេងកីឡាផ្ទាល់ និង 8 នាក់ចូលចិត្តទាំង 2 មុខនេះ ។ គ្រូសួរសិស្ស 6 នាក់ដោយចៃដន្យ ។

រកប្រូបាបនៃព្រឹត្តិការណ៍ :

$A$ : " សិស្សទាំង 6 នាក់ចូលចិត្តលេងកីឡា ឬអានទស្សនាវដ្តីកីឡា "

$B$ : " គ្មានសិស្សណាម្នាក់ចូលចិត្តលេងកីឡា "

$C$ : " មានសិស្សម្នាក់គត់ចូលចិត្តលេងកីឡា " ។

7. គេហូតយកបៀ 1 សន្លឹកចេញពីហ៊ូបៀ 32 សន្លឹក ។

គេតាងព្រឹត្តិការណ៍ :

$C$ : " ហូតបៀបានសន្លឹកកឺ "

$R$ : " ហូតបៀបានសន្លឹកស្តេច "

$F$ : " ហូតបៀបានសន្លឹកក្រមុំ ឬប៊ិច "

ក. តើព្រឹត្តិការណ៍ $C$ និង $R$ អាស្រ័យគ្នាឬទេ ?

ខ. គណនា $P(C/F)$ ។

តើព្រឹត្តិការណ៍ $C$ និង $F$ អាស្រ័យគ្នាឬទេ ?

8. ក្នុងភូមិមួយមានមនុស្ស 15 % កើតជំងឺ $M_a$ ។ ក្នុងចំណោមអ្នកកើតជំងឺ $M_a$ មាន 15 % កើតជំងឺ $M_b$ និងក្នុងចំណោមអ្នកមិនកើតជំងឺ $M_a$ មាន 4 % កើតជំងឺ $M_b$ ។

គេសាកសួរមនុស្សម្នាក់ដោយចៃដន្យ និងគេតាងព្រឹត្តិការណ៍ :

$A$ : " អ្នកកើតជំងឺ $M_a$ "

$B$ : " អ្នកកើតជំងឺ $M_b$ "

ក. គណនា $P(A)$ $P(B/A)$ និង $P(B/\bar{A})$

ខ. គណនា $P(B)$ និង $P(A/B)$ ។

9. រោងចក្រមួយផលិតអំពូលអគ្គិសនីដែលមាន 75 % សមតាមខ្នាត និង 25 % ល្អៀងពីខ្នាត ។ គេធ្វើការជ្រើសរើសរៀបចំអំពូលដែលផលិតរួចដាក់ក្នុងប្រអប់ ។ ដោយការត្រួតពិនិត្យនេះមិនបានល្អិតល្អន់ នោះគេដឹងថាក្នុងចំណោមអំពូលល្អៀងពីខ្នាត គេទទួលយករៀបដាក់ក្នុងប្រអប់ 10 % និងក្នុងចំណោមអំពូលសមតាមខ្នាត គេទទួលយករៀបទុក 90 % ។ រកប្រូបាបដែល :

ក. អំពូលមួយត្រូវទទួលយករៀបទុកក្នុងប្រអប់

ខ. អំពូលមួយសមតាមខ្នាត ដោយដឹងថាជាអំពូលត្រូវទទួលយកទុកក្នុងប្រអប់ ។

គ. បើគេផលិតអំពូល 100 តើគេយកអំពូលរៀបដាក់ក្នុងប្រអប់ចំនួនប៉ុន្មាន ? ហើយក្នុងនោះមានអំពូលល្អសមតាមខ្នាតចំនួនប៉ុន្មាន ?

10. គេមានប្រអប់ 2 ដែលប្រអប់ទី $I$ មានឃ្លីពណ៌ស 2 គ្រាប់ខ្មៅ 3 គ្រាប់និងប្រអប់ទី $II$ មានឃ្លីពណ៌ស 3 គ្រាប់ខ្មៅ 4 គ្រាប់ ។ គេជ្រើសរើសប្រអប់មួយដោយចៃដន្យ រួចចាប់យកឃ្លីមួយដោយចៃដន្យចេញពីប្រអប់នេះ ។

ក. រកប្រូបាបដែលចាប់បានឃ្លីពណ៌ស ។

ខ. រកប្រូបាបនៃឃ្លីយកចេញពីថង់ទី $I$ ដោយដឹងថាជាឃ្លីពណ៌ខ្មៅ ។

# ជំពូក 7

# ចំនួនកុំផ្លិច

1. ចំនួនកុំផ្លិចទម្រង់ពីជគណិត
2. ចំនួនកុំផ្លិចទម្រង់ត្រីកោណមាត្រ
3. ស្វ័យគុណទី n និងឫសទី n នៃចំនួនកុំផ្លិច
4. អនុវត្តន៍ចំនួនកុំផ្លិចក្នុងធរណីមាត្រ



នៅអំឡុងឆ្នាំ 1572 អ្នកគណិតវិទ្យាជនជាតិអ៊ីតាលីម្នាក់ឈ្មោះ Rafaelle Bombelli បានបង្ហាញឱ្យឃើញថា សំណុំចំនួនពិត $\mathbb{R}$ មិនទាន់គ្រប់គ្រាន់សម្រាប់បកស្រាយសមីការពីជគណិតដែលមានទម្រង់ $x^2+a=0$ ដែល $a>0$ នោះទេ ។

ដើម្បីដោះស្រាយសមីការនេះ គេត្រូវបង្កើតចំនួនមួយទៀតគឺ $i$ ដែល $i^2=-1$ ។

មេរៀនទី 1

# ចំនួនកុំផ្លិចទម្រង់ពីជគណិត

## 1. សញ្ញាណនៃចំនួនកុំផ្លិច

**វត្ថុបំណង**

- ស្គាល់ចំនួនកុំផ្លិចទម្រង់ពីជគណិត
- គណនាប្រមាណវិធីលើចំនួនកុំផ្លិច
- តាងចំនួនកុំផ្លិចក្នុងប្លង់

ចំនួនកុំផ្លិចជាចំនួនដែលមានរាង $a+bi$ ដែល $a$ និង $b$ ជាចំនួនពិត ។ $i$ ហៅថាឯកតានិមិត្ត ដែល $i^2=-1$ ។ ផលគុណនៃចំនួនពិតខុសពីសូន្យនិង $i$ ហៅថាចំនួននិមិត្ត ។ ដូចជា $-i$ , $7i$ , $\frac{2}{3}i$ ជាចំនួននិមិត្ត ។

ទម្រង់ $a+bi$ ដែល $a$ និង $b$ ជាចំនួនពិត ហៅថាទម្រង់ពីជគណិតនៃចំនួនកុំផ្លិច ។ $a$ ហៅថាផ្នែកពិត ហើយ $b$ ជាផ្នែកនិមិត្ត ។

***ឧទាហរណ៍*** បើគេតាង $z$ ជាចំនួនកុំផ្លិចដែល $z=-2+3i$ នោះ $a=-2$ និង $b=3$ ។

បើគេតាង $z$ ជាចំនួនកុំផ្លិចដែល $z=-3i$ នោះ $a=0$ និង $b=-3$ ។

$4-3i$ ជាចំនួនកុំផ្លិចឆ្លាស់នៃចំនួនកុំផ្លិច $4+3i$ ។

**ជាទូទៅ** បើគេមានចំនួនកុំផ្លិច $z=a+bi$ នោះចំនួនកុំផ្លិចឆ្លាស់នៃ $z$ តាងដោយ $\bar{z}=a-bi$ ។

$-3-i$ ជាចំនួនកុំផ្លិចផ្ទុយនៃ $3+i$

**ជាទូទៅ** ចំនួនកុំផ្លិចផ្ទុយនៃចំនួនកុំផ្លិច $z=a+bi$ គេតាងដោយ $-z=-a-ib$ ។

**លំហាត់គំរូ** រកចំនួនកុំផ្លិចឆ្លាស់និងចំនួនកុំផ្លិចផ្ទុយនៃចំនួនកុំផ្លិច $1-3i$ , $3+4i$ , $24$ និង $-i$ ។

PROEUS DARA


ចម្លើយ

| ចំនួនកុំផ្លិច | ចំនួនកុំផ្លិចឆ្លាស់ | ចំនួនកុំផ្លិចផ្ទុយ |
|---|---|---|
| $1-3i$ | $1+3i$ | $-1+3i$ |
| $3+4i$ | $3-4i$ | $-3-4i$ |
| $24$ | $24$ | $-24$ |
| $-i$ | $i$ | $i$ |

**ប្រតិបត្តិ** រកចំនួនកុំផ្លិចឆ្លាស់និងចំនួនកុំផ្លិចផ្ទុយនៃចំនួនកុំផ្លិច $4+i$ , $3-5i$ , $-12$ និង $3i$ ។

# 2. ប្រមាណវិធីលើចំនួនកុំផ្លិច

## 2.1 វិធីបូកចំនួនកុំផ្លិច

***ឧទាហរណ៍ 1*** $(5+3i)+(-1+2i) = [5+(-1)]+(3+2)i = 4+5i$ ។

***ឧទាហរណ៍ 2*** $(2+5i)+(3-2i) = (2+3)+(5-2)i = 5+3i$ ។

**ជាទូទៅ** ផលបូកនៃចំនួនកុំផ្លិច $(a+bi)+(c+di) = (a+c)+(b+d)i$

## 2.2 វិធីដកចំនួនកុំផ្លិច

***ឧទាហរណ៍ 1*** $(9-2i)-(4-4i) = (9-4)+[-2-(-4)]i = 5+2i$ ។

***ឧទាហរណ៍ 2*** $(6+4i)-(3+6i) = (6-3)+(4-6)i = 3-2i$ ។

**ជាទូទៅ** ផលដកនៃចំនួនកុំផ្លិច $(a+bi)-(c+di) = (a-c)+(b-d)i$

## 2.3 វិធីគុណចំនួនកុំផ្លិច

***ឧទាហរណ៍ 1*** $3i(5-4i) = 15i-12i^2 = 15i-12(-1)$ ដោយ $i^2 = -1$

$= 12+15i$ ។

***ឧទាហរណ៍ 2*** $(2+3i)(4+2i) = 2(4+2i)+3i(4+2i) = 8+4i+12i+6i^2$

$= 8+16i+6(-1)$

$= 2+16i$ ។

**ជាទូទៅ** ផលគុណនៃចំនួនកុំផ្លិច $(a+bi)(c+di) = (ac-bd)+(ad+bc)i$

## 2.4 វិធីចែកចំនួនកុំផ្លិច

***ឧទាហរណ៍ 1*** គណនា $\frac{3}{2+i}$ រួចសរសេរជាទម្រង់ពីជគណិត ។

គេបាន $\frac{3}{2+i} = \frac{3(2-i)}{(2+i)(2-i)} = \frac{6-3i}{4+1} = \frac{6-3i}{5}$

ដូចនេះ $\frac{3}{2+i} = \frac{6}{5}-\frac{3}{5}i$ ។

***ឧទាហរណ៍ 2*** គណនា $\frac{3+2i}{1-3i}$ រួចសរសេរជាទម្រង់ពីជគណិត ។

គេបាន $\frac{3+2i}{1-3i} = \frac{(3+2i)(1+3i)}{(1-3i)(1+3i)}$

ដោយប្រើរូបមន្ត $(a+b)(a-b) = a^2-b^2$

$$\Rightarrow (1-3i)(1+3i) = 1^1-(3i)^2 = 1-9i^2 = 10$$

ដូចនេះ $\frac{3+2i}{1-3i} = \frac{3+9i+2i+6i^2}{10} = \frac{-3+11i}{10} = -\frac{3}{10}+\frac{11}{10}i$ ។

**លំហាត់គំរូ 1** សរសេរចំនួនកុំផ្លិច $z$ ជាទម្រង់ពីជគណិតដែល $z = \frac{-41+63i}{50}-\frac{6i+1}{1-7i}$ ។

**ចម្លើយ** $z = \frac{-41+63i}{50}-\frac{6i+1}{1-7i} = \frac{-41+63i}{50}-\frac{(6i+1)(1+7i)}{(1-7i)(1+7i)}$

$$= \frac{-41+63i}{50}-\frac{6i+42i^2+1+7i}{50}$$

$$= \frac{-41+63i-13i+41}{50}$$

ដូចនេះ $z = i$ ។

**លំហាត់គំរូ 2** គណនាចំនួន $z = \frac{(2-i)(1+i)}{2i(5+3i)}$ ។

**ចម្លើយ** $z = \frac{(2-i)(1+i)}{2i(5+3i)} = \frac{2+2i-i-i^2}{10i+6i^2} = \frac{3+i}{-6+10i}$

$$= \frac{(3+i)(-6-10i)}{(-6+10i)(-6-10i)}$$

$$= \frac{-18-30i-6i-10i^2}{36+100}$$

$$= \frac{-8-36i}{136}$$

ដូចនេះ $z = -\frac{1}{17}-\frac{9}{34}i$ ។

**ប្រតិបត្តិ 1** សរសេរចំនួនកុំផ្លិច $z = \left(\frac{-1+\sqrt{3}i}{2i}\right)^2$ ជាទម្រង់ពីជគណិត ។

**ប្រតិបត្តិ 2** គេមានចំនួនកុំផ្លិច $z_1 = i$ និង $z_2 = \frac{1}{2} + \frac{\sqrt{3}}{2}i$ ។ គណនា $\frac{z_1 + z_2}{1 + z_1 z_2}$ ។

**សំគាល់** ចំនួនកុំផ្លិចពីរ $a + bi$ និង $c + di$ ស្មើគ្នាលុះត្រាតែ $a = c$ និង $b = d$ ។

**ឧទាហរណ៍** គេមានសមីការ $3x - \sqrt{-25} = -6 + 3yi$ ។ គណនា $x$ និង $y$ ។

សរសេរផ្នែកខាងឆ្វេងនៃសមីការជាទម្រង់ពីជគណិត គេបាន $3x - 5i = -6 + 3yi$ ចំនួនកុំផ្លិចទាំងពីរស្មើគ្នា លុះត្រាតែ $3x = -6$ និង $-5 = 3y$ ។

ដូចនេះ $x = -2$ និង $y = -\frac{5}{3}$ ។

## 2.5 លក្ខណៈនៃចំនួនកុំផ្លិចឆ្លាស់

**ឧទាហរណ៍** គេមានចំនួនកុំផ្លិច $z = 2 - i5$ និង $W = -4 + i$

គេបាន $z + w = -2 - 4i \Rightarrow \overline{z + w} = -2 + 4i$

$z - w = 6 - i6 \Rightarrow \overline{z - w} = 6 + i6$

$\bar{Z} = 2 + i5$ ; $\bar{W} = -4 - i \Rightarrow \bar{Z} + \bar{W} = -2 + i4 \Rightarrow \bar{Z} - \bar{W} = 6 + i6$

> **ជាទូទៅ** បើ $Z$ និង $W$ ជាចំនួនកុំផ្លិច គេបាន $\overline{Z \pm W} = \bar{Z} \pm \bar{W}$

**ឧទាហរណ៍** គេមានចំនួនកុំផ្លិច $Z = 5 - i$ និង $W = 2 + 3i$

គេបាន $ZW = (5 - i)(2 + 3i) = (10 + 3) + (15 - 2)i = 13 + i13 \Rightarrow \overline{ZW} = 13 - i13$

$\bar{Z}\bar{W} = (5 + i)(2 - i3) = (10 + 3) + (-15 + 2)i = 13 - i13$

> **ជាទូទៅ** បើ $Z$ និង $W$ ជាចំនួនកុំផ្លិច គេបាន $\overline{ZW} = \bar{Z} \times \bar{W}$

**ឧទាហរណ៍** គេមានចំនួនកុំផ្លិច $Z = 1 - i3$ និង $W = 4 - i$

គេបាន $\frac{Z}{W} = \frac{1 - i3}{4 - i} = \frac{(1 - i3)(4 + i)}{16 + 1} = \frac{(4 + 3) + (1 - 12)i}{17} = \frac{7 - i11}{17}$

$\Rightarrow \overline{\left(\frac{Z}{W}\right)} = \frac{7 + i11}{17}$

$\frac{\bar{Z}}{\bar{W}} = \frac{1 + i3}{4 + i} = \frac{(1 + i3)(4 - i)}{17} = \frac{(4 + 3) + (-1 + 12)i}{17} = \frac{7 + i11}{17}$

> ជាទូទៅ បើ $Z$ និង $W$ ជាចំនួនកុំផ្លិច គេបាន $\overline{\left(\frac{Z}{W}\right)} = \frac{\bar{Z}}{\bar{W}}$

PROEUS DARA

# 3. ចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

## 3.1 ការតាងចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

គេមានតម្រុយអរតូណរមេ $(xoy)$ ។ គេអាចតាងចំនួនកុំផ្លិច $z = a+bi$ ដោយចំណុច M ដែលមានកូអរដោនេ $(a, b)$ ក្នុងតម្រុយនេះ ។




គេថាចំណុច M ជាចំណុចរូបភាពនៃចំនួនកុំផ្លិច $z = a+bi$ គេកំណត់សរសេរ $M(z)$ ។ ម្យ៉ាងទៀតចំនួនកុំផ្លិច $z = a+bi$ អាចតាងដោយវ៉ិចទ័រ $\overrightarrow{OM}(a, b)$ គេថាវ៉ិចទ័រ $\overrightarrow{OM}$ ជាវ៉ិចទ័ររូបភាពនៃចំនួនកុំផ្លិច $z = a+bi$ ហើយកំណត់សរសេរ $\overrightarrow{OM}(z)$ ។

នៅពេលដែលចំណុចក្នុងតម្រុយតាងចំនួនកុំផ្លិច ប្លង់ដែលប្រដាប់ដោយតម្រុយនេះ ហៅថា ប្លង់កុំផ្លិច ។

អ័ក្ស $(x'ox)$ ហៅថាអ័ក្សនៃផ្នែកពិត ហើយអ័ក្ស $(y'oy)$ ហៅថាអ័ក្សនៃផ្នែកនិមិត្ត ។

***ឧទាហរណ៍*** តាងរូបភាពនៃចំនួនកុំផ្លិច $1+i$ , $-1+2i$ និង $-2-i$ ដោយចំណុចក្នុងប្លង់កុំផ្លិច ។




យើងតាងចំណុច $A$, $B$ និង $C$ ជារូបភាពរៀងគ្នានៃចំនួនកុំផ្លិច $1+i$ , $-1+2i$ និង $-2-i$ រូបខាងស្តាំ ។

### - ចំពោះចំនួនកុំផ្លិចឆ្លាស់

***ឧទាហរណ៍*** រូបភាពនៃចំនួនកុំផ្លិច $z = a+bi$ និង $\bar{z} = a-bi$ ។




តាងចំណុច $M$ និង $M'$ ជារូបភាពនៃចំនួនកុំផ្លិច $z$ និង $\bar{z}$ រៀងគ្នាដូចរូបខាងស្តាំ ។

**សន្និដ្ឋាន** ចំនួនកុំផ្លិចពីរឆ្លាស់គ្នា មានរូបភាពឆ្លុះគ្នាធៀបនឹងអ័ក្សពិត ។

**ប្រតិបត្តិ 1** កំណត់រូបភាពនៃចំនួនកុំផ្លិច $2-3i$ , $-4+i$ , $0-2i$ និង $1+0i$ ក្នុងប្លង់កុំផ្លិច

**ប្រតិបត្តិ 2** កំណត់រូបភាពនៃចំនួនកុំផ្លិច $z$, $\bar{z}$ និង $-z$ បើគេឱ្យ $z = -2-3i$ ។

# 4. វិចទ័ររូបភាពនៃផលបូក ផលដកចំនួនកុំផ្លិចនិងផលគុណចំនួនពិតជាមួយនឹងចំនួនកុំផ្លិច

## 4.1 វិចទ័ររូបភាពនៃផលបូកចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

**ឧទាហរណ៍** កំណត់រូបភាពនៃ $z_1+z_2$ ដែល $z_1=2+i$ និង $z_2=1+2i$ ក្នុងប្លង់កុំផ្លិច ។

តាងវិចទ័រ $\overrightarrow{OM_1}$ ជារូបភាពនៃចំនួនកុំផ្លិច $Z_1$

វិចទ័រ $\overrightarrow{OM_2}$ ជារូបភាពនៃចំនួនកុំផ្លិច $Z_2$ ។

គេបាន $z_1+z_2=\overrightarrow{OM_1}+\overrightarrow{OM_2}$

$=\overrightarrow{OM}$ ជាអង្កត់ទ្រូងនៃ ប្រលេឡូក្រាម

( លក្ខណៈផលបូកនៃវិចទ័រ ) ដូចនេះ $\overrightarrow{OM}$ ជារូបភាពនៃ $z_1+z_2$ ។




ផលបូក $z_1+z_2=(2+i)+(1+2i)$

$=3+3i$ ។

## 4.2 វិចទ័ររូបភាពនៃផលដកចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

**ឧទាហរណ៍** កំណត់រូបភាពនៃផលដក $z_1-z_2$ ដែល $z_1=2+i$ និង $z_2=1+2i$ ។

យើងចាត់ទុកថា $z_1-z_2=z_1+(-z_2)$

តាងវិចទ័រ $\overrightarrow{OM_1}$ ជារូបភាពនៃចំនួនកុំផ្លិច $z_1$

វិចទ័រ $\overrightarrow{OM_2}$ ជារូបភាពនៃចំនួនកុំផ្លិច $z_2$ និង

វិចទ័រ $\overrightarrow{OM}$ ជារូបភាពនៃចំនួនកុំផ្លិច

$-z_2=-1-2i$ ។




គេបាន $z_1-z_2=z_1+(-z_2)$

$=\overrightarrow{OM}+\overrightarrow{OM'_2}$

$=\overrightarrow{OM}$ ជារូបភាពនៃផលដក

ចំនួនកុំផ្លិច $z_1-z_2$ ដែលផលដក $z_1-z_2=2+i-(1+2i)=1-i$ ។

**លំហាត់គំរូ** កំណត់រូបភាពនៃ $z_1+z_2$ និង $z_1-z_2$ បើគេឱ្យ $z_1=3+4i$ និង $z_2=-2+3i$ ។

**ចម្លើយ** តាងវ៉ិចទ័រ $\overrightarrow{OA}$ ជារូបភាពនៃចំនួនកុំផ្លិច $z_1$

វ៉ិចទ័រ $\overrightarrow{OB}$ ជារូបភាពនៃចំនួនកុំផ្លិច $z_2$

គេបាន $z_1 + z_2 = \overrightarrow{OA} + \overrightarrow{OB}$

$= \overrightarrow{OC}$ ជាអង្កត់ទ្រូងនៃប្រលេឡូក្រាម ។




ដូចនេះ វ៉ិចទ័រ $\overrightarrow{OC}$ ជារូបភាពនៃចំនួនកុំផ្លិច $z_1 + z_2$ ។

យើងចាត់ទុកថា $z_1 - z_2 = z_1 + (-z_2)$ ។

តាងវ៉ិចទ័រ $\overrightarrow{OB_2}$ ជារូបភាពនៃចំនួនកុំផ្លិច $-z_2 = 2 - 3i$

គេបាន $z_1 - z_2 = z_1 + (-z_2)$

$= \overrightarrow{OA} + \overrightarrow{OB}$

$= \overrightarrow{OM}$

ដូចនេះ វ៉ិចទ័រ $\overrightarrow{OM}$ ជារូបភាពនៃផលដកចំនួនកុំផ្លិច $z_1 - z_2$ ។

**ប្រតិបត្តិ** កំណត់រូបភាពនៃ $z_1 + z_2$ និង $z_1 - z_2$ បើគេឱ្យ $z_1 = 2 + 4i$ និង $z_2 = 1 - 2i$ ។

## 4.3 វ៉ិចទ័ររូបភាពនៃផលគុណចំនួនពិតនឹងចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

***ឧទាហរណ៍*** កំណត់រូបភាពនៃចំនួនកុំផ្លិច $2z$ បើ $z = 2 + i$ ។




តាងវ៉ិចទ័រ $\overrightarrow{OM_1}$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ហើយ $\overrightarrow{OM}$ ជារូបភាពនៃចំនួនកុំផ្លិច $2z$ ។ គេបាន $\overrightarrow{OM} = 2\overrightarrow{OM_1}$ ជារូបភាពនៃ $2z$ ដែល $2z = 2 \times (2 + i) = 4 + 2i$

**លំហាត់គំរូ** គេឱ្យចំនួនកុំផ្លិច $z_1 = 1 - 2i$ និង $z_2 = 2 + 2i$ ។ កំណត់រូបភាពនៃ $-2z_1$ និង $2z_2 + z_1$ ។




**ចម្លើយ** រូបភាពនៃ $-2z_1$

តាងវ៉ិចទ័រ $\overrightarrow{OM_1}$ ជារូបភាពនៃចំនួនកុំផ្លិច $z_1 = 1-2i$ ហើយវ៉ិចទ័រ $\overrightarrow{OM}$ ជារូបភាពនៃ $-2z_1$ ។ គេបាន $\overrightarrow{OM} = -2\overrightarrow{OM_1}$ ដែលជារូបភាពនៃ $-2z_1$ ។ ដែល

$-2z_1 = -2(1-2i) = -2+4i$ ។

រូបភាពនៃ $2z_2+z_1$

តាងវ៉ិចទ័រ $\overrightarrow{OM_2}$ ជារូបភាពនៃ $z_2 = 2+2i$ ហើយវ៉ិចទ័រ $\overrightarrow{OM'}$ ជារូបភាពនៃ $2z_2$ ។ គេបាន $\overrightarrow{OM'} = 2\overrightarrow{OM_2}$ ជារូបភាពនៃ $2z_2$ ។

$2z_2+z_1 = \overrightarrow{OM'}+\overrightarrow{OM_1} = \overrightarrow{ON}$ ជាអង្កត់ទ្រូងនៃប្រលេឡូក្រាម $OM'NM_1$ ។

ម្យ៉ាងទៀត $2z_2+z_1 = 2(2+2i)+1-2i = 5+2i$ ។

**ប្រតិបត្តិ** កំណត់រូបភាពនៃចំនួនកុំផ្លិច $-\frac{1}{2}z$ បើគេឱ្យ $z = 2+4i$ ។

## លំហាត់

1. គណនា $z_1+z_2$ , $z_1-z_2$ , $z_1z_2$ និង $\frac{z_1}{z_2}$ បើ

   ក. $z_1 = 2+5i$ , $z_2 = 1-7i$ ខ. $z_1 = \sqrt{2}-\sqrt{3}i$ , $z_2 = \sqrt{2}+\sqrt{3}i$ ។

2. សរសេរចំនួនកុំផ្លិចខាងក្រោមជាទម្រង់ $a+bi$

   ក. $\frac{13+12i}{6i-8}+\frac{(2i+1)^2}{2+i}$ ខ. $\frac{(i\sqrt{2}-\sqrt{3})(i\sqrt{3}-\sqrt{2})}{1-i}$ គ. $\frac{1+i}{\sqrt{2}-1}\div\frac{1-i}{\sqrt{2}+1}$

3. គណនា $(1+2i)^3$ និង $(3i-4)^4$ ។

4. គេឱ្យ $x$ ជាចំនួនពិត ។ កំណត់តម្លៃ $x$ ដើម្បីឱ្យ $\frac{3+i}{1+i}+\frac{x-i}{1-i}$ ជាចំនួនពិត ។

5. កំណត់រូបភាព តាងចំណុចនៃចំនួនកុំផ្លិច $-1-3i$ , $-1+3i$ , $2$ , $4i$ និង $2-3i$ ក្នុងប្លង់កុំផ្លិច ។

6. គេឱ្យចំនួនកុំផ្លិច $z_1 = 3+2i$ និង $z_2 = 2+4i$ ក្នុងប្លង់កុំផ្លិច ។ កំណត់រូបភាពនៃ

   ក. $z_1+z_2$ ខ. $z_1-z_2$ គ. $2z_2$ ឃ. $z_2+2z_1$ ។

7. កំណត់រូបភាពនៃ $z_1+z_2$ , $z_1-z_2$ , $-2z_1$ បើ $z_1 = 2+i$ និង $z_2 = -2+i$

មេរៀនទី 2

# ចំនួនកុំផ្លិចទម្រង់ត្រីកោណមាត្រ

## 1. ម៉ូឌុលនៃចំនួនកុំផ្លិច

គេឱ្យចំនួនកុំផ្លិច $z = a + bi$ និងចំណុច $M$ ជារូបភាពនៃ $z$ ក្នុងប្លង់កុំផ្លិច $(xoy)$ ។ $OM$ ជាម៉ូឌុលនៃចំនួនកុំផ្លិច យើងនឹងគណនាម៉ូឌុលនេះ ។

តាមរូបភាពខាងក្រោម យើងឃើញថាត្រីកោណ $OMN$ កែងត្រង់ $N$ ។




**ចំណុចបំណង**

- គណនាម៉ូឌុលនិងអាគុយម៉ង់នៃចំនួនកុំផ្លិច
- ស្គាល់ទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច
- គណនាផលគុណនិងផលចែកនៃចំនួនកុំផ្លិចដែលមានទម្រង់ត្រីកោណមាត្រ
- កំណត់រូបភាពនៃចំនួនកុំផ្លិច $z$ តាមបំលែងវិល

តាមទ្រឹស្តីបទពីតាគ័រ គេបាន

$$OM^2 = ON^2 + NM^2$$

$$= a^2 + b^2$$

ដូចនេះ $OM = \sqrt{a^2 + b^2}$ ។

គេតាងម៉ូឌុលនៃ $z$ ដោយ $|z|$ ហើយគេកំណត់សរសេរ $r = |z| = \sqrt{a^2 + b^2}$ ។

**ឧទាហរណ៍** បើចំនួនកុំផ្លិច $z = 4 - 3i$ គេបាន $|z| = \sqrt{4^2 + (-3)^2} = \sqrt{25} = 5$ ។

**សំគាល់** $|a + bi|$ ជាម៉ូឌុលនៃចំនួនកុំផ្លិច $a + bi$ ។

**លំហាត់គំរូ** គេឱ្យចំនួនកុំផ្លិច $z_1 = -1 - 2i$ និង $z_2 = -4i$ គណនា $|z_1|$ និង $|z_2|$ ។

**ចម្លើយ** $|z_1| = \sqrt{(-1)^2 + (-2)^2} = \sqrt{5}$

$|z_2| = \sqrt{0^2 + (-4)^2} = 4$ ។

**ប្រតិបត្តិ** គណនាម៉ូឌុលនៃចំនួនកុំផ្លិច $2+i2\sqrt{3}$ និង $-1-i$ ។

## លក្ខណៈម៉ូឌុលនៃចំនួនកុំផ្លិច

***ឧទាហរណ៍ 1*** គេមានចំនួនកុំផ្លិច $z = 3-4i$ គណនា $|z|$ , $|\bar{z}|$ និង $|-z|$ ។

$z = 3-4i \Rightarrow |z| = \sqrt{3^2+(-4)^2} = \sqrt{9+16} = 5$

$\bar{z} = 3+4i \Rightarrow |\bar{z}| = \sqrt{3^2+4^2} = \sqrt{9+16} = 5$

$-z = -3+4i \Rightarrow |-z| = \sqrt{(-3)^2+4^2} = \sqrt{9+16} = 5$ ។

> **សន្និដ្ឋាន** បើ $z$ ជាចំនួនកុំផ្លិច នោះ $|z| = |\bar{z}|$

***ឧទាហរណ៍ 2*** គេមានចំនួនកុំផ្លិច $z = 2-i$ គណនា $|z|^2$ និង $z\cdot\bar{z}$ ។

$z = 2-i$ គេបាន $\bar{z} = 2+i$

$z = 2-i \Rightarrow |z| = \sqrt{2^2+(-1)^2} = \sqrt{4+1} = \sqrt{5}$

$|z|^2 = (\sqrt{5})^2 = 5$

$z\cdot\bar{z} = (2-i)(2+i) = 4+1 = 5$

> **សន្និដ្ឋាន** បើ $z$ ជាចំនួនកុំផ្លិច នោះ $|z|^2 = z\cdot\bar{z}$

***ឧទាហរណ៍ 3*** គណនា $|z_1|\cdot|z_2|$ និង $|z_1\cdot z_2|$ បើ $z_1 = 1-i$ និង $z_2 = 2+i$ ។

$z_1 = 1-i \Rightarrow |z_1| = \sqrt{1^2+(-1)^2} = \sqrt{2}$

$z_2 = 2+i \Rightarrow |z_2| = \sqrt{2^2+1^2} = \sqrt{5}$ គេបាន $|z_1|\cdot|z_2| = \sqrt{2}\times\sqrt{5} = \sqrt{10}$

$z_1\cdot z_2 = (1-i)(2+i)$

$= 2+i-2i-i^2$ ដោយ $i^2 = -1$

$= 3-i$

$|z_1\cdot z_2| = \sqrt{3^2+(-1)^2} = \sqrt{10}$ ។

> **សន្និដ្ឋាន** បើ $z_1$ និង $z_2$ ជាចំនួនកុំផ្លិច នោះ $|z_1\cdot z_2| = |z_1|\cdot|z_2|$

**ឧទាហរណ៍ 4** គណនា $\frac{|z_1|}{|z_2|}$ និង $\left|\frac{z_1}{z_2}\right|$ បើគេឱ្យ $z_1 = 3+i$ និង $z_2 = 1-i$ ។

$z_1 = 3+i \Rightarrow |z_1| = \sqrt{3^2+1^1} = \sqrt{10}$

$z_2 = 1-i \Rightarrow |z_2| = \sqrt{1^2+(-1)^2} = \sqrt{2}$

គេបាន $\frac{|z_1|}{|z_2|} = \frac{\sqrt{10}}{\sqrt{2}} = \sqrt{5}$

$\frac{z_1}{z_2} = \frac{3+i}{1-i} = \frac{(3+i)(1+i)}{(1-i)(1+i)} = \frac{3+3i+i+i^2}{1+1} = \frac{2+4i}{2} = 1+2i$

គេបាន $\left|\frac{z_1}{z_2}\right| = \sqrt{1^2+2^2} = \sqrt{5}$

| |
|---|
| **សន្និដ្ឋាន** បើ $z_1$ និង $z_2$ ជាចំនួនកុំផ្លិច គេបាន $\left\|\frac{z_1}{z_2}\right\| = \frac{\|z_1\|}{\|z_2\|}$ |

**ឧទាហរណ៍ 5** គណនា $|z_1|+|z_2|$ និង $|z_1+z_2|$ បើគេដឹងថា $z_1 = 3-4i$ និង $z_2 = -1-i\sqrt{3}$ ។

$z_1 = 3-4i \Rightarrow |z_1| = \sqrt{3^2+(-4)^2} = \sqrt{9+16} = 5$

$z_2 = -1+-i\sqrt{3} \Rightarrow |z_2| = \sqrt{(-1)^2+(-\sqrt{3})^2} = \sqrt{1+3} = 2$

គេបាន $|z_1|+|z_2| = 5+2 = 7$

$z_1+z_2 = 3-4i+(-1-i\sqrt{3}) = 2+(-4-\sqrt{3})i$

$|z_1+z_2| = \sqrt{4+(-4-\sqrt{3})^2} = \sqrt{4+16+8\sqrt{3}+3} = \sqrt{23+8\sqrt{3}} < 7$

| |
|---|
| **សន្និដ្ឋាន** បើ $z_1$ និង $z_2$ ជាចំនួនកុំផ្លិចនោះ គេបាន $\|z_1+z_2\| \le \|z_1\|+\|z_2\|$ |

ម្យ៉ាងទៀត គេអាចបកស្រាយតាមន័យធរណីមាត្រ : គេមានចំនួនកុំផ្លិច $z_1$ និង $z_2$ ដែលមានរូបភាពរៀងគ្នា $N_1$ និង $N_2$ ។ $N$ ជាចំណុចដែលកំណត់ដោយ $\overrightarrow{N_1N} = \overrightarrow{ON_2}$ ( រូបខាងស្តាំ )




$ON_1 = |z_1|$ និង $N_1N = ON_2 = |z_2|$ ។

$N$ ជារូបភាពនៃ $z_1+z_2$ ហើយ $ON = |z_1+z_2|$

តាមវិសមភាពក្នុងត្រីកោណ $ON_1N$ គេបាន $ON \le ON_1 + N_1N$

ដូចនេះ $|z_1+z_2| \le |z_1|+|z_1|$ ។

**លំហាត់គំរូ 1** បង្ហាញថា $|z| = |\bar{z}| = |-z|$ និង $|z|^2 = z \cdot \bar{z}$ បើគេឱ្យចំនួនកុំផ្លិច $z = -1 + i\sqrt{3}$ ។

**ចម្លើយ** $z = -1 + i\sqrt{3}$ គេបាន $\bar{z} = -1 - i\sqrt{3}$ និង $-z = 1 - i\sqrt{3}$

$$= -1 + i\sqrt{3} \Rightarrow |z| = \sqrt{(-1)^2 + (\sqrt{3})^2} = \sqrt{1+3} = 2$$

$$\bar{z} = -1 - i\sqrt{3} \Rightarrow |\bar{z}| = \sqrt{(-1)^2 + (-\sqrt{3})^2} = \sqrt{1+3} = 2$$

$$-z = 1 - i\sqrt{3} \Rightarrow |-z| = \sqrt{1^2 + (-\sqrt{3})^2} = \sqrt{1+3} = 2$$

ដូចនេះ $|z| = |\bar{z}| = |-z|$ ។

$|z|^2 = 2^2 = 4$ ហើយ $z \cdot \bar{z} = (-1 + i\sqrt{3})(-1 - i\sqrt{3}) = (-1)^2 - (i\sqrt{3})^2 = 4$

ដូចនេះ $|z|^2 = z \cdot \bar{z}$ ។

**លំហាត់គំរូ 2** គេមានចំនួនកុំផ្លិច $z_1 = -1 + 2i$ និង $z_2 = 1 + i$ ។ ផ្ទៀងផ្ទាត់ថា :

ក. $|z_1 z_2| = |z_1| \cdot |z_2|$ ខ. $\left|\dfrac{z_1}{z_2}\right| = \dfrac{|z_1|}{|z_2|}$ គ. $|z_1 + z_2| \le |z_1| + |z_2|$ ។

**ចម្លើយ** ក. $z_1 = -1 + 2i \Rightarrow |z_1| = \sqrt{(-1)^2 + 2^2} = \sqrt{5}$

$$z_2 = 1 + i \Rightarrow |z_2| = \sqrt{1^2 + 1^2} = \sqrt{2}$$

គេបាន $|z_1| \cdot |z_2| = \sqrt{5} \times \sqrt{2} = \sqrt{10}$ (1)

$$z_1 z_2 = (-1 + 2i)(1 + i) = -1 - i + 2i + 2i^2$$

$$= -3 + i$$

$|z_1 z_2| = \sqrt{(-3)^2 + 1^2} = \sqrt{10}$ (2)

ដូចនេះ តាមទំនាក់ទំនង (1) និង (2) $\Rightarrow |z_1 z_2| = |z_1| \cdot |z_2|$ ។

ខ. $\dfrac{z_1}{z_2} = \dfrac{(-1+2i)(1-i)}{(1+i)(1-i)} = \dfrac{-1 + i + 2i - 2i^2}{1+1} = \dfrac{1+3i}{2} = \dfrac{1}{2} + \dfrac{3}{2}i$ ។

គេបាន $\left|\dfrac{z_1}{z_2}\right| = \sqrt{\left(\dfrac{1}{2}\right)^2 + \left(\dfrac{3}{2}\right)^2} = \sqrt{\dfrac{1}{4} + \dfrac{9}{4}} = \dfrac{\sqrt{10}}{2}$ (1)

$\dfrac{|z_1|}{|z_2|} = \dfrac{\sqrt{5}}{\sqrt{2}} = \dfrac{\sqrt{10}}{2}$ (2)

ដូចនេះ តាមទំនាក់ទំនង (1) និង (2) $\Rightarrow \left|\dfrac{z_1}{z_2}\right| = \dfrac{|z_1|}{|z_2|}$ ។

គ. $z_1 + z_2 = -1 + 2i + (1+i) = 3i$

$|z_1 + z_2| = \sqrt{0^2 + 3^3} = 3 \qquad (1)$

$|z_1| + |z_2| = \sqrt{5} + \sqrt{2} > 3 \qquad (2)$

ដូចនេះ តាមទំនាក់ទំនង (1) និង (2) $\Rightarrow |z_1 + z_2| \le |z_1| + |z_2|$ ។

**ប្រតិបត្តិ 1** គេមានចំនួនកុំផ្លិច $z = 2 - i$ ។ ផ្ទៀងផ្ទាត់ថា $|z| = |\bar{z}| = |-z|$ ។

**ប្រតិបត្តិ 2** គេមានចំនួនកុំផ្លិច $z_1 = 2 + i$ និង $z_2 = -1 - i$ ។ ផ្ទៀងផ្ទាត់ថា :

ក. $|z_1 z_2| = |z_1| \cdot |z_2|$

ខ. $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}$

គ. $|z_1 + z_2| \le |z_1| + |z_2|$ ។

## 2. អាគុយម៉ង់នៃចំនួនកុំផ្លិច




គេមានចំនួនកុំផ្លិច $z = a + bi$ ស្ថិតនៅក្នុងប្លង់កុំផ្លិច ។ តាងវ៉ិចទ័រ $\overrightarrow{OM}$ ជារូបភាពនៃ $z$ ។ មុំដែលកំណត់ដោយ $(\overrightarrow{Ox}, \overrightarrow{OM})$ ហៅថា អាគុយម៉ង់នៃចំនួនកុំផ្លិច $z$ ។ យើងតាង $\varphi$ ឬ $\arg z$ ជា អាគុយម៉ង់នៃ $z$ នេះ ។

$\arg z = \varphi + 2k\pi \quad , \ k \in \mathbb{Z}$

$N$ ជាចំណោលកែងនៃចំណុច $M$ លើអ័ក្សពិត $(ox)$ ក្នុងត្រីកោណកែង $OMN$ កែងត្រង់ $N$ គេបាន :

$\cos\varphi = \frac{a}{r}$ ហើយ $\sin\varphi = \frac{b}{r}$ ដែល $r = |z| = \sqrt{a^2 + b^2}$ ជាម៉ូឌុលនៃ $z$ ។

ដូចនេះ ដើម្បីរកអាគុយម៉ង់នៃ $z$ យើងត្រូវដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} \cos\varphi = \dfrac{a}{r} \\ \sin\varphi = \dfrac{b}{r} \end{cases} \quad \text{ដែល } r = \sqrt{a^2 + b^2} \text{ ។}$$




**ឧទាហរណ៍ 1** រកអាគុយម៉ង់នៃចំនួនកុំផ្លិច

$z = 1 + i\sqrt{3}$ ។

$z = 1 + i\sqrt{3}$ ដែល $a = 1$ និង $b = \sqrt{3}$

គេបាន $r = \sqrt{1^2 + (\sqrt{3})^2} = 2$

$\cos\varphi = \frac{a}{r} = \frac{1}{2}$ ហើយ $\sin\varphi = \frac{b}{r} = \frac{\sqrt{3}}{2}$

ហេតុនេះអាគុយម៉ង់ $\varphi = \frac{\pi}{3}$ ។

**ឧទាហរណ៍ 2** រកអាគុយម៉ង់នៃចំនួនកុំផ្លិច

$z = -1 + i\sqrt{3}$ ។

$z = -1 + i\sqrt{3}$ ដែល $a = -1$ និង $b = \sqrt{3}$ គេបាន $r = \sqrt{(-1)^2 + (\sqrt{3})^2} = 2$




$\cos\varphi = \frac{a}{r} = -\frac{1}{2}$ ហើយ $\sin\varphi = \frac{b}{r} = \frac{\sqrt{3}}{2}$ យើងឃើញថាក្នុងរង្វង់ត្រីកោណមាត្រ $\cos\varphi = -\frac{1}{2} < 0$ និង $\sin\varphi = \frac{\sqrt{3}}{2} > 0$ ត្រូវស្ថិតក្នុងកាដ្រង់ទី 2 ។

ហេតុនេះ $\varphi = \frac{2\pi}{3}$ ។

**លំហាត់គំរូ 1** គេមានចំនួនកុំផ្លិច $z = \cos a - i\sin a$ គណនាអាគុយម៉ង់នៃ $z$ ។

**ចម្លើយ** $z = \cos a - i\sin a$ មាន

$r = \sqrt{(\cos a)^2 + (-\sin a)^2} = 1$ ។

$\cos\varphi = \cos a$ និង $\sin\varphi = -\sin a$

ព្រោះ $\cos\alpha = \cos(-\alpha)$ និង $\sin\alpha = \sin(-a)$

ដូចនេះ $\varphi = -a + 2k\pi$ , $k \in Z$ ។

**លំហាត់គំរូ 2** គេមានចំនួនកុំផ្លិច $z$ ដែលបំពេញលក្ខខណ្ឌ $|z - 5i| = 3$ ។ រកចំនួនកុំផ្លិច $z$ ដែលមានអាគុយម៉ង់វិជ្ជមានតូចបំផុត ។

**ចម្លើយ** តាងចំនួនកុំផ្លិច $z = x + yi$




គេបាន $|x + yi - 5i| = 3 \Leftrightarrow |x + (y-5)i| = 3$

$\sqrt{x^2 + (y-5)^2} = 3$

$x^2 + (y-5)^2 = 9$ ជារង្វង់ដែលមានផ្ចិត $(0, 5)$ និងកាំស្មើនឹង 3 ។

ដើម្បីរកចំណុចតាងឱ្យចំនួនកុំផ្លិច $z$ ដែលមានអាគុយម៉ង់វិជ្ជមានតូចបំផុត យើងត្រូវគូសបន្ទាត់ប៉ះ $OP$ ទៅនឹងរង្វង់ដែលមានផ្ចិត $(0, 5)$ និងកាំស្មើនឹង 3 ។

តាង $Q$ ជាផ្ចិតនៃរង្វង់ ។ តាមចំណុចប៉ះ $P$ គូសចំណោលកែងលើអ័ក្ស $(ox)$ ត្រង់ $N$ និងលើអ័ក្ស $(oy)$ ត្រង់ $M$ ( រូបខាងលើ ) ។

ក្នុងត្រីកោណកែង $MPQ$ កែងត្រង់ $M$ គេបាន $MP^2 = 9 - QM^2$ (1)

ក្នុងត្រីកោណកែង $MPO$ កែងត្រង់ $M$ គេបាន $MP^2 = 16 - MO^2$ (2)

តាម (1) និង (2) : $9 - QM^2 = 16 - MO^2$

$MO^2 - QM^2 = 7$ (3)

ដោយ $QM + MO = 5 \Rightarrow MO = 5 - QM$

សមីការ (3) អាចសរសេរ $(5 - QM)^2 - QM^2 = 7$

$25 - 10QM + QM^2 - QM^2 = 7$

$10QM = 18 \Rightarrow QM = \frac{9}{5}$

$MP^2 = 9 - QM^2 = 9 - \left(\frac{9}{5}\right)^2 = 9 - \frac{81}{25} = \frac{144}{25} \Rightarrow MP = \sqrt{\frac{144}{25}} = \frac{12}{5}$ ។

$ON = MP = \frac{12}{5}$ ហើយ $OM = OQ - QM = 5 - \frac{9}{5} = \frac{16}{5}$ ។

ដូចនេះ ចំណុច $P\left(\frac{12}{5}, \frac{16}{5}\right)$ ជារូបភាពនៃចំនួនកុំផ្លិច $z = \frac{12}{5} + i\frac{16}{5}$ ដែលជាចំនួនកុំផ្លិចមានអាគុយម៉ង់វិជ្ជមានតូចបំផុត ។

**ប្រតិបត្តិ** គណនាអាគុយម៉ង់នៃចំនួនកុំផ្លិច $-i$ និង $-1 + i$ ។

## 3. ទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច

ចំនួនកុំផ្លិច $z = a+bi$ ជាទម្រង់ពីជគណិត យើងអាចសរសេរ $z$ ទៅជាទម្រង់មួយផ្សេងទៀត ។ ដោយ $\cos\varphi = \frac{a}{r} \Rightarrow a = r\cos\varphi$ និង $\sin\varphi = \frac{b}{r} \Rightarrow b = r\sin\varphi$ បើយើងជំនួសតម្លៃ $a = r\cos\varphi$ និង $b = r\sin\varphi$ ក្នុងចំនួនកុំផ្លិច $z = a+bi$ គេបាន ៖

$z = r\cos\varphi + ir\sin\varphi = r(\cos\varphi + i\sin\varphi)$ ហៅថាទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $z$ ។

**ជាទូទៅ** ចំនួនកុំផ្លិច $z = a+bi$ អាចសរសេរជាទម្រង់ត្រីកោណមាត្រ

$$z = r(\cos\varphi + i\sin\varphi)$$

***ឧទាហរណ៍ 1*** បំប្លែងចំនួនកុំផ្លិច $-4+4i$ ជាទម្រង់ត្រីកោណមាត្រ ។




តាង $z = -4+4i$ ដែល $a = -4$ និង $b = 4$

គេបាន $r = \sqrt{16+16} = 4\sqrt{2}$ ដោយ

$\cos\varphi = \frac{a}{r} = -\frac{4}{4\sqrt{2}} = -\frac{\sqrt{2}}{2}$ និង

$\sin\varphi = \frac{b}{r} = \frac{4}{4\sqrt{2}} = \frac{\sqrt{2}}{2}$ ហេតុនេះ $\varphi = \frac{3\pi}{4}$ ។

ដូចនេះ $z = r(\cos\varphi + i\sin\varphi) = 4\sqrt{2}\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)$ ។

***ឧទាហរណ៍ 2*** បំប្លែងចំនួនកុំផ្លិច $2\sqrt{3}-2i$ ជាទម្រង់ត្រីកោណមាត្រ ។




$2\sqrt{3}-2i$ មាន $a = 2\sqrt{3}$ និង $b = -2$

គេបាន $r = \sqrt{(2\sqrt{3})^2 + (-2)^2} = 4$

ដោយ $\cos\varphi = \frac{a}{r} = \frac{2\sqrt{3}}{4} = \frac{\sqrt{3}}{2}$ ហើយ

$\sin\varphi = \frac{b}{r} = -\frac{2}{4} = -\frac{1}{2}$

ហេតុនេះ $\varphi = \frac{11\pi}{6}$ ។

ដូចនេះ $2\sqrt{3}-2i = 4\left(\cos\frac{11\pi}{6}+i\sin\frac{11\pi}{6}\right)$ ។

**លំហាត់គំរូ 1** សរសេរចំនួនកុំផ្លិច $z_1 = 2\cos\frac{7\pi}{4}-2i\sin\frac{\pi}{4}$ និង $z_2 = -\cos\frac{\pi}{17}+i\sin\frac{\pi}{17}$ ជាទម្រង់ត្រីកោណមាត្រ ។

**ចម្លើយ** ដោយ $\cos\frac{7\pi}{4} = \cos\left(-\frac{\pi}{4}\right)$ និង $-\sin\frac{\pi}{4} = \sin\left(-\frac{\pi}{4}\right)$

គេបាន $z_1 = 2\cos\left(-\frac{\pi}{4}\right)+2i\sin\left(-\frac{\pi}{4}\right)$

ដូចនេះ $z_1 = 2\left[\cos\left(-\frac{\pi}{4}\right)+\sin\left(-\frac{\pi}{4}\right)\right]$ ជាទម្រង់ត្រីកោណមាត្រ ។

ដូចគ្នានេះដែរ $-\cos\frac{\pi}{17} = \cos\left(\pi-\frac{\pi}{17}\right) = \cos\frac{16\pi}{17}$ និង $\sin\frac{\pi}{17} = \sin\left(\pi-\frac{\pi}{17}\right) = \sin\frac{16\pi}{17}$

ដូចនេះ $z_2 = \cos\frac{16\pi}{17}+i\sin\frac{16\pi}{17}$ ជាទម្រង់ត្រីកោណមាត្រ ។

**លំហាត់គំរូ 2** គេមានចំនួនកុំផ្លិច $z = 1+\cos\varphi-i\sin\varphi$ ដែល $-\pi+2k\pi<\varphi<\pi+2k\pi$ , $k\in Z$ ។ សរសេរ $z$ ជាទម្រង់ត្រីកោណមាត្រ ។

**ចម្លើយ** ដោយ $1+\cos\varphi = 2\cos^2\frac{\varphi}{2}$ ហើយ $\sin\varphi = 2\sin\frac{\varphi}{2}\cos\frac{\varphi}{2}$

គេបាន $z = 2\cos^2\frac{\varphi}{2}-i2\sin\frac{\varphi}{2}\cos\frac{\varphi}{2} = 2\cos\frac{\varphi}{2}\left(\cos\frac{\varphi}{2}-i\sin\frac{\varphi}{2}\right)$

$$= 2\cos\frac{\varphi}{2}\left[\cos\left(-\frac{\varphi}{2}\right)+i\sin\left(-\frac{\varphi}{2}\right)\right]$$

ដោយ $-\pi+2k\pi<\varphi<\pi+2k\pi$ នោះ $\frac{-\pi}{2}+k\pi<\frac{\varphi}{2}<\frac{\pi}{2}+k\pi$

$\Rightarrow$ $\cos\frac{\varphi}{2}>0$ , $2\cos\frac{\varphi}{2}$ ជាម៉ូឌុលនៃ $z$

ដូចនេះ $z = 2\cos\frac{\varphi}{2}\left[\cos\left(-\frac{\varphi}{2}\right)+i\sin\left(-\frac{\varphi}{2}\right)\right]$ ជាទម្រង់ត្រីកោណមាត្រ ។

**ប្រតិបត្តិ** បំប្លែងចំនួនកុំផ្លិច $z_1 = -2$ និង $z_2 = 2\sqrt{3}-2i$ ជាទម្រង់ត្រីកោណមាត្រ ។

## 4. ផលគុណចំនួនកុំផ្លិចតាមទម្រង់ត្រីកោណមាត្រ

គេមានចំនួនកុំផ្លិច $z_1 = r_1(\cos\varphi_1+i\sin\varphi_1)$ និង $z_2 = r_2(\cos\varphi_2+i\sin\varphi_2)$ ។

គេបាន $z_1z_2 = [r_1(\cos\varphi_1+i\sin\varphi_1)][r_2(\cos\varphi_2+i\sin\varphi_2)]$

$$= r_1r_2(\cos\varphi_1+i\sin\phi_1)(\cos\varphi_2+i\sin\varphi_2)$$

$$= r_1r_2(\cos\varphi_1\cos\varphi_2+i\sin\varphi_2\cos\varphi_1+i\sin\varphi_1\cos\varphi_2+i^2\sin\varphi_1\sin\varphi_2)$$

$$= r_1r_2(\cos\varphi_1\cos\varphi_2 - \sin\varphi_1\sin\varphi_2 + i\sin\varphi_1\cos\varphi_2 + i\sin\varphi_2\cos\varphi_1)$$

$$= r_1r_2[\cos\varphi_1\cos\varphi_2 - \sin\varphi_1\sin\varphi_2 + i(\sin\varphi_1\cos\varphi_2 + \sin\varphi_2\cos\varphi_1)]$$

តែ $\cos\varphi_1\cos\varphi_2 - \sin\varphi_1\sin\varphi_2 = \cos(\varphi_1+\varphi_2)$

$\sin\varphi_1\cos\varphi_2 + \cos\varphi_1\sin\varphi_2 = \sin(\varphi_1+\varphi_2)$

ដូចនេះ $z_1z_2 = r_1r_2[\cos(\varphi_1+\varphi_2) + i\sin(\varphi_1+\varphi_2)]$

**ជាទូទៅ** បើ $z_1 = r_1(\cos\varphi_1 + i\sin\varphi_1)$ និង $z_2 = r_2(\cos\varphi_2 + i\sin\varphi_2)$

នោះគេបាន $z_1z_2 = r_1r_2[\cos(\varphi_1+\varphi_2) + i\sin(\varphi_1+\varphi_2)]$

## ន័យធរណីមាត្រនៃផលគុណចំនួនកុំផ្លិច

- $|z_1z_2| = |z_1|\cdot|z_2|$
- $\arg z_1z_2 = \arg z_1 + \arg z_2$ ។




***ឧទាហរណ៍ 1*** គេមានចំនួនកុំផ្លិច

$z_1 = \sqrt{2}\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)$ និង $z_2 = 2\left(\cos\frac{4\pi}{3} + i\sin\frac{4\pi}{3}\right)$

គណនា $z_1z_2$ ។

គេបាន $z_1z_2 = \sqrt{2}\times 2\left[\cos\left(\frac{3\pi}{4}+\frac{4\pi}{3}\right) + i\sin\left(\frac{3\pi}{4}+\frac{4\pi}{3}\right)\right]$

$$= 2\sqrt{2}\left(\cos\frac{25\pi}{12} + i\sin\frac{25\pi}{12}\right)$$

ដូចនេះ $z_1z_2 = 2\sqrt{2}\left(\cos\frac{25\pi}{12} + i\sin\frac{25\pi}{12}\right)$

***ឧទាហរណ៍ 2*** គេមានចំនួនកុំផ្លិច $z_1 = \sqrt{2}\left(\cos\frac{11\pi}{4} + i\sin\frac{11\pi}{4}\right)$ និង $z_2 = \sqrt{8}\left(\cos\frac{3\pi}{8} + i\sin\frac{3\pi}{8}\right)$

គណនា $z_1z_2$ ។

គេបាន $z_1z_2 = \sqrt{2}\times\sqrt{8}\left[\cos\left(\frac{11\pi}{4}+\frac{3\pi}{8}\right) + i\sin\left(\frac{11\pi}{4}+\frac{3\pi}{8}\right)\right]$

$$= 4\left(\cos\frac{25\pi}{8} + i\sin\frac{25\pi}{8}\right)$$

ដូចនេះ $z_1z_2 = 4\left(\cos\frac{25\pi}{8} + i\sin\frac{25\pi}{8}\right)$ ។

**លំហាត់គំរូ 1** គេមានចំនួនកុំផ្លិចទម្រង់ពីជគណិត $z_1 = 2\sqrt{3} - 2i$ និង $z_2 = -1 + i\sqrt{3}$ ។ ប្រើទម្រង់ត្រីកោណមាត្រនៃ $z_1$ និង $z_2$ គណនាផលគុណ $z_1 z_2$ ។

**ចម្លើយ** $z_1 = 2\sqrt{3} - 2i$ ដែល $a = 2\sqrt{3}$ និង $b = -2$ គេបាន $r = \sqrt{12+4} = 4$

ដោយ $\cos\varphi = \frac{a}{r} = \frac{2\sqrt{3}}{4} = \frac{\sqrt{3}}{2}$ និង $\sin\varphi = \frac{b}{r} = -\frac{2}{4} = -\frac{1}{2}$ ហេតុនេះ $\varphi = -\frac{\pi}{6}$ ឬ $\varphi = \frac{11\pi}{6} \Rightarrow z_1 = 2\sqrt{3} - 2i = 4\left[\cos\left(-\frac{\pi}{6}\right) + i\sin\left(-\frac{\pi}{6}\right)\right]$ ។

$z_2 = -1 + i\sqrt{3}$ ដែល $a = -1$ និង $b = \sqrt{3}$ គេបាន $r = \sqrt{1+3} = 2$

ដោយ $\cos\varphi = \frac{a}{r} = -\frac{1}{2}$ និង $\sin\varphi = \frac{b}{r} = \frac{\sqrt{3}}{2}$ ហេតុនេះ $\varphi = \frac{2\pi}{3}$ ។

$$\Rightarrow z_2 = -1 + i\sqrt{3} = 2\left(\cos\frac{2\pi}{3} + i\sin\frac{2\pi}{3}\right) \text{ ។}$$

$$z_1 z_2 = 4 \times 2\left[\cos\left(-\frac{\pi}{6} + \frac{2\pi}{3}\right) + \sin\left(-\frac{\pi}{6} + \frac{2\pi}{3}\right)\right] \text{ ។}$$

$$= 8\left(\cos\frac{3\pi}{6} + i\sin\frac{3\pi}{6}\right)$$

$$= 8\left(\cos\frac{\pi}{2} + i\sin\frac{\pi}{2}\right)$$

ដូចនេះ $z_1 z_2 = 8\left(\cos\frac{\pi}{2} + i\sin\frac{\pi}{2}\right)$ ។

**លំហាត់គំរូ 2** គេមានចំនួនកុំផ្លិច $z_1 = 1 + i$ និង $z_2 = 1 + i\sqrt{3}$ គណនា $\cos\frac{7\pi}{12}$ និង $\sin\frac{7\pi}{12}$ ។

**ចម្លើយ** $z_1 = 1 + i \Rightarrow r = \sqrt{1+1} = \sqrt{2}$

ដោយ $\cos\varphi = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$ និង $\sin\varphi = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$ ហេតុនេះ $\varphi = \frac{\pi}{4}$ ។

គេបាន $z_1 = \sqrt{2}\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)$ ។

$z_2 = 1 + i\sqrt{3} \Rightarrow r = \sqrt{1+3} = 2$

ដោយ $\cos\varphi = \frac{1}{2}$ និង $\sin\varphi = \frac{\sqrt{3}}{2}$ ហេតុនេះ $\varphi = \frac{\pi}{3}$ ។

គេបាន $z_2 = 2\left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)$ ។

$$z_1 z_2 = 2\sqrt{2}\left[\cos\left(\frac{\pi}{4} + \frac{\pi}{3}\right) + i\sin\left(\frac{\pi}{4} + \frac{\pi}{3}\right)\right]$$

$$= 2\sqrt{2}\left(\cos\frac{7\pi}{12} + i\sin\frac{7\pi}{12}\right)$$

$$= 2\sqrt{2}\cos\frac{7\pi}{12} + i\left(2\sqrt{2}\cos\frac{7\pi}{12}\right)$$

ម្យ៉ាងទៀត $z_1z_2 = (1+i)(1+i\sqrt{3})$

$= 1+i\sqrt{3}+i-\sqrt{3}$

$= 1-\sqrt{3}+i(1+\sqrt{3}) \qquad (2)$

ប្រៀបធៀប (1) និង (2) គេអាចទាញបាន

$$2\sqrt{2}\cos\frac{7\pi}{12} = 1-\sqrt{3} \Rightarrow \cos\frac{7\pi}{12} = \frac{1-\sqrt{3}}{2\sqrt{2}} = \frac{\sqrt{2}-\sqrt{6}}{4}$$

$$2\sqrt{2}\sin\frac{7\pi}{12} = 1+\sqrt{3} \Rightarrow \sin\frac{7\pi}{12} = \frac{1+\sqrt{3}}{2\sqrt{2}} = \frac{\sqrt{2}+\sqrt{6}}{4}$$

ដូចនេះ $\cos\frac{7\pi}{12} = \frac{\sqrt{2}-\sqrt{6}}{4}$ និង $\sin\frac{7\pi}{12} = \frac{\sqrt{2}+\sqrt{6}}{4}$ ។

**ប្រតិបត្តិ 1** គេមានចំនួនកុំផ្លិច $z_1 = 1+i$ និង $z_2 = -1+i\sqrt{3}$ ។ ប្រើទម្រង់ត្រីកោណមាត្រនៃ $z_1$ និង $z_2$ គណនា $z_1z_2$ ។

**ប្រតិបត្តិ 2** គេមាន $z_1 = 6\left(\cos\frac{5\pi}{12}+i\sin\frac{5\pi}{12}\right)$ និង $z_2 = 2\left(\cos\frac{\pi}{12}+i\sin\frac{\pi}{12}\right)$ ។ គណនា $z_1z_2$ រួចសរសេរជាទម្រង់ $a+bi$ ។

## 5. ផលចែកចំនួនកុំផ្លិចតាមទម្រង់ត្រីកោណមាត្រ

សង្កេតចំនួនកុំផ្លិចឆ្លាស់នៃចំនួនកុំផ្លិច $z$ បើ $z = r(\cos\varphi+i\sin\varphi)$

$= (r\cos\varphi)+i(r\sin\varphi)$

គេបាន $\bar{z} = (r\cos\varphi)-i(r\sin\varphi) = r\cos(-\varphi)+i[r\sin(-\varphi)]$

ដូចនេះ ចំនួនកុំផ្លិចឆ្លាស់នៃ $z = r(\cos\varphi+i\sin\varphi)$ គឺ $\bar{z} = r[\cos(-\varphi)+i\sin(-\varphi)]$ ។

គេមានចំនួនកុំផ្លិច $z_1 = r_1(\cos\varphi_1+i\sin\varphi_1)$ និង $z_2 = r_2(\cos\varphi_2+i\sin\varphi_2)$ ។

គេបាន $\frac{z_1}{z_2} = \frac{z_1}{z_2}\times\frac{\bar{z_2}}{\bar{z_2}} = \frac{r_1(\cos\varphi_1+i\sin\varphi_1)}{r_2(\cos\varphi_2+i\sin\varphi_2)}\times\frac{r_2[\cos(-\varphi_2)+i\sin(-\varphi_2)]}{r_2[\cos(-\varphi_2)+i\sin(-\varphi_2)]}$

$$= \frac{r_1r_2[\cos\varphi_1\cos(-\varphi_2)+i\cos\varphi_1\sin(-\varphi_2)+i\sin\varphi_1\cos(-\varphi_2)+i^2\sin\varphi_1\sin(-\varphi_2)]}{r_2r_2[\cos\varphi_2\cos(-\varphi_2)+i\cos\varphi_2\sin(-\varphi_2)+i\sin\varphi_2\cos(-\varphi_2)+i^2\sin\varphi_2\sin(-\varphi_2)]}$$

$$= \frac{r_1[\cos\varphi_1\cos(-\varphi_2)-\sin\varphi_1\sin(-\varphi_2)+i(\cos\varphi_1\sin(-\varphi_2)+\sin\varphi_1\cos(-\varphi_2))]}{r_2[\cos\varphi_2\cos(-\varphi_2)-\sin\varphi_2\sin(-\varphi_2)+i(\cos\varphi_2\sin(-\varphi_2)+\sin\varphi_2\cos(-\varphi_2))]}$$

$$= \frac{r_1[\cos(\varphi_1-\varphi_2)+i\sin(\varphi_1-\varphi_2)]}{r_2(\cos 0+i\sin 0)}$$

$$= \frac{r_1}{r_2}[\cos(\varphi_1-\varphi_2)+i\sin(\varphi_1-\varphi_2)]$$

ដូចនេះ $\frac{z_1}{z_2} = \frac{r_1}{r_2}[\cos(\varphi_1 - \varphi_2) + i\sin(\varphi_1 - \varphi_2)]$ ។

**ជាទូទៅ** បើគេមានចំនួនកុំផ្លិច $z_1 = r_1(\cos\varphi_1 + i\sin\varphi_1)$ និង $z_2 = r_2(\cos\varphi_2 + i\sin\varphi_2)$ ដែល $z_2 \neq 0$ នោះគេបាន $\frac{z_1}{z_2} = \frac{r_1}{r_2}[\cos(\varphi_1 - \varphi_2) + i\sin(\varphi_1 - \varphi_2)]$ ។

ន័យធរណីមាត្រនៃផលចែកចំនួនកុំផ្លិច

- $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}$
- $\arg\frac{z_1}{z_2} = \arg z_1 - \arg z_2$ ។




**ឧទាហរណ៍ 1** គេមានចំនួនកុំផ្លិច

$z_1 = \sqrt{2}\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)$ និង $z_2 = 2\left(\cos\frac{4\pi}{3} + i\sin\frac{4\pi}{3}\right)$ ។

គេបាន $$\frac{z_1}{z_2} = \frac{\sqrt{2}\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)}{2\left(\cos\frac{4\pi}{3} + i\sin\frac{4\pi}{3}\right)} = \frac{\sqrt{2}}{2}\left[\cos\left(\frac{3\pi}{4} - \frac{4\pi}{3}\right) + i\sin\left(\frac{3\pi}{4} - \frac{4\pi}{3}\right)\right]$$

$$= \frac{\sqrt{2}}{2}\left[\cos\left(-\frac{7\pi}{12}\right) + i\sin\left(-\frac{7\pi}{12}\right)\right]$$

ដូចនេះ $\frac{z_1}{z_2} = \frac{\sqrt{2}}{2}\left[\cos\left(-\frac{7\pi}{12}\right) + i\sin\left(-\frac{7\pi}{12}\right)\right]$ ។

**ឧទាហរណ៍ 2** សរសេរចំនួន $z = \frac{-1+i}{\cos\frac{\pi}{3} + i\sin\frac{\pi}{3}}$ ជាទម្រង់ត្រីកោណមាត្រ ។

តាង $z_1 = -1 + i$ និង $z_2 = \cos\frac{\pi}{3} + i\sin\frac{\pi}{3}$ ។

ចំនួន $z_1 = -1 + i$ ជាទម្រង់ត្រីកោណមាត្រ គេបាន $r = \sqrt{(-1)^2 + 1^2} = \sqrt{2}$

ដោយ $\cos\varphi = \frac{a}{r} = -\frac{1}{\sqrt{2}} = -\frac{\sqrt{2}}{2}$ និង $\sin\varphi = \frac{b}{r} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$ ហេតុនេះ $\varphi = \frac{3\pi}{4}$ ។

គេបាន $z_1 = \sqrt{2}\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)$ ។

$$\Rightarrow \frac{z_1}{z_2} = \frac{\sqrt{2}\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)}{\cos\frac{\pi}{3} + i\sin\frac{\pi}{3}} = \sqrt{2}\left[\cos\left(\frac{3\pi}{4} - \frac{\pi}{3}\right) + i\sin\left(\frac{3\pi}{4} - \frac{\pi}{3}\right)\right]$$

$$= \sqrt{2}\left(\cos\frac{5\pi}{12} + i\sin\frac{5\pi}{12}\right)$$

ដូចនេះ $z = \frac{z_1}{z_2} = \sqrt{2}\left(\cos\frac{5\pi}{12} + i\sin\frac{5\pi}{12}\right)$ ។

**លំហាត់គំរូ 1** សរសេរចំនួន $z = \frac{1+i\sqrt{3}}{2i(\cos 60^\circ + i\sin 60^\circ)}$ ជាទម្រង់ត្រីកោណមាត្រ ។

**ចម្លើយ** $z = \frac{1+i\sqrt{3}}{2i(\cos 60^\circ + i\sin 60^\circ)} = \frac{1+i\sqrt{3}}{2i\left(\frac{1}{2}+i\frac{\sqrt{3}}{2}\right)} = \frac{1}{i}$

តែ $i = \cos\frac{\pi}{2} + i\sin\frac{\pi}{2}$ និង $1 = \cos 2\pi + i\sin 2\pi$ ។

គេបាន $z = \frac{\cos 2\pi + i\sin 2\pi}{\cos\frac{\pi}{2} + i\sin\frac{\pi}{2}}$

$= \cos\left(2\pi - \frac{\pi}{2}\right) + i\sin\left(2\pi - \frac{\pi}{2}\right)$

$= \cos\frac{3\pi}{2} + i\sin\frac{3\pi}{2}$

ដូចនេះ $z = \cos\frac{3\pi}{2} + i\sin\frac{3\pi}{2}$ ។

**លំហាត់គំរូ 2** គេមានចំនួនកុំផ្លិច $z_1 = -1 + i\sqrt{3}$ និង $z_2 = 1 + i$ គណនា $\cos\frac{5\pi}{12}$ និង $\sin\frac{5\pi}{12}$ ។

**ចម្លើយ** $z_1 = -1 + i\sqrt{3} \Rightarrow r = \sqrt{(-1)^2 + (\sqrt{3})^2} = 2$

ដោយ $\cos\varphi = \frac{a}{r} = -\frac{1}{2}$ និង $\sin\varphi = \frac{b}{r} = \frac{\sqrt{3}}{2}$ ហេតុនេះ $\varphi = \frac{2\pi}{3}$ ។

គេបាន $z_1 = -1 + i\sqrt{3} = 2\left(\cos\frac{2\pi}{3} + i\sin\frac{2\pi}{3}\right)$ ។

$z_2 = 1 + i \Rightarrow r = \sqrt{1+1} = \sqrt{2}$

ដោយ $\cos\varphi = \frac{a}{r} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$ និង $\sin\varphi = \frac{b}{r} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$ ហេតុនេះ $\varphi = \frac{\pi}{4}$ ។

គេបាន $z_2 = 1 + i = \sqrt{2}\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)$

$\Rightarrow \frac{z_1}{z_2} = \frac{2\left(\cos\frac{2\pi}{3} + i\sin\frac{2\pi}{3}\right)}{\sqrt{2}\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)}$

$= \sqrt{2}\left[\cos\left(\frac{2\pi}{3} - \frac{\pi}{4}\right) + i\sin\left(\frac{2\pi}{3} - \frac{\pi}{4}\right)\right]$

$= \sqrt{2}\left(\cos\frac{5\pi}{12} + i\sin\frac{5\pi}{12}\right)$

$= \sqrt{2}\cos\frac{5\pi}{12} + i\sqrt{2}\sin\frac{5\pi}{12}$ (1)

ម្យ៉ាងទៀត $\frac{z_1}{z_2} = \frac{-1+i\sqrt{3}}{1+i} = \frac{(-1+i\sqrt{3})(1-i)}{(1+i)(1-i)}$

$$= \frac{-1+i+i\sqrt{3}-i^2\sqrt{3}}{1+1}$$

$$= \frac{-1+\sqrt{3}}{2} + i\left(\frac{1+\sqrt{3}}{2}\right) \qquad (2)$$

ប្រៀបធៀប (1) និង (2) យើងអាចទាញបាន

$$\sqrt{2}\cos\frac{5\pi}{12} = \frac{-1+\sqrt{3}}{2} \Rightarrow \cos\frac{5\pi}{12} = \frac{-1+\sqrt{3}}{2\sqrt{2}} = \frac{\sqrt{6}-\sqrt{2}}{4}$$

$$\sqrt{2}\sin\frac{5\pi}{12} = \frac{1+\sqrt{3}}{2} \Rightarrow \sin\frac{5\pi}{12} = \frac{1+\sqrt{3}}{2\sqrt{2}} = \frac{\sqrt{6}+\sqrt{2}}{4} \text{ ។}$$

ដូចនេះ $\cos\frac{5\pi}{12} = \frac{\sqrt{6}-\sqrt{2}}{4}$ និង $\sin\frac{5\pi}{12} = \frac{\sqrt{6}+\sqrt{2}}{4}$ ។

**ប្រតិបត្តិ 1** គេមានចំនួន $z_1 = 6\left(\cos\frac{5\pi}{12} + i\sin\frac{5\pi}{12}\right)$ និង $z_2 = 5\left(\cos\frac{\pi}{12} + i\sin\frac{\pi}{12}\right)$ ។

គណនាផលចែក $\frac{z_1}{z_2}$ ។

**ប្រតិបត្តិ 2** គេមានចំនួនកុំផ្លិច $z_1 = i$ និង $z_2 = \frac{\sqrt{3}}{2} + i\frac{1}{2}$ ។ ប្រើទម្រង់ត្រីកោណមាត្រនៃ $z_1$ និង $z_2$ គណនាផលចែក $\frac{z_1}{z_2}$ ។

## 6. បំលែងវិលជុំវិញគល់តម្រុយនៃប្លង់កុំផ្លិច

ចំនួនកុំផ្លិច $z = \cos\varphi + i\sin\varphi$ មានរូបភាពកំណត់ដោយចំណុច $M$ ។ គេឱ្យចំណុច $M$ ផ្លាស់ទីទៅកាន់ចំណុច $M'$ ដែលជារូបភាពនៃចំនួនកុំផ្លិច $z' = \left(\cos\frac{\pi}{6} + i\sin\frac{\pi}{6}\right)z$ ។

កំណត់ទីតាំងនៃចំណុច $M'$




$$z' = \left(\cos\frac{\pi}{6} + i\sin\frac{\pi}{6}\right)z$$

$$= \left(\cos\frac{\pi}{6} + i\sin\frac{\pi}{6}\right)(\cos\varphi + i\sin\varphi)$$

$$= \cos\left(\varphi + \frac{\pi}{6}\right) + i\sin\left(\varphi + \frac{\pi}{6}\right)$$

ដូចនេះ ចំណុច $M'$ ជារូបភាពនៃចំនួនកុំផ្លិច

$z' = \cos\left(\varphi + \frac{\pi}{6}\right) + i\sin\left(\varphi + \frac{\pi}{6}\right)$ ដែល $(\vec{ox}, \vec{oM}) = \varphi$ ហើយ $(\vec{ox}, \vec{oM'}) = \varphi + \frac{\pi}{6}$ ។

គេថាចំណុច $M'$ ជារូបភាពនៃ $M$ តាមបម្លាស់ទីដោយវិលជុំវិញគល់ $O$ តាមមុំ $\frac{\pi}{6}$ ។

បម្លាស់ទីបែបនេះហៅថា បំលែងវិលផ្ចិត $O$ មុំ $\frac{\pi}{6}$ ។

**ជាទូទៅ** មានចំនួនកុំផ្លិច $z = \cos\alpha + i\sin\alpha$

បើ $M'(z')$ ជារូបភាពនៃ $M(z)$ តាមបំលែងវិលផ្ចិត $O$

($O$ ជាគល់តម្រុយ ) និងមុំ $\alpha$ នោះ $z' = (\cos\alpha + i\sin\alpha)z$ ។

**លំហាត់គំរូ 1** នៅក្នុងប្លង់កុំផ្លិច $xOy$ ចំណុច $M$ ជារូបភាពនៃចំនួនកុំផ្លិច $z = 1+i$ និង $M'$ ជារូបភាពនៃចំនួនកុំផ្លិច $z'$ ។ កំណត់ $z'$ ដើម្បីឱ្យ $M'$ ជារូបភាពនៃ $M$ តាមបំលែងវិលផ្ចិត $O$ មុំ $\frac{\pi}{3}$ ។

**ចម្លើយ** ចំណុច $M'$ ជារូបភាពនៃចំនួនកុំផ្លិច $z' = \left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)z$

តែ $z = 1+i$ មាន $r = \sqrt{1+1} = \sqrt{2}$

ដោយ $\cos\varphi = \frac{a}{r} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$ និង $\sin\varphi = \frac{b}{r} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$ ហេតុនេះ $\varphi = \frac{\pi}{4}$ ។

គេបាន $z = \sqrt{2}\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)$

$$z' = \left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)\sqrt{2}\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)$$

$$= \sqrt{2}\left[\cos\left(\frac{\pi}{3} + \frac{\pi}{4}\right) + i\sin\left(\frac{\pi}{3} + \frac{\pi}{4}\right)\right]$$

$$= \sqrt{2}\left(\cos\frac{7\pi}{12} + i\sin\frac{7\pi}{12}\right)$$

ដូចនេះ $z' = \sqrt{2}\left(\cos\frac{7\pi}{12} + i\sin\frac{7\pi}{12}\right)$ ។




ម្យ៉ាងទៀត យើងអាចកំណត់ $z'$

ដោយ $z' = \left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)z$

$$= \left(\frac{1}{2} + i\frac{\sqrt{3}}{2}\right)(1+i)$$

$$= \frac{1}{2} + i\frac{1}{2} + i\frac{\sqrt{3}}{2} - \frac{\sqrt{3}}{2}$$

$$= \frac{1-\sqrt{3}}{2} + i\left(\frac{1}{2} + \frac{\sqrt{3}}{2}\right)$$ ។



**លំហាត់គំរូ 2** នៅក្នុងប្លង់កុំផ្លិច $(xoy)$ ចំណុច $M$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ហើយ $M'$ ជារូបភាពនៃ $z' = \frac{\sqrt{2}}{4}(z+iz)$ ដោយដឹងថា $M'$ ជារូបភាពនៃ $M$ តាមបំលែងវិលផ្ចិត $O$ ។ ចូរកំណត់មុំនៃបំលែងវិល ។

**ចម្លើយ** $z' = \frac{\sqrt{2}}{4}(z+iz) = \frac{1}{2}\left(\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2}\right)z$

$$z' = \frac{1}{2}\left(\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2}\right)z = \frac{1}{2}\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)z$$




នេះបញ្ជាក់ថា $M'$ ជារូបភាពនៃ $M$ តាមបំលែងវិលមុំ $\frac{\pi}{4}$ ហើយ $\frac{1}{2}\left(\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2}\right)z$ មានម៉ូឌុលស្មើនឹង $\frac{1}{2}$ នៃម៉ូឌុល $z$ ។

**លំហាត់គំរូ 3** $M'$ ជារូបភាពនៃចំនួនកុំផ្លិច $z' = -1+i\sqrt{3}$ និង $M$ ជារូបភាពនៃចំនួនកុំផ្លិច $z = 2i$ ។ ដោយដឹងថា $M'$ ជារូបភាពនៃ $M$ តាមបំលែងវិលផ្ចិត $O$ ចូរកំណត់មុំនៃការបំលែងវិលនោះ ។

**ចម្លើយ** តាង $\varphi$ ជាមុំនៃបំលែងវិល គេបាន

$$z' = (\cos\varphi + i\sin\varphi)z \Rightarrow \cos\varphi + i\sin\varphi = \frac{z'}{z}$$




តែ $\frac{z'}{z} = \frac{-1+i\sqrt{3}}{2i}$

$$= \frac{(-1+i\sqrt{3})(-2i)}{(2i)(-2i)}$$

$$= \frac{2i-i^2 2\sqrt{3}}{4}$$

$$= \frac{2i+2\sqrt{3}}{4}$$

$$= \frac{\sqrt{3}}{2}+i\frac{1}{2} \text{ ។}$$

$$= \cos\frac{\pi}{6}+i\sin\frac{\pi}{6}$$

ដូចនេះ $\cos\varphi + i\sin\varphi = \cos\frac{\pi}{6}+i\sin\frac{\pi}{6} \Rightarrow \varphi = \frac{\pi}{6}$ ។

គេអាចគណនា $\varphi$ មុំនៃការវិលតាមវិធីមួយទៀត

$z' = -1 + i\sqrt{3}$ ដែល $a = -1$ និង $b = \sqrt{3}$ មានម៉ូឌុល $r = \sqrt{(-1)^2 + (\sqrt{3})^2} = 2$

ដោយ $\cos\alpha = \frac{a}{r} = -\frac{1}{2}$ និង $\sin\alpha = \frac{b}{r} = \frac{\sqrt{3}}{2}$ ហេតុនេះ $\alpha = \frac{2\pi}{3}$ ។

$$\Rightarrow Z = -1 + i\sqrt{3} = 2\left(\cos\frac{2\pi}{3} + i\sin\frac{2\pi}{3}\right)$$ ។

$z = 2i$ ដែល $a = 0$ និង $b = 2$ មានម៉ូឌុល $r = \sqrt{O^2 + 2^2} = 2$

ដោយ $\cos\beta = \frac{a}{r} = 0$ និង $\sin\beta = \frac{b}{r} = \frac{2}{2} = 1$ ហេតុនេះ $\beta = \frac{\pi}{2}$ ។

$$z = 2\left(\cos\frac{\pi}{2} + i\sin\frac{\pi}{2}\right)$$ ។

គេបាន $$\frac{z'}{z} = \frac{2\left(\cos\frac{2\pi}{3} + i\sin\frac{2\pi}{3}\right)}{2\left(\cos\frac{\pi}{2} + i\sin\frac{\pi}{2}\right)}$$

$$= \left[\cos\left(\frac{2\pi}{3} - \frac{\pi}{2}\right) + i\sin\left(\frac{2\pi}{3} - \frac{\pi}{2}\right)\right]$$

$$= \cos\frac{\pi}{6} + i\sin\frac{\pi}{6}$$

$\cos\varphi + i\sin\varphi = \cos\frac{\pi}{6} + i\sin\frac{\pi}{6}$ ដូចនេះ $\varphi = \frac{\pi}{6}$ ។

**ប្រតិបត្តិ 1** ចូរកំណត់ $z'$ ដោយដឹងថា $M'(z)$ ជារូបភាពនៃ $M(z = 4 - 2i)$ តាមបំលែងវិល ផ្ចិត $O$ មុំ $-\frac{7\pi}{6}$ ។

**ប្រតិបត្តិ 2** ចូរកំណត់ $z$ ដោយដឹងថាតាមបំលែងវិលផ្ចិត $O$ មុំ $\frac{-\pi}{4}$

ចំណុច $M(z)$ មានរូបភាព $M'(z' = \frac{\sqrt{2}}{2} + i\frac{\sqrt{2}}{2})$ ។

## លំហាត់

1. គណនាម៉ូឌុលនៃចំនួនកុំផ្លិច

ក. $|-2i|$ ខ. $|\sqrt{3}+1|$ គ. $|4+3i|+|4-3i|$

ឃ. $|(4+3i)+(4-3i)|$ ង. $|i^7|$ ច. $|i^{100}|$ ។

2. បើ $z_1$ និង $z_2$ ជាចំនួនកុំផ្លិច ។ ស្រាយបញ្ជាក់សមភាពខាងក្រោម :

ក. $\overline{z_1+z_2} = \bar{z}_1+\bar{z}_2$ ខ. $\overline{z_1 z_2} = \bar{z}_1 \cdot \bar{z}_2$ គ. $\overline{\left(\frac{z_1}{z_2}\right)} = \frac{\bar{z}_1}{\bar{z}_2}$ , $z_2 \neq 0$

3. គណនាអាគុយម៉ង់នៃចំនួនកុំផ្លិចខាងក្រោម :

ក. $2+2i$ ខ. $-3+3i$ គ. $-2+i2\sqrt{3}$ ឃ. $-1-i$

ង. $4i$ ច. $-4$ ឆ. $-\sqrt{3}+i$ ។

4. គណនាម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិចខាងក្រោម :

ក. $z_1 = 1+i$ ខ. $z_2 = -1+i\sqrt{3}$ គ. $z_1 z_2$ ឃ. $z_1^2$ ង. $\frac{z_1}{z_2}$ ។

5. តើចំនួនខាងក្រោម មួយណាមានទម្រង់ត្រីកោណមាត្រ

ក. $2\left[\cos\left(-\frac{\pi}{6}\right)+i\sin\left(-\frac{\pi}{6}\right)\right]$ ខ. $-5\left(\cos\frac{\pi}{8}+i\sin\frac{\pi}{8}\right)$

គ. $-2\left[\cos\left(-\frac{3\pi}{4}\right)+i\sin\left(-\frac{3\pi}{4}\right)\right]$ ឃ. $6\left(\cos\frac{\pi}{5}+i\sin\frac{\pi}{5}\right)$

ង. $\sqrt{2}\left(\cos\frac{3\pi}{4}+i\sin\frac{5\pi}{6}\right)$ ច. $-\sqrt{3}\left(\sin\frac{2\pi}{3}+i\cos\frac{2\pi}{3}\right)$ ។

6. សរសេរចំនួនកុំផ្លិចខាងក្រោម ជាទម្រង់ត្រីកោណមាត្រ

ក. $-5-i5\sqrt{3}$ ខ. $\frac{-5+i}{2-3i}$ គ. $2+2i$ ឃ. $-i$

ង. $-20i$ ច. $15$ ឆ. $2\sqrt{3}+2i$ ជ. $-6i$ ។

7. សរសេរចំនួនកុំផ្លិច $z = \dfrac{\cos\frac{\pi}{9}+i\sin\frac{\pi}{9}}{\cos\frac{4\pi}{9}+i\sin\frac{4\pi}{9}}$ ជាទម្រង់ត្រីកោណមាត្រ ។

8. សរសេរចំនួនកុំផ្លិច $z$ ជាទម្រង់ពីជគណិតបើគេឱ្យ

ក. $|z| = 2$ និង $\arg z = \frac{\pi}{3}$ ខ. $|z| = 4$ និង $\arg z = \frac{3\pi}{4}$

គ. $|z| = 1$ និង $\arg z = -\frac{\pi}{2}$ ឃ. $|z| = 6$ និង $\arg z = \frac{7\pi}{6}$

9. គេឱ្យចំនួនកុំផ្លិច $z = \tan\alpha + i$ ដែល $0 < \alpha < \frac{\pi}{2}$ និង $w = 4\left(\cos\frac{\pi}{10} + i\sin\frac{\pi}{10}\right)$ គណនា

ក. $|z|$

ខ. $|zw|$

គ. $\arg z$

ឃ. $\arg\left(\frac{z}{w}\right)$ ។

10. សរសេរចំនួនកុំផ្លិច $z = \dfrac{1 + \sin\alpha + i\cos\alpha}{1 + \sin\alpha - i\cos\alpha}$ ជាទម្រង់ត្រីកោណមាត្រ ។

11. គេមានចំនួនកុំផ្លិច $z$ និង $w$ ដែល $z = -2 + 5i$ , $zw = 14 + 23i$ ។

ក. គណនា $w$

ខ. កំណត់រូបភាពនៃ $z$ និង $w$ ក្នុងប្លង់កុំផ្លិចតែមួយ ។

12. ប្រើទម្រង់ត្រីកោណមាត្រនៃ $z_1$ និង $z_2$ គណនា $z_1 z_2$ និង $\frac{z_1}{z_2}$ បើ ៖

ក. $z_1 = \sqrt{2}\left(\cos\frac{\pi}{5} + i\sin\frac{\pi}{5}\right)$ និង $z_2 = 3\sqrt{3}\left(\cos\frac{\pi}{15} + i\sin\frac{\pi}{15}\right)$

ខ. $z_1 = -5 + 5i$ និង $z_2 = -3i$

គ. $z_1 = 2i$ និង $z_2 = -3i$ ។

13. នៅក្នុងប្លង់កុំផ្លិច $(xoy)$ តាមចំណុច $M'(z')$ ជារូបភាពនៃ $M(z = -4 + 4i)$ តាមបំលែងវិលផ្ចិត $O$ មុំ $\frac{\pi}{6}$ ។ ចូរកំណត់ $z'$ ។

14. នៅក្នុងប្លង់កុំផ្លិច $(xoy)$ ចំណុច $M(z)$ មានរូបភាព $M'(z')$ តាមបំលែងវិលផ្ចិត $O$ មុំ $\theta$ ។ ចូរកំណត់ $\theta$ ដោយដឹងថា $z'$ កំណត់ដោយចំនួនកុំផ្លិចខាងក្រោម :

ក. $-\frac{iz}{3}$

ខ. $\frac{3\sqrt{3}}{4}z - \frac{3}{4}zi$

គ. $\frac{1}{2}zi$ ។

មេរៀនទី 3

# ស្វ័យគុណទី n និងឬសទី n នៃចំនួនកុំផ្លិច

## 1. ស្វ័យគុណទី n នៃចំនួនកុំផ្លិច

**ចំណុចបំណង**

- គណនាស្វ័យគុណទី $n$ និងឬសទី $n$ នៃចំនួនកុំផ្លិច
- អនុវត្តក្នុងត្រីកោណមាត្រ

គេមានចំនួនកុំផ្លិច $z = r(\cos\varphi + i\sin\varphi)$

ដោយអនុវត្តន៍តាមរូបមន្ត

$$z_1z_2 = r_1r_2[\cos(\varphi_1+\varphi_2) + i\sin(\varphi_1+\varphi_2)]$$

គេបាន $zz = rr[\cos(\varphi+\varphi) + i\sin(\varphi+\varphi)]$

$$z^2 = r^2(\cos 2\varphi + i\sin 2\varphi)$$

$$z^3 = z^2 \times z = (r^2\times r)[\cos(2\varphi+\varphi) + i\sin(2\varphi+\varphi)] = r^3(\cos 3\varphi + i\sin 3\varphi)$$

$$z^4 = z^3 \times z = (r^3\times r)[\cos(3\varphi+\varphi) + i\sin(3\varphi+\varphi)] = r^4(\cos 4\varphi + i\sin 4\varphi)$$

$$z^5 = z^4 \times z = (r^4\times r)[\cos(4\varphi+\varphi) + i\sin(4\varphi+\varphi)] = r^5(\cos 5\varphi + i\sin 5\varphi)$$

..........................................................................................

..........................................................................................

$z^n = z^{n-1}\times z = r^n(\cos n\varphi + i\sin n\varphi)$ ។

**ជាទូទៅ** បើ $z = r(\cos\varphi + i\sin\varphi)$ នោះ $z^n = [r(\cos\varphi + i\sin\varphi)]^n$

$$= r^n(\cos n\varphi + i\sin n\varphi)$$

គ្រប់ $n$ ជាចំនួនគត់រ៉ឡាទីបវិជ្ជមាន ។ គេអាចទាញបាន :

$(\cos\varphi + i\sin\varphi)^n = \cos n\varphi + i\sin n\varphi$ ហៅថា រូបមន្ត ដឺម័រ ។

***ឧទាហរណ៍ 1*** គេមានចំនួនកុំផ្លិច $z = 2\left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)$ គណនា $z^3$ ។

$$z^3 = \left[2\left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)\right]^3 = 2^3\left[\cos\left(\frac{\pi}{3}\times 3\right) + i\sin\left(\frac{\pi}{3}\times 3\right)\right]$$

$$= 8(\cos\pi + i\sin\pi)$$

ដូចនេះ $z^3 = 8(\cos\pi + i\sin\pi) = -8$ ។

**ឧទាហរណ៍ 2** គណនា $(-1+i)^{10}$ ។

តាង $z = -1+i$ ដែល $a = -1$ និង $b = 1$ គេបាន $r = \sqrt{a^2+b^2} = \sqrt{(-1)^2+1^2} = \sqrt{2}$

ដោយ $\cos\varphi = \frac{a}{r} = -\frac{1}{\sqrt{2}} = -\frac{\sqrt{2}}{2}$ និង $\sin\varphi = \frac{b}{r} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$ ហេតុនេះ $\varphi = \frac{3\pi}{4}$ ។

គេបានចំនួនកុំផ្លិច $z$ ទម្រង់ត្រីកោណមាត្រ $z = \sqrt{2}\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)$

តាមរូបមន្ត

$$(-1+i)^{10} = \left[\sqrt{2}\left(\cos\frac{3\pi}{4}+i\sin\frac{3\pi}{4}\right)\right]^{10}$$

$$= 2^5\left[\cos\left(10\times\frac{3\pi}{4}\right)+i\sin\left(10\times\frac{3\pi}{4}\right)\right]$$

$$= 2^5\left(\cos\frac{15\pi}{2}+i\sin\frac{15\pi}{2}\right)$$

$$= 2^5\left[\cos\left(6\pi+\frac{3\pi}{2}\right)+i\sin\left(6\pi+\frac{3\pi}{2}\right)\right]$$

$$= 2^5\left(\cos\frac{3\pi}{2}+i\sin\frac{3\pi}{2}\right)$$

$$= -2^5 i$$

ដូចនេះ $(-1+i)^{10} = -32i$ ។

**លំហាត់គំរូ 1** សរសេរចំនួនកុំផ្លិច $(-\sqrt{3}+i)^{13}$ ជាទម្រង់ពីជគណិត $a+bi$ ។

**ចម្លើយ** ដំបូងត្រូវបំប្លែងចំនួនខាងលើ ជាទម្រង់ត្រីកោណមាត្រ ។

គេមាន $-\sqrt{3}+i$ ដែល $a = -\sqrt{3}$ និង $b = 1$ គេបាន $r = \sqrt{a^2+b^2} = \sqrt{(-3)^2+1^2} = 2$

ដោយ $\cos\varphi = \frac{a}{r} = -\frac{\sqrt{3}}{2}$ និង $\sin\varphi = \frac{b}{r} = \frac{1}{2}$ ហេតុនេះ $\varphi = \frac{5\pi}{6}$ ។

គេបាន $-\sqrt{3}+i = 2\left(\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}\right)$ ។

តាមរូបមន្តដឺម័រ

$$(-\sqrt{3}+i)^{13} = 2^{13}\left[\cos\left(13\times\frac{5\pi}{6}\right)+i\sin\left(13\times\frac{5\pi}{6}\right)\right]$$

$$= 2^{13}\left(\cos\frac{65\pi}{6}+i\sin\frac{65\pi}{6}\right)$$

$$= 2^{13}\left[\cos\left(10\pi+\frac{5\pi}{6}\right)+i\sin\left(10\pi+\frac{5\pi}{6}\right)\right]$$

$$= 2^{13}\left(\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}\right)$$

$$(-\sqrt{3}+i)^{13} = 2^{13}\left(-\frac{\sqrt{3}}{2}+i\frac{1}{2}\right)$$

$$= -2^{12}\sqrt{3}+i2^{12}$$

ដូចនេះ $(-\sqrt{3}+i)^{13} = -2^{12}\sqrt{3}+i2^{12}$ ។

**លំហាត់គំរូ 2** គណនា $z = \left(\frac{1+i}{1-i}\right)^{2n}$ ដែល $n$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន ។

**ចម្លើយ** គេបាន $\frac{1+i}{1-i} = \frac{(1+i)(1+i)}{(1-i)(1+i)} = \frac{1+2i-1}{1+1} = i$

សរសេរចំនួនកុំផ្លិច $i$ ជាទម្រង់ត្រីកោណមាត្រ

$i$ មាន $a = 0$ និង $b = 1$ គេបាន $r = \sqrt{0^2+1^2} = 1$

ដោយ $\cos\varphi = \frac{a}{r} = 0$ និង $\sin\varphi = \frac{b}{r} = 1$ ហេតុនេះ $\varphi = \frac{\pi}{2}$ ។

$i = \cos\frac{\pi}{2} + i\sin\frac{\pi}{2}$ ។

$$z = (i)^{2n} = \left(\cos\frac{\pi}{2} + i\sin\frac{\pi}{2}\right)^{2n}$$

$$= \cos\left(2n\times\frac{\pi}{2}\right) + i\sin\left(2n\times\frac{\pi}{2}\right)$$

$$= \cos(n\pi) + i\sin(n\pi)$$

$$= (\cos\pi + i\sin\pi)^n$$

ដូចនេះ $z = (-1)^n$ ។ បើ $n$ គូ , $z = 1$ ហើយបើ $n$ សេស $z = -1$

**លំហាត់គំរូ 3** ស្រាយបញ្ជាក់សមភាពខាងក្រោម :

$$\left(\frac{1+\sin\varphi+i\cos\varphi}{1+\sin\varphi-i\cos\varphi}\right)^n = \cos\left[n\left(\frac{\pi}{2}-\varphi\right)\right] + i\sin\left[n\left(\frac{\pi}{2}-\varphi\right)\right]$$

**ចម្លើយ**

$$\frac{1+\sin\varphi+i\cos\varphi}{1+\sin\varphi-i\cos\varphi} = \frac{(1+\sin\varphi+i\cos\varphi)(1+\sin\varphi+i\cos\varphi)}{(1+\sin\varphi-i\cos\varphi)(1+\sin\varphi+i\cos\varphi)}$$

$$= \frac{(1+\sin\varphi+i\cos\varphi)^2}{(1+\sin\varphi)^2-(i\cos\varphi)^2}$$

$$= \frac{1+\sin^2\varphi-\cos^2\varphi+2\sin\varphi+2i\cos\varphi+2i\sin\varphi\cos\varphi}{1+2\sin\varphi+\sin^2\varphi+\cos^2\varphi}$$

ដោយ $\sin^2\varphi = 1-\cos^2\varphi$

$$= \frac{2\sin^2\varphi+2\sin\varphi+2i\cos\varphi+2i\sin\varphi\cos\varphi}{2(1+\sin\varphi)}$$

$$= \frac{2\sin\varphi(1+\sin\varphi)+2i\cos\varphi(1+\sin\varphi)}{2(1+\sin\varphi)}$$

$$= \frac{(1+\sin\varphi)(2\sin\varphi+2i\cos\varphi)}{2(1+\sin\varphi)}$$

$$= \sin\varphi + i\cos\varphi$$

ដោយ $\sin\varphi = \cos\left(\frac{\pi}{2}-\varphi\right)$ និង $\cos\varphi = \sin\left(\frac{\pi}{2}-\varphi\right)$

គេបាន $\dfrac{1+\sin\varphi+i\cos\varphi}{1+\sin\varphi-i\cos\varphi} = \cos\left(\dfrac{\pi}{2}-\varphi\right)+i\sin\left(\dfrac{\pi}{2}-\varphi\right)$

$$\Rightarrow\left(\frac{1+\sin\varphi+i\cos\varphi}{1+\sin\varphi-i\cos\varphi}\right)^n = \left[\cos\left(\frac{\pi}{2}-\varphi\right)+i\sin\left(\frac{\pi}{2}-\varphi\right)\right]^n$$

$$= \cos\left[n\left(\frac{\pi}{2}-\varphi\right)\right]+i\sin\left[n\left(\frac{\pi}{2}-\varphi\right)\right]$$

ដូចនេះ $\left(\dfrac{1+\sin\varphi+i\cos\varphi}{1+\sin\varphi-i\cos\varphi}\right)^n = \cos\left[n\left(\dfrac{\pi}{2}-\varphi\right)\right]+i\sin\left[n\left(\dfrac{\pi}{2}-\varphi\right)\right]$ ។

**ប្រតិបត្តិ 1** គណនា $(1+i)^{60}$ ។

**ប្រតិបត្តិ 2** សរសេរ $z$ ជាទម្រង់ $a+bi$ បើគេឱ្យ $z=\left(-\dfrac{\sqrt{3}}{2}+i\dfrac{1}{2}\right)^{13}$ ។

## 2. អនុវត្តន៍ក្នុងត្រីកោណមាត្រ

គេអាចគណនា $(\cos\varphi+i\sin\varphi)^n$ តាមរបៀបពីរយ៉ាង

- តាមស្វ័យគុណនៃផលបូកទ្វេធាតុ
- តាមស្វ័យគុណនៃចំនួនកុំផ្លិច

***ឧទាហរណ៍*** គណនា $(\cos\varphi+i\sin\varphi)^n$ ។

- ករណី $n=2$

តាមស្វ័យគុណនៃផលបូកទ្វេធាតុ

$$(\cos\varphi+i\sin\varphi)^2 = \cos^2\varphi+2i\cos\varphi\sin\varphi+i^2\sin^2\varphi$$

$$= \cos^2\varphi-\sin^2\varphi+i(2\cos\varphi\sin\varphi)$$ ។

តាមស្វ័យគុណនៃចំនួនកុំផ្លិច

$$(\cos\varphi+i\sin\varphi)^2 = \cos2\varphi+i\sin2\varphi$$ ។

ផ្ទឹមលទ្ធផលទាំង 2 យើងទាញបាន $\cos2\varphi=\cos^2\varphi-\sin^2\varphi$ និង $\sin2\varphi=2\sin\varphi\cos\varphi$

គឺជារូបមន្តត្រីកោណមាត្រដែលបានស្រាយបញ្ជាក់រួចហើយ

- ករណី $n=3$

តាមស្វ័យគុណនៃផលបូកទ្វេធាតុ

$$(\cos\varphi+i\sin\varphi)^3 = \cos^3\varphi+3\cos^2\varphi(i\sin\varphi)+3\cos\varphi(i\sin\varphi)^2+(i\sin\varphi)^3$$

$$= \cos^3\varphi+3i\cos^2\varphi\sin\varphi-3\cos\varphi\sin^2\varphi-i\sin^3\varphi$$

$$= \cos^3\varphi-3\cos\varphi\sin^2\varphi+i(3\cos^2\varphi\sin\varphi-\sin^3\varphi)$$ ។

តាមស្វ័យគុណនៃចំនួនកុំផ្លិច

$(\cos\varphi + i\sin\varphi)^3 = \cos 3\varphi + i\sin 3\varphi$ ។

យើងទាញបាន $\cos 3\varphi = \cos^3\varphi - 3\cos\varphi\sin^2\varphi = 4\cos^3\varphi - 3\cos\varphi$ និង

$\sin 3\varphi = 3\cos^2\varphi\sin\varphi - \sin^3\varphi = -4\sin^3\varphi + 3\sin\varphi$

- ករណី $n = 4$

តាមស្វ័យគុណនៃផលបូកទ្វេធាតុ

$$(\cos\varphi + i\sin\varphi)^4 = \cos^4\varphi + 4\cos^3\varphi(i\sin\varphi) + 6\cos^2\varphi(i\sin\varphi)^2 + 4\cos\varphi(i\sin\varphi)^3 + (i\sin\varphi)^4$$

$$= \cos^4\varphi + 4i\cos^3\varphi\sin\varphi - 6\cos^2\varphi\sin^2\varphi - 4i\cos\varphi\sin^3\varphi + \sin^4\varphi$$

$$= \cos^4\varphi + \sin^4\varphi - 6\cos^2\varphi\sin^2\varphi + i(4\cos^3\varphi\sin\varphi - 4\cos\varphi\sin^3\varphi)$$ ។

តាមស្វ័យគុណនៃចំនួនកុំផ្លិច

$(\cos\varphi + i\sin\varphi)^4 = \cos 4\varphi + i\sin 4\varphi$ ។

យើងទាញបាន $\cos 4\varphi = \cos^4\varphi + \sin^4\varphi - 6\cos^2\varphi\sin^2\varphi$ និង $\sin 4\varphi = 4\cos^3\varphi\sin\varphi - 4\cos\varphi\sin^3\varphi$

## 3. ឫសទី n នៃចំនួនកុំផ្លិច

បើ $w$ ជាឫសទី $n$ នៃចំនួនកុំផ្លិច $z$ នោះគេបាន $w^n = z$ ។ ទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $z$ និង $w$ គឺ $z = r(\cos\varphi + i\sin\varphi)$ និង $w = s(\cos\alpha + i\sin\alpha)$ ។

គេបាន $w^n = [s(\cos\alpha + i\sin\alpha)]^n$

$= s^n(\cos n\alpha + i\sin n\alpha)$ ។

ដោយ $w^n = z$ គេបាន $s^n(\cos n\alpha + i\sin n\alpha) = r(\cos\varphi + i\sin\varphi)$ ចំនួនកុំផ្លិចពីរស្មើគ្នា ម៉ូឌុលរបស់វាក៏ស្មើគ្នាដែរ ។ គេទាញបាន $s^n = r$ ដោយ $s > 0$ និង $r > 0$ នោះ $s = \sqrt[n]{r}$ ។

$\cos n\alpha + i\sin n\alpha = \cos\varphi + i\sin\varphi$ គេទាញបាន $\cos n\alpha = \cos\varphi$ , $n\alpha = \varphi + 2k\pi$

$\alpha = \dfrac{\varphi + 2k\pi}{n}$ ដែល $k \in \mathbb{Z}$ ។

ជំនួស $\alpha = \dfrac{\varphi + 2k\pi}{n}$ និង $s = \sqrt[n]{r}$ ក្នុងទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $w$ គេបាន

$$w = \sqrt[n]{r}\left[\cos\left(\frac{\varphi + 2k\pi}{n}\right) + i\sin\left(\frac{\varphi + 2k\pi}{n}\right)\right]$$ ។

បើគេជំនួស $k = 0, 1, 2, 3, \ldots\ldots, n-1$ គេបាន $n$ ឫសទី $n$ ផ្សេងៗគ្នានៃចំនួនកុំផ្លិច $z$ ។

**ជាទូទៅ** បើ $z = r(\cos\varphi + i\sin\varphi)$ ជាចំនួនកុំផ្លិចមិនសូន្យ ហើយ $n$ ជាចំនួនគត់វិជ្ជមាន នោះ $z$ មាន $n$ ឫសទី $n$ កំណត់ដោយ :

$$W_k = \sqrt[n]{r}\left[\cos\left(\frac{\varphi + 2k\pi}{n}\right) + i\sin\left(\frac{\varphi + 2k\pi}{n}\right)\right]$$

$k = 0, 1, 2, \ldots\ldots, n-1$

**ឧទាហរណ៍ 1** គណនាឫសទី 5 នៃចំនួនកុំផ្លិច $-1+i$ រួចតាងចំណុចរូបភាពនៃឫសទាំងនោះលើរង្វង់ ។

តាង $z = -1+i$ ដែល $a = -1$ និង $b = 1$ គេបាន $r = \sqrt{a^2+b^2} = \sqrt{(-1)^2+1^2} = \sqrt{2}$

ដោយ $\cos\varphi = \frac{a}{r} = -\frac{1}{\sqrt{2}} = -\frac{\sqrt{2}}{2}$ និង $\sin\varphi = \frac{b}{r} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$ ហេតុនេះ $\varphi = \frac{3\pi}{4}$ ។

គេបាន $z = -1+i = \sqrt{2}\left(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4}\right)$ ។

ឫសទី 5 នៃ $z$ កំណត់ដោយ

$$w_k = 2^{\frac{1}{10}}\left[\cos\left(\frac{\frac{3\pi}{4} + 2k\pi}{5}\right) + i\sin\left(\frac{\frac{3\pi}{4} + 2k\pi}{5}\right)\right]$$

$$= 2^{\frac{1}{10}}\left[\cos\left(\frac{3\pi + 8k\pi}{20}\right) + i\sin\left(\frac{3\pi + 8k\pi}{20}\right)\right]$$

ដែល $k = 0, 1, 2, 3, 4$ ។




បើ $k = 0$ នោះ $w_0 = 2^{\frac{1}{10}}\left[\cos\left(\frac{3\pi}{20}\right) + i\sin\left(\frac{3\pi}{20}\right)\right]$

បើ $k = 1$ នោះ $w_1 = 2^{\frac{1}{10}}\left[\cos\left(\frac{3\pi + 8\pi}{20}\right) + i\sin\left(\frac{3\pi + 8\pi}{20}\right)\right]$

$$= 2^{\frac{1}{10}}\left(\cos\frac{11\pi}{20} + i\sin\frac{11\pi}{20}\right)$$

បើ $k = 2$ នោះ $w_2 = 2^{\frac{1}{10}}\left[\cos\left(\frac{3\pi + 16\pi}{20}\right) + i\sin\left(\frac{3\pi + 16\pi}{20}\right)\right] = 2^{\frac{1}{10}}\left(\cos\frac{19\pi}{20} + i\sin\frac{19\pi}{20}\right)$

បើ $k = 3$ នោះ $w_3 = 2^{\frac{1}{10}}\left[\cos\left(\frac{3\pi + 24\pi}{20}\right) + i\sin\left(\frac{3\pi + 24\pi}{20}\right)\right] = 2^{\frac{1}{10}}\left(\cos\frac{27\pi}{20} + i\sin\frac{27\pi}{20}\right)$

បើ $k = 4$ នោះ $w_4 = 2^{\frac{1}{10}}\left[\cos\left(\frac{3\pi + 32\pi}{20}\right) + i\sin\left(\frac{3\pi + 32\pi}{20}\right)\right] = 2^{\frac{1}{10}}\left(\cos\frac{35\pi}{20} + i\sin\frac{35\pi}{20}\right)$ ។

ចំណុច $M_0, M_1, M_2, M_3, M_4$ តាង $w_0, w_1, w_2, w_3, w_4$ ជាកំពូលនៃបញ្ចកោណនិយ័ត

**ឧទាហរណ៍ 2** គណនាឫសទី 4 នៃចំនួនកុំផ្លិច $-8+i8\sqrt{3}$ រួចតាងឫសទាំងនោះលើរង្វង់ ។

តាង $z = -8 - i8\sqrt{3}$ ដែល $a = -8$ និង $b = -8\sqrt{3}$ គេបាន $r = \sqrt{(-8)^2 + (8\sqrt{3})^2} = 16$

ដោយ $\cos\varphi = \frac{a}{r} = -\frac{8}{16} = -\frac{1}{2}$ និង $\sin\varphi = \frac{b}{r} = \frac{-8\sqrt{3}}{16} = \frac{-\sqrt{3}}{2}$ ហេតុនេះ $\varphi = \frac{4\pi}{3}$ ។

គេបាន $z = -8 - i8\sqrt{3} = 16\left(\cos\frac{4\pi}{3} + i\sin\frac{4\pi}{3}\right)$

ឫសទី 4 នៃ $z$ កំណត់ដោយ :

$$w_k = 16^{\frac{1}{4}}\left[\cos\left(\frac{\frac{4\pi}{3} + 2k\pi}{4}\right) + i\sin\left(\frac{\frac{4\pi}{3} + 2k\pi}{4}\right)\right]$$ ដែល $k = 0,\ 1,\ 2,\ 3$ ។

$$w_k = 2\left[\cos\left(\frac{4\pi + 6k\pi}{12}\right) + i\sin\left(\frac{4\pi + 6k\pi}{12}\right)\right]$$




បើ $k = 0$ នោះ $w_0 = 2\left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right) = 1 + i\sqrt{3}$

បើ $k = 1$ នោះ $w_1 = 2\left(\cos\frac{5\pi}{6} + i\sin\frac{5\pi}{6}\right) = -\sqrt{3} + i$

បើ $k = 2$ នោះ $w_2 = 2\left(\cos\frac{8\pi}{6} + i\sin\frac{8\pi}{6}\right) = -1 + i\sqrt{3}$

បើ $k = 3$ នោះ $w_3 = 2\left(\cos\frac{11\pi}{6} + i\sin\frac{11\pi}{6}\right) = \sqrt{3} - i$ ។

ចំណុច $M_0,\ M_1,\ M_2,\ M_3$ តាង $w_0,\ w_1,\ w_2,\ w_3$ ជាកំពូលនៃការេ

**លំហាត់គំរូ 1** ដោះស្រាយសមីការ $z^6 + 64 = 0$ ។

**ចម្លើយ** $z^6 = -64$ , $z$ ជាឫសទី6 នៃ $-64$ ។

$-64 = -64 + 0i$ មានម៉ូឌុល $r = \sqrt{(-64)^2 + 0} = 64$

ដោយ $\cos\varphi = \frac{a}{r} = -\frac{64}{64} = -1$ និង $\sin\varphi = \frac{b}{r} = \frac{0}{64} = 0$ ហេតុនេះ $\varphi = \pi$ ។

គេបាន $-64 = 64(\cos\pi + i\sin\pi)$ ឫសទី 6 នៃ $-64$ កំណត់ដោយ :

$$w_k = 64^{\frac{1}{6}}\left[\cos\left(\frac{\pi + 2k\pi}{6}\right) + i\sin\left(\frac{\pi + 2k\pi}{6}\right)\right]$$ ដែល $k = 0,\ 1,\ 2,\ 3,\ 4,\ 5$ ។

បើ $k = 0$ នោះ $w_0 = 2\left(\cos\frac{\pi}{6} + i\sin\frac{\pi}{6}\right) = \sqrt{3} + i$

បើ $k = 1$ នោះ $w_1 = 2\left(\cos\frac{\pi}{2} + i\sin\frac{\pi}{2}\right) = 2i$

បើ $k = 2$ នោះ $w_2 = 2\left(\cos\frac{5\pi}{6} + i\sin\frac{5\pi}{6}\right) = -\sqrt{3} + i$

បើ $k = 3$ នោះ $w_3 = 2\left(\cos\frac{7\pi}{6} + i\sin\frac{7\pi}{6}\right) = -\sqrt{3} - i$

បើ $k = 4$ នោះ $w_4 = 2\left(\cos\frac{3\pi}{2} + i\sin\frac{3\pi}{2}\right) = -2i$

បើ $k = 5$ នោះ $w_5 = 2\left(\cos\frac{11\pi}{6} + i\sin\frac{22\pi}{6}\right) = \sqrt{3} - i$ ។

ដូចនេះ $z$ ស្មើនឹង $\sqrt{3} + i$ , $2i$ , $-\sqrt{3} + i$ , $-\sqrt{3} - i$ , $-2i$ និង $\sqrt{3} - i$ ។

**លំហាត់គំរូ 2** ដោះស្រាយសមីការ $(z-2)^3 = 1$ ។

**ចម្លើយ** $(z-2)^3 = 1$ , $z-2$ ជាឫសគូបនៃ 1

$1 = 1 + 0i$ មានម៉ូឌុល $r = \sqrt{1^2 + 0^2} = 1$

ដោយ $\cos\varphi = \frac{a}{r} = \frac{1}{1} = 1$ និង $\sin\varphi = \frac{b}{r} = \frac{0}{1} = 0$ ហេតុនេះ $\varphi = 0$ ។

គេបាន $1 = \cos 0 + i\sin 0$

ឫសទី 3 នៃ 1 កំណត់ដោយ

$$w_k = \cos\left(\frac{0+2k\pi}{3}\right) + i\sin\left(\frac{0+2k\pi}{3}\right) \text{ ដែល } k = 0 \text{ , } 1, \text{ } 2 \text{ ។}$$

បើ $k = 0$ នោះ $w_0 = \cos 0 + i\sin 0 = 1$

បើ $k = 1$ នោះ $w_1 = \cos\frac{2\pi}{3} + i\sin\frac{2\pi}{3} = -\frac{1}{2} + \frac{\sqrt{3}}{2}i$

បើ $k = 2$ នោះ $w_2 = \cos\frac{4\pi}{3} + i\sin\frac{4\pi}{3} = -\frac{1}{2} - \frac{\sqrt{3}}{2}i$

ដោយ $z - 2 = \sqrt[3]{1}$ , $z = \sqrt[3]{1} + 2$

បើ $w_0 = 1$ នោះ $z_0 = 1 + 2 = 3$

បើ $w_1 = -\frac{1}{2} + \frac{\sqrt{3}}{2}i$ នោះ $z_1 = -\frac{1}{2} + \frac{\sqrt{3}}{2}i + 2$

$$= \frac{3}{2} + \frac{\sqrt{3}}{2}i$$

បើ $w_2 = -\frac{1}{2} - \frac{\sqrt{3}}{2}i$ នោះ $z_2 = -\frac{1}{2} - \frac{\sqrt{3}}{2}i + 2$

$$= \frac{3}{2} - \frac{\sqrt{3}}{2}i$$

ដូចនេះ ឫសនៃសមីការមាន $z_0 = 3$ , $z_1 = \frac{3}{2} + \frac{\sqrt{3}}{2}i$ និង $z_2 = \frac{3}{2} - \frac{\sqrt{3}}{2}i$ ។

**លំហាត់គំរូ 3** ដោះស្រាយសមីការ $z^6+2z^3+1=0$ ។

**ចម្លើយ** $z^6+2z^3+1=(z^3+1)^2$

គេបាន $(z^3+1)^2=0$ , $z^3=-1$ ឬ $z$ ជាឫសគូបនៃ $-1$ ។

តែ $-1=-1+0i$ ដែល $a=-1$ និង $b=0$ គេបាន $r=\sqrt{(-1)^2+0^2}=1$

ដោយ $\cos\varphi=\frac{a}{r}=-\frac{1}{1}=-1$ និង $\sin\varphi=\frac{b}{r}=0$ ហេតុនេះ $\varphi=\pi$

គេបាន $-1=\cos\pi+i\sin\pi$

ឫសទី 3 នៃ $-1$ កំណត់ដោយ

$w_k=\sqrt[3]{1}\left(\cos\frac{\pi+2k\pi}{3}+i\sin\frac{\pi+2k\pi}{3}\right)$ ដែល $k=0$ , 1, 2 ។

បើ $k=0$ នោះ $w_0=\cos\frac{\pi}{3}+i\sin\frac{\pi}{3}=\frac{1}{2}+\frac{\sqrt{3}}{2}i$

បើ $k=1$ នោះ $w_1=\cos\pi+i\sin\pi=-1$

បើ $k=2$ នោះ $w_2=\cos\frac{5\pi}{3}+i\sin\frac{5\pi}{3}=\frac{1}{2}-\frac{\sqrt{3}}{2}i$ ។

ដូចនេះ ឫសនៃសមីការគឺ $z_0=\frac{1}{2}+\frac{\sqrt{3}}{2}i$ , $z_1=-1$ និង បើ $z_2=\frac{1}{2}-\frac{\sqrt{3}}{2}i$ ។

**ប្រតិបត្តិ 1** គណនាឫសទី 5 នៃ $-\sqrt{3}-i$ រួចតាងឫសទាំងនោះលើរង្វង់ ។

**ប្រតិបត្តិ 2** ដោះស្រាយសមីការ $z^6+1=0$ ។

## លំហាត់

1. គណនា ក. $(1+i)^{12}$ ខ. $(1-i)^{10}$ គ. $(3+3i)^5$ ឃ. $(-4\sqrt{3}+4i)^5$

ង. $\left(-\frac{\sqrt{2}}{2}+\frac{\sqrt{2}}{2}i\right)^{15}$ ច. $(\sqrt{3}+i)^7$ ឆ. $(-1+i)^{50}$ ជ. $\left(\frac{\sqrt{2}}{2}+\frac{\sqrt{2}}{2}i\right)^{25}$ ។

2. គណនាចំនួនកុំផ្លិចខាងក្រោម :

ក. $u = (1+i\sqrt{3})^5+(1-i\sqrt{3})^5$ ខ. $v = (1+i\sqrt{3})^5-(1-i\sqrt{3})^5$ ។

3. សរសេរចំនួនខាងក្រោម ជាទម្រង់ត្រីកោណមាត្រ

ក. $\frac{(1+i)^5}{(1-i)^3}$ ខ. $\left(\frac{1+i\sqrt{3}}{1-i}\right)^{20}$ គ. $(1+i)^8(1-i\sqrt{3})^{-6}$ ។

4. បង្ហាញថា ក. $(1+i)^n = 2^{\frac{n}{2}}\left(\cos\frac{n\pi}{4}+i\sin\frac{n\pi}{4}\right)$ ខ. $(\sqrt{3}-i)^n = 2^n\left(\cos\frac{n\pi}{6}-i\sin\frac{n\pi}{6}\right)$ ។

5. គេឱ្យចំនួនកុំផ្លិច $z = \cos\frac{\pi}{6}+i\sin\frac{\pi}{6}$ ។

ក. ដៅចំណុចរូបភាពនៃចំនួនកុំផ្លិច $z,\ z^2,\ z^3,\ z^4,\ z^5,\ z^6,\ z^7$ លើរង្វង់ត្រីកោណមាត្រ

ខ. កំណត់តំលៃនៃ $1+z+z^2+z^3+\ldots+z^{11}$ ។

6. គណនា ក. $\sqrt{9\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)}$ ខ. $\sqrt[8]{-1}$ គ. $\sqrt[5]{1+i}$

ឃ. $\sqrt[4]{-2-i2\sqrt{3}}$ ង. $\sqrt[6]{1+i\sqrt{3}}$ ច. $\sqrt[5]{(2-2i)^4}$

7. គណនាឫសទី 5 នៃ $-\sqrt{3}-i$ ហើយតាងឫសទាំងនោះលើរង្វង់ត្រីកោណមាត្រ ។

8. គណនាឫសទី 6 នៃ 1 ហើយតាងឫសទាំងនោះលើរង្វង់ត្រីកោណមាត្រ ។

9. ដោះស្រាយសមីការខាងក្រោម :

ក. $z^4-8(-1+i\sqrt{3}) = 0$ ខ. $z^3+8i = 0$

គ. $z^4+81 = 0$ ឃ. $z^3+27i = 0$

ង. $z^3-4\sqrt{3}+4i = 0$ ច. $z^5+\frac{1}{\sqrt{2}}+\frac{1}{\sqrt{2}}i = 0$ ។

មេរៀនទី 4

# អនុវត្តន៍ចំនួនកុំផ្លិចក្នុងធរណីមាត្រ

## 1. ចំងាយរវាងពីរចំណុច

**វត្ថុបំណង**

- គណនាចំងាយរវាងពីរចំណុចក្នុងប្លង់កុំផ្លិច
- រកកូអរដោនេនៃចំណុចចែកក្នុងនិងចែកក្រៅ
- រកសំណុំចំណុចដែលផ្ទៀងផ្ទាត់ល័ក្ខខ័ណ្ឌដែលឱ្យ

*ឧទាហរណ៍ 1* គេឱ្យចំនួនកុំផ្លិច $z_1 = 1+2i$ និង $z_2 = 4+3i$ ស្ថិតនៅក្នុងប្លង់កុំផ្លិច ដែលមានរូបភាពតាងដោយ $A(z_1)$ និង $B(z_2)$ ។ យើងចង់ដឹងថា តើចម្ងាយរវាង $A$ និង $B$ ស្មើនឹងប៉ុន្មាន ?

( មើលរូបខាងក្រោម)




ភ្ជាប់ចំណុច $O$ និង $A$ គេបាន $OA$ ។ តាមចំណុច $O$ គូសអង្កត់ស្របនឹង $AB$ ហើយតាមចំណុច $B$ គូសអង្កត់ស្របនឹង $AO$ អង្កត់ទាំងពីរប្រសព្វគ្នាត្រង់ចំណុច $B'$ ។

គេបានចតុកោណ $OAB'B$ ជាប្រលេឡូក្រាម

វិបាក $OA = BB'$ និង $[OA] /\!/ [BB']$ ។

តាង $A'(-z_1)$ ជារូបភាពនៃ $-z_1$ គេបាន $OA = OA'$ ។

$OA = B'B$ ហើយ $OA = OA'$, $B'B = OA'$ ចតុកោណ $OA'B'B$ មាន $OA' = BB'$ និង $[OA'] /\!/ [BB']$ ជាប្រលេឡូក្រាម ។ គេបាន $B'(z_2 - z_1)$ ជារូបភាពនៃចំនួនកុំផ្លិច $z_2 - z_1$ ។

ដោយ $AB = OB'$ នោះ $AB = |z_2 - z_1|$

$$= |4+3i-1-2i|$$

$$= |3+i|$$

$$= \sqrt{9+1} = \sqrt{10}$$

ម្យ៉ាងទៀត $|z_1-z_2| = |1+2i-4-3i| = |-3-i| = \sqrt{(-3)^2+(-1)^2} = \sqrt{10}$

ដូចនេះ ប្រវែងនៃ $AB = \sqrt{10}$ ឯកតា ។

**ជាទូទៅ** បើ $A(z_1)$ និង $B(z_2)$ ជារូបភាពនៃចំនួនកុំផ្លិច $z_1$ និង $z_2$ នោះចម្ងាយ $AB = |z_2-z_1| = |z_1-z_2|$ ។

***ឧទាហរណ៍ 2*** គណនាចំងាយរវាង $A$ និង $B$ ដែលតាងចំនួនកុំផ្លិច $z_1 = -3+5i$ និង $z_2 = 1+2i$ ។

តាង $A(z_1)$ និង $B(z_2)$ ជារូបភាពរៀងគ្នានៃ $z_1$ និង $z_2$




អនុវត្តរូបមន្ត $AB = |1+2i+3-5i|$

$= |4-3i|$

$= \sqrt{16+9} = 5$ ដូចនេះ $AB = 5$ ឯកតា ។

**លំហាត់គំរូ 1** គណនាចម្ងាយរវាងចំណុច $A$ និង $B$ តាងចំនួនកុំផ្លិច $z_1 = a_1+b_1i$ និង $z_2 = a_2+b_2i$ ។

**ចម្លើយ** តាង $A(z_1)$ និង $B(z_2)$ ជារូបភាពរៀងគ្នានៃ $z_1$ និង $z_2$ ។

គេបាន $AB = |z_2-z_1|$

$= |a_2+b_2i-a_1-b_1i|$

$= |(a_2-a_1)+i(b_2-b_1)|$

$= \sqrt{(a_2-a_1)^2+(b_2-b_1)^2}$

ដូចនេះ ប្រវែង $AB = \sqrt{(a_2-a_1)^2+(b_2-b_1)^2}$ ។

**លំហាត់គំរូ 2** គេឱ្យចំនួនកុំផ្លិច $z_1 = -5+2i$ , $z_2 = 3+6i$ និង $z_3 = 4-6i$ ។ $A,B,C$ ជារូបភាពនៃ $z_1$, $z_2$, $z_3$ នៅក្នុងប្លង់កុំផ្លិច ។ បង្ហាញថាត្រីកោណ $ABC$ ជាត្រីកោណសមបាត ។

**ចម្លើយ** ចម្ងាយរវាង $A$ និង $C$ គឺ $AC = |z_3-z_1|$

$= |4-6i+5-2i|$

$= |9-8i|$

$AC = \sqrt{81+64} = \sqrt{145}$ ។

ចម្ងាយរវាង $B$ និង $C$ គឺ $BC = |z_3 - z_2|$

$= |4 - 6i - 3 - 6i|$

$= |1 - 12i|$

$= \sqrt{1+144} = \sqrt{145}$ ។




យើងបាន $AC = BC = \sqrt{145}$

ដូចនេះ ត្រីកោណ $ABC$ ជាត្រីកោណសមបាត ។

**ប្រតិបត្តិ 1** គណនាចម្ងាយរវាង $M$ និង $N$ តាងចំនួនកុំផ្លិច $z_1 = 1+3i$ និង $z_2 = 4+2i$ ។

**ប្រតិបត្តិ 2** គេមានចំនួនកុំផ្លិច $z_1 = 3+2i$ , $z_2 = -1-i$ និង $z_3 = 11-6i$ ។

$M, N, P$ ជារូបភាពនៃ $z_1, z_2, z_3$ នៅក្នុងប្លង់កុំផ្លិច ។ គណនារង្វាស់ជ្រុងនៃត្រីកោណ $MNP$ ។

## 2. ចំណុចចែកអង្កត់តាមផលធៀបមួយ

***ឧទាហរណ៍ 1*** គេឱ្យចំនួនកុំផ្លិច $z_1 = a_1 + b_1 i$ និង $z_2 = a_2 + b_2 i$ ដែលមានរូបភាពតាងដោយចំណុច $A(z_1)$ និង $B(z_2)$ រៀងគ្នា ។ តាងចំណុច $P(z)$ ជា រូបភាពនៃចំនួនកុំផ្លិច $z$ ដែលស្ថិតនៅលើ $[AB]$ ហើយចែក $[AB]$ តាមផលធៀប $m : n$ ។ យើងចង់រកចំនួនកុំផ្លិច $z$ ។




ភ្ជាប់ចំណុច $O$ និង $A$ ។ តាមចំណុច $O$ គូសអង្កត់ស្របនឹង $[AB]$ ហើយតាមចំណុច $B$ គូសអង្កត់ស្របនឹង $[OB]$ អង្កត់ទាំងពីរជួបគ្នាត្រង់ចំណុច $C$ ។

តាមចំណុច $P$ គូសបន្ទាត់ស្របនឹង $[AO]$ កាត់ $[OC]$ ត្រង់ចំណុច $Q$ ។ តាង $A'(-z_1)$ ជារូបភាពនៃ $-z_1$ ។

គេបាន $Q(z-z_1)$ ជារូបភាពនៃ $z+(-z_1)$ ឬ $z-z_1$

$C(z_2-z_1)$ ជារូបភាពនៃ $z_2+(-z_1)$ ឬ $z_2-z_1$ ។

$\frac{m}{m+n} = \frac{z-z_1}{z_2-z_1}$ , $z - z_1 = \frac{m}{m+n}(z_2-z_1)$

$$z = \frac{m}{m+n}(z_2-z_1)+z_1 = \frac{mz_2}{m+n} - \frac{mz_1}{m+n} + \frac{mz_1+nz_1}{m+n} = \frac{nz_1+mz_2}{m+n}$$

ដូចនេះ $z = \frac{nz_1+mz_2}{m+n}$ ។

PROEUS DARA

ម្យ៉ាងទៀត $z = \dfrac{nz_1 + mz_2}{m+n} = \dfrac{z_1 + \frac{m}{n}z_2}{1+\frac{m}{n}}$ បើគេតាង $\dfrac{m}{n} = \lambda$ គេបាន $z = \dfrac{z_1 + \lambda z_2}{1+\lambda}$ ។

> **ជាទូទៅ** បើគេមាន $z_1$ និង $z_2$ ជាចំនួនកុំផ្លិចដែលមានរូបភាពរៀងគ្នា $A(z_1)$ និង $B(z_2)$ ហើយចំណុច $P(z)$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ដែល $P$ ស្ថិតនៅលើ $AB$ ហើយចែក $AB$ តាមផលធៀប $m : n$ នោះគេបាន $z = \dfrac{z_1 + \lambda z_2}{1+\lambda}$ ដែល $\lambda = \dfrac{m}{n}$ ។

**សំគាល់** - បើ $\lambda = 1$ នោះចំណុច $P$ ស្ថិតនៅកណ្តាលអង្គត់ $[AB]$

- បើ $\lambda > 0$ នោះចំណុច $P$ ស្ថិតនៅចន្លោះ $A$ និង $B$
- បើ $\lambda < 0$ នោះចំណុច $P$ ស្ថិតនៅលើបន្លាយនៃ $[AB]$ ឬនៅក្រៅ $[AB]$ ។

**ឧទាហរណ៍ 2** គេមានចំនួនកុំផ្លិច $z_1 = 2+4i$ និង $z_2 = 8+6i$ ដែលមានរូបភាពរៀងគ្នា $A(z_1)$ និង $B(z_2)$ ចំណុច $P(z)$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ដែល $P$ ចែក $[AB]$ តាមផលធៀប $AP : PB = 2 : 1$ គណនា $z$ ។

តាមរូបមន្ត $z = \dfrac{z_1 + \lambda z_2}{1+\lambda}$ ដែល $\lambda = 2$

$$= \frac{2+4i+2(8+6i)}{1+2} = \frac{18+16i}{3}$$

ដូចនេះ $z = 6 + i\dfrac{16}{3}$ ។

**ឧទាហរណ៍ 3** គេមានចំនួនកុំផ្លិច $z_1 = 2+4i$ និង $z_2 = 8+6i$ ដែលមានរូបភាពជាចំណុច $A(2,\ 4)$ និង $B(8,\ 6)$ ។

ក. រកកូអរដោនេនៃចំណុច $P$ ដែលចែកអង្គត់ $[AB]$ តាមផលធៀប $AP : PB = -2$

ខ. រកកូអរដោនេនៃចំណុច $P$ កណ្តាល $[AB]$ ។

**ចម្លើយ** ក. តាមរូបមន្ត $z = \dfrac{z_1 + \lambda z_2}{1+\lambda}$

ដែល $\lambda = -2$ នាំឱ្យចំណុច $P$ ស្ថិត នៅលើបន្លាយនៃ $AB$ ។




$$z = \frac{2+4i-2(8+6i)}{1-2} = 14+8i$$

ដូចនេះ កូអរដោនេនៃចំណុច $P$ ដែលចែក $[AB]$ តាមផលធៀប $AP : PB = -2$ គឺ $P(14,\ 8)$ ។

ខ. តាមរូបមន្ត $z = \dfrac{z_1 + \lambda z_2}{1+\lambda}$ ដែល $\lambda = 1$

$$= \frac{z_1 + z_2}{2} = \frac{2+4i+8+6i}{2} = 5+5i$$

ដូចនេះ កូអរដោនេនៃ $P$ កណ្ដាល $AB$ គឺ $P(5,\ 5)$ ។

**លំហាត់គំរូ 1** គេឱ្យចំនួនកុំផ្លិច $z_1 = 7+4i$ និង $z_2 = 10-2i$ ដែលមានរូបភាពជាចំណុច $A(7,\ 4)$ និង $B(10,\ -2)$ ។ រកកូអរដោនេនៃចំណុច $M$ ដែលចែកអង្កត់ $[AB]$ តាមផលធៀប $AM : MB = 0.2$ ។

**ចម្លើយ** តាមរូបមន្ត $z = \dfrac{z_1+\lambda z_2}{1+\lambda} = \dfrac{7+4i+0.2(10-2i)}{1+0.2} = \dfrac{7+4i+2-0.4i}{1.2}$

$$= \frac{9+3.6i}{1.2} = 7.5+3i$$

ដូចនេះ ចំណុច $M(7.5,\ 3)$ ជារូបភាពនៃ $z = 7.5+3i$ ។

**លំហាត់គំរូ 2** គេឱ្យចំនួនកុំផ្លិច $z_1 = -3-7i$ និង $z_2 = 10+2i$ ដែលមានរូបភាព $A(-3,\ -7)$ និង $B(10,\ 2)$ ។ រកកូអរដោនេនៃចំណុច $M$ ដែលចែកអង្កត់ $[AB]$ ត្រង់ចំណុច $\frac{1}{3}$ នៃ $AB$ ។

**ចម្លើយ** ចំណុច $M$ ចែកអង្កត់ $[AB]$ ត្រង់ $\frac{1}{3}$ នៃ $AB$ មានពីរករណី

- ករណី $AM : MB = \frac{1}{2}$




គេបាន $z = \dfrac{z_1+\lambda z_2}{1+\lambda} = \dfrac{-3-7i+\frac{1}{2}(10+2i)}{1+\frac{1}{2}} = \dfrac{2-6i}{\frac{3}{2}} = \dfrac{4}{3} - 4i$

ដូចនេះ កូអរដោនេនៃ $M\left(\frac{4}{3},\ -4\right)$ ។

- ករណី $AM : MB = 2 : 1$




គេបាន $z = \dfrac{z_1+\lambda z_2}{1+\lambda} = \dfrac{-3-7i+2(10+2i)}{1+2} = \dfrac{17-3i}{3} = \left(\dfrac{17}{3} - i\right) = \dfrac{17}{3} - i$

ដូចនេះ កូអរដោនេនៃ $M\left(\frac{17}{3},\ -1\right)$ ។

**ប្រតិបត្តិ** គេឱ្យចំនួនកុំផ្លិច $z_1 = 6+4i$ និង $z_2 = 1+9i$ ដែលមានរូបភាពតាងដោយចំណុច $A(6,\ 4)$ និង $B(1,\ 9)$ ។ រកកូអរដោនេនៃចំណុច $M$ ដែលចែកអង្កត់ $[AB]$ តាមផលធៀប $AM : MB = 2 : 3$ ។

# 3. ផលធៀបជ្រុងនិងមុំនៃត្រីកោណក្នុងប្លង់កុំផ្លិច

នៅក្នុងប្លង់កុំផ្លិច គេតាងចំនួនកុំផ្លិច $z$, $z_1$ និង $z_2$ ដោយចំណុចរៀងគ្នា $A$, $B$ និង $C$ ។ គេបានត្រីកោណ $ABC$ (រូបខាងស្តាំ)។ ដើម្បីគណនា $\angle BAC$ ដោយប្រើចំនួនកុំផ្លិច គេសង់វ៉ិចទ័រ $\overrightarrow{OB'} = \overrightarrow{AB}$ និង $\overrightarrow{OC'} = \overrightarrow{AC}$ ។ គេបាន $ABC$ និង $OC'B'$ ជាត្រីកោណដូចគ្នា ហើយ $\angle BAC = \angle B'OC'$ ។




$\overrightarrow{AB}$ ជារូបភាពនៃចំនួនកុំផ្លិច $z_1 - z$ ហើយ $\overrightarrow{AC}$ ជារូបភាពនៃចំនួនកុំផ្លិច $z_2 - z$ ។

យើងបាន $\overrightarrow{OB'}(z_1 - z)$ និង $\overrightarrow{OC'}(z_2 - z)$

$$(\overrightarrow{Ox}, \overrightarrow{OB'}) = \arg(z_1 - z) \text{ និង } (\overrightarrow{Ox}, \overrightarrow{OC'}) = \arg(z_2 - z)$$

ហើយ $\angle B'OC' = \arg(z_2 - z) - \arg(z_1 - z) = \arg\left(\frac{z_2 - z}{z_1 - z}\right)$

ដូចនេះ $\angle BAC$ កំណត់ដោយ $\angle BAC = \arg\left(\frac{z_2 - z}{z_1 - z}\right)$ ផលធៀបជ្រុងនៃត្រីកោណ

$\frac{AC}{AB} = \frac{|z_2 - z|}{|z_1 - z|} = \left|\frac{z_2 - z}{z_1 - z}\right|$ ។

**ជាទូទៅ** បើ $A(z)$ , $B(z_1)$ និង $C(z_2)$ បង្កើតបានត្រីកោណ $ABC$ នោះគេបាន

$\frac{AC}{AB} = \left|\frac{z_2 - z}{z_1 - z}\right|$ ហើយ $\angle BAC = \arg\left(\frac{z_2 - z}{z_1 - z}\right)$ ។

***ឧទាហរណ៍ 1*** បើ $A(-1-i)$ , $B(1+i)$ និង $C(-1+i)$ បង្កើតបានត្រីកោណ $ABC$ ។ គណនាផលធៀប $\frac{AC}{AB}$ និង $\angle BAC$ នៃត្រីកោណ $ABC$ ។

តាមរូបមន្ត $\frac{AC}{AB} = \left|\frac{z_2 - z}{z_1 - z}\right|$

តែ $\frac{z_2 - z}{z_1 - z} = \frac{-1 + i - (-1 - i)}{1 + i - (-1 - i)} = \frac{i}{1 + i}$

$$\left|\frac{z_2 - z}{z_1 - z}\right| = \left|\frac{i}{1 + i}\right| = \frac{|i|}{|1 + i|} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$$

ដូចនេះ $\frac{AC}{AB} = \frac{\sqrt{2}}{2}$ ។

$$\angle BAC = \arg\left(\frac{z_2 - z}{z_1 - z}\right) = \arg\left(\frac{i}{1+i}\right)$$
$$= arg\, i - arg(1+i)$$
$$= \frac{\pi}{2} - \frac{\pi}{4}$$

ដូចនេះ $\angle BAC = \frac{\pi}{4}$ ។

**លំហាត់គំរូ 1** គេឱ្យចំណុច $M$, $M_1$ និង $M_2$ ជារូបភាពរៀងគ្នានៃចំនួនកុំផ្លិច $z$, $z_1 = 2 - 3i$ និង $z_2 = i$ ។ ចូរកំណត់ចំណុច $M$ ដែល $\frac{MM_1}{MM_2} = 3$ ។

**ចម្លើយ** $\frac{MM_1}{MM_2} = \left|\frac{z_1 - z}{z_2 - z}\right| = \frac{|z_1 - z|}{|z_2 - z|}$ តាមចំនួនកុំផ្លិច $z = x + iy$

$$= \frac{|2 - 3i - x - yi|}{|i - x - yi|}$$
$$= \frac{|(2-x) + (-3-y)i|}{|-x + (1-y)i|}$$

តែ $|(2-x) + (-3-y)i| = \sqrt{(2-x)^2 + (-3-y)^2}$

$|(-x) + (1-y)i| = \sqrt{(-x)^2 + (1-y)^2}$

គេបាន $\frac{\sqrt{(2-x)^2 + (-3-y)^2}}{\sqrt{(-x)^2 + (1-y)^2}} = 3 \Leftrightarrow \frac{(2-x)^2 + (-3-y)^2}{x^2 + (1-y)^2} = 9$

$$\frac{4 + 4x + x^2 + 9 + 6y + y^2}{x^2 + 1 - 2y + y^2} = 9$$
$$13 - 4x + x^2 + 6y + y^2 = 9x^2 + 9 - 18y + 9y^2$$
$$2(x^2 + 2x) + 2(y^2 - 3y) - 1 = 0$$
$$2(x^2 + 2x + 1 - 1) + 2\left(y^2 - 3y + \frac{9}{4} - \frac{9}{4}\right) - 1 = 0$$
$$2[(x+1)^2 - 1] + 2\left[\left(y - \frac{3}{2}\right)^2 - \frac{9}{4}\right] - 1 = 0$$
$$2(x+1)^2 - 2 + 2\left(y - \frac{3}{2}\right)^2 - \frac{9}{2} - 1 = 0$$
$$2(x+1)^2 + 2\left(y - \frac{3}{2}\right)^2 = \frac{15}{2}$$
$$(x+1)^2 + \left(y - \frac{3}{2}\right)^2 = \frac{15}{4}$$

ដូចនេះសំណុំចំណុច $M$ គឺជារង្វង់ផ្ចិត $\left(-1, \frac{3}{2}\right)$ និងកាំស្មើ $\frac{\sqrt{15}}{2}$ ។

**លំហាត់គំរូ 2** គេឱ្យចំណុច $M$, $M_1$ និង $M_2$ ជារូបភាពរៀងគ្នានៃចំនួនកុំផ្លិច $z$, $z_1 = -2i$ និង $z_2 = 2i$ ។ ចូរកំណត់ចំណុច $M$ ដែល $arg\left(\frac{z - z_1}{z - z_2}\right) = \frac{\pi}{4}$ ។

**ចម្លើយ** តាង $z = x + yi$

គេបាន $\dfrac{z - z_1}{z - z_2} = \dfrac{x + yi + 2i}{x + yi - 2i} = \dfrac{x + i(y+2)}{x + i(y-2)}$

$$= \frac{[x + i(y+2)][x - i(y-2)]}{[x + i(y-2)][x - i(y-2)]}$$

$$= \frac{x^2 - ix(y-2) + ix(y+2) + y^2 - 4}{x^2 + (y-2)^2}$$

$$= \frac{x^2 + y^2 - 4 + 4xi}{x^2 + (y-2)^2}$$

$$= \frac{x^2 + y^2 - 4}{x^2 + (y-2)^2} + \frac{4x}{x^2 + (y-2)^2}\, i$$

$$\Rightarrow \arg\left(\frac{x^2 + y^2 - 4}{x^2 + (y-2)^2} + \frac{4x}{x^2 + (y-2)^2}\, i\right) = \frac{\pi}{4}$$

គេបាន $\dfrac{\dfrac{4x}{x^2 + (y-2)^2}}{\dfrac{x^2 + y^2 - 4}{x^2 + (y-2)^2}} = \tan\dfrac{\pi}{4}$

$$\frac{4x}{x^2 + (y-2)^2} \times \frac{x^2 + (y-2)^2}{x^2 + y^2 - 4} = \tan\frac{\pi}{4} = 1$$

$$x^2 + y^2 - 4 = 4x$$

$$x^2 - 4x + y^2 = 4$$

$$(x-2)^2 + y^2 = 8$$

ដូចនេះសំណុំចំណុច $M$ គឺជារង្វង់មានផ្ចិត $(2, 0)$ និងមានកាំស្មើនឹង $2\sqrt{2}$ ។

**ប្រតិបត្តិ** គេឱ្យចំណុច $A$, $B$ និង $C$ ជារូបភាពរៀងគ្នានៃចំនួនកុំផ្លិច $z = -1 - i$ , $z_1 = 1 + i$ និង $z_2 = -1 + i$ ។ គណនាផលធៀបជ្រុង និងមុំនៃត្រីកោណ $ABC$

ក. $\dfrac{AC}{AB}$ និង $\angle BAC$

ខ. $\dfrac{CB}{CA}$ និង $\angle BCA$

គ. $\dfrac{BA}{BC}$ និង $\angle ABC$ ។

# 4. សំណុំចំណុចក្នុងប្លង់កុំផ្លិច

ពិនិត្យមើលចំនួនកុំផ្លិច $z = x+yi$ និងរូបភាពនៃ $z$ ដែលតាងដោយចំណុច $P(x, y)$ នៅប្លង់កុំផ្លិច ។ បើគេឱ្យលក្ខខណ្ឌដែល $z$ ត្រូវតែបំពេញតាម នោះសំណុំនៃរូបភាព $P$ ទាំងអស់ដែលអាចមាន បង្កើតបានជាសំណុំចំណុច $P$ ។

***ឧទាហរណ៍ 1*** រកសំណុំចំណុច $P$ ជារូបភាពនៃ $z$ ដែលបំពេញតាមលក្ខខណ្ឌ $|z-i| = 1$ ។

តាងចំនួនកុំផ្លិច $z = x+yi$

គេបាន $|x+yi-i| = 1 \Leftrightarrow |x+(y-1)i| = 1$

$$\sqrt{x^2+(y-1)^2} = 1$$

$$x^2+(y-1)^2 = 1$$




ដូចនេះសំណុំចំណុច $P$ គឺជារង្វង់ដែលមានផ្ចិត $(0, 1)$ និងកាំស្មើនឹង $1$ ។

***ឧទាហរណ៍ 2*** រកសំណុំចំណុច $P$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ដែលបំពេញតាមលក្ខខណ្ឌ $|z-3| = |z-2i|$ ។

តាង $z = x+yi$ គេបាន

$$|x+yi-3| = |x+yi-2i|$$

$$|(x-3)+yi| = |x+(y-2)i|$$

$$\sqrt{(x-3)^2+y^2} = \sqrt{x^2+(y-2)^2}$$

$$(x-3)^2+y^2 = x^2+(y-2)^2$$

$$x^2-6x+9+y^2 = x^2+y^2-4y+4$$

$$-6x+4y = -5$$




ដូចនេះ សំណុំចំណុច $P$ គឺជាបន្ទាត់ដែលមានសមីការ $4y-6x = -5$ ។

***ឧទាហរណ៍ 3*** រកសំណុំចំណុច $P$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ដែលបំពេញតាមលក្ខខណ្ឌ $arg(z+1) = \frac{3\pi}{4}$ ។

តាង $z = x + yi$ ដោយ $\arg(z+1) = \frac{3\pi}{4}$

$\arg(x+1+yi) = \frac{3\pi}{4}$

គេបាន

$\frac{y}{x+1} = \tan\frac{3\pi}{4} = -1$

$\frac{y}{x+1} = -1$ , $y = -x - 1$ ។

ដូចនេះ សំណុំចំណុច $P$ គឺជាបន្ទាត់ដែលមាន




សមីការ $y = -x - 1$ ដែល $y \geq 0$ ។

**លំហាត់គំរូ 1** រកសំណុំចំនួន $P$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ដែលបំពេញតាមល័ក្ខខ័ណ្ឌខាងក្រោម៖

ក. $|z| = 3$

ខ. $|z+2i| = |z-1|$

**ចម្លើយ** ក. ឧបមាថា $z = x + yi$

គេបាន $|x+yi| = 3$ , $\sqrt{x^2+y^2} = 3$

$x^2 + y^2 = 9$

ដូចនេះសំណុំចំណុច $P$ គឺជារង្វង់ដែលមាន

ផ្ចិតស្ថិតនៅចំគល់នៃអ័ក្ស និងមានកាំស្មើនឹង 3 ។




ខ. ឧបមាថា $z = x + yi$

គេបាន $|z+2i| = |z-1|$ , $|x+yi+2i|$

$= |x+yi-1|$

$|x+(y+2)i| = |(x-1)+yi|$

$\sqrt{x^2+(y+2)^2} = \sqrt{(x-1)^2+y^2}$

$x^2+y^2+4y+4 = x^2-2x+1+y^2$

$4y+2x+3 = 0$

ដូចនេះ សំណុំចំណុច $P$ គឺជាបន្ទាត់ដែល

មានសមីការ $4y+2x+3 = 0$ ។



PROEUS DARA

**លំហាត់គំរូ 2** រកសំណុំចំណុច $P$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ដែលបំពេញតាមលក្ខខណ្ឌ $|z-2| = 3|z+2|$

**ចម្លើយ** ឧបមាថា $z = x+yi$




គេបាន $|z-2| = 3|z+2|$

$$|x+4i-2| = 3|x+yi+2|$$

$$|(x-2)+yi| = 3|(x-2)+yi|$$

$$\sqrt{(x-2)^2+y^2} = 3\sqrt{(x+2)^2+y^2}$$

$$(x-2)^2+y^2 = 9[(x-2)^2+y^2]$$

$$x^2-4x+4+y^2 = 9(x^2+4x+4+y^2)$$

$$x^2+5x+4+y^2 = 0$$

$$x^2+5x+\frac{25}{4}-\frac{25}{4}+4+y^2 = 0$$

$$\left(x+\frac{5}{2}\right)^2+y^2 = \frac{9}{4}$$ ។

ដូចនេះ សំណុំចំណុច $P$ គឺជារង្វង់ដែលមានផ្ចិត $\left(-\frac{5}{2}, 0\right)$ ហើយមានកាំស្មើនឹង $\frac{3}{2}$ ។

## ប្រតិបត្តិ

រកសំណុំចំណុច $P$ ដែលជារូបភាពនៃចំនួនកុំផ្លិច $z$ ហើយបំពេញតាមលក្ខខណ្ឌខាងក្រោម ៖

ក. $\arg z = \frac{\pi}{4}$

ខ. $|z-18| = 2|z+18i|$ ។

# មេរៀនសង្ខេប

- ចំនួនកុំផ្លិចជាចំនួនដែលមានរាង $a+bi$ ដែល $a$ និង $b$ ជាចំនួនពិត ។ ហើយ $i^2 = -1$
- ចំនួនកុំផ្លិច $a+bi$ និង $c+di$ ស្មើគ្នា លុះត្រាតែ $a = c$ និង $b = d$ ។
- ផលបូកចំនួនកុំផ្លិច $(a+bi)+(c+di) = (a+c)+i(b+d)$
- ផលដកចំនួនកុំផ្លិច $(a+bi)-(c+di) = (a-c)+i(b-d)$
- ផលគុណចំនួនកុំផ្លិច $(a+bi)(c+di) = (ac-bd)+i(ad+bc)$
- ចំនួនកុំផ្លិចឆ្លាស់នៃចំនួនកុំផ្លិច $z = a+bi$ តាងដោយ $\bar{z} = a-bi$ ។
- ចំនួនកុំផ្លិចផ្ទុយនៃចំនួនកុំផ្លិច $z = a+bi$ តាងដោយ $-z = -a-bi$ ។
- បើគេមានចំនួនកុំផ្លិច $z = a+bi$ នោះម៉ូឌុលនៃ $z$ តាងដោយ $r = |z| = \sqrt{a^2+b^2}$ ។
- លក្ខណៈម៉ូឌុលនៃចំនួនកុំផ្លិច
  - បើ $z$ ជាចំនួនកុំផ្លិចនោះ $|z| = |\bar{z}| = |-z|$
  - បើ $z_1$ និង $z_2$ ជាចំនួនកុំផ្លិច នោះគេបាន $|z_1z_2| = |z_1|\cdot|z_2|$ , $\left|\dfrac{z_1}{z_2}\right| = \dfrac{|z_1|}{|z_2|}$ , $|z_1+z_2| \le |z_1|+|z_2|$
- វ៉ិចទ័រ $\overrightarrow{OM}$ ជារូបភាពនៃចំនួនកុំផ្លិច $z$ តាង $\varphi$ ជាមុំតូចបំផុតនៃ $(\overrightarrow{Ox}, \overrightarrow{OM})$ $\varphi$ ហៅថា អាគុយម៉ង់នៃចំនួនកុំផ្លិច $z$ ។ ដើម្បីគណនាមុំ $\varphi$ យើងត្រូវដោះស្រាយប្រព័ន្ធសមីការ :

$$\begin{cases} \cos\varphi = \dfrac{a}{\sqrt{a^2+b^2}} = \dfrac{a}{r} \\ \sin\varphi = \dfrac{b}{\sqrt{a^2+b^2}} = \dfrac{b}{r} \end{cases}$$

- $z = r(\cos\varphi + i\sin\varphi)$ ហៅថាទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច $z = a+bi$ ។
- បើ $z_1 = r_1(\cos\varphi_1 + i\sin\varphi_1)$ និង $z_2 = r_2(\cos\varphi_2 + i\sin\varphi_2)$ នោះគេបាន
  - $z_1z_2 = r_1r_2[\cos(\varphi_1+\varphi_2) + i\sin(\varphi_1+\varphi_2)]$
  - $\dfrac{z_1}{z_2} = \dfrac{r_1}{r_2}[\cos(\varphi_1-\varphi_2) + i\sin(\varphi_1-\varphi_2)]$
  - $z^n = [r(\cos\varphi + i\sin\varphi)]^n = r^n(\cos n\varphi + i\sin n\varphi)$ គ្រប់ $n$ ជាចំនួនគត់រ៉ឺឡាទីប ។

គេអាចទាញបាន $(\cos\varphi + i\sin\varphi)^n = \cos n\varphi + i\sin n\varphi$ ហៅថាទ្រឹស្តីបទដឺម័រ ។

- បើ $z = r(\cos\varphi + i\sin\varphi)$ ជាចំនួនកុំផ្លិចមិនសូន្យ ហើយ $n$ ជាចំនួនគត់វិជ្ជមាន នោះ $z$ មាន $n$ ឫសទី $n$ គឺ $w_0, w_1, w_2, \ldots, w_{n-1}$ ។
- បើ $z_1$ និង $z_2$ ជាចំនួនកុំផ្លិចមានរូបភាពរៀងគ្នា តាងដោយចំណុច $A$ និង $B$ នោះ ប្រវែង $AB = |z_2 - z_1| = |z_1 - z_2|$ ។
- បើគេមានចំនួនកុំផ្លិច $z_1$ និង $z_2$ ដែលមានរូបភាពរៀងគ្នា តាងដោយ $A(z_1)$ និង $B(z_2)$ ហើយចំណុច $P(z)$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ដែល $P$ ស្ថិតនៅលើ $AB$ ចែក $AB$ តាមផលធៀប $m : n$ នោះគេបាន $z = \dfrac{z_1 + \lambda z_2}{1+\lambda}$ ដែល $\lambda = \dfrac{m}{n}$ ។
  - បើ $\lambda = 1$ នោះចំណុច $P$ ស្ថិតនៅកណ្ដាលអង្កត់ $AB$
  - បើ $\lambda > 0$ នោះចំណុច $P$ ស្ថិតនៅចន្លោះ $A$ និង $B$
  - បើ $\lambda < 0$ នោះចំណុច $P$ ស្ថិតនៅលើបន្លាយនៃ $AB$ ឬនៅក្រៅអង្កត់ $AB$ ។
  - បើ $A(z)$ , $B(z_1)$ និង $C(z_2)$ បង្កើតបានត្រីកោណ $ABC$

គេបាន $\dfrac{AC}{AB} = \left|\dfrac{z_2 - z}{z_1 - z}\right|$ ហើយ $\angle BAC = \arg\left(\dfrac{z_2 - z}{z_1 - z}\right)$ ។

## លំហាត់

1. គេមានចំនួនកុំផ្លិច $3 - 2i$ និង $4 + 5i$ ដែលមានរូបភាពតាងដោយចំណុចរៀងគ្នា $A$ និង $B$ ។ គណនាប្រវែង $AB$ ។

2. គេមានចំនួនកុំផ្លិច $1 - 3i$ និង $2 + i$ ដែលមានរូបភាពតាងដោយចំណុចរៀងគ្នា $A$ និង $B$ ។

   ក. គណនាប្រវែង $AB$

   ខ. រកកូអរដោនេចំណុចកណ្ដាល $AB$ ។

3. ចំណុច $A, B$ និង $C$ ជារូបភាពរៀងគ្នានៃចំនួនកុំផ្លិច $2 + i$ , $-1$ និង $3 - 2i$ ។ ប្រាប់ប្រភេទនៃត្រីកោណ $ABC$ ។

4. គេមានចំនួនកុំផ្លិច $3 + 2i$ , $-1 - i$ និង $11 - 6i$ ដែលមានរូបភាពរៀងគ្នាតាងដោយចំណុច $A, B$ និង $C$ គណនាមេដ្យានទាំងបីនៃត្រីកោណ $ABC$ ។

5. ចំណុច $A$, $B$, $C$ និង $D$ ជារូបភាពរៀងគ្នានៃចំនួនកុំផ្លិច $-2+i$ , $4i$ , $\frac{7}{2}+2i$ និង $\frac{3}{2}-i$ ។ ប្រាប់ប្រភេទនៃចតុកោណ $ABCD$ ។

6. គេឱ្យចំនួនកុំផ្លិច $6+4i$ និង $1+9i$ ដែលមានរូបភាពរៀងគ្នា តាងដោយចំណុច $A$ និង $B$ ។ កំណត់រូបភាព $M$ នៃចំនួនកុំផ្លិច $z$ ដែលចំណុច $M$ ចែក $AB$ តាមផលធៀប $AM : MB = 2 : 1$ ។

7. គេមានចំនួនកុំផ្លិច $z$, $z_1$ និង $z_2$ ដែលមានរូបភាពតាងដោយចំណុចរៀងគ្នា $A$, $B$ និង $C$ ។ ដោយដឹងថា $\frac{z_2-z}{z_1-z} = 2+i2\sqrt{3}$ គណនាផលធៀប $\frac{AC}{AB}$ និង $\angle BAC$ នៃត្រីកោណ $ABC$ ។

8. រកសំណុំចំណុច $P$ នៃចំនួនកុំផ្លិច $z$ ដែលបំពេញលក្ខខណ្ឌខាងក្រោម ៖

ក. $|z| = 5$

ខ. $|z-2| = 5$

គ. $|z-2i| = 4$

ឃ. $|z+2+2i| = 2\sqrt{2}$

ង. $|z+3-i\sqrt{3}| = 2\sqrt{3}$

ច. $2|z-i| = 3$ ។

9. រកសំណុំចំណុច $P$ នៃចំនួនកុំផ្លិច $z$ ដែលបំពេញលក្ខខណ្ឌខាងក្រោម ៖

ក. $\arg z = \frac{3\pi}{4}$

ខ. $\arg(z+2) = \frac{\pi}{2}$

គ. $\arg(z-3i) = \frac{\pi}{3}$ ។

10. រកសំណុំចំណុច $P$ នៃចំនួនកុំផ្លិច $z$ ដែលបំពេញលក្ខខណ្ឌខាងក្រោម ៖

ក. $|z-2| = |z-4|$

ខ. $|z-6| = |z+3|$

គ. $|z-1| = 3|z+2|$ ។

# លំហាត់ជំពូក

1. គណនា $z_1+z_2$ , $z_1-z_2$ , $z_1z_2$ និង $\frac{z_1}{z_2}$ បើ

ក. $z_1 = 3+2i$ និង $z_2 = 1-7i$

ខ. $z_1 = \sqrt{3}-i\sqrt{5}$ និង $z_2 = \sqrt{3}+i\sqrt{5}$ ។

2. សរសេរចំនួនកុំផ្លិច $z$ ខាងក្រោមជាទម្រង់ពីជគណិត

ក. $z = \frac{-41+63i}{50} - \frac{6i+1}{1-7i}$

ខ. $z = \frac{(1+2i)^2-(1-i)^3}{(3+2i)^3-(2+i)^2}$

គ. $z = \frac{13+12i}{6i-8} + \frac{(2i+1)^2}{2+i}$

ឃ. $z = \left(\frac{-1+i\sqrt{3}}{2i}\right)^2$ ។

3. គណនាម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិច $z = \frac{(1+i)^{13}}{(1-i)^7}$ ។

4. បំប្លែងចំនួនខាងក្រោមជាទម្រង់ត្រីកោណមាត្រ

ក. $(\sqrt{3}-i)^{100}$

ខ. $1+\cos\frac{10\pi}{9}+i\sin\frac{10\pi}{9}$

5. គេមានចំនួនកុំផ្លិច $z = \dfrac{\cos\frac{\pi}{9}+i\sin\frac{\pi}{9}}{\cos\frac{4\pi}{9}+i\sin\frac{4\pi}{9}}$ សរសេរចំនួន $z$ ជាទម្រង់ត្រីកោណមាត្រ រួចជាទម្រង់ពីជគណិត ។

6. ដោះស្រាយសមីការ

ក. $z^4+8+i8\sqrt{3} = 0$

ខ. $z^2+|z|^2 = 0$ ។

7. ចំនួនកុំផ្លិច $z$ បំពេញលក្ខខណ្ឌ $|z+3-i\sqrt{3}| = \sqrt{3}$ ។ គណនា $z$ ដែលមានអាគុយម៉ង់វិជ្ជមានតូចបំផុត ។

8. រកសំណុំនៃចំនួនកុំផ្លិច $z$ ដែលបំពេញលក្ខខណ្ឌខាងក្រោម ៖

ក. $|z-2i| = 4$

ឃ. $|z+2| < |z-2|$

ខ. $|z-1-3i| = 5$

ង. $|z-i| = |z-1|$

គ. $|z| = |z-2i|$

ច. $|z-4+i| = |z-1-2i|$

PROEUS DARA


# ជំពូក 8

# វិចទ័រក្នុងលំហ




យើងបានសិក្សាវិចទ័រក្នុងប្លង់រួចរាល់ហើយនៅថ្នាក់ទី 10 ឥឡូវយើងនឹងសិក្សាពីវិចទ័រក្នុងលំហម្តង ។

មូលដ្ឋានសំខាន់ៗនៃវិចទ័រក្នុងលំហ គឺដូចវិចទ័រក្នុងប្លង់ដែរ ប៉ុន្តែគ្រាន់តែយើងសិក្សាឱ្យស៊ីជម្រៅជាងមុនបន្តិច គឺយើងសិក្សាលើតម្រុយដែលមានអ័ក្សបី ឬគេហៅថា បីឌីម៉ង់ស្យុង ដើម្បីឱ្យកាន់តែស៊ីជម្រៅលើផ្នែកធរណីមាត្រ ។

យើងឃើញថាបន្ទាត់ត្រង់ យើងសិក្សាលើអ័ក្សមួយ ( មួយឌីម៉ង់ស្យុង ) រីឯប្លង់យើងសិក្សាលើអ័ក្សពីរ ( ពីរឌីម៉ង់ស្យុង ) ចំណែកឯស្វ៊ែរវិញ យើងសិក្សាលើអ័ក្សបី ( បីឌីម៉ង់ស្យុង ) ។ សព្វថ្ងៃយើងសិក្សាផងដែរទៅលើលំហដែលមានអ័ក្ស $n$($n$ ឌីម៉ង់ស្យុង) ។ យើងឃើញថាទោះជាវិចទ័រមិនបានពង្រីកបញ្ញត្តិធរណីមាត្រឱ្យបានស៊ីជម្រៅយ៉ាងណាក៏ដោយ ក៏វាជាកម្មវត្ថុនៃគណិតវិទ្យាដែលរៀបរាប់ពី " វិចទ័រក្នុងលំហ " ដែរ ។ លក្ខណៈបែបនេះហើយ គឺជាវិធីសាស្ត្រដ៏ទំនើបដែលធ្វើឱ្យគណិតវិទ្យាកាន់តែរីកចម្រើនឡើង ។

លោក Giuseppe peano (1858-1932) ជាអ្នកគណិតវិទ្យាដែលលោកទទួលខុសត្រូវចំពោះស្វ័យសត្យនិយមន័យរបស់បញ្ញត្តិវិចទ័រក្នុងលំហ ហើយដែលបានផ្តល់ឱ្យយើងដឹងនូវប្រព័ន្ធស្វ័យសត្យ
13 នៃចំនួនគត់ធម្មជាតិផងដែរ ។

មេរៀនទី 1

# វ៉ិចទ័រក្នុងលំហ

## 1. វ៉ិចទ័រក្នុងលំហ

### 1.1 សញ្ញាណវ៉ិចទ័រ

**វត្ថុបំណង**

- កំណត់និយមន័យនៃវ៉ិចទ័រក្នុងលំហ
- គណនាកូអរដោនេនៃវ៉ិចទ័រក្នុងលំហ
- គណនាប្រមាណវិធីលើវ៉ិចទ័រក្នុងលំហ
- គណនាផលគុណស្កាលែនៃវ៉ិចទ័រក្នុងលំហ

***ឧទាហរណ៍*** ចលនានៃចំណុចផ្លាស់ទីពី $A$ ទៅ $B$ ក្នុងលំហ អាចតាងដោយអង្កត់មានទិសដៅ$AB$ ដែលមានព្រួញ ( ដូចរូបខាងក្រោម ) ។




អង្កត់មានទិសដៅ $AB$ ហៅថា **វ៉ិចទ័រក្នុងលំហ** ដែលមាន $A$ ជាគល់ និង $B$ ជាចុង ។ គេកំណត់សរសេរដោយ $\overrightarrow{AB}$ ។

| | |
|---|---|
| **និយមន័យ** | អង្កត់មានទិសដៅ $AB$ នៅក្នុងលំហហៅថា វ៉ិចទ័រក្នុងលំហ ដែលមាន $A$ ជាគល់ និង $B$ ជាចុង ។ គេកំណត់សរសេរដោយ $\overrightarrow{AB}$ |

**ជាទូទៅ** គេតាងអក្សរណាមួយក៏បានសម្រាប់តាងឱ្យវ៉ិចទ័រ ។

***ឧទាហរណ៍*** $\overrightarrow{AB} = \vec{a}$ , $\overrightarrow{CD} = \vec{u},...$ ។ $AB = |\overrightarrow{AB}|$ ឬ $a = |\vec{a}|$ ហៅថាប្រវែងនៃវ៉ិចទ័រ $\overrightarrow{AB}$ ឬ $\vec{a}$

PROEUS DARA

## 1.2 វ៉ិចទ័រស្មើគ្នានៅក្នុងលំហ

### និយមន័យ

***ឧទាហរណ៍*** គេមានគូប $ABCD\text{-}EFGH$ មួយ ។

គេថាវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{DC}$ មានប្រវែងស្មើគ្នានិងមានទិសដៅដូចគ្នា គេសរសេរ $\overrightarrow{AB} = \overrightarrow{DC}$ ។

ដូចគ្នាដែរវ៉ិចទ័រ $\overrightarrow{EH} = \overrightarrow{FG}$ ។




**ជាទូទៅ** គេបានវ៉ិចទ័រ $\overrightarrow{AB} = \overrightarrow{DC}$ កាលណាវា

- ស្របគ្នា ឬមានទម្ររួម
- មានទិសដៅដូចគ្នា
- មានប្រវែងស្មើគ្នា ($|\overrightarrow{AB}| = |\overrightarrow{CD}|$)

## 1.3 វ៉ិចទ័រផ្ទុយគ្នាក្នុងលំហ

### និយមន័យ

***ឧទាហរណ៍*** គេមានគូប $ABCD\text{-}EFGH$ ។ គេថាវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{CD}$ មានប្រវែងស្មើគ្នា និងមានទិសដៅផ្ទុយគ្នា

គេសរសេរ $\overrightarrow{AB} = -\overrightarrow{CD}$ ឬ $\overrightarrow{CD} = -\overrightarrow{AB}$ នោះគេថា $\overrightarrow{CD}$ ជាវ៉ិចទ័រផ្ទុយគ្នានឹងវ៉ិចទ័រ $\overrightarrow{AB}$ ។

ដូចគ្នាដែរ $\overrightarrow{EH} = -\overrightarrow{GF}$ ឬ $\overrightarrow{GF} = -\overrightarrow{EH}$ នោះគេថា $\overrightarrow{GF}$ ជាវ៉ិចទ័រផ្ទុយគ្នានឹងវ៉ិចទ័រ $\overrightarrow{EH}$ ។




**ជាទូទៅ** គេបានវ៉ិចទ័រ $\overrightarrow{AB} = -\overrightarrow{CD}$ កាលណាវា :

- ស្របគ្នា ឬមានទម្ររួម
- មានទិសដៅផ្ទុយគ្នា
- មានប្រវែងស្មើគ្នា ($|\overrightarrow{AB}| = |\overrightarrow{CD}|$)

### 1.4 វ៉ិចទ័រសូន្យ

**និយមន័យ** វ៉ិចទ័រ $\vec{a}$ ជា **វ៉ិចទ័រសូន្យ** លុះត្រាតែ $|\vec{a}| = 0$ ។

គេកំណត់វ៉ិចទ័រសូន្យដោយ $\overrightarrow{AA} = \vec{O}$ , $\overrightarrow{BB} = \vec{O}, \ldots$ ។

**លំហាត់គំរូ** គេឱ្យប្រលេពីប៉ែតកែង $ABCD\text{-}EFGH$ មួយ ។

ក. រកវ៉ិចទ័រដែលស្មើនឹង $\overrightarrow{AB}$ , $\overrightarrow{AD}$ និង $\overrightarrow{AE}$ ។

ខ. តើវ៉ិចទ័រ $\overrightarrow{AD}$ និង $\overrightarrow{CB}$ , $\overrightarrow{AB}$ និង $\overrightarrow{FE}$ , $\overrightarrow{AE}$ និង $\overrightarrow{HD}$ ជាវ៉ិចទ័រយ៉ាងដូចម្ដេចនឹងគ្នា ?

**ចម្លើយ** ក. តាមរូបគេបាន $\overrightarrow{AB} = \overrightarrow{DC} = \overrightarrow{EF} = \overrightarrow{HG}$ , $\overrightarrow{AD} = \overrightarrow{BC} = \overrightarrow{EH} = \overrightarrow{FG}$ .

$\overrightarrow{AE} = \overrightarrow{BF} = \overrightarrow{DH} = \overrightarrow{CG}$ ។

ខ. វ៉ិចទ័រ $\overrightarrow{AD}$ និង $\overrightarrow{CB}$ ជាវ៉ិចទ័រផ្ទុយគ្នា ។

វ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{FE}$ ជាវ៉ិចទ័រផ្ទុយគ្នា ។

វ៉ិចទ័រ $\overrightarrow{AE}$ និង $\overrightarrow{HD}$ ជាវ៉ិចទ័រផ្ទុយគ្នា ។




**ប្រតិបត្តិ** គេឱ្យប្រលេពីប៉ែតទ្រេត $ABCD\text{-}EFGH$ មួយ ។

ក. រកវ៉ិចទ័រដែលស្មើនឹង $\overrightarrow{AB}$ , $\overrightarrow{AD}$ និង $\overrightarrow{AE}$ ។

ខ. តើវ៉ិចទ័រ $\overrightarrow{AD}$ និង $\overrightarrow{CB}$ , $\overrightarrow{AB}$ និង $\overrightarrow{FE}$ , $\overrightarrow{AE}$ និង $\overrightarrow{HD}$ ជាវ៉ិចទ័រយ៉ាងដូចម្ដេចនឹងគ្នា ?

## 2. ប្រមាណវិធីនៃវ៉ិចទ័រក្នុងលំហ

### 2.1 ប្រមាណវិធីបូក និងដក

#### ក. ប្រមាណវិធីបូក

***ឧទាហរណ៍*** គេមានប្រលេពីប៉ែត $ABCD\text{-}EFGH$ មួយដែលមានបាតជាប្រលេឡូក្រាម ។

**1. ករណីវ៉ិចទ័រតគ្នា**

គេមាន $\overrightarrow{DH} = \overrightarrow{BF} = \overrightarrow{AE}$

នោះ $\overrightarrow{AB} + \overrightarrow{DH} = \overrightarrow{AB} + \overrightarrow{BF} = \overrightarrow{AF}$

នោះគេថា $\overrightarrow{AF}$ **ជាផលបូករវាង** $\overrightarrow{AB}$ និង $\overrightarrow{BF}$ ។

ដូចនេះ $\boxed{\overrightarrow{AB} + \overrightarrow{BF} = \overrightarrow{AF}}$



### 2. ករណីវ៉ិចទ័រមានគល់រួម

គេមាន $\overrightarrow{AD} = \overrightarrow{BC}$ និង $\overrightarrow{AE} = \overrightarrow{CG}$

នោះ $\overrightarrow{AB} + \overrightarrow{AD} + \overrightarrow{AE} = \overrightarrow{AB} + \overrightarrow{BC} + \overrightarrow{CG} = \overrightarrow{AG}$

នោះគេថាវ៉ិចទ័រ $\overrightarrow{AG}$ ជាផលបូករវាងវ៉ិចទ័រ $\overrightarrow{AB}$ , $\overrightarrow{AD}$ និង $\overrightarrow{AE}$ ។

ដូចនេះ $\boxed{\overrightarrow{AB} + \overrightarrow{AD} + \overrightarrow{AE} = \overrightarrow{AG}}$

### ខ. ប្រមាណវិធីដក




គេមានប្រលេពីប៉ែត $ABCD\ EFGH$ មួយ ដែលមានបាតជាប្រលេឡូក្រាម ។

គេមាន $\overrightarrow{DH} = \overrightarrow{BF} = \overrightarrow{AE}$ នោះ

$\overrightarrow{AB} - \overrightarrow{DH} = \overrightarrow{AB} - \overrightarrow{AE} = \overrightarrow{EB}$

នោះគេថា វ៉ិចទ័រ $\overrightarrow{EB}$ ជាផលដករវាងវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AE}$ ។

ដូចនេះ $\boxed{\overrightarrow{EB} = \overrightarrow{AB} - \overrightarrow{AE}}$

**លំហាត់គំរូ** គេឱ្យប្រលេពីប៉ែតកែង $ABCD\ EFGH$ មួយ ។ គេតាង $\overrightarrow{AB} = \vec{a}$ , $\overrightarrow{AD} = \vec{b}$ និង $\overrightarrow{AE} = \vec{c}$ ។ ចូររកវ៉ិចទ័រ

ក. $\overrightarrow{AG}$ ជាអនុគមន៍នៃ $\vec{a}, \vec{b}$ និង $\vec{c}$

ខ. $\overrightarrow{FD}$ ជាអនុគមន៍នៃ $\vec{a}, \vec{b}$ និង $\vec{c}$




**ចម្លើយ** ក. $\overrightarrow{AG} = \overrightarrow{AB} + \overrightarrow{BC} + \overrightarrow{CG} = \vec{a} + \vec{b} + \vec{c}$ ។

ខ. $\overrightarrow{FD} = \overrightarrow{FE} + \overrightarrow{EH} + \overrightarrow{HD} = -\vec{a} + \vec{b} + (-\vec{c})$

$= -\vec{a} + \vec{b} - \vec{c}$ ។

**ប្រតិបត្តិ** គេឱ្យប្រលេពីប៉ែត $OADB\text{-}CEFG$ មួយ ។

គេតាង $\overrightarrow{OA} = \vec{a}$ , $\overrightarrow{OB} = \vec{b}$ និង $\overrightarrow{OC} = \vec{c}$ ដូចរូប ។

គណនាជាអនុគមន៍នៃ $\vec{a}, \vec{b}$ និង $\vec{c}$ ចំពោះវ៉ិចទ័រ




ក. $\overrightarrow{AG}$

ខ. $\overrightarrow{OP}$

គ. $\overrightarrow{PD}$ ។

## 2.2 ប្រមាណវិធីគុណវ៉ិចទ័រនឹងចំនួនពិត

### ក. និយមន័យ

***ឧទាហរណ៍*** ចំពោះរូបខាងក្រោមចំណុច $M$ និង $N$ ជាចំណុចកណ្ដាលនៃជ្រុង $PQ$ និង $PR$ របស់ត្រីកោណ $PQR$ រៀងគ្នា។




ដោយ $\overrightarrow{QR}$ និង $\overrightarrow{MN}$ មានទិសដៅដូចគ្នា នោះ

$QR = 2MN$ នាំឱ្យ $\overrightarrow{QR} = 2\overrightarrow{MN}$ និង

$MN = \frac{1}{2}QR$ នាំឱ្យ $\overrightarrow{MN} = \frac{1}{2}\overrightarrow{QR}$

គេបានផងដែរ

$\overrightarrow{QR} = 2\overrightarrow{MN}$ នាំឱ្យ $\overrightarrow{RQ} = -2\overrightarrow{MN}$

$\overrightarrow{MN} = \frac{1}{2}\overrightarrow{QR}$ នាំឱ្យ $\overrightarrow{MN} = -\frac{1}{2}\overrightarrow{RQ}$

តាមឧទាហរណ៍នេះ យើងទាញបាន

> វ៉ិចទ័រ $\vec{b}$ ដែល $\vec{b} = k\vec{a}$ , $k \neq 0$ ជាវ៉ិចទ័រដែលកំណត់ដោយ ៖
>
> - $\vec{b} // \vec{a}$
> - $|\vec{b}| = |k||\vec{a}|$
> - $\vec{b}$ មានទិសដៅដូច $\vec{a}$ បើ $k > 0$ ហើយ $\vec{b}$ មានទិសដៅផ្ទុយ $\vec{a}$ បើ $k < 0$ ។

### ខ. វ៉ិចទ័រស្រប

> **និយមន័យ** ពីរវ៉ិចទ័រ $\vec{a} \neq \vec{0}$ និង $\vec{b} \neq \vec{0}$ ជាវ៉ិចទ័រស្របគ្នាលុះត្រាតែ $\vec{a} = m\vec{b}$ ដែល $m$ ជាចំនួនពិត បានន័យថា $\vec{a} // \vec{b}$ សមមូល $\vec{a} = m\vec{b}$

## 2.3 វ៉ិចទ័រឯកតា

> **និយមន័យ** វ៉ិចទ័រដែលមានប្រវែងស្មើនឹង 1 ហៅថា **វ៉ិចទ័រឯកតា**។

បើ $\vec{a}$ ជាវ៉ិចទ័រមិនសូន្យ នោះគេបាន $\vec{i} = \frac{\vec{a}}{|\vec{a}|}$ ជាវ៉ិចទ័រឯកតាដែលមានទិសដៅដូច $\vec{a}$ ។

## 2.4 លក្ខណៈនៃប្រមាណវិធីបូក និងប្រមាណវិធីគុណវ៉ិចទ័រនឹងចំនួនពិតក្នុងលំហ

> បើពីរវ៉ិចទ័រ $\vec{a}$ និង $\vec{b}$ នៅក្នុងលំហ ហើយពីរចំនួនពិត $m$ និង $n$ នោះគេបាន :
>
> (1). $\vec{a}+\vec{b} = \vec{b}+\vec{a}$ (2). $(\vec{a}+\vec{b})+\vec{c} = \vec{a}+(\vec{b}+\vec{c})$
>
> (3). $(mn)\vec{a} = m(n\vec{a})$ (4). $(m+n)\vec{a} = m\vec{a}+n\vec{a}$ (5). $m(\vec{a}+\vec{b}) = m\vec{a}+m\vec{b}$
>
> បើ $m\vec{a} = 0$ នោះគេបាន $m = 0$ ឬ $\vec{a} = \vec{0}$ ។

**លំហាត់គំរូ**

1. គណនាកន្សោមខាងក្រោម ៖

ក. $3\vec{a}+4\vec{a}-2\vec{a}$ ខ. $2(\vec{a}+5\vec{b})+3(2\vec{a}-\vec{b})$

2. រក $\vec{x}$ ដែលផ្ទៀងផ្ទាត់សមីការខាងក្រោមជាអនុគមន៍នៃ $\vec{a}$ និង $\vec{b}$ ៖

ក. $2\vec{a}+\vec{x} = 3\vec{b}+2\vec{x}$ ខ. $4\vec{x}-\vec{a} = 3\vec{a}-4\vec{b}+2\vec{x}$

**ចម្លើយ**

1. ក. $3\vec{a}+4\vec{a}-2\vec{a} = (3+4-2)\vec{a} = 5\vec{a}$

ខ. $2(\vec{a}+5\vec{b})+3(2\vec{a}-\vec{b}) = 2\vec{a}+10\vec{b}+6\vec{a}-3\vec{b}$

$= (2+6)\vec{a}+(10-3)\vec{b}$

$= 8\vec{a}+7\vec{b}$

2. ក. $2\vec{a}+\vec{x} = 3\vec{b}+2\vec{x}$

$2\vec{x}-\vec{x} = 2\vec{a}-3\vec{b} \Leftrightarrow (2-1)\vec{x} = 2\vec{a}-3\vec{b}$

$\vec{x} = 2\vec{a}-3\vec{b}$

ខ. $4\vec{x}-\vec{a} = 3\vec{a}-4\vec{b}+2\vec{x}$

$4\vec{x}-2\vec{x} = 3\vec{a}+\vec{a}-4\vec{b}$ , $(4-2)\vec{x} = 4\vec{a}-4\vec{b}$

$2\vec{x} = 4(\vec{a}-\vec{b})$

$\vec{x} = 2(\vec{a}-\vec{b})$

**ប្រតិបត្តិ**

1. គណនាកន្សោមខាងក្រោម ៖

ក. $3(2\vec{a}-\vec{b})+4(\vec{a}-2\vec{b})$ ខ. $2(-\vec{a}+3\vec{b})-(5\vec{a}-4\vec{b})$

គ. $\frac{1}{3}(\vec{a}+2\vec{b})+\frac{2}{3}(\vec{a}-\vec{b})$ ឃ. $\frac{1}{2}(-\vec{a}+2b)-\frac{1}{3}(2\vec{a}+\vec{b})$

2. រក $\vec{x}$ ដែលផ្ទៀងផ្ទាត់សមីការខាងក្រោមជាអនុគមន៍នៃ $\vec{a}$ និង $\vec{b}$ ៖

ក. $3(\vec{a}+\vec{x}) = 2(\vec{x}-3\vec{b})$ ខ. $2\vec{b}-7\vec{x} = 3(4\vec{a}+\vec{b})+4(2\vec{a}+\vec{b}-3\vec{x})$

គ. $3\vec{x}-2\vec{a} = \vec{x}-4\vec{b}$ ឃ. $2(\vec{a}+\vec{x})+3(\vec{b}-\vec{x}) = \vec{0}$

# 3. កូអរដោនេក្នុងលំហ

## 3.1 តម្រុយក្នុងលំហ

**និយមន័យ** គេហៅតម្រុយក្នុងលំហ គឺគ្រប់ចតុធាតុ $(O;\vec{i},\vec{j},\vec{k})$ , $O$ ជាចំណុចមួយក្នុងលំហ នឹង $\vec{i},\vec{j},\vec{k}$ ជាបីវ៉ិចទ័រមិនស្ថិតនៅក្នុងប្លង់តែមួយ ។

ចំណុច $O$ ហៅថា គល់តម្រុយ

- វ៉ិចទ័រ $\vec{i}$ ហៅថា **វ៉ិចទ័រឯកតា** នៃអ័ក្សអាប់ស៊ីស $(x'x)$
- វ៉ិចទ័រ $\vec{j}$ ហៅថា **វ៉ិចទ័រឯកតា** នៃអ័ក្សអរដោនេ $(y'y)$
- វ៉ិចទ័រ $\vec{k}$ ហៅថា **វ៉ិចទ័រឯកតា** នៃអ័ក្សកូត $(zz')$ ,

$(x'x)$ , $(y'y)$ , $(zz')$ ហៅថាអ័ក្ស ។




## 3.2 កូអរដោនេនៃចំណុច

នៅក្នុងតម្រុយ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $P$ មួយ

គេតាងកូអរដោនេនៃ $P$ ដោយ $(x,y,z)$ ។

យកចំណុច

$P_1(x,0,0)$ នៅលើអ័ក្ស $x$

$P_2(0,y,0)$ នៅលើអ័ក្ស $y$

$P_3(0,0,z)$ នៅលើអ័ក្ស $z$

គេគូសបន្ទាត់ $PP'$ ពីចំណុច $P$ ឱ្យកែងទៅនឹងប្លង់ $(xoy)$ ដូចក្នុងរូបខាងស្តាំ នោះគេបាន




$\overrightarrow{OP} = \overrightarrow{OP_1} + \overrightarrow{P_1P'} + \overrightarrow{P'P}$ ។ តែ $\overrightarrow{P_1P'} = \overrightarrow{OP_2}$ និង $\overrightarrow{P'P} = \overrightarrow{OP_3}$

ដូចនេះ $\overrightarrow{OP} = \overrightarrow{OP_1} + \overrightarrow{OP_2} + \overrightarrow{OP_3}$ (1)

ដោយ $P_1 \in (Ox)$ , $P_2 \in (Oy)$ និង $P_3 \in (Oz)$ នោះមានចំនួនពិត $x, y$ និង $z$ ដែល $\overrightarrow{OP_1} = x\vec{i}$ , $\overrightarrow{OP_2} = y\vec{j}$ , $\overrightarrow{OP_3} = z\vec{k}$ ។

យក $\overrightarrow{OP_1} = x\vec{i}$ , $\overrightarrow{OP_2} = y\vec{j}$ , $\overrightarrow{OP_3} = z\vec{k}$ ទៅជំនួសចូលក្នុងទំនាក់ទំនង (1)

នាំឱ្យគេបានវ៉ិចទ័រ $\overrightarrow{OP} = x\vec{i} + y\vec{j} + z\vec{k}$ ។ $(x, y, z)$ ហៅថាកូអរដោនេនៃចំណុច $P$

| | |
|---|---|
| **ទ្រឹស្តីបទនិងនិយមន័យ :** | គេមានតម្រុយ $(O; \vec{i}, \vec{j}, \vec{k})$ មួយក្នុងលំហ ចំពោះគ្រប់ចំណុច $P$ មានត្រីធាតុ $(x, y, z)$ តែមួយគត់ ដែល $\overrightarrow{OP} = x\vec{i} + y\vec{j} + z\vec{k}$ ។ ត្រីធាតុ $(x, y, z)$ ហៅថាកូអរដោនេនៃចំណុច $P$ គេកំណត់សរសេរ $P(x, y, z)$ ហើយ $x$ ជា **អាប់ស៊ីស** $y$ ជា **អរដោនេ** និង $z$ ជា **កូត** ។ |

## ករណីពិសេស

វ៉ិចទ័រឯកតា $\vec{i} = (1, 0, 0)$ , $\vec{j} = (0, 1, 0)$ , $\vec{k} = (0, 0, 1)$

ម្យ៉ាងទៀត $(x, y, z) = (x', y', z')$ សមមូល $(x = x', y = y', z = z')$ ។

## សំគាល់

ក. បើ $z = 0$ គេបាន $\overrightarrow{OP} = x\vec{i} + y\vec{j}$ នាំឱ្យ $P$ ជាចំណុចមួយក្នុងប្លង់ $xoy$ ។

ច្រាសមកវិញ បើ $P$ ជាចំណុចមួយនៃប្លង់ $xoy$ នោះមានគូ $(x, y)$ នៃចំនួនពិត ដែល $\overrightarrow{OP} = x\vec{i} + y\vec{j}$ ។

ខ. បើ $x = y = 0$ គេបាន $\overrightarrow{OP} = z\vec{k}$ ។

**លំហាត់គំរូ** គេឱ្យពីរចំណុច $A(2, 1, 3)$ និង $B(3, 5, 2)$ នៅក្នុងតម្រុយ $(O, \vec{i}, \vec{j}, \vec{k})$ ។ សរសេរវ៉ិចទ័រ $\overrightarrow{OA}$ និង $\overrightarrow{OB}$ ជាអនុគមន៍នៃវ៉ិចទ័រឯកតា $\vec{i}, \vec{j}$ និង $\vec{k}$ ។

**ចម្លើយ** តាមបម្រាប់គេបាន $\overrightarrow{OA} = 2\vec{i} + \vec{j} + 3\vec{k}$ ហើយ $\overrightarrow{OB} = 3\vec{i} + 5\vec{j} + 2\vec{k}$

**ប្រតិបត្តិ** 1. គេឱ្យបីចំណុច $A(-2, 3, -1)$ , $B(4, -7, 5)$ និង $C(3, -6, 0)$ ។

សរសេរវ៉ិចទ័រ $\overrightarrow{OA}$ , $\overrightarrow{OB}$ និង $\overrightarrow{OC}$ ជាអនុគមន៍នៃវ៉ិចទ័រឯកតា $\vec{i}, \vec{j}$ និង $\vec{k}$ ។

2. សង់ចំណុច $P(2, 4, 5)$ និង $Q\left(-\frac{3}{2}, -2, \frac{5}{2}\right)$ នៅក្នុងតម្រុយ $(O,\vec{i},\vec{j},\vec{k})$ ។

3. គេឱ្យបីវ៉ិចទ័រ $\overrightarrow{OP} = -2\vec{i}+3\vec{j}-\vec{k}$ , $\overrightarrow{OM} = 4\vec{i}-7\vec{j}+5\vec{k}$ និង $\overrightarrow{OQ} = 3\vec{i}-6\vec{j}+\overrightarrow{OK}$ ។ រកកូអរដោនេនៃចំណុច $P$, $M$ និង $Q$ ។

## 3.3 លក្ខណៈកូអរដោនេ

ក. បើ $P(x, y, z)$ និង $P'(x', y', z')$ ជាពីរចំណុចនៃលំហប្រកបដោយតម្រុយ $(O, \vec{i}, \vec{j}, \vec{k})$ ។ គេបាន

- $P = P'$ សមមូល $x = x'$ និង $y = y'$ និង $z = z'$ ។
- $P \neq P'$ សមមូល $x \neq x'$ ឬ $y \neq y'$ ឬ $z \neq z'$ ។
- $\overrightarrow{P'P}$ មានកូអរដោនេ $(x-x', y-y', z-z')$ ។
- ចំណុចកណ្ដាលនៃ $\overrightarrow{PP'}$ មានកូអរដោនេ $\left(\frac{x+x'}{2}, \frac{y+y'}{2}, \frac{z+z'}{2}\right)$ ។

ខ. បើ $\vec{u} = (x, y, z)$ និង $\vec{u}' = (x', y', z')$ ជាពីរវ៉ិចទ័រក្នុងលំហប្រកបដោយគោល $(\vec{i}, \vec{j}, \vec{k})$ គេបាន

- $\vec{u} = \vec{u}'$ សមមូល $x = x'$ និង $y = y'$ និង $z = z'$ ។
- $\vec{u} \neq \vec{u}'$ សមមូល $x \neq x'$ ឬ $y \neq y'$ ឬ $z \neq z'$ ។
- វ៉ិចទ័រ $(\vec{u}+\vec{u}')$ មានកូអរដោនេ $(x+x' , y+y' , z+z')$ ។
- វ៉ិចទ័រ $(\vec{u}-\vec{u}')$ មានកូអរដោនេ $(x-x' , y-y' , z-z')$ ។
- $\forall k \in \Re$ វ៉ិចទ័រ $k\vec{u}$ មានកូអរដោនេ $(kx, ky, kz)$ ។
- $\forall (k, k') \in \Re^2$ វ៉ិចទ័រ $k\vec{u}+k'\vec{u}'$ មានកូអរដោនេ $(kx+k'x' , ky+k'y' , kz+k'z')$ ។

**លំហាត់គំរូ 1** គេឱ្យ $\vec{a} = (1, -1, 5)$ , $\vec{b} = (0, -1, 6)$ និង $\vec{c} = (3, -1, 3)$ ។

គណនាកូអរដោនេនៃវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ដែល

ក. $\vec{u} = 2\vec{a}-3\vec{b}$

ខ. $\vec{v} = 3(\vec{a}-\vec{b})-4(\vec{b}-3\vec{c})$ ។

**ចម្លើយ** ក. $\vec{u} = 2\vec{a} - 3\vec{b}$ នាំឱ្យ គេបាន $\vec{u} = (2,\ -2,\ 10) - (0,\ -3,\ 18) = (2,\ 1,\ -8)$

ដូចនេះ កូអរដោនេនៃ $\vec{u} = (2,\ 1,\ -8)$ ។

ខ. $\vec{v} = 3(\vec{a} - \vec{b}) - 4(\vec{b} - 3\vec{c})$ នាំឱ្យ គេបាន

$\vec{v} = 3\vec{a} - 3\vec{b} - 4\vec{b} + 12\vec{c} = 3\vec{a} - 7\vec{b} + 12\vec{c}$

$= (3,\ -3,\ 15) - (0,\ -7,\ 42) + (36,\ -12,\ 36) = (39,\ -8,\ 9)$

ដូចនេះ កូអរដោនេនៃ $\vec{v} = (15,\ 0,\ -15)$ ។

**លំហាត់គំរូ 2** 1. ក្នុងលំហាប្រកបដោយតម្រុយ $(O,\ \vec{i},\ \vec{j},\ \vec{k})$ គេឱ្យចំណុច $A(-1,\ 2,\ 3)$ , $B(1,\ -2,\ -1)$ , $C(0,\ -3,\ -4)$ ។

ក. គណនាកូអរដោនេនៃ $\overrightarrow{AB},\ \overrightarrow{BC},\ \overrightarrow{CA}$ ។

ខ. រកកូអរដោនេចំណុចកណ្ដាលនៃវ៉ិចទ័រទាំងបី ។

2. ត្រីកោណ $ABC$ មួយមានកំពូល $A(2,\ -1,\ 4)$ , $B(3,\ -2,\ 5)$ , $C(-1,6,2)$ ។ ចូរសរសេរជាទម្រង់ $a\vec{i} + b\vec{j} + c\vec{k}$ ចំពោះវ៉ិចទ័រ $\overrightarrow{AB},\ \overrightarrow{BC},\ \overrightarrow{CA}$ ។

**ចម្លើយ** 1. ក. $\overrightarrow{AB} = (2,\ -4,\ -4)$ , $\overrightarrow{BC} = (-1,\ -1,\ -3)$ , $\overrightarrow{CA} = (-1,\ 5,\ 7)$ ។

ខ. $(0,\ 0,\ 1)$ , $\left(\frac{1}{2},\ -\frac{5}{2},\ -\frac{5}{2}\right)$ , $\left(-\frac{1}{2},\ -\frac{1}{2},\ -\frac{1}{2}\right)$ ។

2. $\overrightarrow{AB} = \overrightarrow{OB} - \overrightarrow{OA}$

$= (3\vec{i} - 2\vec{j} + 5\vec{k}) - (2\vec{i} - \vec{j} + 4\vec{k}) = \vec{i} - \vec{j} + \vec{k}$

$\overrightarrow{BC} = \overrightarrow{OC} - \overrightarrow{OB}$

$= (-\vec{i} + 6\vec{j} + 2\vec{k}) - (3\vec{i} - 2\vec{j} + 5\vec{k}) = -4\vec{i} + 8\vec{j} - 3\vec{k}$

$\overrightarrow{CA} = \overrightarrow{OA} - \overrightarrow{OC}$

$= (2\vec{i} - \vec{j} + 4\vec{k}) - (-\vec{i} + 6\vec{j} + 2\vec{k}) = 3\vec{i} - 7\vec{j} + 2\vec{k}$




**ប្រតិបត្តិ** 1. គេឱ្យ $\vec{a} = (2,\ -3,\ 0)$ , $\vec{b} = (-3,\ 2,\ 5)$ និង $\vec{C} = (6,\ 0,\ -3)$ ។

រកកូអរដោនេនៃវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ដែល

ក. $\vec{u} = 3\vec{a} - 4\vec{b}$ ខ. $\vec{v} = 2(\vec{a} + \vec{b}) - 3(\vec{b} - 2\vec{c})$ ។

2. បើកូអរដោនេនៃវ៉ិចទ័រ $\vec{u} = (x,\ y,\ z)$ និង $\vec{v} = (x',\ y',\ z')$ ខុសពីសូន្យ ។

បង្ហាញថា $\vec{u} // \vec{v} \Leftrightarrow \frac{x}{x'} = \frac{y}{y'} = \frac{z}{z'}$ ។

## 3.4 ទិសដៅកូស៊ីនុស

គេឱ្យវ៉ិចទ័រ $\vec{u} = (x, y, z)$ មួយ និងចំណុច $P$ នៅក្នុងលំហដែល $\vec{u} = \overrightarrow{OP}$ ។

យក $\alpha, \beta$ និង $\gamma$ ជាមុំដែលកើតឡើងដោយ $OP$ ជាមួយនិងអ័ក្ស $(Ox)$ អ័ក្ស $(Oy)$ និងអ័ក្ស $(Oz)$ រៀងគ្នា ដូចរូបខាងស្តាំ ។ តាមទំនាក់ទំនងមាត្រក្នុងត្រីកោណកែង គេបាន :




$$\cos\alpha = \frac{x}{|\overrightarrow{OP}|} \ , \quad x = |\overrightarrow{OP}|\cos\alpha$$

$$\cos\beta = \frac{y}{|\overrightarrow{OP}|} \ , \quad y = |\overrightarrow{OP}|\cos\beta$$

$$\cos\gamma = \frac{z}{|\overrightarrow{OP}|} \ , \quad z = |\overrightarrow{OP}|\cos\gamma$$

គេបាន

$$|\overrightarrow{OP}|^2 = x^2 + y^2 + z^2$$

$$= |\overrightarrow{OP}|^2(\cos^2\alpha + \cos^2\beta + \cos^2\gamma) \text{ នាំឱ្យ } \cos^2\alpha + \cos^2\beta + \cos^2\gamma = \frac{|\overrightarrow{OP}|^2}{|\overrightarrow{OP}|^2} = 1$$

ដូចនេះ $\cos^2\alpha + \cos^2\beta + \cos^2\gamma = 1$ ។

តម្លៃ $\cos\alpha$ , $\cos\beta$ និង $\cos\gamma$ នេះ គឺបញ្ជាក់ពី ទិសដៅកូស៊ីនុស នៃវ៉ិចទ័រ $\vec{u} = \overrightarrow{OP}$ ។

**លំហាត់គំរូ** 1. គេឱ្យកូអរដោនេនៃចំណុច $P$ គឺ $(-2, 6, 9)$ ។

ក. រកទិសដៅកូស៊ីនុសនៃ $\overrightarrow{OP}$ ។

ខ. បង្ហាញថា $\cos^2\alpha + \cos^2\beta + \cos^2\gamma = 1$ ។

2. គេឱ្យកូអរដោនេនៃចំណុច $M$ គឺ $(2, 3, -6)$ ។

ក. រកទិសដៅកូស៊ីនុសនៃ $\overrightarrow{OM}$ ។

ខ. បង្ហាញថា $\cos^2\alpha + \cos^2\beta + \cos^2\gamma = 1$ ។

**ចម្លើយ** ក. រកទិសដៅនៃកូស៊ីនុសនៃ $\overrightarrow{OP}$

ដោយ $|\overrightarrow{OP}| = \sqrt{(-2)^2 + 6^2 + 9^2} = 11$

ដូចនេះ $x = |\overrightarrow{OP}|\cos\alpha$ , $\cos\alpha = \dfrac{x}{|\overrightarrow{OP}|} = \dfrac{-2}{11}$

$y = |\overrightarrow{OP}|\cos\beta$ , $\cos\beta = \dfrac{y}{|\overrightarrow{OP}|} = \dfrac{6}{11}$

$z = |\overrightarrow{OP}|\cos\gamma$ , $\cos\gamma = \dfrac{z}{|\overrightarrow{OP}|} = \dfrac{9}{11}$

ខ. បង្ហាញថា $\cos^2\alpha + \cos^2\beta + \cos^2\gamma = 1$

ដោយ $\cos\alpha = \dfrac{-2}{11}$ , $\cos^2\alpha = \dfrac{4}{121}$

$\cos\beta = \dfrac{6}{11}$ , $\cos^2\beta = \dfrac{36}{121}$ និង $\cos\gamma = \dfrac{9}{11} \Rightarrow \cos^2\gamma = \dfrac{81}{121}$

$$\cos^2\alpha + \cos^2\beta + \cos^2\gamma = \frac{4}{121} + \frac{36}{121} + \frac{81}{121} = \frac{121}{121} = 1$$

ដូចនេះ $\cos^2\alpha + \cos^2\beta + \cos^2\gamma = 1$ ។

2. ក. $|\overrightarrow{OP}| = \sqrt{(2)^2 + 3^2 + (-6)^2} = 7$ ដោយ $(2, 3, -6)$

ដូចនេះ $x = |\overrightarrow{OP}|\cos\alpha$ , $\cos\alpha = \dfrac{x}{|\overrightarrow{OP}|} = \dfrac{2}{7}$

$y = |\overrightarrow{OP}|\cos\beta$ , $\cos\beta = \dfrac{y}{|\overrightarrow{OP}|} = \dfrac{3}{7}$

$z = |\overrightarrow{OP}|\cos\gamma$ , $\cos\gamma = \dfrac{z}{|\overrightarrow{OP}|} = -\dfrac{6}{7}$

ខ. $\cos^2\alpha + \cos^2\beta + \cos^2\gamma = \dfrac{4}{49} + \dfrac{9}{49} + \dfrac{36}{49} = \dfrac{49}{49} = 1$

ដូចនេះ $\cos^2\alpha + \cos^2\beta + \cos^2\gamma = 1$ ។

## ប្រតិបត្តិ

1. គេឱ្យកូអរដោនេនៃចំណុច $Q$ គឺ $(3, 4, 5)$ ។

ក. រកទិសដៅនៃកូស៊ីនុសនៃ $\overrightarrow{OQ}$ ។

ខ. បង្ហាញថា $\cos^2\alpha + \cos^2\beta + \cos^2\gamma = 1$ ។

2. គេឱ្យវ៉ិចទ័រ $\vec{a} = 2\vec{i} + 3\vec{j} + 4\vec{k}$ ។ ចូររក

ក. ទិសដៅកូស៊ីនុសនៃវ៉ិចទ័រ $\vec{a}$ ។

ខ. បង្ហាញថា $\cos^2\alpha + \cos^2\beta + \cos^2\gamma = 1$ ។

# 4. ផលគុណស្កាលែនៃវ៉ិចទ័រក្នុងលំហ

## 4.1 និយមន័យ

ផលគុណស្កាលែនៃពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ក្នុងលំហ គឺជាចំនួនពិត $k$ មួយដែលកំណត់ដោយ :

• $k = \vec{u}\cdot\vec{v} = 0$ បើ $\vec{u} = \vec{0}$ ឬ $\vec{v} = \vec{0}$ ។

• $k = \vec{u}\cdot\vec{v} = |\vec{u}|\cdot|\vec{v}|\cos\theta$ បើ $\vec{u}\neq\vec{0}$ និង $\vec{v}\neq\vec{0}$

ហើយ $\theta$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។




**លំហាត់គំរូ**

1. គេឱ្យពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ដែល $|\vec{u}| = \frac{\sqrt{2}}{2}$ , $|\vec{v}| = \frac{\sqrt{2}}{2}$ និង $\theta = 90^\circ$ ដែល $\theta$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។
គណនាផលគុណស្កាលែរវាង $\vec{u}$ និង $\vec{v}$ ។

2. គេឱ្យពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ដែល $|\vec{u}| = \frac{\sqrt{3}}{2}$ , $|\vec{v}| = \sqrt{3}$ និង $\theta = 120^\circ$ ដែល $\theta$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។ គណនាផលគុណស្កាលែរវាង $\vec{u}$ និង $\vec{v}$ ។

**ចម្លើយ**

1. $\vec{u}\cdot\vec{v} = |\vec{u}|\times|\vec{v}|\cos\theta$

$$= \frac{\sqrt{2}}{2}\times\frac{\sqrt{2}}{2}\times\cos 90^\circ \quad \text{តែ} \quad \cos 90^\circ = 0$$

$$\vec{u}\cdot\vec{v} = \frac{\sqrt{2}}{2}\times\frac{\sqrt{2}}{2}\times 0 = 0$$

2. $\vec{u}\cdot\vec{v} = |\vec{u}|\times|\vec{v}|\cos\theta = \frac{\sqrt{3}}{2}\times\sqrt{3}\times\cos 120^\circ$

តែ $\cos 120^\circ = \cos(180^\circ - 60^\circ) = -\cos 60^\circ = -\frac{1}{2}$

$$\vec{u}\cdot\vec{v} = \frac{\sqrt{3}}{2}\times\sqrt{3}\times\left(-\frac{1}{2}\right) = -\frac{3}{4} \text{ ។}$$

**ប្រតិបត្តិ** គេឱ្យត្រីកោណសម័ង្ស $ABC$ ដែលមានរង្វាស់ជ្រុងស្មើ $a$ ។

គណនាជាអនុគមន៍នៃ $a$ ចំពោះផលគុណស្កាលែដូចខាងក្រោម :

ក. $\overrightarrow{AB}\cdot\overrightarrow{AC}$

ខ. $\overrightarrow{AB}\cdot\overrightarrow{BC}$

## 4.2 លក្ខណៈ

ផលគុណស្កាលែក្នុងលំហមានលក្ខណៈដូចផលគុណស្កាលែក្នុងប្លង់ដែរ ។ យើងសន្មតលក្ខណៈទាំងនេះដោយមិនបាច់ស្រាយបញ្ជាក់ ។

- ចំពោះបីចំណុច $A, B, C$ ដែល $A \neq B$ និង $A \neq C$ គេបាន
$\overrightarrow{AB}\cdot\overrightarrow{AC} = |\overrightarrow{AB}|\cdot|\overrightarrow{AC}|\cos\theta$ ដែល $\theta$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AC}$ ។

- បើ $H$ ជាចំណោលកែងនៃ $C$ លើ $AB$
គេបាន $\overrightarrow{AB}\cdot\overrightarrow{AC} = |\overrightarrow{AB}|\cdot|\overrightarrow{AH}|$ ។
$\overrightarrow{AB}\cdot\overrightarrow{AC} = |\overrightarrow{AB}|\cdot|\overrightarrow{AH}|$ បើ $\overrightarrow{AB}$ និង $\overrightarrow{AH}$ មានទិសដៅដូចគ្នា
$\overrightarrow{AB}\cdot\overrightarrow{AC} = -|\overrightarrow{AB}|\cdot|\overrightarrow{AH}|$ បើ $\overrightarrow{AB}$ និង $\overrightarrow{AH}$ មានទិសដៅផ្ទុយគ្នា




- ក. ចំពោះគ្រប់វ៉ិចទ័រ $\vec{u}$ គេបាន $\vec{u}^2 = |\vec{u}|^2$ ហៅថា
ការេស្កាលែនៃវ៉ិចទ័រ $\vec{u}$ ហើយ $|\vec{u}| = \sqrt{\vec{u}\cdot\vec{u}}$
ហៅថាណមនៃ $\vec{u}$ ។

ខ. ចំពោះគូ $(A, B)$ គេបាន $(\overrightarrow{AB})^2 = AB^2$ ហើយ $d(A, B) = AB = |\overrightarrow{AB}|$ ហៅថា ចំងាយពីចំណុច $A$ ទៅ $B$ ។

- ចំពោះគ្រប់ $\vec{u}$ , $\vec{v}$ និងចំនួនពិត $m$ មួយ គេបាន
(1). $\vec{u}\cdot\vec{v} = \vec{v}\cdot\vec{u}$
(2). $\vec{u}\perp\vec{v}$ សមមូល $\vec{u}\cdot\vec{v} = 0$ $(\vec{u}\neq 0,\ \vec{v}\neq 0)$
(3). $(m\vec{u})\cdot\vec{v} = m(\vec{u}\cdot\vec{v})$

- (1). $|\vec{u}\cdot\vec{v}| \leq |\vec{u}|\cdot|\vec{v}|$ ហៅថា វិសមភាពកូស៊ី
(2). $|\vec{u}+\vec{v}| \leq |\vec{u}|+|\vec{v}|$ ហៅថា វិសមភាពត្រីកោណ ។

**លំហាត់គំរូ 1** គេឱ្យចតុមុខ $OABC$ មួយដែល $\overrightarrow{OA}\cdot\overrightarrow{AC} = m$ និង $\overrightarrow{OA}\cdot\overrightarrow{AB} = n$ ។
គណនាផលគុណស្កាលែ $\overrightarrow{OA}\cdot\overrightarrow{CB}$ ជាអនុគមន៍នៃ $m$ និង $n$ ។




**ចម្លើយ** តាមរូប គេបាន $\overrightarrow{CB} = \overrightarrow{AB} - \overrightarrow{AC}$

$$\overrightarrow{OA}\cdot\overrightarrow{CB} = \overrightarrow{OA}(\overrightarrow{AB}-\overrightarrow{AC})$$
$$= \overrightarrow{OA}\cdot\overrightarrow{AB} - \overrightarrow{OA}\cdot\overrightarrow{AC}$$
$$= n - m \text{ ។}$$

**លំហាត់គំរូ 2** គេឱ្យការេ $MNOP$ ដែលជ្រុងមានរង្វាស់ស្មើ $a$ និងកន្លះបន្ទាត់ $MT$ ក្នុងលំហ ដែល $\angle NMT = \angle PMT = 60°$ ។

$M'$ ជាចំណុចមួយនៅលើ $MT'$ ដែល $MN' = a$ ។

ក. គណនាផលគុណស្កាលែ $\overrightarrow{MN}\cdot\overrightarrow{MM'}$ , $\overrightarrow{MP}\cdot\overrightarrow{MM'}$ និង $\overrightarrow{MO}\cdot\overrightarrow{MM'}$ ។

ខ. ទាញរក $\cos\angle OMT$ រួចរករង្វាស់មុំ $\angle OMT$ គិតជាដឺក្រេ ។

**ចម្លើយ** តាមរូប គេបាន




ក. $\overrightarrow{MN}\cdot\overrightarrow{MM'} = |\overrightarrow{MN}|\cdot|\overrightarrow{MM'}|\cos 60°$

$= a\cdot a\cdot\frac{1}{2} = \frac{1}{2}a^2$

$\overrightarrow{MP}\cdot\overrightarrow{MM'} = |\overrightarrow{MP}|\cdot|\overrightarrow{MM'}|\cos 60°$

$= a\cdot a\cdot\frac{1}{2} = \frac{1}{2}a^2$

$\overrightarrow{MO}\cdot\overrightarrow{MM'} = |\overrightarrow{MO}|\cdot|\overrightarrow{MM'}|\cos 0°$

$= a\cdot a = a^2$

ខ. ដោយ $\overrightarrow{MO}\cdot\overrightarrow{MM'} = |\overrightarrow{MO}|\cdot|\overrightarrow{MM'}|\cos\angle OMT$ , $\cos\angle OMT = \dfrac{\overrightarrow{MO}\cdot\overrightarrow{MM'}}{|\overrightarrow{MO}|\cdot|\overrightarrow{MM'}|}$

តែ $\overrightarrow{MO}\cdot\overrightarrow{MM'} = a^2$ , $\overrightarrow{MM'} = a$ និង $|\overrightarrow{MO}| = a\sqrt{2}$

នោះគេបាន $\cos\angle OMT = \dfrac{a^2}{a\sqrt{2}\cdot a} = \dfrac{1}{\sqrt{2}} = \dfrac{\sqrt{2}}{2}$

ដូចនេះ $\cos\angle OMT = \dfrac{\sqrt{2}}{2}$ ។

ដោយ $\cos\angle OMT = \dfrac{\sqrt{2}}{2}$ , $\angle OMT = 45°$ ។

**ប្រតិបត្តិ** គេឱ្យគូបមួយមានជ្រុង $a$ ដូចរូបខាងស្តាំ។ រកផលគុណស្កាលែនៃវ៉ិចទ័រខាងក្រោម :




ក. $\overrightarrow{AB}\cdot\overrightarrow{AF}$

ខ. $\overrightarrow{AF}\cdot\overrightarrow{BG}$

ឃ. $\overrightarrow{BG}\cdot\overrightarrow{DE}$

ង. $\overrightarrow{DE}\cdot\overrightarrow{FC}$

# 5. ផលគុណស្កាលែនិងការតាងកូអរដោនេ

## 5.1 គោលនិងតម្រុយអរតូណរម៉ាល់ក្នុងលំហ

### ក. គោលអរតូណរម៉ាល់

$i)$. គេឱ្យមុំកែង $xoy$ និងកន្លះបន្ទាត់ $oz$ នៅក្នុងលំហដែលគល់ $O$ អរតូកូណាល់នឹងប្លង់ $xoy$ ។ យើងតាង $I, J, K$ ជាបីចំណុចស្ថិតនៅលើកន្លះបន្ទាត់ $Ox, Oy, Oz$ រៀងគ្នា ដែល $OI = OJ = OK = 1$ ។




គេកំណត់ $\vec{i} = \overrightarrow{OI}$ , $\vec{j} = \overrightarrow{OJ}$ , $\vec{k} = \overrightarrow{OK}$

ដែល $O, I, J, K$ មិនស្ថិតនៅក្នុងប្លង់តែមួយ ។

វ៉ិចទ័រ $\vec{i}, \vec{j}, \vec{k}$ ផ្តុំបានគោលនៃលំហមួយ ។

ម្យ៉ាងទៀត វ៉ិចទ័រទាំងបីនេះ ជាវ៉ិចទ័រឯកតា ហើយអរតូកូណាល់គ្នាពីរៗ ។

| | |
|---|---|
| **និយមន័យ** | គេហៅគោលអរតូណរម៉ាល់នៃវ៉ិចទ័រ គឺគ្រប់ត្រីធាតុ $(\vec{i}, \vec{j}, \vec{k})$ ដែល $\lvert\vec{i}\rvert = \lvert\vec{j}\rvert = \lvert\vec{k}\rvert = 1$ និង $\vec{i}\cdot\vec{j} = \vec{j}\cdot\vec{k} = \vec{k}\cdot\vec{i} = 0$ |

$ii)$. **កន្សោមវិភាគនៃផលគុណស្កាលែក្នុងគោលអរតូកូណាល់**

***ឧទាហរណ៍*** ក្នុងគោលអរតូណរម៉ាល់ $\vec{i}, \vec{j}, \vec{k}$ មានវ៉ិចទ័រពីរ $\vec{u} = x\vec{i} + y\vec{i} + z\vec{k}$ និង $\vec{v} = x'\vec{i} + y'\vec{j} + z'\vec{k}$ ។ គណនាផលគុណស្កាលែរវាងវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។

**ចម្លើយ** គេបាន $\vec{u}\cdot\vec{v} = (x\vec{i} + y\vec{j} + x\vec{k})\cdot(x'\vec{i} + y'\vec{j} + z'\vec{k})$

$$= xx'\vec{i}^2 + yy'\vec{j}^2 + zz'\vec{k}^2 + (xy' + yx')\vec{i}\cdot\vec{j} + (yz' + zy')\vec{j}\cdot\vec{k} + (zx' + xz')\vec{k}\cdot\vec{l}$$

ដោយ $\vec{i}^2 = \vec{j}^2 = \vec{k}^2 = 1$ និង $\vec{i}\cdot\vec{j} = \vec{i}\cdot\vec{j} = \vec{i}\cdot\vec{j} = 0$

ដូចនេះ $\vec{u}\cdot\vec{v} = xx' + yy' + zz'$ ។

| | |
|---|---|
| **ទ្រឹស្តីបទ** | ក្នុងគោលអរតូណរម៉ាល់នៃលំហ ផលគុណស្កាលែនៃពីរវ៉ិចទ័រ $\vec{u} = (x, y, z)$ និង $\vec{v} = (x', y', z')$ គឺ $\vec{u}\cdot\vec{v} = xx' + yy' + zz'$ ។ |

14

**សំគាល់** ចំពោះគ្រប់វ៉ិចទ័រ $\vec{u} = (x,\ y,\ z)$ ក្នុងគោលអរតូណរម៉ាល់ $(\vec{i},\ \vec{j},\ \vec{k})$ គេបាន $\vec{u}\cdot\vec{i} = x$ , $\vec{u}\cdot\vec{j} = y$ , $\vec{u}\cdot\vec{k} = z$ ។

## ក្ដូវលៃ

ក. ពីរវ៉ិចទ័រ $\vec{u} = (x,\ y,\ x)$ និង $\vec{v} = (x',\ y',\ z')$ អរតូកូណាល់គ្នា លុះត្រាតែ $\vec{u}\cdot\vec{v} = 0$ បានន័យថា $\boxed{\vec{u}\perp\vec{v} \text{ សមមូល } xx' + yy' + zz' = 0}$ ។

ខ. ស្កាលែនិងណម នៃវ៉ិចទ័រ $\vec{u} = (x,\ y,\ z)$ កំណត់ដោយ

$$\boxed{\vec{u}^2 = x^2 + y^2 + z^2 \text{ និង } |\vec{u}| = \sqrt{x^2 + y^2 + z^2}}$$

គ. ផលគុណស្កាលែនៃពីរវ៉ិចទ័រមិនសូន្យ $\vec{u},\ \vec{v}$ និងមុំ $\theta$ ( គិតជារ៉ាដ្យង់ ) កំណត់ដោយ

$$\boxed{\vec{u}\cdot\vec{v} = |\vec{u}|\cdot|\vec{v}|\cos\theta \text{ នាំឱ្យ } \cos = \frac{\vec{u}\cdot\vec{v}}{|\vec{u}|\cdot|\vec{v}|} = \frac{xx' + yy' + zz'}{\sqrt{x^2 + y^2 + z^2}\ \sqrt{x'^2 + y'^2}}}$$ ។

**លំហាត់គំរូ** គណនា $|\vec{u}|,\ |\vec{v}|,\ \vec{u}\cdot\vec{v}$ , $\cos\theta$ និង $\theta$ ( ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$) នៃគូវ៉ិចទ័រខាងក្រោម ៖

ក. $\vec{u} = (3,\ -1,\ 2)$ , $\vec{v} = (1,\ -1,\ -2)$

ខ. $\vec{u} = (-4,\ 0,\ 2)$ , $\vec{v} = (2,\ 0,\ -1)$

**ចម្លើយ** ក. $|\vec{u}| = \sqrt{3^2 + (-1)^2 + 2^2} = \sqrt{14}$ , $|\vec{v}| = \sqrt{1^2 + (-1)^2 + (-2)^2} = \sqrt{6}$ ។

ខ. $|\vec{u}| = \sqrt{(-4)^2 + 0^2 + 2^2} = 2\sqrt{5}$ , $|\vec{v}| = \sqrt{2^2 + 0^2 + (-1)^2} = \sqrt{5}$ ។

ក. $\vec{u}\cdot\vec{v} = 3\cdot 1 + (-1)(-1) + (2)(-2) = 3 + 1 - 4 = 0$

ខ. $\vec{u}\cdot\vec{v} = (-4)(2) + (0)(0) + (2)(-1) = -8 - 2 = -10$ ។

ក. $\cos\theta = \dfrac{\vec{u}\cdot\vec{v}}{|\vec{u}||\vec{v}|} = \dfrac{0}{\sqrt{14}\sqrt{6}} = \dfrac{0}{\sqrt{84}} = 0 \Rightarrow \theta = \dfrac{\pi}{2}$ ។

ខ. $\cos\theta = \dfrac{\vec{u}\cdot\vec{v}}{|\vec{u}||\vec{v}|} = \dfrac{-10}{\sqrt{20}\sqrt{5}} = \dfrac{-10}{\sqrt{100}} = -1 \Rightarrow \theta = \pi$ ។

**ប្រតិបត្តិ** 1. រកផលគុណស្កាលែនៃគូវ៉ិចទ័រខាងក្រោម :

ក. $\vec{u} = (-2,\ 2,\ 3)$ , $\vec{v} = (4,\ 5,\ 6)$ ខ. $\vec{u} = 4\vec{i} + 3\vec{j} - \vec{k}$ , $\vec{v} = -2\vec{i} + \vec{j} + 3\vec{k}$

គ. $\vec{a} = (1,\ 1,\ 2)$ , $\vec{b} = (2,\ -1,\ 1)$ ឃ. $\vec{a} = (1,\ -1,\ 4)$ , $\vec{b} = (2,\ 1,\ 2)$

2. បើ $\overrightarrow{AB} = \vec{a}$ , $\overrightarrow{AC} = \vec{b}$ ជាជ្រុងនៃត្រីកោណ $ABC$ ។ បង្ហាញថា ក្រឡាផ្ទៃត្រីកោណ $S$ គឺ $S = \frac{1}{2}\sqrt{|\vec{a}|^2|\vec{b}|^2 - (\vec{a}\vec{b})^2}$ ។

## *iii*). លក្ខណៈផលគុណស្កាលែវ៉ិចទ័រក្នុងលំហ

$$(1)\ \vec{u}\cdot(\vec{v}+\vec{w}) = \vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$$
$$(2)\ (\vec{u}+\vec{v})\cdot\vec{w} = \vec{u}\cdot\vec{w}+\vec{v}\cdot\vec{w}$$
$$(3)\ \vec{u}\cdot(m\vec{v}) = m(\vec{u}\cdot\vec{v})$$
$$(4)\ (m\vec{u})\cdot\vec{v} = m(\vec{u}\cdot\vec{v})$$

## សម្រាយបញ្ជាក់

(1). $\vec{u}\cdot(\vec{v}+\vec{w}) = \vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$

សន្មតថាកូអរដោនេនៃវ៉ិចទ័រ $\vec{u}$, $\vec{v}$ និង $\vec{w}$ គឺ :

$\vec{u} = (u_1,\ u_2,\ u_3)$ , $\vec{v} = (v_1,\ v_2,\ v_3)$ , $\vec{w} = (w_1,\ w_2,\ w_3)$

នោះ $\vec{v}+\vec{w} = (v_1+w_1,\ v_2+w_2,\ v_3+w_3)$

ដូចនេះ $\vec{u}\cdot(\vec{v}+\vec{w}) = u_1(v_1+w_1)+u_2(v_2+w_2)+u_3(v_3+w_3)$

$= (u_1v_1+u_2v_2+u_3v_3)+(u_1w_1+u_2w_2+u_3w_3)$

$= \vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$

(2). $(\vec{u}+\vec{v})\cdot\vec{w} = \vec{u}\cdot\vec{w}+\vec{v}\cdot\vec{w}$

$(\vec{u}+\vec{v})\cdot\vec{w} = (u_1+v_1)w_1+(u_2+v_2)w_2+(u_3+v_3)w_3$

$= (u_1w_1+u_2w_2+u_3w_3)+(v_1w_1+v_2w_2+v_3w_3)$

$= \vec{u}\cdot\vec{w}+\vec{v}\cdot\vec{w}$

(3). $\vec{u}\cdot(m\vec{v}) = m(\vec{u}\cdot\vec{v})$

ដោយ $\vec{u} = (u_1,\ u_2,\ u_3)$ នោះ $m\vec{v} = (mv_1,\ mv_2,\ mv_3)$

គេបាន $\vec{u}(m\vec{v}) = (u_1mv_1+u_2mv_2+u_3mv_3)$

$= [m(u_1v_1)+m(u_2v_2)+m(u_3v_3)]$

$= m(u_1v_1+u_2v_2+u_3v_3)$

$= m(\vec{u}\cdot\vec{v})$

(4). ដូចគ្នាដែរ គេបាន $(m\vec{u})\cdot\vec{v} = m(\vec{u}\cdot\vec{v})$

**លំហាត់គំរូ 1** គេឱ្យ $\vec{u} = (1, -1, 2)$ និង $\vec{v} = (-1, -2, 1)$ ។

កំណត់តម្លៃនៃចំនួនពិត $l$ ដែល $\vec{u} - l\vec{v}$ និង $\vec{u}$ កែងគ្នា។

**ចម្លើយ** កំណត់តម្លៃនៃចំនួនពិត $l$

ដោយ $\vec{u} - l\vec{v} = (1+l,\ 2l-1,\ 2-l)$ ។

តែ $\vec{u} - l\vec{v}$ និង $\vec{u}$ កែងគ្នា នោះ $(\vec{u} - l\vec{v})\cdot\vec{u} = 0$

នាំឱ្យ គេបាន $(\vec{u} - l\vec{v})\cdot\vec{u} = (1)(1+l) + (-1)(2l-1) + (2)(2-l)$

$= 1 + l - 2l + 1 + 2 - 2l = -3l + 4$

តែ $(\vec{u} - l\vec{v})\cdot\vec{u} = 0$ , $-3l + 4 = 0 \Rightarrow l = \frac{4}{3}$

ដូចនេះ $l = \frac{4}{3}$ ។

**លំហាត់គំរូ 2** ក្នុងតម្រុយអរតូណរមេ គេឱ្យបីចំណុច $A(1, 4, 2)$ , $B(2, 1, 3)$ , $C(-2, 2, -1)$ ។

ចូរបង្ហាញថា $\overrightarrow{AC} \perp \overrightarrow{AB}$ ។

**ចម្លើយ** តាមបម្រាប់ គេបាន $\overrightarrow{AB} = (2-1,\ 1-4,\ 3-2) = (1, -3, 1)$

$\overrightarrow{AC} = (-2-1,\ 2-4,\ -1-2) = (-3, -2, -3)$

$\overrightarrow{AC}\cdot\overrightarrow{AB} = (-3)(1) + (-2)(-3) + (-3)(1) = -3 + 6 - 3 = 0$

ដូចនេះ $\overrightarrow{AC} \perp \overrightarrow{AB}$ ។

**ប្រតិបត្តិ**

1. គេឱ្យ $\vec{u} = (2, -1, 4)$ និង $\vec{v} = (-4, 5, 3)$ ។

   កំណត់តម្លៃនៃចំនួនពិត $k$ ដែល $\vec{u} - k\vec{v}$ និង $\vec{u}$ កែងគ្នា។

2. គេឱ្យគូប $ABCD.EFGH$ ហើយចំណុច $L$, $M$ និង $N$ ជាចំណុចកណ្តាលនៃជ្រុង $EF$, $FG$ និង $GC$ ។ ចូរកំណត់មុំ $\angle LMN = \theta$ ។

3. ក្នុងតម្រុយអរតូណរមេ គេឱ្យបីចំណុច $A(2, 1, 0)$ , $B(0, 2, 1)$ , $C(0, -1, 4)$

ក. គណនាផលគុណស្កាលែ $\overrightarrow{AB}\cdot\overrightarrow{AC}$ ។

ខ. គណនាមុំ $\theta$ ជាមុំដែលផ្គុំឡើងដោយ $\overrightarrow{AB}$ និង $\overrightarrow{AC}$ ។

## ខ. តម្រុយអរតូណរម៉ាល់

**និយមន័យ** គេហៅថាតម្រុយអរតូណរម៉ាល់ក្នុងលំហ គឺគ្រប់ចតុធាតុ $(O, \vec{i}, \vec{j}, \vec{k})$ ដែល $O$ ជាចំណុចមួយនៃលំហហៅថា **គល់** និង $(\vec{i}, \vec{j}, \vec{k})$ ហៅថា **គោលអរតូណរម៉ាល់** នៃលំហ ។

- បន្ទាត់ $(x'x)$ ដែលមានទិសដៅតាម $\vec{i}$ ហៅថា អ័ក្សអាប់ស៊ីស $(x'x)$ ។
- បន្ទាត់ $(y'y)$ ដែលមានទិសដៅតាម $\vec{j}$ ហៅថា អ័ក្សអរដោនេ $(y'y)$ ។
- បន្ទាត់ $(z'z)$ ដែលមានទិសដៅតាម $\vec{k}$ ហៅថា អ័ក្សកូត $(z'z)$ ។

ចំពោះគ្រប់ចំណុច $M(x, y, z)$ នៅក្នុងតម្រុយ $(O, \vec{i}, \vec{j}, \vec{k})$ នោះគេបានវ៉ិចទ័រ $\overrightarrow{OM} = (x, y, z)$ នៅក្នុងគោលអរតូណរម៉ាល់ $(\vec{i}, \vec{j}, \vec{k})$ ។

ដូចនេះ $\overrightarrow{OM}\cdot\vec{i} = x$ , $\overrightarrow{OM}\cdot\vec{j} = y$ , $\overrightarrow{OM}\cdot\vec{z} = z$ ។

### គ. ចម្ងាយរវាងពីរចំណុចនៅក្នុងលំហ




គេឱ្យចំណុច $P(x, y, z)$ នៅក្នុងតម្រុយអរតូណរម៉ាល់ $(O; \vec{i}, \vec{j}, \vec{k})$ ។

គូសបន្ទាត់ $PH$ ឱ្យកែងទៅនឹងប្លង់ $(xy)$ នោះកូអរដោនេនៃ $H$ គឺ $(x, y, o)$ ។

ដូចនេះ គេបាន $OH^2 = x^2 + y^2$ ។

ដោយ $\Delta POH$ ជាត្រីកោណកែងត្រង់ $H$ នោះគេបាន $OP^2 = OH^2 + PH^2 = x^2 + y^2 + z^2$ ។

ដូចនេះ $OP = \sqrt{x^2 + y^2 + z^2}$ ។

ជាទូទៅ បើឱ្យពីរចំណុច $P(x_1, y_1, z_1)$ និង $Q(x_2, y_2, z_2)$ នៅក្នុងតម្រុយអរតូណរម៉ាល់ $(O; \vec{i}, \vec{j}, \vec{k})$ ។

នោះវ៉ិចទ័រ $\overrightarrow{PQ}$ មានកូអរដោនេ $(x_2-x_1,\ y_2-y_1,\ z_2-z_1)$ ។




គេបាន

$$PQ = \left|\overrightarrow{PQ}\right| = \sqrt{(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2}$$

ដូចនេះ ចម្ងាយរវាង $P$ និង $Q$ កំណត់ដោយ

$$d(P,\ Q) = PQ = \sqrt{(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2}$$ ។

**លំហាត់គំរូ** រកចម្ងាយរវាងគូចំណុចខាងក្រោម ៖

ក. $Q(1,\ 2,\ 3)$ , $P(3,\ 4,\ 5)$ ខ. $A(-1,\ -2,\ -5)$ , $B(-3,\ -4,\ -5)$

**ចម្លើយ** ក. យក $d$ ជាចម្ងាយរវាងពីរចំណុច $Q(1,\ 2,\ 3)$ , $P(3,\ 4,\ 5)$ នោះគេបាន

$$d = (Q,\ P) = PQ = \sqrt{(3-1)^2+(4-2)^2+(5-3)^2} = \sqrt{4+4+4}$$

$$= \sqrt{12} = 2\sqrt{3}$$ ។

ខ. $$d(A,\ B) = AB = \sqrt{(-3+1)^2+(-4+2)^2+(-5+5)^2} = \sqrt{4+4+0}$$

$$= \sqrt{8} = 2\sqrt{2}$$ ។

**លំហាត់គំរូ** ក្នុងតម្រុយអរតូណរម៉ាល់ $(O;\ \vec{i},\ \vec{j},\ \vec{k})$ គេមានចំណុច $M(3,\ 1,\ 5)$ , $N(3,\ 5,\ 1)$ និង $P(-1,\ 5,\ 5)$ ។

ក. គណនា $MN$, $MP$ និង $\cos\theta$ ដែល $\theta$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\overrightarrow{MN}$ និង $\overrightarrow{MP}$ ។

ខ. តើគេអាចថាយ៉ាងណាចំពោះត្រីកោណ $MNP$ ។

**ចម្លើយ** តាមបម្រាប់ គេបាន $MN = \sqrt{(3-3)^2+(5-1)^2+(1-5)^2} = \sqrt{32}$

$$MP = \sqrt{(-1-3)^2+(5-1)^2+(5-5)^2} = \sqrt{32}$$

ដោយ $\overrightarrow{MN} = (0,\ 4,\ -4)$ និង $\overrightarrow{MP} = (-4,\ 4,\ 0)$ នោះគេបាន

$$\overrightarrow{MN}\cdot\overrightarrow{MP} = (0)(-4)+4\times4+(-4)(0) = 16$$

ដូចនេះ $$\cos\theta = \frac{\overrightarrow{MN}\cdot\overrightarrow{MP}}{\left|\overrightarrow{MN}\right|\cdot\left|\overrightarrow{MP}\right|} = \frac{16}{\sqrt{32}\times\sqrt{32}} = \frac{16}{32} = \frac{1}{2} \Rightarrow \theta = \frac{\pi}{3}$$ ។

**ប្រតិបត្តិ** 1. រកចម្ងាយរវាងគូចំណុចខាងក្រោម ៖

ក. $A(3, -2, 4)$ , $B(2, 0, 3)$ ខ. $A(0, 2, 3)$ , $B(-4, 0, 1)$

2. ចម្ងាយពីចំណុចមួយទៅបន្ទាត់មួយ ៖ ក្នុងលំហប្រកបដោយតម្រុយអរតូណរម៉ាល់ កំណត់ចម្ងាយពីចំណុច $P(-2, 1, 3)$ ទៅបន្ទាត់ $(\Delta)$ ដែលកាត់តាមចំណុច $Q(-1, 2, 1)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u} = (-2, 1, 2)$ ។

# 6. សមីការនៃស្វ៊ែ

## 6.1 និយមន័យ

| |
|---|
| សំណុំនៃចំណុចដែលមានចម្ងាយថេរ $r$ ពីចំណុចនឹង $C$ ហៅថា **ស្វ៊ែ** ដែលមានផ្ចិត $C$ និងកាំ $r$ ។ |

បើ $(a, b, c)$ ជាកូអរដោនេនៃផ្ចិត $C$ ហើយលក្ខខណ្ឌ $CP = r$ ។




យក $P(x, y, z)$ ជាចំណុចស្ថិតនៅលើផ្ទៃស្វ៊ែ ។

ដោយ $C(a, b, c)$ និង $P(x, y, z)$ នោះ

តាមរូបមន្តចម្ងាយរវាងពីរចំណុចនៅក្នុងលំហ គេបាន

$CP^2 = (x-a)^2 + (y-b)^2 + (z-c)^2$

$\Rightarrow (x-a)^2 + (y-b)^2 + (z-c)^2 = r^2$ ។

សមីការនេះហៅថា **សមីការនៃស្វ៊ែ** ។

ដូចនេះ គេបាន

| |
|---|
| សមីការនៃស្វ៊ែដែលមានផ្ចិតត្រង់ $(a, b, c)$ និងកាំ $r$ គឺ $(x-a)^2 + (y-b)^2 + (z-c)^2 = r^2$ ។ |

**លំហាត់គំរូ 1** គេឱ្យចំណុច $A(5, -2, 3)$ ជាចុងម្ខាងនៃអង្កត់ផ្ចិតស្វ៊ែនិងចំណុច $B(0, 4, -3)$ ជាចុងម្ខាងទៀតនៃអង្កត់ផ្ចិតស្វ៊ែ ។ រកសមីការនៃស្វ៊ែនេះ ។

**ចម្លើយ** តាមរូបមន្តចំណុចកណ្ដាល នោះគេបានផ្ចិតនៃស្វ៊ែគឺ ៖

$$\left(\frac{5+0}{2}, \frac{-2+4}{2}, \frac{3-3}{2}\right) = \left(\frac{5}{2}, 1, 0\right)$$

តាមរូបមន្តចម្ងាយ នោះគេបានកាំ $r$ នៃស្វ៊ែគឺ ៖

$$r = \sqrt{\left(0-\frac{5}{2}\right)^2+(4-1)^2+(-3-0)^2}$$

$$= \sqrt{\frac{97}{4}} = \frac{\sqrt{97}}{2}$$

ដូចនេះ សមីការនៃស្វ៊ែគឺ $\left(x-\frac{5}{2}\right)^2+(y-1)^2+(z-0)^2 = \frac{97}{4}$ ។

**លំហាត់គំរូ 2** 1. បង្ហាញសមីការ $x^2+y^2+z^2-6x+8z = 0$ ជាសមីការនៃស្វ៊ែ រួចរកផ្ចិតនិងកាំ $r$ ។

2. រកសមីការស្វ៊ែ រួចរកផ្ចិតនិងកាំនៃស្វ៊ែ $x^2+y^2+z^2-2x+6y+8z+1 = 0$

**ចម្លើយ** 1. ដោយសមីការ $x^2+y^2+z^2-6x+8z = 0$ អាចបំលែងជា

$$(x^2-6x+9)+y^2+(z^2+8z+16) = 9+16$$

$$(x-3)^2+y^2+(z+4)^2 = 5^2$$

នោះគេបានសមីការ $(x-3)^2+y^2+(z+4)^2 = 5^2$ ជាសមីការនៃស្វ៊ែ ដែលមានផ្ចិតត្រង់ $(3, 0, -4)$ និងមានកាំ $r = 5$ ។

2. $x^2+y^2+z^2-2x+6y+8z+1 = 0$

បំលែងសមីការនេះ គេបាន

$$(x^2-2x+1)-1+(y^2+6y+9)-9+(z^2+8z+16)-16+1 = 0$$

$$(x^2-2x+1)+(y^2+6y+9)+(z^2+8z+16) = 25$$

$$(x-1)^2+(y+3)^2+(z+4)^2 = 5^2$$

សមីការនេះជាសមីការស្វ៊ែដែលមានផ្ចិតត្រង់ $(1, -3, -4)$ និងមានកាំស្មើនឹង 5 ។

**ប្រតិបត្តិ 1** រកសមីការនៃស្វ៊ែខាងក្រោម ៖

ក. ដែលមានផ្ចិតត្រង់ $(2, 0, -3)$ និងមានកាំស្មើ 6 ។

ខ. ដែលមានផ្ចិតត្រង់ $(4, -3, 5)$ ហើយប៉ះទៅនឹងប្លង់ $(yz)$ ។

**ប្រតិបត្តិ 2** រកសមីការស្វ៊ែ រួចរកផ្ចិត និងកាំនៃស្វ៊ែ

ក. $x^2+y^2+z^2+18x-10z+91 = 0$

ខ. $x^2+y^2+z^2-4x+6y+2z = 11$

គ. $9x^2+9y^2+9z^2-6x+18y+1 = 0$

ឃ. $4x^2+4y^2+4z^2-4x-32y+8z+33 = 0$

## 6.2 វិសមីការតំបន់ផ្នែកខាងក្នុងនិងខាងក្រៅនៃស្វ៊ែ

### ក. វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែ




**និយមន័យ** វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែ គឺជាសំណុំចំណុចដែលចម្ងាយពីផ្ចិតតូចជាងកាំ ។

ដូចនេះ វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែដែលមានផ្ចិតត្រង់ $(a, b, c)$ និងមានកាំ $r$ គឺ : $\{(x,y,z)/(x-a)^2+(y-b)^2+(z-c)^2<r^2\}$ ។

### ខ. វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែ

**និយមន័យ** វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែ គឺជាសំណុំចំណុចដែលចម្ងាយពីផ្ចិតធំជាងកាំ ។

ដូចនេះ វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែ ដែលមានផ្ចិតត្រង់ $(a, b, c)$ និងមានកាំ $r$ គឺ : $\{(x,y,z)/(x-a)^2+(y-b)^2+(z-c)^2>r^2\}$ ។

**លំហាត់គំរូ** សរសេរវិសមីការតំបន់ផ្នែកខាងក្នុងនិងផ្នែកខាងក្រៅនៃស្វ៊ែ ដែលមានផ្ចិតនៅត្រង់គល់ $O(0, 0, 0)$ និងកាំស្មើ 4 ។

**ចម្លើយ** វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែ

$(x-0)^2+(y-0)^2+(z-0)^2<4^2$

$x^2+y^2+z^2<4^2$

វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែ

$(x-0)^2+(y-0)^2+(z-0)^2>4^2$

$x^2+y^2+z^2>4^2$

**ប្រតិបត្តិ** សរសេរវិសមីការតំបន់ផ្នែកខាងក្នុងនិងខាងក្រៅនៃស្វ៊ែ ដែលមានផ្ចិតនៅត្រង់ $(2, 1, -3)$ និងកាំស្មើ 1 និងស្វ៊ែដែលមានផ្ចិតត្រង់ $(2, 1, -3)$ និងកាំស្មើ 4 ។

## លំហាត់

1. គេឱ្យ $\vec{u} = (4, -2, 5)$ និង $\vec{v} = (7, 9, -8)$ ។

   រកវ៉ិចទ័រ $\vec{x}$ ដែលផ្ទៀងផ្ទាត់ទំនាក់ទំនងខាងក្រោម ៖

   ក. $2\vec{u} + \vec{x} = 3\vec{v}$ ខ. $4\vec{x} - \vec{u} = 3\vec{u} - 4\vec{v} + 2\vec{x}$

2. គេឱ្យ $\vec{u} = (1, 1, 0)$ , $\vec{v} = (1, 0, 1)$ , $\vec{w} = (0, 1, 1)$ និង $\vec{p} = (5, 6, 7)$ ។

   បង្ហាញ $\vec{p}$ ជាទម្រង់ $\vec{p} = l\vec{u} + m\vec{v} + n\vec{w}$ ។

3. រកទិសដៅកូស៊ីនុសនៃវ៉ិចទ័រខាងក្រោម ៖

   ក. $\vec{u} = (3, -4, 5)$ ខ. $\vec{v} = (-3, 2, 2\sqrt{3})$ ។

4. គេឱ្យវ៉ិចទ័រ $\vec{u} = (2, -1, 5)$ , $\vec{v} = (3x, 5, 4y-2)$ និង $\vec{w} = (z-1, 2, z+1)$

   ក. រកតម្លៃ $x$ និង $y$ ដែល $\vec{u} // \vec{v}$ ។

   ខ. រកតម្លៃ $z$ ដែល $\vec{u} \perp \vec{w}$ ។

5. រកតម្លៃ $x$, $y$ និង $z$ ដែលវ៉ិចទ័រ $\vec{u} = (x, 4, 6)$ , $\vec{v} = (2, y, 6)$ និង $\vec{w} = (2, 4, z)$ កែងគ្នា ។

6. គេឱ្យ $\vec{u} = (1, 2, -3)$ និង $\vec{v} = (2, -1, -2)$ និង $\vec{w} = (1, -1, 1)$ ។

   បើវ៉ិចទ័រ $\vec{x} = (x_1, x_2, x_3)$ ប្រសព្វទៅនឹងវ៉ិចទ័រ $\vec{u}$ , $\vec{v}$ និង $\vec{w}$ ហើយដែល $\vec{u}$ , $\vec{v}$ និង $\vec{w}$ អរតូកូណាល់គ្នា ។ រក $x_1 : x_2 : x_3$ ដែល $\vec{x} \neq \vec{0}$ ។

7. គេឱ្យ $\vec{u} = (2, -2, 1)$ និង $\vec{v} = (2, 3, -4)$

   តាង $\vec{v} - k\vec{u} = \vec{w}$ ដែល $k$ ជាចំនួនពិត ។

   បើ $\vec{w}$ និង $\vec{u}$ កែងគ្នា ។ កំណត់តម្លៃ $k$ និង $\vec{w}$ ។

8. គេឱ្យចំណុច $A(0, 3, 0)$ , $B(0, 1, -2)$ និង $C(2, 3, -2)$ ។

   ក. តើ $\Delta ABC$ ជាប្រភេទត្រីកោណអ្វី ?

   ខ. រកសមីការនៃស្វ៊ែដែលកាត់តាមចំណុច $A$, $B$, $C$ និងចំណុចគល់ ។

9. រកសមីការនៃស្វ៊ែខាងក្រោម :

   ក. ស្វ៊ែដែលមានអង្កត់ផ្ចិតដែលភ្ជាប់ពីរចំណុច $(-2, 1, 5)$ និង $4, -3, -1$ ។

   ខ. ស្វ៊ែដែលកាត់តាមចំណុច $(-5, 1, 4)$ ហើយប៉ះទៅនឹងប្លង់កូអរដោនេទាំងបី ។

10. តើសំណុំចំណុចនៃ $P$ ជាប្លង់អ្វី ? ហើយរកសមីការនៃប្លង់នោះ បើ

ក. ចំណុច $P$ ជាចំណុចដែលផលធៀបរបស់វាមានចម្ងាយពីចំណុច $A(-1, 0, 0)$ និង $B(2, 0, 0)$ គឺ $2 : 1$ ។

ខ. ចំណុច $P$ ដែលផលបូកការេនៃចម្ងាយរបស់វាពីចំណុចពីរ $A(1, 2, 0)$ និង $B(-1, 4, 2)$ គឺ 38 ។

11. $(\vec{i}, \vec{j}, \vec{k})$ ជាគោលអរតូណរម៉ាល់មួយ ។ ចូរគណនា $\vec{u}\cdot\vec{v}$ , $\vec{v}\cdot\vec{w}$ , $\vec{w}\cdot\vec{u}$ ក្នុងករណីនីមួយៗខាងក្រោម :

ក. $\vec{u} = (1+\sqrt{2})\vec{i} + \sqrt{3}\vec{i}$ , $\vec{v} = (1-\sqrt{2})\vec{i} - \vec{k}$ , $\vec{w} = \sqrt{3}\vec{j} + \vec{k}$ ។

ខ. $\vec{u} = \frac{2}{3}\vec{i} - \frac{1}{6}\vec{j} + \frac{1}{2}\vec{k}$ , $\vec{v} = \frac{1}{2}\vec{i} - 2\vec{j} + \frac{2}{5}\vec{k}$ , $\vec{w} = \vec{i} + \vec{k}$ ។

12. $SABCD$ ជាពីរ៉ាមីតដែលមានបាតជាការេ មានកំពូល $S$ និងទ្រនុងមានរង្វាស់ $a$ ស្មើគ្នាទាំងអស់ ។ គណនាផលគុណស្កាលែខាងក្រោមនេះជាអនុគមន៍នៃ $a$ ។

ក. $\overrightarrow{SA}\cdot\overrightarrow{SB}$

ខ. $\overrightarrow{SA}\cdot\overrightarrow{SC}$

គ. $\overrightarrow{SA}\cdot\overrightarrow{AC}$




13. គេឱ្យរង្វង់ $(C)$ អង្កត់ផ្ចិត $AB$ នៅក្នុងប្លង់ $\alpha$ ត្រង់ $A$ ។
បង្ហាញថា ចំពោះគ្រប់ $M \in (C)$ គេបាន $\overrightarrow{CM}\cdot\overrightarrow{MB} = 0$ ។



មេរៀនទី 2

# សមីការបន្ទាត់ និងសមីការប្លង់ក្នុងលំហ

## 1. វ៉ិចទ័រទីតាំង

**វត្ថុបំណង**

- កំណត់វ៉ិចទ័រទីតាំងក្នុងលំហ
- កំណត់សមីការនៃប្លង់
- កំណត់សមីការនៃស្វ៊ែរ
- កំណត់សមីការនៃបន្ទាត់ក្នុងលំហ
- គណនាចម្ងាយរវាងចំណុចនិងប្លង់ក្នុងលំហ ។

### 1.1 និយមន័យ

គេមានវ៉ិចទ័រ $\overrightarrow{OP} = \vec{p}$ មួយនៅក្នុងលំហ ។ គេកំណត់ $P$ ជាចំណុចចល័ត ហើយ $O$ ជាចំណុចនឹង ។




គេថាវ៉ិចទ័រ $\vec{p}$ ជា វ៉ិចទ័រទីតាំង នៃចំណុច $P$ ដែលចំណុច $O$ ជាចំណុចគល់ ។
គេកំណត់វ៉ិចទ័រទីតាំងនៃចំណុច $P$ គឺ $\vec{p}$ ហើយគេសរសេរ $P(\vec{p})$ ។

### 1.2 វ៉ិចទ័រទីតាំងនៃចំណុចចែកក្នុងនិងចែកក្រៅអង្កត់

គេឱ្យពីរចំណុច $A(\vec{a})$ និង $B(\vec{b})$ ក្នុងលំហនិងវ៉ិចទ័រទីតាំង $\vec{c}$ នៃចំណុច $C$ ហើយ $C$ ចែកអង្កត់ $[AB]$ ខាងក្នុងតាមផលធៀប $m : n$ និងវ៉ិចទ័រទីតាំង $\vec{d}$ នៃចំណុច $D$ ហើយ $D$ ចែកអង្កត់ $[AB]$ ខាងក្រៅតាមផលធៀប $m : n$ ។

តាមផលធៀបទាំងពីរ គេបានរូបមន្តខាងក្រោម :

វ៉ិចទ័រទីតាំង $\vec{c}$ នៃចំណុច $C$ ដែលចែកអង្កត់ $[AB]$ ខាងក្នុងតាមផលធៀប $m : n$ គឺ $\vec{c} = \dfrac{m\vec{b} + n\vec{a}}{m+n}$

វ៉ិចទ័រទីតាំង $\vec{d}$ នៃចំណុច $D$ ដែលចែកអង្កត់ $[AB]$ ខាងក្រៅតាមផលធៀប $m : n$ គឺ $\vec{d} = \dfrac{m\vec{b} - n\vec{a}}{m-n}$

## សម្រាយបញ្ជាក់

- ស្រាយថា វ៉ិចទ័រទីតាំង $\vec{c} = \dfrac{m\vec{b}+n\vec{a}}{m+n}$ បើគេតាង $\overrightarrow{AC}$ និង $\overrightarrow{AB}$ ជាវ៉ិចទ័រ




ទីតាំង នោះ $\overrightarrow{AC} = \vec{c}-\vec{a}$ , $\overrightarrow{AB} = \vec{b}-\vec{a}$

តាមរូបមន្ត គេបាន $\overrightarrow{AC} = \dfrac{m}{m+n}\overrightarrow{AB}$

ដូចនេះ គេបាន : $\vec{c}-\vec{a} = \dfrac{m}{m+n}(\vec{b}-\vec{a})$

$\vec{c} = \dfrac{m}{m+n}(\vec{b}-\vec{a})+\vec{a}$

$\vec{c} = \dfrac{m\vec{b}-m\vec{a}+m\vec{a}+n\vec{a}}{m+n}$ នាំឱ្យ គេបាន

$\vec{c} = \dfrac{m\vec{b}+n\vec{a}}{m+n}$

- ស្រាយថាវ៉ិចទ័រទីតាំង $\vec{d} = \dfrac{m\vec{b}-n\vec{a}}{m-n}$

បើគេតាង $\overrightarrow{AD}$ និង $\overrightarrow{AB}$ ជាវ៉ិចទ័រទីតាំង នោះ $\overrightarrow{AD} = \vec{d}-\vec{a}$ , $\overrightarrow{AB} = \vec{b}-\vec{a}$

តាមរូបគេបាន : $\overrightarrow{AD} = \dfrac{m}{m-n}\overrightarrow{AB}$

ដូចនេះ $\vec{d}-\vec{a} = \dfrac{m}{m-n}(\vec{b}-\vec{a})$ , $\vec{d} = \dfrac{m}{m-n}(\vec{b}-\vec{a})+\vec{a}$

$\vec{d} = \dfrac{m\vec{b}-m\vec{a}+m\vec{a}-n\vec{a}}{m-n} = \dfrac{m\vec{b}-n\vec{a}}{m-n}$




**លំហាត់គំរូ** មានបីចំណុច $A(\vec{a})$ , $B(\vec{b})$ និង $C(\vec{c})$ ជាចំណុចនៅត្រង់កំពូលត្រីកោណ $ABC$ ។ រកវ៉ិចទ័រទីតាំង $\vec{g}$ នៃចំណុច $G$ ដែល $G$ ជាទីប្រជុំទម្ងន់របស់ $\Delta ABC$ ។

**ចម្លើយ** តាង $D(\vec{d})$ ជាចំណុចកណ្ដាលនៃ $[BC]$ នោះ គេបានវ៉ិចទ័រទីតាំង $\vec{d} = \dfrac{\vec{b}+\vec{c}}{2}$

ដោយ $G$ ជាទីប្រជុំទម្ងន់ នោះ $G$ ចែកអង្កត់ $[AD]$ ខាងក្នុងតាមផលធៀប $2:1$ នោះគេបានវ៉ិចទ័រទីតាំង $\vec{g}$ នៃចំណុច $G$ គឺ




$$\vec{g} = \frac{\vec{a}+2\vec{d}}{3} = \frac{\vec{a}+2\times\dfrac{\vec{b}+\vec{c}}{2}}{3} = \frac{\vec{a}+\vec{b}+\vec{c}}{3}$$

ដូចនេះ វ៉ិចទ័រទីតាំងនៃទីប្រជុំទម្ងន់ $G$ គឺ $\vec{g} = \dfrac{\vec{a}+\vec{b}+\vec{c}}{3}$ ។

PROEUS DARA

**ប្រតិបត្តិ** មានបួនចំណុច $A(\vec{a})$ , $B(\vec{b})$ , $C(\vec{c})$ និង $D(\vec{d})$ ជាចំណុចកំពូលរបស់ចតុមុខនិយ័ត $ABCD$ ។ ចំណុច $G$ ជាទីប្រជុំទម្ងន់នៃត្រីកោណ $BCD$ ។ រកវ៉ិចទ័រទីតាំង $\vec{p}$ នៃចំណុច $P$ ដែល $P$ ចែក $[AG]$ ខាងក្នុងតាមផលធៀប $3 : 1$ ។

## 1.3 វ៉ិចទ័រទីតាំងនិងការតាងកូអរដោនេ




គេឱ្យកូអរដោនេអាប់ស៊ីស ដែលមាន $O$ ជាចំណុចគល់នៃវ៉ិចទ័រទីតាំង ។

បើ $\vec{p}$ ជាវ៉ិចទ័រទីតាំងនៃចំណុច $P(x, y, z)$ នោះតាមរូប គេបានវ៉ិចទ័រ $\vec{p}$ គឺ :

$\vec{p} = x\vec{i} + y\vec{j} + z\vec{k}$ ។

ដូចនេះ កូអរដោនេនៃវ៉ិចទ័រទីតាំង $\vec{p}$ គឺ $(x, y, z)$ ដែលគេកំណត់សរសេរ $\vec{p} = (x, y, z)$ ដែលមាន$O$ ជាចំណុចគល់ ។

កូអរដោនេនៃវ៉ិចទ័រទីតាំង $\vec{p} = (x, y, z)$ ក៏ជាកូអរដោនេនៃចំណុច $P$ ដែរ ។

**លំហាត់គំរូ** រកកូអរដោនេនៃទីប្រជុំទម្ងន់ $G$ របស់ត្រីកោណ $ABC$ ដែលកំពូលរបស់ត្រីកោណនេះមានកូអរដោនេគឺ $A(-1, 2, 3)$ , $B(1, -2, -1)$ និង $C(0, -3, -4)$ ។

**ចម្លើយ** តាង $\vec{a}, \vec{b}$ និង $\vec{c}$ ជាវ៉ិចទ័រទីតាំងនៃចំណុច $A, B$ និង $C$ រៀងគ្នា។ នោះគេបាន $\vec{a} = (-1, 2, 3)$ , $\vec{b} = (1, -2, -1)$ និង $\vec{c} = (0, -3, -4)$ ។

តាង $\vec{g} = (x, y, z)$ ជាវ៉ិចទ័រទីតាំងនៃចំណុច $G$ ដែល $G$ ជាទីប្រជុំទម្ងន់របស់ត្រីកោណ $ABC$ ។ ដូចនេះ គេបានវ៉ិចទ័រទីតាំង $\vec{g}$ នៃទីប្រជុំទម្ងន់ត្រីកោណដែលមានកំពូល $A, B$ និង $C$ គឺ

$$\vec{g} = \frac{\vec{a}+\vec{b}+\vec{c}}{3} = \frac{(-1, 2, 3)+(1, -2, -1)+(0, -3, -4)}{3}$$

$$= \frac{(0, -3, -2)}{3} = \left(0, -1, -\frac{2}{3}\right)$$

ដូចនេះ កូអរដោនេនៃ $G$ គឺ $\left(0, -1, -\frac{2}{3}\right)$ ។

**ប្រតិបត្តិ** រកកូអរដោនេនៃទីប្រជុំទម្ងន់ $G$ របស់ត្រីកោណដែលកំពូលរបស់ត្រីកោណ គឺ

ក. $A(6, -2, 3)$ , $B(-1, 6, 3)$ និង $C(1, 5, -3)$ ។

ខ. $P(2, 3, 6)$ , $Q(1, 2, -3)$ និង $R(4, 2, -5)$ ។

## 1.4 អនុវត្តន៍វ៉ិចទ័រទីតាំងលើរូបធរណីមាត្រ

**ឧទាហរណ៍** គេឱ្យបួនចំណុច $O, A, B$ និង $C$ នៅក្នុងលំហ ។

បង្ហាញថា បើ $[OB]\perp[CA]$ និង $[OC]\perp[AB]$ នោះ $[OA]\perp[BC]$ ។

**ចម្លើយ** យក $O$ ជាគល់ ហើយ $\vec{a}, \vec{b}$ និង $\vec{c}$ ជាវ៉ិចទ័រទីតាំងនៃបីចំណុច $A, B$ និង $C$ ។

ដោយ $[OB]\perp[CA]$ នោះ $\vec{b}\cdot(\vec{a}-\vec{c}) = 0$ ។

ដូចនេះ $\vec{b}\cdot\vec{a} = \vec{b}\cdot\vec{c}$ (1)

ដោយ $[OC]\perp[AB]$ នោះ $\vec{c}\cdot(\vec{b}-\vec{a}) = 0$ ។

ដូចនេះ $\vec{c}\cdot\vec{b} = \vec{c}\cdot\vec{a}$ (2)

តាម (1) និង (2) គេបាន $\vec{b}\cdot\vec{a} = \vec{c}\cdot\vec{a}$ ។

នាំឱ្យ $(\vec{b}-\vec{c})\cdot\vec{a} = 0$ ។

ដូចនេះ $[OA]\perp[BC]$ ។




**លំហាត់គំរូ** គេឱ្យចតុមុខនិយ័ត $ABCD$ មួយក្នុងលំហ ។

គេតាង $\overrightarrow{AB} = \vec{b}$ , $\overrightarrow{AC} = \vec{c}$ , $\overrightarrow{AD} = \vec{d}$ ។ បង្ហាញថា $[AB]\perp[CD]$ ។

**ចម្លើយ** តាមរូបគេបាន $\overrightarrow{AB}\cdot\overrightarrow{CD} = \vec{b}\cdot(\vec{d}-\vec{c}) = \vec{b}\cdot\vec{d}-\vec{b}\cdot\vec{c}$

ដោយ $|\vec{b}| = |\vec{c}| = |\vec{d}|$ ហើយមុំផ្គុំឡើងដោយ $\vec{b}$ និង $\vec{c}$ ស្មើ $60°$ និងមុំផ្គុំឡើងដោយ $\vec{b}$ និង $\vec{d}$ ស្មើ $60°$

នោះគេបាន $\vec{b}\cdot\vec{c} = \vec{b}\cdot\vec{d} \Rightarrow \overrightarrow{AB}\cdot\overrightarrow{CD} = 0$ នោះ

ដូចនេះ $\overrightarrow{AB}\perp\overrightarrow{CD}$

នាំឱ្យ $[OA]\perp[BC]$ ។



**ប្រតិបត្តិ** បង្ហាញថា បើបួនចំណុច $A, B, C$ និង $D$ នៅក្នុងលំហ ដែលផ្ទៀងផ្ទាត់ $AB^2+CD^2 = AC^2+BD^2$ នោះ $[AD]\perp[BC]$ ។




## 2. សមីការបន្ទាត់ក្នុងលំហ

គេឱ្យបន្ទាត់ $L$ មួយដែលកំណត់ដោយ $P_0(x_0, y_0, z_0)$ និងវ៉ិចទ័រប្រាប់ទិស $\vec{u} = (a, b, c)$ ដែល $(\vec{u} \neq \vec{0})$ ។

តាង $P$ ជាចំណុចផ្លាស់ទីលើ $L$ ដែល $\overrightarrow{P_oP} \,//\, \vec{u}$ ។

ដូចនេះមានចំនួនពិត $t$ មួយដែល $\overrightarrow{P_0P} = t\vec{u}$ , $(t\in\Re)$ ។

តាង $(x, y, z)$ ជាកូអរដោនេនៃចំណុច $P$ នោះគេបានកូអរដោនេនៃ $\overrightarrow{P_0P}$ គឺ $(x-x_0 \ , y-y_0 \ , z-z_0)$ ហើយកូអរដោនេនៃ $t\vec{u}$ គឺ $(ta, tb, tc)$ ។

ដូចនេះ $\overrightarrow{P_0P} = t\vec{u}$ នាំឱ្យ $\boxed{\begin{cases} x-x_0 = at \\ y-y_0 = bt \\ z-z_0 = ct \end{cases}}$ (1)

ចំពោះ $a\neq 0$ , $b\neq 0$ , $c\neq 0$ ហើយដោយបំបាត់ $t$ ពី (1) គេបាន

$\dfrac{x-x_0}{a} = \dfrac{y-y_0}{b} = \dfrac{z-z_2}{c}$ ។

ដូចនេះ

| |
|---|
| សមីការបន្ទាត់ $L$ កាត់តាមចំណុច $P_0(x_0, y_0, z_0)$ ស្របទៅនឹងវ៉ិចទ័រប្រាប់ទិស $\vec{u} = (a, b, c)$ គឺ $\dfrac{x-x_0}{a} = \dfrac{y-y_0}{b} = \dfrac{z-z_0}{c}$ ។ |

ទំនាក់ទំនង (1) ហៅថាសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $L$ ដែលមាន $t$ ជាប៉ារ៉ាម៉ែត្រ និង $\vec{u} = (a, b, c)$ ហៅថា **វ៉ិចទ័រប្រាប់ទិស** នៃបន្ទាត់ $L$ ។

**លំហាត់គំរូ**

1. រកសមីការនៃបន្ទាត់ $L$ ដែលកាត់តាមចំណុច $(-2, 3, 4)$ និងមានវ៉ិចទ័រប្រាប់ទិសដូចខាងក្រោម ៖

   ក. $(-3, 2, 4)$ ខ. $(1, 4, 5)$ ។

2. រកសមីការនៃបន្ទាត់ $L$ ដែលកាត់តាមចំណុច $(-2, 3, 5)$ ហើយស្របទៅនឹងបន្ទាត់ $x-1 = \dfrac{y-4}{2} = \dfrac{3-z}{5}$ ។

**ចម្លើយ**

1. តាមរូបមន្ត សមីការបន្ទាត់ $L$ កាត់តាមចំណុច $P_0(x_0, y_0, z_0)$ ស្របទៅនឹងវ៉ិចទ័រប្រាប់ទិស $\vec{u} = (a, b, c)$ គឺ $\frac{x-x_0}{a} = \frac{y-y_0}{b} = \frac{z-z_0}{c}$ នោះគេបាន

   ក. សមីការ $L$ កាត់តាមចំណុច $(-2, 3, 4)$ មានវ៉ិចទ័រប្រាប់ទិស $(-3, 2, 4)$ គឺ $\frac{x+2}{-3} = \frac{y-3}{2} = \frac{z-4}{4}$ ឬ $\frac{-x-2}{3} = \frac{y-3}{2} = \frac{z-4}{4}$

   ខ. សមីការបន្ទាត់ $L$ កាត់តាមចំណុច $(-2, 3, 4)$ មានវ៉ិចទ័រប្រាប់ទិស $(1, 4, 5)$ គឺ $\frac{x+2}{1} = \frac{y-3}{4} = \frac{z-4}{5}$ ឬ $x+1 = \frac{y-3}{4} = \frac{z-4}{5}$

2. ដោយសមីការបន្ទាត់ $L$ ស្របនឹងបន្ទាត់ $x-1 = \frac{y-4}{2} = \frac{3-z}{5}$ នោះ $L$ ក៏ស្របទៅនឹងវ៉ិចទ័រប្រាប់ទិសបន្ទាត់នេះដែរ ។
   ដូចនេះ វ៉ិចទ័រប្រាប់ទិសរបស់ $x-1 = \frac{y-4}{2} = \frac{3-z}{5}$ គឺ $(1, 2, 5)$ ។

ដូចនេះ សមីការបន្ទាត់ $L$ គឺ $\frac{x+2}{1} = \frac{y-3}{2} = \frac{z-5}{5}$ ឬ $x+2 = \frac{y-3}{2} = \frac{z-5}{5}$ ។

**ប្រតិបត្តិ**

1. រកសមីការនៃបន្ទាត់ $d$ ដែលកាត់តាមចំណុច $(3, 4, -2)$ និងមានវ៉ិចទ័រប្រាប់ទិសដូចខាងក្រោម ៖

   ក. $(-2, 1, 3)$ ខ. $(5, 1, 4)$ គ. $(3, 4, 0)$ ឃ. $(2, 0, 0)$

2. រកសមីការនៃបន្ទាត់ $L$ ដែលកាត់តាមចំណុច $(5, -2, 3)$ ហើយស្របទៅនឹងបន្ទាត់ $x-2 = \frac{y-5}{3} = \frac{4-z}{6}$ ។

3. ក. គេឱ្យចំណុច $A(-1, 3, 2)$ និង $B(2, 1, -2)$ ។
   - រកសមីការនៃបន្ទាត់ $(AB)$
   - គណនាកូអរដោនេនៃចំណុចប្រសព្វរវាងបន្ទាត់ $(AB)$ និងប្លង់ $(O, \vec{i}, \vec{j})$ , $(O, \vec{k}, \vec{i})$ និង $(O, \vec{i}, \vec{k})$ ។

   ខ. បន្ទាត់ $L$ មួយមានសមីការ $\frac{x-1}{-3} = \frac{y-2}{2} = z+1$ ។
   - កំណត់ចំណុចមួយនៃ $L$ និងវ៉ិចទ័រប្រាប់ទិសរបស់វា
   - តើចំណុចខាងក្រោមនេះស្ថិតនៅលើបន្ទាត់ $L$ ឬទេ ?

   $M\left(-4, \frac{16}{3}, \frac{2}{3}\right)$ , $M_1\left(\frac{11}{2}, \frac{6}{5}, -\frac{8}{5}\right)$ , $M_2\left(-\frac{3}{2}, \frac{11}{3}, -\frac{1}{6}\right)$ ។

5

# 3. សមីការបន្ទាត់កាត់តាមពីរចំណុច

គេមានពីរចំណុច $P_0(x_0,\ y_0,\ z_0)$ និង $P_1(x_1,\ y_1,\ z_1)$ នៅក្នុងលំហ ។

តាមពីរចំណុចនេះ គេបានកូអរដោនេនៃ $\overrightarrow{P_0P_1}$ គឺ $(x_1-x_0,\ y_1-y_0,\ z_1-z_0)$ ។

ពេលដែល $x_1 \neq x_0$ , $y_1 \neq y_0$ , $z_1 \neq z_0$ នោះគេបានសមីការបន្ទាត់កាត់តាមពីរចំណុច $P_0(x_0,\ y_0,\ z_0)$ និង $P_1(x_1,\ y_1,\ z_1)$ គឺ $\dfrac{x-x_0}{x_1-x_0} = \dfrac{y-y_0}{y_1-y_0} = \dfrac{z-z_0}{z_1-z_0}$ ។

ដូចនេះ

| សមីការបន្ទាត់កាត់តាមពីរចំណុច $P_0(x_0,\ y_0,\ z_0)$ និង $P_1(x_1,\ y_1,\ z_1)$ គឺ $\dfrac{x-x_0}{x_1-x_0} = \dfrac{y-y_0}{y_1-y_0} = \dfrac{z-z_0}{z_1-z_0}$ |
|---|

**លំហាត់គំរូ 1** រកសមីការនៃបន្ទាត់ដែលកាត់តាមគូចំណុចខាងក្រោម ៖

ក. $(1,\ -2,\ -3)$ , $(-4,\ 5,\ -6)$

ខ. $(3,\ 0,\ -2)$ , $(-4,\ -7,\ -5)$

គ. $(-3,\ -4,\ 2)$ , $(-5,\ -3,\ 4)$

ឃ. $(2,\ -5,\ -3)$ , $(4,\ 0,\ -1)$

**ចម្លើយ** តាមរូបមន្ត សមីការបន្ទាត់កាត់តាមពីរចំណុច $P_0(x_0,\ y_0,\ z_0)$ និង $P_1(x_1,\ y_1,\ z_1)$ គឺ $\dfrac{x-x_0}{x_1-x_0} = \dfrac{y-y_0}{y_1-y_0} = \dfrac{z-z_0}{z_1-z_0}$ នោះគេបាន

ក. $\dfrac{x-1}{-4-1} = \dfrac{y+2}{5+2} = \dfrac{z+3}{-6+3}$ ឬ $\dfrac{1-x}{5} = \dfrac{y+2}{7} = \dfrac{-z-3}{3}$

ខ. $\dfrac{x-3}{-4-3} = \dfrac{y-0}{-7-0} = \dfrac{z+2}{-5+2}$ ឬ $\dfrac{3-x}{7} = \dfrac{-y}{7} = \dfrac{-z-2}{3}$

គ. $\dfrac{x+3}{-5+3} = \dfrac{y+4}{-3+4} = \dfrac{z-2}{4-2}$ ឬ $\dfrac{-x-3}{2} = \dfrac{y+4}{1} = \dfrac{z-2}{2}$

ឃ. $\dfrac{x-2}{4-2} = \dfrac{y+5}{5} = \dfrac{z+3}{-1+3}$ ឬ $\dfrac{x-2}{2} = \dfrac{y+5}{5} = \dfrac{z+3}{2}$

**លំហាត់គំរូ 2** គេមានបន្ទាត់ $L : \dfrac{x}{3} = y+6 = \dfrac{z-2}{2}$ ។ រកកូអរដោនេនៃចំណុច $Q$ នៅលើ $L$ ដែលមានចម្ងាយពី $[PQ]$ ទៅចំណុច $P(3,\ -1,\ 2)$ មានតម្លៃអប្បបរមា ។

**ចម្លើយ** យក $(x,\ y,\ z)$ ជាកូអរដោនេនៃចំណុច $Q$ នោះគេបាន :

$$PQ^2 = (x-3)^2 + (y+1)^2 + (z-2)^2 \qquad (1)$$

ដោយចំណុច $Q$ នៅលើ $L$ នោះ

$$\begin{cases} x = 3t \\ y = t-6 \\ z = 2t+2 \end{cases} \quad (2)$$




ជំនួស (2) ទៅក្នុង (1) គេបាន

$$PQ^2 = (3t-3)^2 + (t-5)^2 + 4t$$

$$= 14t^2 - 28t + 34 = 14(t-1)^2 + 20$$

ដូចនេះ $PQ^2$ អប្បបរមា ចំពោះ $t = 1$ ។

ដូចនេះ កូអរដោនេនៃចំណុច $Q$ ពេលដែល $PQ$ អប្បបរមាគឺ $(3, -5, 4)$ ។

**ប្រតិបត្តិ** 1. រកសមីការនៃបន្ទាត់ $L$ ដែល :

ក. កាត់តាម $A(-1, 2, 3)$ និង $B(4, -5, 6)$

ខ. កាត់តាម $A(-3, 0, 2)$ និង $B(4, 7, 5)$

គ. កាត់តាម $A(3, 4, -2)$ និង $B(5, 3, -2)$

ឃ. កាត់តាម $A(-2, 5, 5)$ និង $B(-2, 0, 3)$

2. រកសមីការបន្ទាត់ $L$ ដែល

ក. កាត់តាម $A(1, 2, -1)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u} = (-2, 3, 2)$ ។

ខ. កាត់តាមចំណុច $A(-2, 1, 3)$ និង $B(-1, 2, 1)$ ។

3. គេមានបន្ទាត់ $L : \dfrac{x-1}{-3} = \dfrac{y-2}{2} = z+1$ ។ រកកូអរដោនេនៃចំណុច $P$ នៅលើ $L$ ដែលចម្ងាយពី $PQ$ ទៅចំណុច $Q(-1, 3, 2)$ មានតម្លៃអប្បបរមា ។

# 4. សមីការប្លង់ក្នុងតម្រុយអរតូណរម៉ាល់

## 4.1 វ៉ិចទ័រណរម៉ាល់នៃប្លង់

- វ៉ិចទ័រណរម៉ាល់នៃប្លង់ $(\alpha)$ គឺគ្រប់វ៉ិចទ័រ $\vec{n}$ មិនសូន្យ ហើយមានទិសអរតូកូណាល់នឹងប្លង់ $(\alpha)$ ។

- គេមានចំណុច $P$ មួយ និងវ៉ិចទ័រ $\vec{n}$ មិនសូន្យមួយ ។

សំណុំចំណុច $Q$ នៃលំហដែលផ្ទៀងផ្ទាត់ $\overrightarrow{PQ} \cdot \vec{n} = 0$ គឺជាប្លង់ដែលកាត់តាមចំណុច $P$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{n}$ ។






**ឧទាហរណ៍** គេមានអង្កត់ $[MN]$ មួយ និង $I$ ជាចំណុចកណ្ដាលនៃ $[MN]$ ។ សំណុំចំណុច $P$ ដែលស្ថិតនៅស្មើចម្ងាយពីចំណុច $M$ និង $N$ ជាប្លង់មេដ្យាទ័រនៃ $[MN]$ ហើយជាប្លង់ដែលកាត់តាម $I$ និងមានវ៉ិចទ័រណរម៉ាល់ $\overrightarrow{MN}$

## 4.2 សមីការប្លង់កំណត់ដោយចំណុចមួយនិងវ៉ិចទ័រណរម៉ាល់មួយ

**ឧទាហរណ៍** គេឱ្យចំណុច $P(1, 4, 2)$ និង $\vec{n} = (3, 2, 4)$ ។ $Q(x, y, z)$ ជាចំណុចមួយនៃប្លង់ $(\alpha)$ ។

ក. ចូររកកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{PQ}$ ។

ខ. ដោយប្រើទំនាក់ទំនង $\overrightarrow{PQ} \cdot \vec{n} = 0$ បង្ហាញថា $Q \in (\alpha)$ លុះត្រាតែ $3x + 2y + 4z - 19 = 0$ ។

គ. ករណីទូទៅនៃប្លង់ $(\alpha)$ កំណត់ដោយ $P_0(x_0, y_0, z_0)$ និងវ៉ិចទ័រណរម៉ាល់ $\vec{n} = (a, b, c)$ ដែល $(a, b, c) \neq (0,0,0)$ ។ បង្ហាញថាចំណុច $Q(x, y, z) \in (\alpha)$ លុះត្រាតែ $ax + by + cz + d = 0$ ដែល $d$ ជាចំនួនត្រូវកំណត់ ។

**ចម្លើយ** ក. $\overrightarrow{PQ}$ មានកូអរដោនេ $(x-1, y-4, z-2)$ ។

ខ. $Q \in (\alpha) \Leftrightarrow \overrightarrow{PQ} \cdot \vec{n} = 0$ ឬ $Q \in (\alpha) \Leftrightarrow [3(x-1) + 2(y-4) + 4(z-2)] = 0$

$Q \in (\alpha) \Leftrightarrow 3x - 3 + 2y - 8 + 4z - 8 = 0$ ឬ $3x + 2y + 4z - 19 = 0$ ។

ទំនាក់ទំនងនេះ ហៅថាសមីការនៃប្លង់ $(\alpha)$ ។

គ. $Q \in (\alpha) \Leftrightarrow \overrightarrow{PQ} \cdot \vec{n} = 0$

តែ $\overrightarrow{PQ} = (x - x_0, y - y_o, z - z_0)$ និង $\vec{n} = (a, b, c)$

ដូចនេះ $Q \in (\alpha) \Leftrightarrow (x - x_0)a + (y - y_0)b + (z - z_0)c = 0$ ។

$Q \in (\alpha) \Leftrightarrow ax + by + cz - (ax_0 + by_0 + cz_0) = 0$ ។

តាង $d = (ax_0 + by_0 + cz_0)$ នោះគេបានសមីការនៃប្លង់ $(\alpha)$ គឺ $ax + by + cz + d = 0$ ។

**សន្និដ្ឋាន** គេមានតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j}, \vec{k})$ មួយ ។

- សមីការប្លង់ដែលកំណត់ដោយចំណុច $P(x_0, y_0, z_0)$ និងវ៉ិចទ័រណរម៉ាល់ $\vec{n} = (a, b, c)$ មានរាង $ax + by + cz + d = 0$
- សំណុំចំណុច $Q(x, y, z)$ ផ្ទៀងផ្ទាត់សមីការ $ax + by + cz + d = 0$ ( ដែល $a, b, c, d$ ជាចំនួនពិត ហើយ $a, b, c$ មិនសូន្យព្រមគ្នា ) គឺជាប្លង់ដែលមានវ៉ិចទ័រណរម៉ាល់ $\vec{n} = (a, b, c)$ ។

## ករណីពិសេស




បើ $z = 0$ ជាសមីការប្លង់ $(O, \vec{i}, \vec{j})$

បើ $x = 0$ ជាសមីការប្លង់ $(O, \vec{j}, \vec{k})$

បើ $y = 0$ ជាសមីការប្លង់ $(O, \vec{i}, \vec{k})$

**លំហាត់គំរូ 1** ក្នុងតម្រុយអរតូណរម៉ាល់ គេឱ្យចំណុច $P(2, -1, 4)$ និងវ៉ិចទ័រ $\vec{u} = (1, -2, 3)$ ។

រកសមីការនៃប្លង់ $(\alpha)$ ដែលកាត់តាម $P$ និងវ៉ិចទ័រណរម៉ាល់ $\vec{u}$ ។

## ចម្លើយ

***របៀបទី 1:*** សមីការនៃប្លង់ $(\alpha)$ មានរាង $ax + by + cz + d = 0$ ដែល $(a, b, c)$ ជាកូអរដោនេនៃវ៉ិចទ័រ $\vec{u}$ ។ ដោយកូអរដោនេនៃ $\vec{u}$ គឺ $(1, -2, 3)$ នោះគេបាន

$a = 1$ , $b = -2$ , $c = 3$ នាំឱ្យ $x - 2y + 3z + d = 0$ ។

ដោយ $P \in (\alpha)$ គេបាន $2 - (2)(-1) + 3(4) + d = 0$ , $d = -16$ ។

ដូចនេះ សមីការនៃប្លង់ $(\alpha)$ គឺ $x - 2y + 3z - 16 = 0$ ។

***របៀបទី 2 :*** $(\alpha)$ ជាសំណុំចំណុច $Q(x, y, z)$ ដែល $\overrightarrow{PQ} \cdot \vec{u} = 0$ ។

ដោយ $\overrightarrow{PQ}$ មានកូអរដោនេ $(x - 2, y + 1, z - 4)$ នោះគេបាន

$\overrightarrow{PQ} \cdot \vec{u} = (x - 2)1 + (y + 1)(-2) + (z - 4)3 = x - 2y + 3z - 16$

ដូចនេះ $\overrightarrow{PQ} \cdot \vec{u} = 0$ សមមូល $x - 2y + 3z - 16 = 0$ ជាសមីការនៃប្លង់ $(\alpha)$ ។

**លំហាត់គំរូ2** 1. ក្នុងលំហប្រកបដោយតម្រុយអរតូណរម៉ាល់ គេឱ្យចំណុច $A(6,\ 4,\ 2)$ និងវ៉ិចទ័រ $\vec{n} = (1,\ 2,\ -3)$ ។ ចូរកំណត់សមីការនៃប្លង់ $(\alpha)$ ដែលកាត់តាម $A$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{n}$ ។

2. ក្នុងលំហប្រកបដោយតម្រុយអរតូណរម៉ាល់ គេឱ្យពីរចំណុច $A(4,\ 3,\ 2)$ និង $B(2,\ -4,\ 6)$ ។ កំណត់សមីការនៃប្លង់ $(\alpha)$ ដែលកាត់តាមចំណុច $A$ ហើយអរតូកូណាល់ទៅនឹងវ៉ិចទ័រ $\overrightarrow{AB}$ ។

**ចម្លើយ** 1. តាមបម្រាប់ គេបាន $(x-6)+2(y-4)-3(z-2) = 0$

$$x-6+2y-8-3z+6 = 0$$

$$x+2y-3z-8 = 0$$

ដូចនេះ សមីការប្លង់ $(\alpha)$ គឺ $x+2y-3z-8 = 0$

2. តាមបម្រាប់ គេបាន $a(x-4)+b(y-3)+c(z-2) = 0$ (1)

តែវ៉ិចទ័រណរម៉ាល់ $\overrightarrow{AB} = (2-1,\ -4-3,\ 6-2) = (1,\ -7,\ 4)$ នោះគេបាន

$a = 1$ , $b = -7$ , $c = 4$ , (1) អាចសរសេរជា

$(x-4)-7(y-3)+4(z-2) = 0$

$x-4-7y+21+4z-8 = 0$

$x-7y+4z+13 = 0$

ដូចនេះ សមីការប្លង់ $(\alpha)$ គឺ $x-7y+4z+13 = 0$ ។

**ប្រតិបត្តិ** 1. ក្នុងលំហប្រកបដោយតម្រុយអរតូណរម៉ាល់ គេឱ្យចំណុច $A(2,\ 4,\ 5)$ និងវ៉ិចទ័រ $\vec{a} = (3,\ -1,\ -2)$ ។ កំណត់សមីការប្លង់ $(\alpha)$ ដែលកាត់តាម $A$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{a}$ ។

2. ក្នុងលំហប្រកបដោយតម្រុយអរតូណរម៉ាល់ គេឱ្យពីរចំណុច $A(3,\ 2,\ 5)$ និង $B(4,\ -2,\ 1)$ ។ កំណត់សមីការប្លង់ $(\alpha)$ ដែលកាត់តាមចំណុច $A$ ហើយអរតូកូណាល់ទៅនឹងវ៉ិចទ័រ $\overrightarrow{AB}$ ។

3. ក្នុងលំហប្រកបដោយតម្រុយអរតូណរម៉ាល់ គេឱ្យបីចំណុច $A(2,\ 4,\ 5)$ , $B(-5,\ -2,\ 3)$ និង $C(3,\ -1,\ -2)$ ។ កំណត់សមីការប្លង់ $(\alpha)$ ដែលកាត់តាមចំណុច $C$ ហើយអរតូកូណាល់ទៅនឹងវ៉ិចទ័រ $\overrightarrow{AB}$ ។

4. កំណត់សមីការប្លង់ $(\alpha)$ ដែលកាត់តាមបីចំណុច $A(4,\ 0,\ 0)$ , $B(2,\ 0,\ 3)$ និង $C(0,\ -1,\ 4)$ ។

## 4.3 ចម្ងាយពីចំណុចមួយទៅប្លង់មួយ




***ឧទាហរណ៍*** ក្នុងលំហប្រកបដោយតម្រុយ អរតូណរម៉ាល់ $(O, \vec{i}, \vec{j}, \vec{k})$ គេឱ្យប្លង់ $(\alpha)$ ដែលមាន សមីការ $ax+by+cz+d = 0$ និងចំណុច $P_0(x_0, y_0, z_0)$ មិននៅក្នុងប្លង់ $(\alpha)$ ។

តាង $H$ ជាចំណោលកែងនៃ $P_0$ លើប្លង់ $(\alpha)$ ។ ប្រវែង $P_0H$ ហៅថាចម្ងាយពីចំណុច $P_0$ ទៅប្លង់ $(\alpha)$ ។ រកចម្ងាយ $d(P_0, \alpha)$ ពីចំណុច $P_0$ ទៅប្លង់ $(\alpha)$ ។

បើ $\vec{u} = (a, b, c)$ ជាវ៉ិចទ័រណរម៉ាល់នឹង $(\alpha)$ និងចំណុច $P_1$ កំណត់ដោយ $\overrightarrow{P_0P_1} = \vec{u}$

$P_0P_1 = |\vec{u}| = \sqrt{a^2+b^2+c^2}$ ។

តាង $(x_H, y_H, z_H)$ ជាកូអរដោនេនៃ $H$ នោះគេបាន $\overrightarrow{P_0H}$ មានកូអរដោនេ $(x_H-x_0, y_H-y_0, z_H-z_0)$ នោះ

$$\overrightarrow{P_0P_1}\cdot\overrightarrow{P_0H} = \vec{u}\cdot\overrightarrow{P_0H} = a(x_H-x_0)+b(y_H-y_0)+c(z_H-z_0)$$

$$= (ax_H+by_H+cz_H)-(ax_0+by_0+cz_0)$$

ដោយ $H\in(\alpha)$ គេបាន $(ax_H+by_H+cz_H) = 0$ និង $ax_0+by_0+cz_0 = -d$

$$(\overrightarrow{P_0P_1}\cdot\overrightarrow{P_0H}) = -(ax_0+by_0+cz_0) \qquad (1)$$

យក $\theta$ ជាមុំផ្គុំឡើងដោយ $\overrightarrow{P_0P_1}$ និង $\overrightarrow{P_0H}$ នោះគេបាន

$$\overrightarrow{P_0P_1}\cdot\overrightarrow{P_0H} = |\overrightarrow{P_0P_1}||\overrightarrow{P_oH}|\cos\theta \qquad (2)$$

តាម (1) និង (2) គេទាញបាន $P_0H = |\overrightarrow{P_0H}| = \dfrac{-(ax_0+by_0+cz_0+d)}{|P_0P_1|\cdot\cos\theta}$

ដោយ $P_0H$ ជាចម្ងាយ នោះ $P_0H>0$ នាំឱ្យ $\dfrac{-(ax_0+by_0+cz_0+d)}{|\overrightarrow{P_0P_1}|\cdot\cos\theta}$ ជាចំនួនវិជ្ជមាន ។

គេបាន $P_0H = |\overrightarrow{P_0H}| = \dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}\cdot|\cos\theta|}$

ដោយ $P_0, P_1, H$ រត់ត្រង់គ្នា នាំឱ្យមុំ $\theta = 180°$ នោះ $|\cos 180°| = 1$

ដូចនេះ $d = (P_0, \alpha) = P_0H = \dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$ ។

**ជាទូទៅ** ក្នុងលំហប្រកបដោយតម្រុយអរតូណរម៉ាល់ ចម្ងាយពីចំណុច $P_0(x_0,\ y_0,\ z_0)$ ទៅប្លង់ $(\alpha): ax+by+cz+d=0$ កំណត់ដោយ $d(P_0,\ \alpha)=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$ ។

**លំហាត់គំរូ 1** រក

ក. ចម្ងាយពីចំណុច $A(-4,\ -1,\ 3)$ ទៅនឹងប្លង់ $(\alpha): x-2y+3z-16=0$ ។

ខ. ចម្ងាយពីចំណុច $O(0,\ 0,\ 0)$ ទៅនឹងប្លង់ $(\alpha): ax+by+cz+d=0$ ។

**ចម្លើយ** តាមរូបមន្តចម្ងាយ គេបាន

$$d(A,\ \alpha)=\frac{|(-4)(1)+(-1)(-2)+(3)(3)-16|}{\sqrt{(-1)^2+(-2)^2+3^2}}=\frac{9}{\sqrt{14}}\approx 2.41$$

ខ. $d(0,\ \alpha)=\dfrac{|d|}{\sqrt{a^2+b^2+c^2}}$

**លំហាត់គំរូ 2** បង្ហាញថាសមីការនៃបន្ទាត់ $L$ ដែលជាប្រសព្វរវាងប្លង់ :

$$\begin{cases}2x-y+z=3 & (1)\\ x+2y-4z=4 & (2)\end{cases}$$

មានទម្រង់ $\dfrac{x-p}{a}=\dfrac{y-q}{b}=\dfrac{z}{c}$ ។

**ចម្លើយ** ដំបូងត្រូវគណនា $z$ ជាអនុគមន៍នៃ $x$ និង $y$ ដោយតាម (1) និង (2) ។

យើងគុណសមីការ (1) និង 2 រួចបូកនឹងសមីការ (2) គេបាន

$$+\begin{cases}2x-y+z=3 & (1)\times 2\\ x+2y-4z=4 & (2)\end{cases}$$
$$\overline{\quad 5x-2z=10\quad}$$

$$z=\frac{5x-10}{2} \qquad (3)$$

យើងគុណសមីការ (2) នឹង 2 រួចយកសមីការ (1) ដក គេបាន

$$-\begin{cases}2x-y+z=3 & (1)\\ x+2y-4z=4 & (2)\times 2\end{cases}$$
$$\overline{\quad -5y+9z=-5\quad}$$

$$z=\frac{5y-5}{9} \qquad (4)$$

តាម (3) និង (4)

គេបាន $\frac{5x-10}{2} = \frac{5y-5}{9} = z$ (5)

ចែកសមីការ (5) និង 5 នាំឱ្យ គេបាន $\frac{x-2}{2} = \frac{y-1}{9} = \frac{z}{5}$ ។

**លំហាត់គំរូ 3** ក្នុងលំហប្រកបដោយតម្រុយអរតូណរម៉ាល់ គេឱ្យចំណុច $A(-3, 1, 2)$ និងប្លង់ $(\alpha)$ ដែលមានសមីការ $2x - y + z - 2 = 0$ ។

ក. កំណត់កូអរដោនេនៃវ៉ិចទ័រណរម៉ាល់ $\vec{u}$ មួយទៅនឹងប្លង់ $(\alpha)$ ។ គណនា $|\vec{u}|$ ។

ខ. គណនា $d(A, \alpha)$ ។

**ចម្លើយ** ក. ដោយរាងទូទៅនៃសមីការប្លង់គឺ $(\alpha) : ax + by + cz + d = 0$ ដែល $a, b, c$ ជាកូអរដោនេនៃវ៉ិចទ័រណរម៉ាល់ $\vec{u}$ នៃប្លង់ $(\alpha)$ ។

តែសមីការប្លង់ $(\alpha)$ ដែលឱ្យគឺ $2x - y + z - 2 = 0$ ។

គេទាញបាន $a = 2$ , $b = -1$ , $c = 1$ , $d = -2$ ។

ដូចនេះ កូអរដោនេនៃ $\vec{u}$ ណរម៉ាល់នឹង $(\alpha)$ គឺ $\vec{u} = (2, -1, 1)$ ។

នោះគេបាន $|\vec{u}| = \sqrt{2^2 + (-1)^2 + 1^2} = \sqrt{6}$ ។

ខ. ចម្ងាយពី $A$ ទៅ $(\alpha)$ គឺ $d(A, \alpha) = \frac{|2(-3) + (-1)1 + 1(2) - 2|}{\sqrt{6}} = \frac{7}{\sqrt{6}} = \frac{7\sqrt{6}}{6}$ ។

**ប្រតិបត្តិ** 1. ចូររក

ក. ចម្ងាយពីចំណុច $A(3, 1, 4)$ ទៅនឹងប្លង់ $(\alpha) : x - 2y + 2z + 3 = 0$ ។

ខ. ចម្ងាយពីចំណុច $O(0, 0, 0)$ ទៅនឹងប្លង់ $(\alpha) : 3x + 2y - 4z + 5 = 0$ ។

គ. ចម្ងាយពីចំណុច $M(2, 1, 1)$ ទៅនឹងប្លង់ $(\alpha) : 2x - y + 4z - 16 = 0$ ដែលមានវ៉ិចទ័រណរម៉ាល់ $(2, -1, 4)$ ។

2. បង្ហាញថា សមីការនៃបន្ទាត់ $L$ ដែលជាប្រសព្វរវាងប្លង់

$$\begin{cases} x + y + z - 2 = 0 & (1) \\ 2x - y + z + 1 = 0 & (2) \end{cases}$$

មានទម្រង់ $\frac{x-p}{a} = \frac{y-q}{b} = \frac{z}{c}$ ។

# មេរៀនសង្ខេប

- ពីរវ៉ិចទ័រ $\vec{a}\neq\vec{0}$ និង $\vec{b}\neq\vec{0}$ ជាវ៉ិចទ័រស្របគ្នាលុះត្រាតែ $\vec{a}=m\vec{b}$ ដែល $m$ ជាចំនួនពិត បានន័យថា $\vec{a}\,/\!/\,\vec{b}$ សមមូល $\vec{a}=m\vec{b}$ ។
- ចំពោះពីរវ៉ិចទ័រ $\vec{a}$ និង $\vec{b}$ នៅក្នុងលំហ ហើយពីរចំនួនពិត $m$ និង $n$ គេបាន :

  (1). $\vec{a}+\vec{b}=\vec{b}+\vec{a}$ (2). $(\vec{a}+\vec{b})+\vec{c}=\vec{a}+(\vec{b}+\vec{c})$

  (3). $(mn)\vec{a}=m(n\vec{a})$ (4). $(m+n)\vec{a}=m\vec{a}+n\vec{b}$

  (5). $m(\vec{a}+\vec{b})=m\vec{a}+n\vec{b}$

  បើ $m\vec{a}=0$ នោះគេបាន $m=0$ ឬ $\vec{a}=\vec{0}$ ។
- ក. បើ $P(x,\ y,\ z)$ និង $P'(x',\ y',\ z')$ ជាពីរចំណុចនៃលំហប្រកបដោយតម្រុយ $(O,\ \vec{i},\ \vec{j},\ \vec{k})$ គេបាន
  - $P=P'$ សមមូល $x=x'$ និង $y=y'$ និង $z=z'$ ។
  - $P\neq P'$ សមមូល $x\neq x'$ ឬ $y\neq y'$ ឬ $z\neq z'$ ។
  - $\overrightarrow{P'P}$ មានកូអរដោនេ $(x-x',\ y-y',\ z-z')$ ។
  - ចំណុចកណ្តាលនៃ $PP'$ មានកូអរដោនេ $\left(\frac{x+x'}{2},\ \frac{y+y'}{2},\ \frac{z+z'}{2}\right)$ ។

ខ. បើ $\vec{u}=(x,\ y,\ z)$ និង $\vec{u}'=(x',\ y',\ z')$ ជាពីរវ៉ិចទ័រក្នុងលំហប្រកបដោយគោល $(\vec{i},\ \vec{j},\ \vec{k})$ គេបាន
  - $\vec{u}=\vec{u}'\Leftrightarrow x=x'\ ,\ y=y'\ ,\ z=z'$ ។
  - $\vec{u}\neq\vec{u}'\Leftrightarrow x\neq x'\ ,\ y\neq y'\ ,\ z\neq z'$ ។
  - វ៉ិចទ័រ $(\vec{u}+\vec{u}')$ មានកូអរដោនេ $(x+x',\ y+y',\ z+z')$ ។
  - វ៉ិចទ័រ $(\vec{u}-\vec{u}')$ មានកូអរដោនេ $(x-x',\ y-y',\ z-z')$ ។
  - $\forall k\in\Re$ វ៉ិចទ័រ $k\vec{u}$ មានកូអរដោនេ $(kx,\ ky,\ kz)$ ។
  - $\forall(k,\ k')\in\Re^2$ និងវ៉ិចទ័រ $k\vec{u}+k'\vec{u}'$ មានកូអរដោនេ $(kx+k'x',\ \ ky+k'y',\ kz+k'z')$ ។

- ផលគុណស្កាលែនៃពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ក្នុងលំហ គឺជាចំនួនពិត $k$ មួយ កំណត់ដោយ :
  - $k=\vec{u}\cdot\vec{v}=0$ បើ $\vec{u}=\vec{0}$ ឬ $\vec{v}=\vec{0}$ ។
  - $k=\vec{u}\cdot\vec{v}=|\vec{u}|\cdot|\vec{v}|\cos\theta$ បើ $\vec{u}\neq\vec{0}$ និង $\vec{v}\neq\vec{0}$

$\theta$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។

- ក្នុងគោលអរតូណរមាល់នៃលំហ ផលគុណស្កាលែនៃពីរវ៉ិចទ័រ $\vec{u} = (x,\ y,\ z)$ និង $\vec{v} = (x',\ y',\ z')$ គឺ $\vec{u}\cdot\vec{v} = xx' + yy' + zz'$ ។

ក. ពីរវ៉ិចទ័រ $\vec{u} = (x,\ y,\ z)$ និង $\vec{v} = (x',\ y',\ z')$ អរតូកូណាល់គ្នា លុះត្រាតែ $\vec{u}\cdot\vec{v} = 0$ បានន័យថា $\vec{u}\perp\vec{v}$ សមមូល $xx' + yy' + zz' = 0$ ។

ខ. **ការេស្កាលែ** និង **ណម** នៃវ៉ិចទ័រ $\vec{u} = (x,\ y,\ z)$ កំណត់ដោយ

$\vec{u}^2 = x^2 + y^2 + z^2$ និង $|\vec{u}| = \sqrt{x^2 + y^2 + z^2}$ ។

គ. ផលគុណស្កាលែនៃពីរវ៉ិចទ័រមិនសូន្យ $\vec{u},\ \vec{v}$ និងមុំ $\theta$ ( គិតជារ៉ាដ្យង់ ) កំណត់ដោយ

$\vec{u}\cdot\vec{v} = |\vec{u}|\cdot|\vec{v}|\cos\theta$ នាំឱ្យ $\cos\theta = \dfrac{\vec{u}\cdot\vec{v}}{|\vec{u}|\cdot|\vec{v}|} = \dfrac{xx' + yy' + zz'}{\sqrt{x^2+y^2+z^2}\ \sqrt{x'^2+y'^2+z'^2}}$ ។

- ចម្ងាយរវាង $P$ និង $Q$ កំណត់ដោយ

$d(P,\ Q) = PQ = \sqrt{(x_2-x_1)^2 + (y_2-y_1)^2 + (z_2-z_1)^2}$ ។

- សមីការនៃស្វ៊ែរដែលមានផ្ចិតត្រង់ $(a,\ b,\ c)$ និងកាំ $r$ គឺ

$(x-a)^2 + (y-b)^2 + (z-c)^2 = r^2$ ។

- វ៉ិចទ័រទីតាំង $\vec{c}$ នៃចំណុច $C$ ដែលចែកអង្កត់ $[AB]$ ខាងក្នុងតាមផលធៀប $m : n$ គឺ

$\vec{c} = \dfrac{m\vec{b} + n\vec{a}}{m+n}$ ។

- វ៉ិចទ័រទីតាំង $\vec{c}$ នៃចំណុច $D$ ដែលចែកអង្កត់ $[AB]$ ខាងក្រៅតាមផលធៀប $m : n$ គឺ

$\vec{d} = \dfrac{m\vec{b} - n\vec{a}}{m-n}$ ។

- សមីការបន្ទាត់ $(L)$ កាត់តាមចំណុច $P_0(x_0,\ y_0,\ z_0)$ ស្របទៅនឹងវ៉ិចទ័រប្រាប់ទិស $\vec{u} = (a,\ b,\ c)$ គឺ $\dfrac{x-x_0}{a} = \dfrac{y-y_0}{b} = \dfrac{z-z_0}{c}$ ។

- សមីការបន្ទាត់កាត់តាមពីរចំណុច $P_0(x_0,\ y_0,\ z_0)$ និង $P_1(x_1,\ y_1,\ z_1)$ គឺ

$\dfrac{x-x_0}{x_1-x_0} = \dfrac{y-y_0}{y_1-y_0} = \dfrac{z-z_0}{z_1-z_0}$ ។

- សមីការប្លង់ដែលកំណត់ដោយចំណុច $P_0(x_0,\ y_0,\ z_0)$ និងវ៉ិចទ័រណរម៉ាល់ $\vec{n} = (a,\ b,\ c)$ មានរាង $ax + by + cz + d = 0$

- សំណុំចំណុច $Q(x,\ y,\ z)$ ផ្ទៀងផ្ទាត់សមីការ $ax + by + cz + d = 0$ ( ដែល $a,\ b,\ c,\ d$ ជាចំនួនពិត ហើយ $a,\ b,\ c$ មិនសូន្យព្រមគ្នា ) គឺជាប្លង់ដែលមានវ៉ិចទ័រណរម៉ាល់ $\vec{n} = (a,\ b,\ c)$ ។

- ក្នុងលំហប្រកបដោយតម្រុយអរតូណរម៉ាល់ ចម្ងាយពីចំណុច $P_0(x_0,\ y_0,\ z_0)$ ទៅប្លង់ $(\alpha) : ax + by + cz = 0$ មានរាង $d(P_0,\ \alpha) = \dfrac{|ax_0 + by_0 + cz_0 + d|}{\sqrt{a^2+b^2+c^2}}$ ។

## លំហាត់

1. គេឱ្យតេត្រាអែតនិយ័ត $ABCD$ ដែលមានជ្រុងស្មើ $a$ ។ យក $M$ ជាចំណុចកណ្ដាលនៃជ្រុង $[CD]$ ។ បង្ហាញថា
   ក. រកផលគុណស្កាលែ $\overrightarrow{AM}\cdot\overrightarrow{CD}$ និង $\overrightarrow{BM}\cdot\overrightarrow{CD}$
   ខ. បង្ហាញថា $[AB]\perp[CD]$ ។
2. ក. រកសមីការនៃបន្ទាត់កាត់តាមចំណុច $(2,\ -3,\ 7)$ ដែលមានវ៉ិចទ័រទិសដៅ $(1,\ 1,\ -4)$ ។
   ខ. រកវ៉ិចទ័រទិសដៅនៃបន្ទាត់ $2x-6=4-y=z-5$ ។
   គ. រកមុំរវាង ក. និង ខ. ។
3. យក $(L)$ ជាបន្ទាត់ $\dfrac{x-1}{2}=\dfrac{2-y}{3}=z+2$ និង $(\alpha)$ ជាប្លង់ $3x-y-2z=12$ ។
   ក. រកកូអរដោនេនៃ $P$ ជាចំណុចដែល $(L)$ ប្រសព្វប្លង់ $(\alpha)$ ។
   ខ. រកមុំដែលកើតឡើងដោយបន្ទាត់ $(L)$ និងវ៉ិចទ័រណរម៉ាល់នៃប្លង់ $(\alpha)$ ។
4. ចូររកសមីការនៃប្លង់ខាងក្រោម :
   ក. ប្លង់កាត់តាមចំណុច $(5,\ 3,\ 4)$ ស្របទៅនឹងប្លង់ $(yz)$ ។
   ខ. ប្លង់កាត់តាមចំណុច $(3,\ -2,\ 5)$ កែងទៅនឹងវ៉ិចទ័រ $(-4,\ 2,\ -3)$ ។
   គ. ប្លង់កាត់តាមចំណុច $(4,\ -2,\ 3)$ ស្របទៅនឹងប្លង់ $3x+6y-4z=t$ ។
   ឃ. ប្លង់កាត់តាមបីចំណុច $(3,\ 0,\ 0)$ , $(0,\ 4,\ 0)$ និង $(0,\ 0,\ 5)$ ។
5. គេឱ្យប្លង់ពីរ $3x+z-1=0$ និង $x-\sqrt{5}y+2z=0$ ។
   រកវ៉ិចទ័រណរម៉ាល់នៃប្លង់នីមួយៗ ហើយរកមុំដែលកើតឡើងដោយប្លង់ទាំងពីរនេះ ។
6. រកសមីការនៃប្លង់កាត់តាមចំណុច $(-2,\ 1,\ 3)$ ហើយកែងទៅនឹងប្លង់ $x-y+z=0$ និងប្លង់ $2x+3y-z=5$ ។
7. គេឱ្យប្លង់ $(\alpha):\ 2x+3y-6z+5=0$ និងចំណុច $M(4,\ 2,\ -5)$ ។
   ក. កំណត់វ៉ិចទ័រណរម៉ាល់នៃប្លង់ $(\alpha)$ ។
   ខ. យក $\overrightarrow{HM_0}=t\cdot\vec{n}$ ( $t$ ជាចំនួនពិត ) ។ កំណត់តម្លៃ $t$ ដើម្បីឱ្យ $H\in(\alpha)$
   គ. កំណត់កូអរដោនេនៃចំណុច $H$ និងចម្ងាយ $HM_0$

PROEUS DARA


# លំហាត់ជំពូក

1. ស្វ៊ែរមួយមានផ្ចិត $(3,\ 7,\ 4)$ និងមានកាំស្មើនឹង $5$ ហើយប្រសព្វជាមួយប្លង់ $(xy)$ និង $(yz)$ បង្កើតបានរង្វង់ពីរ ។ រកផ្ចិត និងកាំនៃរង្វង់នីមួយៗ ។

2. ក. ផ្ទៀងផ្ទាត់តម្លៃ $m$ និង $n$ ដែលបីចំណុច $A(2,\ 3,\ -4)$ , $B(3,\ 1,\ -1)$ និង $C(m,\ 7,\ n-1)$ ស្ថិតនៅលើបន្ទាត់មួយ ។

   ខ. ផ្ទៀងផ្ទាត់តម្លៃ $m$ ដែលបួនចំណុច $P(4,\ -2,\ 5)$ , $Q(-3,\ 4,\ -4)$ , $R(1,\ 2,\ 4)$ និង $S(m,\ 1-m,\ 4)$ ស្ថិតនៅលើបន្ទាត់មួយ ។

3. រកសមីការនៃបន្ទាត់ដែលកាត់តាមចំណុច $(3,\ -1,\ 2)$ ដែលបង្កើតមុំ $60°$ , $45°$ និង $60°$ ជាមួយអ័ក្សអាប់ស៊ីស អ័ក្សអរដោនេ និងអ័ក្សកូតរៀងគ្នា ។

4. បង្ហាញថា បន្ទាត់ពីរ $\frac{x}{2} = \frac{y-2}{3} = z+4$ និង $\frac{x-1}{2} = \frac{y}{3} = z$ ស្របគ្នា ហើយរកសមីការនៃប្លង់ដែលកំណត់ដោយបន្ទាត់ទាំងពីរ ។

5. បង្ហាញថា បន្ទាត់ពីរ $\frac{x-1}{3} = \frac{y-3}{4} = \frac{z+2}{5}$ និង $\frac{x-1}{2} = \frac{y-3}{5} = \frac{z+2}{3}$ ប្រសព្វគ្នាត្រង់មួយចំណុច ហើយរកសមីការនៃប្លង់ដែលកំណត់ដោយបន្ទាត់ទាំងពីរ ។

6. រកមាឌនៃសូលីតដែលខ័ណ្ឌដោយប្លង់ $(xy)$ ប្លង់ $(yz)$ និងប្លង់ $(zx)$ ហើយនឹងប្លង់ $6x+4y+3z = 12$ ។

7. យក $(\alpha)$ ជាប្លង់ $4x+3y+5z = 50$

   ក. រកចម្ងាយរវាងប្លង់ $(\alpha)$ និងចំណុចគល់តម្រុយ ។

   ខ. រកកូអរដោនេនៃចំណុចស៊ីមេទ្រីទៅនឹងគល់តម្រុយធៀបទៅនឹងប្លង់ $(\alpha)$ ។




8. បើប្រវែងនៃពីរវ៉ិចទ័រ $t\vec{a}+\vec{b}$ និង $\vec{a}-t\vec{b}$ ស្មើគ្នា ។ រកមុំដែលផ្គុំឡើងដោយវ៉ិចទ័រ $\vec{a}$ និង $\vec{b}$ ហើយបង្ហាញថា $|\vec{a}| = |\vec{b}| \neq 0$ និង $t \neq 0$ ។

9. ក. យក $\vec{a} = (1, 1, \sqrt{2})$ និង $\vec{b} = (1, 2, 3)$ ។ ចូររកតម្លៃនៃ $t$ ដែល $|\vec{b} - t\vec{a}|$ អប្បបរមា។

ខ. យក $t_0$ ជាតម្លៃដែលរកឃើញនៅសំណួរ ក. ។

បង្ហាញថា $\vec{b} - t_0\vec{a}$ កែងទៅនឹងវ៉ិចទ័រ $\vec{a}$ ។

10. តើសំណុំចំណុច $P$ ជារូបអ្វី ដែលមានចម្ងាយស្មើពីបីចំណុច $A(4, 3, -2)$ , $B(4, -3, 6)$ និង $C(-4, 5, 6)$ ? រកសមីការនៃរូបនោះ។

11. យក $A$ ជាចំណុច $(-2, 1, 3)$ និង $(\alpha)$ ជាប្លង់ $3x + y - 2z = 17$ ។

ក. រកកូអរដោនេនៃចំណុច $H$ ដែល $H$ ជាចំណុចប្រសព្វត្រង់បន្ទាត់កែងកាត់តាមចំណុច $A$ ទៅនឹងប្លង់ $(\alpha)$ ។

ខ. រកកូអរដោនេនៃចំណុច $B$ ដែល $B$ ស៊ីមេទ្រីនឹងចំណុច $A$ ធៀបទៅនឹងប្លង់ $(\alpha)$ ។

12. បន្ទាត់ $(L)$ កាត់តាមចំណុច $(2, 3, -4)$ ហើយប្រសព្វប្លង់ $(xy)$ ត្រង់ចំណុច $(5, 5, 0)$ ។




ក. រក $a : b : c$ បើប្លង់ $ax + by + cz = d$ អរតូកូណាល់ជាមួយ $(L)$ ។

ខ. រកសមីការនៃប្លង់ក្នុងសំណួរ ក. បើវាកាត់តាមចំណុច $(4, 3, 6)$ ។

13. កំណត់មេគុណ $b$, $c$ និង $d$ ដែលប្លង់ $x + by + cz + d = 0$ មានបន្ទាត់ពីរ $3x = -2y = 6z$ និង $2x = y = -z$ ដែលប្រសព្វគ្នាត្រង់គល់តម្រុយ ។

14. ចូររកសមីការនៃប្លង់ដែលមានបន្ទាត់ $\frac{x-1}{2} = \frac{y-2}{2} = \frac{z-1}{3}$ និងកាត់តាមចំណុច $(1, -1, 2)$ ។

15. គេឱ្យ $M_0(3, -2, 1)$ និងបន្ទាត់ $(L) : 2 - x = \frac{2-y}{3} = z + 1$ ។

ក. កំណត់វ៉ិចទ័រណរម៉ាល់ $\vec{u}$ នៃ $(L)$ ។

ខ. កំណត់សមីការនៃប្លង់ $(\alpha)$ ដែលកាត់តាម $M_0$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{u}$ ។

គ. គណនាចម្ងាយ $HM_0$ ។

# ចម្លើយជំពូក ១

## មេរៀនទី ១

1. ក. $\sum_{k=1}^{100} k$  ខ. $\sum_{k=1}^{22} k^2$  គ. $\sum_{k=1}^{15} k^3$  ឃ. $\sum_{n=1}^{20} n \times (n+2)$

2. ក. $1+2+3+4+5+6$  ខ. $1^2+2^2+3^2+4^2+5^2$

   គ. $(3.4-1)+(3.5-1)+\ldots+(3.9-1)$

   ឃ. $(-1)^2 \cdot 2+(-1)^3 \cdot 3+(-1)^4 \cdot 4+\ldots+(-1)^7 \cdot 7$ ។

3. ក. 506  ខ. 4900  គ. 4394 ។

4. ក. 90000  ខ. 14400  គ. 75600 ។

5. ក. $\frac{n(n+1)(n+2)}{3}$  ខ. 8120  6. ក. $\frac{n(n+1)(n+2)(n+3)}{4}$  ខ. 153130

7. ក. $n^2-2n+2$  ខ. $\frac{1}{6}n(2n^2-3n+7)$

8. ក. $a_n = \frac{2n^3+3n^2+7n-6}{6}$  ខ. $\frac{n^4+4n^3+11n^2-64n}{12}$

9. $a_n = \frac{1}{2}[(p+q)+(-1)^{n-1}(p-q)]$

## មេរៀនទី ២

1. ក. 2, 3, 0, –4  ខ. 5, 7, 17, 55  2. 21

3. $p = 4$ , $q = -2$ , $p = -4$ , $q = \frac{10}{3}$

4. ក. $3\left[1-\left(\frac{2}{3}\right)^n\right]$  ខ. $a_n = 1+(n-1)\frac{4}{4}$  គ. $a_n = \frac{n^2-n+2}{2}$ ។

5. ខ. $b_n = n$ , $a_n = \frac{1}{n}+3$ ។ 6. ក. $2a_{n+1} = a_n + \frac{1}{2^{n-1}}$  ខ. $a_n = \frac{n}{2^{n-1}}$

## មេរៀនទី ៣

5. ក. $(3x-1)^4 = 81x^4-108x^3+54x^2-12x+1$

   ខ. $(2x+y^6) = 64x^6+192x^5y+240x^4y^2+160x^3y^3+60x^2y^4+12xy^5+y^6$

   គ. $(a+b)^6 = a^6+a^5b+a^4b^2+a^3b^3+a^2b^4+ab^5+b^6$

# ចម្លើយលំហាត់ជំពូក

1. 3, 7, 11 2. $S_8 = 40$ ឬ $S_8 = -24$

4. ក. $U_{10} = \frac{4}{6561}$ ខ. តួទី 8 នៃស៊ីត គ. $S_{20} = \frac{6\times 3^{19} - 2}{3^{18}}$

5. $S_n = 3^n - 1$ 6. $S_n = \frac{1-(n-1)x^n + nx^{n+1}}{(1-x)^2}$ 7. $U_1 = 16$

8. $U_1 = 3$ , $U_2 = 15$ , $U_3 = 75$ , $U_1 = 75$ , $U_2 = 15$ , $U_3 = 3$

9. ក. $S_n = \frac{2n}{n+1}$ ខ. $S_n = \frac{n^2+n}{2(2n+1)^2}$

10. ក. $a_n = \frac{1}{6}(2n-1)(n-1)n + 1$ 11. ក. $\frac{n}{3}(n+2)(2n-1)$ ខ. 5720 ។

12. $\sum_{n=1}^{100}(3n-2)$ 15. ក. $U_1 = \frac{4}{3} U_2 = \frac{10}{7} U_3 = \frac{24}{17}$

16. ក. $b_n = 6 + (n-2)2^{n+1}$ ខ. $a_n = (n-2)2^n + \frac{6}{2^n}$ ។ 17. $(x^2-2y)^7 = \sum_{r=0}^{7} {}_7C_r x^{7-r} y^r$

ខ. $-{}_7C_5(x^2)^{7-5}(2y)^5 = -21\cdot x^4 \cdot 32y^5 = -672x^4y^5$

18. $(1+x)^n = {}_nC_0 1^n + {}_nC_1 1^{n-1}x + {}_nC_2 1^{n-2}x^2 + {}_nC_3 1^{n-3}x^3 + \ldots + {}_nC_{n-1}1x^{n-1} + {}_nC_n x^n$

បើ $x = 1$ គេបាន ${}_nC_0 + {}_nC_1 + {}_nC_2 + {}_nC_3 + \ldots + {}_nC_{n-1} + {}_nC_n = 2^n$

19. ${}_nC_0 + {}_nC_1 + {}_nC_2 + {}_nC_3 + \ldots + {}_nC_{n-1} + {}_nC_n = 2^n$ គេដឹងថា ${}_nC_0 = {}_nC_n$ ; ${}_nC_1 = {}_nC_{n-1} = \ldots$

នោះ $2({}_nC_0 + {}_nC_2 + {}_nC_4 + \ldots + {}_nC_{n-1}) = 2({}_nC_1 + {}_nC_3 + {}_nC_5 + \ldots + {}_nC_n) = 2^n$

ដូចនេះ ${}_nC_0 + {}_nC_2 + {}_nC_4 + \ldots + {}_nC_{n-1} = {}_nC_1 + {}_nC_3 + {}_nC_5 + \ldots + {}_nC_n = 2^{n-1}$

# ចម្លើយជំពូក ២

## មេរៀនទី ១

2. ក. 6 ខ. 2 គ. 8 ឃ. 4 ង. $\frac{1}{8}$ ច. 6 ឆ. 7 ជ. 27

3. $f(x) = a^x$ , $f(y) = a^y$ គេបាន $f(x)f(y) = a^x \cdot a^y = a^{x+R}$ នោះ $f(x)f(y) = f(x+y)$ ។

6. ក. $a^x = 1$ បើ $a > 0$ ហើយ $x = 0$ ឬ បើ $a = 1$ ហើយ $x \in R$

ខ. $a^x > 1$ បើ $a > 1$ ហើយ $x > 0$ ឬ បើ $0 < a < 1$ ហើយ $x < 0$

គ. $0 < a^x < 1$ បើ $a > 1$ ហើយ $x < 0$ ឬ បើ $0 < a < 1$ ហើយ $x > 0$

9. ក. $3^{x^2+4x} = \frac{1}{27}$ , $3^{x^2+4x} = 3^{-3}$ , $x^2+4x+3 = 0$ នាំឱ្យ $x = -1$ ; $x = -3$

ខ. $3^{5x}\cdot 9^{x^2} = 27$ , $3^{5x}\cdot 3^{2x^2} = 3^3$ , $3^{2x^2+5x} = 3^3$ , $2x^2+5x-3 = 0$

នាំឱ្យ $x = \frac{1}{2}$ ; $x = 3$

គ. $4^{3x^2+2x+1} = 16$ ,$4^{3x^2+2x+1} = 4^2$ ,$3x^2+2x-1 = 0$ នាំឱ្យ $x = -1$ ; $x = \frac{1}{3}$

## មេរៀនទី ២

3. ក. $f^{-1}(x) = \log_5 x$

5. $f(x) = \log_a x$ , $f(y) = \log_a y$ គេបាន $f(xy) = \log_a xy$ ,$f(xy) = \log_a x + \log_a y$

ដូចនេះ $f(xy) = f(x)+f(y)$ ។

8. ក. $f(g(x)) = f(2^x) = 2^x - \log_2 2^x = 2^x - x$   ខ. $g(f(x)) = g(x-\log_2 x) = 2^{x-\log_2 x}$

9. ក. $x = 2$   ខ. $x = 2^{\frac{10}{3}}$   គ. $x = 10^{\frac{\log 3125}{1+\log 5}}$   ឃ. $\sqrt{50}-5$

10. $2 < m \le 3$   11. $-\frac{1}{2} < a < 0$

# ចម្លើយជំពូក ៣

## មេរៀនទី ១

3. ក. $x = \pm\frac{\pi}{3}+2k\pi$ , $k\in Z$   ខ. $-1 < m < 0$

5. ក. $\frac{\pi}{4}+2k\pi < x < \frac{5\pi}{4}+2k\pi$   ខ. $\left[\begin{array}{l} -\frac{3\pi}{4}+k\pi < x < \alpha + k\pi \\ x = \frac{\pi}{2} \quad ; \quad \tan\alpha = -\frac{3}{4} \end{array}\right.$

គ. $-\frac{\pi}{3}+k\pi < x < \frac{\pi}{3}+k\pi$   ឃ. $\left[\begin{array}{l} -\pi+2k\pi < x < -\pi+\alpha+2k\pi \\ -\alpha+2k\pi < x < 2k\pi \quad ; \quad \sin\alpha = -\frac{1}{3} \end{array}\right.$

7. $\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2} \le \frac{1}{8} \iff \frac{1}{2}\sin\frac{A}{2}\left[\cos\left(\frac{B-C}{2}\right) - \cos\left(\frac{B+C}{2}\right)\right] \le \frac{1}{8}$

$$\sin^2\frac{A}{2} - \sin\frac{A}{2}\cos\left(\frac{B-C}{2}\right) + \frac{1}{4} \ge 0$$

$$\left[\sin\frac{A}{2} - \frac{1}{2}\cos\left(\frac{B-C}{2}\right)\right]^2 + \frac{1}{2}\sin^2\left(\frac{B-C}{2}\right) \ge 0 \text{ ពិត}$$

6

PROEUS DARA

## មេរៀនទី២

3. ក. $2x^3 - 17x^2 + 7x + 8$ ខ. $\left(\sin x + \frac{1}{2}\right)(\sin x - 8)(\sin x - 1) = 0$

7. ក. $\begin{cases} x = \frac{\pi}{2} + 2k\pi \\ y = \frac{\pi}{2} + 2k\pi \\ y = \frac{5\pi}{6} + 2k\pi \end{cases}$ ឬ $\begin{cases} x = \frac{\pi}{6} + 2k\pi \\ x = \frac{5\pi}{6} + 2k\pi \\ y = \frac{\pi}{2} + 2k\pi \end{cases}$

ខ. $x = \frac{\pi}{2} + k\pi \;;\; y = k\pi \quad (k \in z)$ គ. $\begin{cases} x = \frac{5\pi}{24} + \frac{k\pi}{2} \\ y = \frac{\pi}{24} + \frac{k\pi}{2} \end{cases} (k \in Z)$

9. $\frac{A+C}{2} = B$ ដោយ $A + B + C = \pi \Rightarrow 3B = \pi \Rightarrow B = \frac{\pi}{3}$

$$\sin A + \sin\frac{\pi}{3} + \sin C = \frac{3}{2} + \frac{\sqrt{3}}{2}$$

$$\sin A + \sin C = \frac{3}{2}$$

$$2\cos\frac{\pi}{6}\cos\frac{A-C}{2} = \frac{3}{2} = \cos\frac{\pi}{6}$$

$A - C = \frac{\pi}{3}$ ដែល $A + C = \pi - B = \frac{2\pi}{3}$

$$2A = \frac{\pi}{3} + \frac{2\pi}{3} = \pi \quad \Rightarrow \quad A = \frac{\pi}{2}$$

$$= \pi - (A + B) = \pi - \left(\frac{\pi}{2} + \frac{\pi}{3}\right) =$$

ដូចនេះ $A = \frac{\pi}{2}$ , $B = \frac{\pi}{3}$ , $C = \frac{\pi}{6}$

# ចម្លើយជំពូក ៤

## មេរៀនទី១

2. ក. $\begin{bmatrix} -1 & 3 \\ -2 & 1 \end{bmatrix}$ ខ. $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 9 \\ -4 \end{bmatrix}$ គ. $\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} -2 \\ \frac{9}{7} \end{bmatrix}$

3. $f(3\vec{u} - 2\vec{v}) = \begin{bmatrix} 7 \\ 4 \end{bmatrix}$

6. $\begin{bmatrix} 5 & -2 \\ -3 & 1 \end{bmatrix}$

## ចម្លើយលំហាត់ជំពូក

**1.** k, y) = (−6, 7)  **2.** k, y) = (6, −6) ឬ x, y) = (−6, 6)

**3.** $K = -1$ ឬ $K = 6$  **5.** $\begin{bmatrix} a & 0 \\ 0 & a \end{bmatrix}$  **6.** $\begin{bmatrix} -3 & -2 \\ 3 & 2 \end{bmatrix}$

**7.** $\begin{bmatrix} a & b \\ 2a & 2b \end{bmatrix}$ (បង្ហាញថា $a \neq o$ ឬ $b \neq o$ ) **8.** ខ. $\begin{bmatrix} \cos 2\theta & \sin 2\theta \\ \sin 2\theta & -\cos 2\theta \end{bmatrix}$

**9.** បន្ទាត់ $\begin{bmatrix} x \\ y \end{bmatrix} = \begin{bmatrix} 7 \\ -2 \end{bmatrix} + t\begin{bmatrix} 5 \\ -2 \end{bmatrix}$  **10.** ក. អ័ក្ស ox : បន្ទាត់ $y = -\frac{a}{2}x$

អ័ក្ស oy : បន្ទាត់ $y = o$

**11.** $a = -2;\ b = -3$  **12.** $\begin{bmatrix} 1 & 0 \\ 1 & -1 \end{bmatrix}$

**14.** $l_1 : x + y - 1 = o$

$l_2 : 3x + y - 1 = 0$

## ចម្លើយជំពូក ៥

### មេរៀនទី ១

**1.** ក.




ខ. $m > 0$ : សមីការមានឫសមួយ

$m = 0$ : សមីការមានឫសពីរផ្សេងគ្នា

$-4 < m < 0$ : សមីការមានឫសបីផ្សេងគ្នា

$m = -4$ : សមីការមានឫសពីរផ្សេងគ្នា

$m < 4$ : សមីការមានឫសមួយ

**2.** ក.




ខ. $a > 4\sqrt{2} + 5$ : សមីការមានឫស $x_3 > 0$

$a = 4\sqrt{2} + 5$ : សមីការមានឫស $x_1 = x_2 < 0 < x_3$

$5 < a < 4\sqrt{2} + 5$ : សមីការមានឫស $x_1 < x_2 < 0 < x_3$

$a = 5$ : សមីការមានឫស $x_1 < x_2 = 0 < x_3$

$-4\sqrt{2} + 5 < a < 5$ : សមីការមានឫស $x_1 < 0 < x_2 < x_3$

$a = -4\sqrt{2}+5$ : សមីការមានឫស $x_1 < 0 < x_2 = x_3 = \sqrt{2}$

$a < -4\sqrt{2}+5$ : សមីការមានឫស $x_1 < 0$

3. ក. សមីការមានឫសបីផ្សេងគ្នា កាលណា $k \in (-20,\ 13)$

ខ. $k \in (-20,\ 0)$

4. ក.




ខ. $p > 3$ : មានឫស $x_3$ ដែល $-1 < 1 < x_3$

$p = 3$ : មានឫស $x_1 = x_2 = -1 < 1 < x_3$

$-1 < p < 3$ : មានឫស $x_1 < -1 < x_2 < 1 < x_3$

$p = -1$ : មានឫស $x_1 < -1 < x_2 = x_2 = 1$

$p < -1$ : មានឫស $x_1 < -1 < 1$

5. ក.




ខ. $m > 22$ : មានឫស $x_1 < -1 < 2 < x_2$

$m = 22$ : មានឫស $x_1 < -1 < x_2 = 2$

$-2 < m < 22$ :មានឫស $x_1 < -1 < x_2 < 2$

$m = -2$ : មានឫស $x_1 = -1 < x_2 < 2$

$-4 < m < -2$ :មានឫស $-1 < x_1 < x_2 < 2$

$m = -4$ : មានឫស $-1 < x_1 = x_2 = 0 < 2$

$m < -4$ : គ្មានឫស

6. ក. $a \in \left(-1,\ \frac{7}{16}\right)$

ខ. $a \in \left(\frac{7}{16},\ +\infty\right)$

7. ក.




ខ. សំណុំឫស

$S = [0,\ +\infty)$

**8.** ក.




ខ. ក្រាប C ស្ថិតនៅពីខាងក្រោម ឬប៉ះអ័ក្សអាប់ស៊ីស

ចំពោះ $x \le 2$

ដូចនេះ $x^3 + 3x^2 - 4 \le 0$ ចំពោះ $x \le 2$

**9.** ក. $S = (-\infty, -1] \cup [1, +\infty)$

ខ. ក្រាបស្ថិតនៅពីខាងក្រោមអ័ក្សអាប់ស៊ីសចំពោះ $x \in (-1, 1)$

ដូចនេះ $\frac{1}{2}x^4 + x^2 - \frac{3}{2} < 0$ ចំពោះ $x \in (-1, 1)$ ។

**10** ក.




ខ. $S = [-\sqrt{2}, \sqrt{2}]$

គ. ក្រាបតាង f ស្ថិតនៅក្រោមបន្ទាត់ $y = -2$

ចំពោះ $x < -\sqrt{2}$ ឬ $x > \sqrt{2}$

ដូចនេះ $f(x) < -2$ ចំពោះ $x < -\sqrt{2}$ ឬ $x > \sqrt{2}$

**11.** ក.




ខ. តាមក្រាប $C_1$ ស្ថិតនៅពីខាងក្រោម $C_2$

ចំពោះ $x_2 \ge 0$ ដូចនេះ ចំពោះ $x \ge 0$ គេបាន

$3x^4 + 1 > 8x^3 - 18x^2$ ។

គ. $f'(x) = 12x(x^2 - 2x + 3)$

$f(0) = 1$

ឃ.

| x | $-\infty$ | 0 | $+\infty$ |
|---|---|---|---|
| f'(x) | − | 0 | $+\infty$ |
| f(x) | ↘ | 1 | ↗ |

ដូចនេះ ចំពោះ $x \ge 0$ គេបាន $f(x) > 0$ ។

# ចម្លើយជំពូក ៦

## មេរៀនទី ២

1. A = គ្រាប់ឡុកឡាក់ចេញលេខ 1 , B = គ្រាប់ឡុកឡាក់ចេញលេខខុសគ្នា

$n(A\cap B) = 10$ , $n(B) = 6\times 5 = 30$

$$P(A/B) = \frac{P(A\cap B)}{P(B)} = \frac{1}{3}$$

2. ក. $P(A/B) = \frac{5\times4\times4}{5\times5\times4} = \frac{4}{5}$ , $Pc/(A\cap B) = \frac{5\times4\times1}{5\times4\times4} = \frac{1}{4}$

$$P(A/c) = \frac{P(A\cap c)}{P(c)} = \frac{P(c)}{P(c)} = \frac{5\times4\times1}{5\times4\times1} = 1$$

ខ. $P(A/c)\neq P(A)$ : A និង C អាស្រ័យគ្នា

គ. $P(A) = \frac{5\times5\times4}{6\times5\times4} = \frac{5}{6}$ , $P(A/B) = \frac{4}{5}$

$P(A/B)\neq P(A)$ : A និង B អាស្រ័យគ្នា

3. ក. $P(A) = \frac{1}{4}$ , $P(B) = \frac{3}{4}$ , $P(c/B) = \frac{3}{5}$

ខ. $P(c) = P(A\cap C) + P(B\cap C) = \frac{1}{8} + \frac{9}{20} = \frac{23}{40} = 0.575$




គ. $(A/c) = \frac{\frac{1}{8}}{\frac{23}{40}} = \frac{5}{23} = 0.21$

4.




$P(B) = P(B\cap A) + P(B\cap G) = \frac{1}{2}\times0.7 + \frac{1}{2}\times0.5 = 0.6$

$P(G/B) = \frac{P(B\cap G)}{P(B)} = \frac{0.25}{0.6} = 0.416$

# ចម្លើយលំហាត់ជំពូក

1. ក. $S = \{\{1,\ 1\},\{1,\ 2\},\{1,\ 3\},\{2,\ 2\},\{2,\ 3\}\}$

$P(\{1,\ 1\}) = \frac{c(3,2)}{c(6,2)} = \frac{3}{15}$ , $P(\{1,\ 2\}) = \frac{c(3,1)\times c(2,1)}{c(6,2)} = \frac{6}{15}$

$P(\{1,\ 3\}) = \frac{3}{15}$ , $P(\{2,\ 2\}) = \frac{1}{15}$ , $P(\{2,\ 3\}) = \frac{2}{15}$

ខ. $A = \{\{1, 2\},\{1,3\},\{2,3\}\}$

$P(A) = \frac{6}{15} + \frac{3}{15} + \frac{2}{15} = \frac{11}{15}$

$B = \{\{1, 2\},\{1, 3\}\}$

$P(B) = \frac{3}{5}$

$C = \{(1, 1),(1, 2),(1, 3)\}$

$P(C) = \frac{4}{5}$

គ. $D = \{\{1, 3\},\{2,2\}\}$

$P(D) = \frac{4}{15}$

2. ក. $P(\bar{A}) = 1 - P(A) = 0.7$ , $P(\bar{B}) = 1 - P(B) = 0.5$

$P(A \cup B) = P(A) + P(B) - P(A \cap B) = 0.3 + 0.5 - 0.2 = 0.6$

ខ. $(A \cap B) \cup (A \cap \bar{B}) = ((A \cap B) \cup A) \cap (A \cap B \cup \bar{B}) = A \cap A = A$

$P(A \cap B) + P(A \cap \bar{B}) = P(A) \Rightarrow P(A \cap \bar{B}) = 0.3 - 0.2 = 0.1$

$P(A \cup \bar{B}) = P(A) + P(\bar{B}) - P(A \cap \bar{B}) = 0.7$ , $P(\bar{A} \cap B) = 0.3$

$P(\bar{A} \cup B) = 0.9$

3. ក. A ព្រឹត្តិការណ៍គ្មានត្រូវរង្វាន់សោះ $P(A) = \frac{c(145, 10)}{c(150, 10)} = 0.7048$

ខ. ព្រឹត្តិការណ៍ដែលត្រូវរង្វាន់យ៉ាងតិចមួយសន្លឹកគឺ $\bar{A}$ : $P(\bar{A}) = 1 - 0.7048 = 0.2952$

គ. $P(B) = \frac{c(5, 3) \times c(145, 7)}{c(150, 10)} = 0.002$ ឃ. $P(c) = \frac{c(5, 5) \times c(145, 5)}{c(150, 10)} = 0.0000004$

4. ក. ប្រូបាបត្រូវចម្លើយត្រៀមរួច 3 សំណួរ : $P(A) = 0.0142$

ខ. $P(B) = \frac{c(25, 2) \times c(75, 1)}{c(100, 3)} = 0.1391$ គ. $P(c) = \frac{c(75, 3)}{c(100, 3)} = 0.4176$

ឃ. $P(\bar{c}) = 1 - P(c) = 0.5824$

5. $P(A) = 0.3877$ , $P(B) = 0.0135$ , $P(c) = 0.10298$

6. ក. $P(C) = \frac{1}{4}$ , $P(R) = \frac{1}{8}$ , $P(C \cap R) = \frac{1}{32}$

$P(C \cap R) = P(C) \times P(R) \Rightarrow$ C និង R មិនអាស្រ័យគ្នា

ខ. $P(C/F) = \frac{1}{11}$ C និង F អាស្រ័យគ្នា

7. ក. $P(A) = 0.15$ , $P(B/A) = 0.15$ , $P(B/\bar{A}) = 0.04$

ខ. $P(B) = P(B \cap A) + P(B \cap \bar{A}) = 0.0225 + 0.034 = 0.0565$

$$P(A/B) = \frac{0.0225}{0.0565} = 0.398$$

8. ក. $P(B) = 0.025 + 0.675 = 0.7$

ខ. $P(\bar{D}/B) = \dfrac{0.675}{0.7} = 0.9642$

គ. $n(B) = 70$

$n(\bar{D}) \approx 68$




# ចម្លើយជំពូក ៧

## មេរៀនទី ១

2. ក. $\frac{26}{35} + \frac{529}{70}i$ ខ. $\frac{5}{2} - \frac{5}{2}i$ គ. $\frac{3 + 2\sqrt{2}}{6} + \frac{i}{3}$

3. $-11 - 2i$ និង $625 - 336i$ 4. $x = 3$

## មេរៀនទី ២

6. ក. $10\left(\cos\frac{4\pi}{3} + i\sin\frac{4\pi}{3}\right)$ ខ. $\sqrt{2}\left(\cos\frac{5\pi}{4} + i\sin\frac{5\pi}{4}\right)$

គ. $2\sqrt{2}\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)$ ង. $4\left(\cos\frac{\pi}{6} + i\sin\frac{\pi}{6}\right)$

8. ក. $z = 1 + i\sqrt{3}$ ខ. $z = -2\sqrt{2} + i2\sqrt{2}$

គ. $z = -i$ ឃ. $z = -3\sqrt{3} - 3i$

9. ក. $|z| = \frac{1}{\cos\alpha}$ ខ. $|zw| = \frac{4}{\cos\alpha}$

គ. $\arg(z) = \frac{\pi}{2} - \alpha$ ឃ. $\arg\left(\frac{z}{w}\right) = \frac{2\pi}{5} - \alpha$

10. ក. $z = \cos\left(\frac{\pi}{2} - \alpha\right) + i\sin\left(\frac{\pi}{2} - \alpha\right)$

13. $z' = 4\sqrt{2}\left(\cos\frac{11\pi}{12} + i\sin\frac{11\pi}{12}\right)$

## មេរៀនទី ៣

5. ខ. $1+z+z^2+\ldots+z^{11} = 0$ 9. ង. $z_k = 2\left(\cos\frac{11\pi+12k\pi}{18} + i\sin\frac{11\pi+12k\pi}{18}\right)$

$k = 0,\ 1,\ 2$

ច. $z_k = \cos\frac{5\pi+8k\pi}{20} + i\sin\frac{5\pi+8k\pi}{20}$ , $k = 0,\ 1,\ 2,\ 3,\ 4$

## មេរៀនទី ៤

4. 1. $AB = 5\sqrt{2}$ 2. ក. $AB = \sqrt{17}$ ខ. $z = \frac{3}{2} - i$

4. $AP = \frac{\sqrt{137}}{2}$ , $BN = 8$ , $CM = \frac{\sqrt{569}}{2}$ 7. $\frac{AC}{AB} = 16$ និង $\varphi = \frac{\pi}{3}$

10. ក. បន្ទាត់ $2x - y - 3 = 0$ ខ. បន្ទាត់ $x = \frac{3}{2}$

គ. រង្វង់ផ្ចិត $\left(-\frac{38}{16}\ ,\ 0\right)$ និង $R = \frac{38}{16}$ ។

# ចម្លើយលំហាត់ជំពូក

4. ក. $(\sqrt{3}-i)^{100} = 2^{100}\left(\cos\frac{4\pi}{3} + i\sin\frac{4\pi}{3}\right)$

6. ក. $z_0 = 1 + i\sqrt{3}$ , $z_1 = -\sqrt{3} + i$ , $z_2 = -1 - \sqrt{3}i$ , $z_3 = \sqrt{3} - i$

8. គ. បន្ទាត់ $y = 1$ ឃ. វិសមីការ $x < 0$ ង. និង ច. $y = x$

# ចម្លើយជំពូក ៤

## មេរៀនទី ១

1. ក. $\vec{x} = (13,\ 31,\ -34)$ ខ. $\vec{x} = (-6,\ -22,\ 26)$

2. $\ell = 2$ , $m = 3$ , $n = 4$ , $\vec{p} = (5,\ 6,\ 7)$

3. ក. $\cos\alpha = \frac{3\sqrt{2}}{10}$ , $\cos\beta = \frac{-4\sqrt{2}}{10}$ , $\cos\gamma = \frac{\sqrt{2}}{2}$

ខ. $\cos\alpha = \frac{-3}{5}$ , $\cos\beta = \frac{2}{5}$ , $\cos\gamma = \frac{2\sqrt{3}}{5}$

4. ក. $(x,\ y) = \left(-\frac{10}{3},\ -\frac{23}{4}\right)$ ខ. $z = -\frac{1}{7}$ ដូចនេះតម្លៃ $(x,\ y,\ z) = \left(-\frac{10}{3},\ -\frac{23}{4},\ -\frac{1}{7}\right)$

5. $(x, y, z) = \left(-12, -3, \frac{4}{3}\right)$ 6. $x_1 : x_2 : x_3 = 3 : 4 : 5$ 7. $k = -\frac{2}{3}$

8. ក. $\Delta ABC$ ជាត្រីកោណសម័ង្ស ខ. $\left(x-\frac{3}{2}\right)^2+\left(y-\frac{3}{2}\right)^2+\left(z+\frac{1}{2}\right)^2 = \frac{19}{4}$

9. ក. $(x-1)^2+(y+1)^2+(z-2)^2 = 22$

11. ក. $\vec{u}\cdot\vec{v} = -1$ , $\vec{v}\cdot\vec{w} = -1$ , $\vec{w}\cdot\vec{u} = 3$

ខ. $\vec{u}\cdot\vec{v} = \frac{13}{15}$ , $\vec{v}\cdot\vec{w} = \frac{9}{10}$ , $\vec{w}\cdot\vec{u} = \frac{7}{6}$

12. $\overrightarrow{SA}\cdot\overrightarrow{SB} = a^2$ , $\overrightarrow{SA}\cdot\overrightarrow{SC} = a^2$ , $\overrightarrow{SA}\cdot\overrightarrow{AC} = 0$

## មេរៀនទី ២

1. ក. $\overrightarrow{AM}\cdot\overrightarrow{CD} = \frac{1}{2}a^2$ , $\overrightarrow{BM}\cdot\overrightarrow{CD} = \frac{1}{2}a^2$

2. ក. $x-2 = y+3 = \frac{7-2}{4}$ ខ. $(1, 1, 1)$

3. ក. $(3, -1, -1)$ ខ. $\theta = \frac{\pi}{2}$ ឬ $\theta = 90°$

4. ក. $y+z-7 = 0$ ខ. $4x-2y+3z-31 = 0$

គ. $3x+6y-4z+12 = 0$ ឃ. $20x+15y+12z-120 = 0$

5. $\vec{n} = (3, 0, 1)$ , $\vec{n} = (1, -\sqrt{5}, 2)$ , $\theta = \frac{\pi}{3}$ ឬ $\theta = 60°$

6. $x-y+z = 0$ , $2x+3y-z+4 = 0$

7. ក. $\vec{n} = (2, 3, -6)$ ខ. $t = 1$ គ. $H(2, -1, 1)$

ចម្ងាយ $HM_0 = 7$

## មេរៀនទី ៣

1. ផ្ចិត $(3, 7, 0)$ កាំ 3 ជាមួយប្លង់ $xy$

ផ្ចិត $(0, 7, 4)$ កាំ 4 ជាមួយប្លង់ $yz$

2. ក. $m = 0$ , $n = -9$ ខ. $m = 5$ 3. $2(x-3) = \sqrt{2}(y+1) = 2(z-2)$

4. $2x-y-z = 2$ 5. $13x-y-7z = 24$ 6. 4 7. ក. $5\sqrt{2}$ ខ. $(8, 6, 10)$

8. $\theta = \frac{\pi}{2}$ ឬ $\theta = 90°$ 9. $t = \frac{3(1+\sqrt{2})}{4}$ 10. $\frac{x+1}{4} = \frac{y}{4} = \frac{z-2}{3}$ 11. ក. $(4, 3, -1)$

ខ. $(10, 5, -5)$ 12. ក. $3 : 2 : 4$ ខ. $3x+2y+4z = 42$ 13. $b = \frac{5}{4}$ , $c = \frac{7}{4}$ , $d = 0$

14. $2x+2y+3z-6 = 0$ 15. ក. $\vec{U} = (1, 3, 1)$ ខ. $x+3y+z+2 = 0$ ។

# បទានុក្រម

## ក

**កាទីល** ( Quatile ) ភាគបួននៃទិន្នន័យទាំងអស់ ។

**កូអរដោនេនៃវ៉ិចទ័រ :** បើគេមានវ៉ិចទ័រណរម៉ាល់ $\vec{u} = a\vec{i}+b\vec{j}+c\vec{k}$ នោះកូអរដោនេនៃវ៉ិចទ័រណរម៉ាល់ $\vec{u}$ គឺ $(a,\ b,\ c)$ ឬ $\vec{u} = (a,\ b,\ c)$ ។

**កន្សោមវិភាគផលគុណស្កាលែ :** បើ $\vec{u} = x\vec{i}+y\vec{j}+z\vec{k}$ , $\vec{v} = x'\vec{i}+y'\vec{j}+z'\vec{k}$ នោះគេបាន : $\vec{u}\cdot\vec{v} = xx'+yy'+zz'$

**កូអរដោនេចែកក្នុងនៃវ៉ិចទ័រទីតាំង :** វ៉ិចទ័រទីតាំង $\vec{c}$ នៃចំណុច $C$ ដែលចែកអង្កត់ $AB$ ខាងក្នុងតាមផលធៀប $m:n$ គឺ $\vec{c} = \dfrac{m\vec{b}+n\vec{a}}{m+n}$

**កូអរដោនេចែកក្រៅនៃវ៉ិចទ័រទីតាំង :** វ៉ិចទ័រទីតាំង $\vec{d}$ នៃចំណុច $D$ ដែលចែកអង្កត់ $AB$ ខាងក្រៅតាមផលធៀប $m:n$ គឺ $\vec{d} = \dfrac{m\vec{b}-n\vec{a}}{m-n}$

## គ

**គំរូ** ( Sample ) : ជាសំណុំរងនៃសំណុំស្ថិតិសកល ។

**គំលាត ឬគំលាតស្តង់ដា :** ( Standard deviation ) ជាឬសការេនៃវ៉ារ្យង់ ។

## ច

**ចម្ងាយពីចំណុចមួយទៅប្លង់ក្នុងលំហ :** ចម្ងាយពីចំណុច $P_0(x_0,\ y_0,\ z_0)$ ទៅប្លង់ $(\alpha)$: $+by+cz+d = $ មានរាង

$$d = (P_0,\ \alpha) = \frac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$$

**ចំណុចរបត់ :** ចំណុចណាមួយនៃក្រាបតាងអនុគមន៍ ដែលនៅត្រង់នោះ ក្រាបប្តូរភាពប៉ោង ផត ។

**ចំនួនកុំផ្លិច :** ( Complex number) ជាចំនួនដែលមានរាង $a+bi$ ដែល $a$ និង $b$ ជាចំនួនពិត ។

**ចំណុចឥតប្រែប្រួល :** បើ $Q$ ជាចំណុចឥតប្រែប្រួលទៅតាមបំលែង $A$ កាលណា $A(Q) = Q$ ។

**ច្បាប់នៃវិធីគុណ :** ប្រើដើម្បីគណនាប្រូបាបនៃព្រឹត្តិការណ៍សមាស

## ឈ

*ឈ្នាប់* : ការភ្ជាប់រវាងសំណើពីរដោយពាក្យ ឬសញ្ញាបង្កើតបានសំណើថ្មីហៅថាឈ្នាប់

*ឈ្នាប់និង* : $P \wedge q$

*ឈ្នាប់ឬ* : $P \vee q$

*ឈ្នាប់នាំឱ្យ* : $P \Rightarrow q$

*ឈ្នាប់សមមូល* : $P \Leftrightarrow q$

## ដ

*ដេរីវេ* : លីមីតនៃអត្រាបម្រែបម្រួលមធ្យម កាលណាអថេរមានបម្រែបម្រួលតូចស្មើរតែសូន្យ ។

## ត

*តម្លៃ* **Z ( Z Value )** ជាចម្ងាយរវាងតម្លៃដែលគេបានជ្រើសរើស និងមធ្យមស្ថិតិសកល ចែកនឹងគំលាតស្តង់ដា $Z = \dfrac{X-\mu}{\delta}$ ។

*តម្រុយអរតូណរម៉ាល់* : គឺគ្រប់ចតុធាតុ $(o, \vec{i}, \vec{j}, \vec{k})$ ដែល $o$ ជាចំណុចមួយនៃលំហហៅថា គល់ និង $(\vec{i}, \vec{j}, \vec{k})$ ហៅថាគោលអរតូណរម៉ាល់នៃលំហ ។

*តម្រុយក្នុងលំហ* : គេហៅតម្រុយក្នុងលំហ គឺគ្រប់ចតុធាតុ $(o, \vec{i}, \vec{j}, \vec{k})$ ជាចំណុចមួយក្នុងលំហានិង $\vec{i}, \vec{j}, \vec{k}$ ជាបីវ៉ិចទ័រមិនស្ថិតក្នុងប្លង់តែមួយ ។

## ទ

*ទិសដៅកូស៊ីនុស* : $\cos\alpha = \dfrac{x}{|\vec{u}|}$ , $\cos\beta = \dfrac{y}{|\vec{u}|}$ , $\cos\gamma = \dfrac{z}{|\vec{u}|}$

ដែល $\vec{u} = (x, y, z)$

*ទីតាំងនៃចំណុច* : $P$ គឺ $\vec{p}$ ដែលកំណត់សរសេរ $P(\vec{p})$ ។

*ទ្វេធា* : គឺជាពហុធាដែលមានពីរតួ ។

*ទ្រឹស្តីបទបៃយេស* : រកឃើញដោយ Reverend Thomas Bayes នៅសតវត្សទី 18

***បំណែងចែកន័រម៉ាល់*** : ( Normal distribution )

ជាបំណែងចែកដែលមានរាងជាជួងមានលក្ខណស៊ីមេទ្រី និងមានមធ្យម ម៉ូត មេដ្យាននៅត្រួតស៊ីគ្នា ។

***ប្រូបាប*** **:** តម្លៃដែលយកក្នុងចន្លោះបិទ 0 និង 1 ដែលបង្ហាញពីសំណាងដែលត្រូវមាននៃព្រឹត្តិការណ៍មួយនឹងត្រូវកើតឡើង ។

***ប្រូបាបមានលក្ខខណ្ឌ*** **:** សំណាងដែលត្រូវមាននៃព្រឹត្តិការណ៍មួយនឹងកើតឡើងដោយដឹងថាមានព្រឹត្តិការណ៍មួយទៀតបានកើតមុនរួចហើយ ។

***បើ $A$ និង $B$ ជាព្រឹត្តិការណ៍មិនអាស្រ័យគ្នា :***

$$P(A \cap B) = P(A) \times P(B)$$

***បើ $A$ និង $B$ ជាព្រឹត្តិការណ៍អាស្រ័យគ្នា :***

$$P(A \cap B) = P(A) \times P(B/A)$$

$$P(B) \times P(A/B)$$

***បើព្រឹត្តិការណ៍ $B$ កើតឡើងក្នុងព្រឹត្តិការណ៍ $A_1$*** និងកើតឡើងក្នុងព្រឹត្តិការណ៍ $A_2$ ដែល $A_1 \cap A_2 = \varnothing$ : នោះ

$$\frac{P(A_1)P(B/A_1)}{P(A_1)P(B/A_1) + P(A_2)P(B/A_2)}$$

***បំលែងលីនេអ៊ែ*** **:** គឺជាការប្លែងចំណុច $M(k_1 y)$ ទៅ $M'(x', y')$ កំណត់ដោយសមីការ $\begin{cases} x' = ax + cy \\ y' = bx + dy \end{cases}$ ។

គេអាចសរសេរបំលែងនេះជាម៉ាទ្រីសដូចខាងក្រោម ៖

$$\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} a & b \\ c & d \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$$

***បំលែងលីនេអ៊ែច្រាស*** **:** បើ $A = \begin{bmatrix} a & b \\ c & d \end{bmatrix}$

នោះបំលែងលីនេអ៊ែច្រាសរបស់ $A$ គឺ $A^{-1} = \dfrac{1}{ad - bc} \begin{bmatrix} d & -c \\ -b & a \end{bmatrix}$ ។

***បំលែងឆ្លុះធៀបអ័ក្ស $x'x$*** **:** ជាបំលែងដែលមានរាង $Sx'x$ : $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} 1 & 0 \\ 0 & -1 \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$ ។

***បំលែងឆ្លុះធៀបនឹងគល់ $O$*** **:** ជាបលែងដែលមានរាង $S_o$ : $\begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} -1 & 0 \\ 0 & -1 \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$ ។

***បំលែងរំកិល*** **:** ជាបំលែងដែលមានរាង

$$R(o, \alpha) : \begin{bmatrix} x' \\ y' \end{bmatrix} = \begin{bmatrix} \cos\alpha - \sin\alpha \\ \sin\alpha \quad \cos\alpha \end{bmatrix} \begin{bmatrix} x \\ y \end{bmatrix}$$

***បំលែងបណ្ដាក់*** **:** បើ $A = \begin{bmatrix} a & c \\ b & d \end{bmatrix}$ ;

$$B = \begin{bmatrix} a' & c' \\ b' & d' \end{bmatrix}$$

នោះគេបានបំលែងបណ្តាក់គឺ:

$$M \xrightarrow{A} M' \xrightarrow{B} M''$$

$$\begin{bmatrix} x'' \\ y'' \end{bmatrix} = B \begin{bmatrix} x' \\ y' \end{bmatrix} = BA \begin{bmatrix} x \\ y \end{bmatrix}$$

**ប្រមាណវិធីគុណវ៉ិចទ័រ** : $\vec{b} = k\vec{a}$ បើ $k > 0$ នោះ $\vec{a}$ និង $\vec{b}$ មានទិសដៅដូចគ្នា ហើយ $|\vec{b}| = |k||\vec{a}|$ បើ $k < 0$ នោះ $\vec{a}$ និង $\vec{b}$ មានទិសដៅផ្ទុយគ្នា ហើយ $|\vec{b}| = |k||\vec{a}|$

**ប្រមាណវិធីបូកវ៉ិចទ័រ** : $\overrightarrow{OA} + \overrightarrow{AB} = \overrightarrow{OB}$ ឬ $\vec{a} + \vec{b} = \vec{c}$




**ប្រមាណវិធីដកវ៉ិចទ័រ** : $\overrightarrow{AB} = \overrightarrow{OB} - \overrightarrow{OA}$




## ផ

**ផលគុណស្កាលែក្នុងលំហ** : $\vec{u} \cdot \vec{v} = |\vec{u}||\vec{v}| \cdot \cos\theta$ ($\theta$ : ជាមុំផ្គុំដោយ $\vec{u}$ និង $\vec{v}$

$\vec{u} \cdot \vec{v} = 0$ បើ $\vec{u} = 0$ ឬ $\vec{v} = 0$ ។

**ផលសងរួមនៃស្វ៊ីតនព្វន្ត** : គឺជាផលសងនៃពីរតួបន្តបន្ទាប់គ្នាជាចំនួនថេរតាងដោយ $d = U_{n+1} - U_n$ ។

**ផលធៀបរួមនៃស្វ៊ីតធរណីមាត្រ** : គឺជាផលធៀបនៃពីរតួបន្តបន្ទាប់គ្នាតាងដោយ $q = \dfrac{U_{n+1}}{U_n}$ ។

**ផលធៀបរួម ឬរេស៊ុងនៃស្វ៊ីតធរណីមាត្រ** : គឺជាផលធៀបនៃពីរតួបន្តបន្ទាប់គ្នាតាងដោយ $q = \dfrac{U_{n+1}}{U_n}$ ។

## ព

**ពហុគុណរួមតូចបំផុត** : ពហុគុណរួមតូចបំផុតនៃកន្សោម $A$ និង$B$ គឺជាផលគុណកត្តារួមមាននិទស្សន្តធំជាងគេ កត្តាមិនរួមទាំងអស់ ។

**ពហុធា** : ជាផលបូកនៃម៉ូនូមច្រើនឯកធា ។

## ភ

**វិស័យ** ( Range ) ជាផលសងរវាងតម្លៃទិន្នន័យ ដែលខ្ពស់ជាងគេនិងតម្លៃនៃទិន្នន័យដែលទាបជាងគេ ។

## ម

**វ៉ារ្យង់** ( Variance ) ជាមធ្យមនៃការេគំលាតពីមធ្យម ។

**វ៉ិចទ័រក្នុងលំហ** : អង្កត់មានទិសដៅនៅក្នុងលំហ ហៅថាវ៉ិចទ័រក្នុងលំហ ។

**វ៉ិចទ័រស្របគ្នា** : វ៉ិចទ័រ $\vec{a} // \vec{b} \Leftrightarrow \vec{a} = k\vec{b}$ $\cdot (k \in \mathbb{R})$

**វ៉ិចទ័រឯកតា** : វ៉ិចទ័រដែលមានប្រវែងស្មើ 1 ហៅថាវ៉ិចទ័រឯកតា ។

**វ៉ិចទ័រស្មើគ្នា** : វ៉ិចទ័រស្មើគ្នា ជាវ៉ិចទ័រដែលមានប្រវែងស្មើគ្នា និងមានទិសដៅដូចគ្នា ។

***វ៉ិចទ័រផ្ទុយគ្នា*** **:** វ៉ិចទ័រផ្ទុយគ្នា ជាវ៉ិចទ័រដែលមានប្រវែងស្មើគ្នា មានទិសដៅផ្ទុយគ្នា។

***វ៉ិចទ័រសូន្យ*** **:** វ៉ិចទ័រសូន្យ ជាវ៉ិចទ័រដែលមានប្រវែងស្មើសូន្យ។

***វ៉ិចទ័រទីតាំង*** **:** វ៉ិចទ័រ $\vec{p}$ ជាវ៉ិចទ័រទីតាំងនៃចំណុច $P$ គឺជាវ៉ិចទ័រដែលមាន $O$ ជាគល់។

***វិចារកំណើន ឬវិចារអនុមានរួមសំណើ*** $P(n)$ ពិតចំពោះ $n = 1, 2, \ldots$ បើវាផ្ទៀងផ្ទាត់សំណើពីរខាងក្រោម :

(1) $P(1)$ និង (2) $P(k)$

ពិតនាំឱ្យ $P(k+1)$ ពិតចំពោះគ្រប់ $k$ ។

## ស

***ស្ថិតិសកល*** **:** ( Population ) ជាសំណុំនៃឯកតាទាំងអស់ ដែលគេលើកយកមកសិក្សា មានដូចជាក្រុមមនុស្ស សត្វ ឬវត្ថុ។

***ស្កាលែ និងណម*** **:**

$\vec{u} = x\vec{i} + y\vec{j} + z\vec{k} \Rightarrow$

$\vec{u}^2 = \vec{u}\cdot\vec{u} = x^2 + y^2 + z^2$ ហើយ

$|\vec{u}| = \sqrt{x^2 + y^2 + z^2}$

***ស្វ៊ែរ*** **:** សំណុំចំណុចដែលមានចម្ងាយថេរ $r$ ពីចំណុចនឹង $c$ ស្វ៊ែរដែលមានផ្ចិត $c$ និងកាំ $r$

***សមីការស្វ៊ែរ*** **:** គេមាន $C(a, b, c)$ ជាផ្ចិតនៃស្វ៊ែរ ហើយ $P(x, y, z)$ ស្ថិតនៅលើស្វ៊ែរ នោះគេបានសមីការស្វ៊ែរគឺ

$(x-a)^2 + (y-b)^2 + (z-c)^2 = r^2$

ដែល $r$ ជាកាំ។

***សមីការបន្ទាត់ក្នុងលំហ*** **:** សមីការបន្ទាត់ $L$ កាត់តាមចំណុច $P_0(x_0, y_0, z_0)$ ស្របទៅនឹងវ៉ិចទ័រប្រាប់ទិស $\vec{u}(a, b, c)$ គឺ :

$(L): \dfrac{x-x_0}{a} = \dfrac{y-y_0}{b} = \dfrac{z-z_0}{c}$

សមីការបន្ទាត់កាត់តាមពីរចំណុច : សមីការបន្ទាត់កាត់តាមពីរចំណុច $P_0(x_0, y_0, z_0)$ និង $P_1(x_1, y_1, z_1)$ គឺ :

$$\frac{x-x_0}{x_1-x_0} = \frac{y-y_0}{y_1-y_0} = \frac{z-z_0}{z_1-z_0}$$

***សមីការប៉ារ៉ាម៉ែត្រ*** **:** សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $L$ ដែលមានវ៉ិចទ័រប្រាប់ទិស $\vec{u} = (a, b, c)$ ហើយកាត់តាមចំណុច $M_0(x_0, y_0, z_0)$ គឺ :

$x - x_0 = at \Leftrightarrow x = x_0 + at$

$y - y_0 = bt \Leftrightarrow y = y_0 + bt$

$z - z_0 = ct \Leftrightarrow z = z_0 + ct$

***សមីការប្លង់*** **:** សមីការប្លង់ដែលកំណត់ដោយចំណុច $P(x_0, y_0, z_0)$ និងវ៉ិចទ័រណរម៉ាល់ $\vec{n}(a, b, c)$ មានរាង $ax + by + cz + d = 0$ សំណុំចំណុច $Q(x, y, z)$ ផ្ទៀងផ្ទាត់សមីការ $+ by + cz + d = ($ ដែល $a, b, c, d$ ជាចំនួនពិតហើយ $a, b, c$ មិនសូន្យព្រមគ្នា ) គឺជាប្លង់វ៉ិចទ័រណរម៉ាល់ $\vec{n} = (a, b, c)$ ។

*ស្វ៊ីត ចុះ :* ស្វ៊ីត $(a_n)$ ជាស្វ៊ីតចុះចេញពី $n_0$ លុះត្រាតែ $a_{n+1} \le a_n$ ចំពោះ $\forall n \ge n_0$ ។

*ស្វ៊ីត ម៉ូណូតូន :* ស្វ៊ីត $(a_n)$ ជាស្វ៊ីតម៉ូណូតូន បើ

$a_1 \le a_2 \le a_3 \le a_4 \le \ldots \le a_n \le a_{n+1} \le \ldots$

ឬ

$a_1 \ge a_2 \ge a_3 \ge a_4 \ge \ldots \ge a_n \ge a_{n+1} \ge \ldots$

*ស្វ៊ីត ម៉ូណូតូន កើន :* ស្វ៊ីត $(a_n)$ ជាស្វ៊ីតម៉ូណូតូនកើន បើ

$a_1 < a_2 < a_3 < a_4 < \ldots < a_n < a_{n+1} < \ldots$

*ស្វ៊ីត ម៉ូណូតូនចុះ :* ស្វ៊ីត $(a_n)$ ជាស្វ៊ីតម៉ូណូតូនចុះ បើ

$a_1 > a_2 > a_3 > a_4 > \ldots > a_n > a_{n+1} > \ldots$

*ស្វ៊ីតទាល់លើ :* ស្វ៊ីត $(a_n)$ ជាស្វ៊ីតទាល់លើលុះត្រាតែមានចំនួនពិត $M$ ដែល $a_n \le M$ ចំពោះ $\forall n \in \mathbb{N}$ ហើយចំនួន $M$ ហៅថាគោលលើនៃស្វ៊ីត ។

*ស្វ៊ីតទាល់ក្រោម :* ស្វ៊ីត $(a_n)$ ជាស្វ៊ីតទាល់ក្រោមលុះត្រាតែមានចំនួនពិត $m$ ដែល $a_n \ge m$ ចំពោះ $\forall n \in \mathbb{N}$ ហើយចំនួន $m$ ហៅថាគោលក្រោមនៃស្វ៊ីត ។

*ស្វ៊ីតទាល់ :* ស្វ៊ីត $(a_n)$ ជាស្វ៊ីតទាល់កាលណាស្វ៊ីត $(a_n)$ ទាល់លើផងនិងទាល់ក្រោមផង ។

*ស្វ៊ីតនព្វន្ត :* គឺជាស្វ៊ីតនៃចំនួនពិតដែលមានតួនីមួយៗ ( ក្រៅពីតួទី 1 ) ស្មើនឹងតួមុនបន្ទាប់បូកចំនួនថេរ $d$ មួយ ។

*ស៊េរី :* គឺជាផលបូកតួនៃស្វ៊ីត ។

*ស្វ៊ីតធរណីមាត្រ :* គឺជាស្វ៊ីតចំនួនពិតដែលតួនីមួយៗ ( ក្រៅពីតួទី 1 ) ស្មើនឹងតួមុនបន្ទាប់គុណនឹងចំនួនថេរ $q$ ដែល $q \ne 0$ ។

## អ

*អត្រាបម្រែបម្រួលមធ្យម :* ផលធៀបរវាងបម្រែបម្រួលនៃអនុគមន៍និងបម្រែបម្រួលនៃអថេរ

*អតិបរមាធៀប :* តម្លៃនៃអនុគមន៍ដែលនៅត្រង់ចំណុចនោះ មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះប្តូរសញ្ញាពីបូកទៅដក ។

*អប្បបរមាធៀប :* តម្លៃនៃអនុគមន៍ដែលនៅត្រង់ចំណុចនោះ មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះប្តូរសញ្ញាពីដកទៅបូក ។

*អនុគមន៍ប៊ីការេ :* អនុគមន៍ដែលមានរាងទូទៅ $y = ax^4 + bx^2 + 2 \quad (a \ne 0)$

*អត្ថិភាពឫស :* ភាពដែលមានឬគ្មានឫសនៃសមីការមួយ ។

*អថេរភាព :* ភាពប្រែប្រួលនៃអនុគមន៍មួយ ។

*អាស៊ីមតូត :* បន្ទាត់មួយដែលមានចម្ងាយស្មើរតែសូន្យពីចំណុចនៃខ្សែកោង កាលណាចំណុចនោះរត់លើខ្សែកោងទៅឆ្ងាយអនន្ត ។